# ដីសម្បទានគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា
# ទស្សនៈវិស័យខាងសិទ្ធិមនុស្ស

## មាតិការឿង

ទំព័រ


**បុព្វកថា** ........................................ ២-៣

**សេចក្តីផ្តើម** ........................................ ៤-៩

**អនុសាសន៍** ........................................ ១០-១៣

**ផ្នែកទី១ - ប្រវត្តិ ច្បាប់ និង ការអនុវត្តបច្ចុប្បន្ន** ........................................ ១៤-៤១

ការវិវឌ្ឍន៍នៃប្រព័ន្ធសម្បទាន - ចាប់ពីសង្គ្រាមស៊ីវិលរហូតមកដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ទសវត្សឆ្នាំ១៩៩០ - ច្បាប់ភូមិបាលបច្ចុប្បន្ន - សម្បទាន និង សម្បទានិក - កិច្ចសន្យាសម្បទាន និង ការអនុវត្តន៍កិច្ចសន្យាសម្បទាន - សម្បទានដើម្បីគោលដៅអ្វី? ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា សិទ្ធិទទួលបានពត៌មាន និង អំពើពុករលួយ ។

**ផ្នែកទី២ - ផលប៉ះពាល់សិទ្ធិមនុស្ស និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន** ........................................ ៤២-៦២

កម្មសិទ្ធិដីធ្លី និង ការយល់ដឹងអំពីសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋមូលដ្ឋាន - ដីធ្លីគឺជាមូលដ្ឋានគ្រឹះ សំរាប់ការរៀបចំសង្គម វប្បធម៌ និង ជីវភាពរស់នៅ ការមិនបានការពិគ្រោះយោបល់ ការបដិសេធសិទ្ធិ មានជីវភាពរស់នៅជាប្រពៃណីយ ការភ័យខ្លាច លក្ខខណ្ឌបំរើការងារ និង ពលកម្ម ការជម្លៀស ការទន្ទ្រានយកដី ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន - ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ (Flour Manufacturing Company) ។

**សេចក្តីសន្និដ្ឋានរួម** ........................................ ៦៣-៦៩

**ឧបសម្ព័ន្ធទី ១ :** ចំការកៅស៊ូទីរីង (Tum Ring Rubber Plantation) -ករណីសិក្សា........................................ ៧០-៨៤

**ឧបសម្ព័ន្ធទី ២ :** ក្រុមហ៊ុនស៊ីជេ កម្ពុជា (CJ Cambodia Company) ........................................ ៨៥-៨៨

**ឧបសម្ព័ន្ធទី ៣ :** បញ្ជីឈ្មោះសម្បទានគោលដៅសេដ្ឋកិច្ច ........................................ ៨៩-១០២

**ឧបសម្ព័ន្ធទី ៤:** ក្រុមហ៊ុនភាពីម៉ិច ចំកាត់ និងដីសម្បទាន ក្នុងខេត្តពោធិសាត់ និង កំពង់ឆ្នាំង ........ ១០៣-១២៩

**ឧបសម្ព័ន្ធទី ៥:** ក្រុមហ៊ុន **WUZHISHAN L.S. GROUP** ចំការដើមស្រល់ នៅខេត្តមណ្ឌលគីរី ...... ១៣០-១៦០

## បុព្វកថា

ក្នុងពេលបំពេញបេសកកម្មរបស់ខ្ញុំនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៣ ខ្ញុំបានទៅទស្សនាសហគមន៍ជនបទមួយចំនួនដែលរស់នៅលើ ឬ នៅជិតដីធំៗរបស់រដ្ឋ ដែលបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជននានា ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម និង ពាណិជ្ជកម្ម ។ ខ្ញុំមានបំណងស្វែងយល់ជាដំបូង អំពីផលប៉ះពាល់នៃគោលនយោបាយសម្បទានដីដល់ប្រជាពលរដ្ឋមូលដ្ឋាន លើទស្សនៈវិស័យដ៏ទូលំទូលាយខាងសិទ្ធិមនុស្ស ។ មានករណីរំលោភ សិទ្ធិមនុស្សជាច្រើនបានទាក់ទាញការចាប់អារម្មណ៍របស់ខ្ញុំ ។

សភាពការណ៍ដែលខ្ញុំបានជួបប្រទះបានធ្វើឱ្យខ្ញុំរន្ធត់ជាខ្លាំង ។ ក្រុមហ៊ុនជាច្រើនត្រូវបានផ្តល់សិទ្ធិប្រើប្រាស់ដីធ្លីដែលមានលក្ខណៈប្រហាក់ប្រហែលនិងសិទ្ធិកម្មសិទ្ធិ ។ ក្រុមហ៊ុនទាំងនេះបានគិតគូរយកចិត្តទុកដាក់តិចតួច ឬ មិនបានយកចិត្តទុកដាក់ទាល់តែសោះដល់សុខមាលភាព ហើយបានរួមចំណែកតិចតួចបំផុត ឬ គ្មានទាល់តែសោះដល់ប្រាក់ចំណូលជាតិទាំងមូល ។ ខ្ញុំបានធ្វើសេចក្តីសន្និដ្ឋានថា គោលនយោបាយទាំងនេះគឺមិនត្រឹមត្រូវទេ ។ គោលនយោបាយនេះមិនត្រឹមតែមិនបានជួយកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តោយឱ្យមានការបន្តលួចប្លន់យកធនធានធម្មជាតិរបស់ខ្លួនទៀតផង ។ គេប្រើប្រយោគជាភាសារខ្មែរថាពួកគេ " កំពុងតែសោយរាជ្យ " ។

បញ្ហាព្រួយបារម្ភមានលក្ខណៈបន្ទាន់ ។ ប្រជាពលរដ្ឋកម្ពុជាដែលក្រីក្រនៅជនបទ គឺជាជនដែលងាយទទួលរង គ្រោះជាងគេបំផុត ដោយការធ្វើតាមទំនើងចិត្តពីអាជ្ញាធរសាធារណៈ និង ជនដែលមានអំណាច ហើយប្រជាពលរដ្ឋទាំងនេះស្ទើរតែគ្មានមធ្យោបាយដោះស្រាយតាមផ្លូវច្បាប់ ដើម្បីជួយការពារពួកគេទាល់តែសោះ ។ ខ្ញុំបានសន្យាជាមួយសហគមន៍ទាំងនោះថាខ្ញុំនឹងជួយតស៊ូមតិជួសមុខសហគមន៍ និង ទាក់ទាញការយកចិត្តទុកដាក់ចំពោះស្ថានភាពពួកគេ ។

ខ្ញុំបានពិភាក្សាបញ្ហាដែលបានលើកឡើងក្នុងរបាយការណ៍នេះ ជាមួយព្រះមហាក្សត្រនរោត្តម សីហនុ នាយករដ្ឋមន្ត្រីហ៊ុន សែន  ទេសរដ្ឋមន្ត្រី និង មន្ត្រីនៃរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និង ទីភ្នាក់ងារនៃប្រទេសអ្នកផ្តល់ជំនួយនានា ។ ខ្ញុំបានចូលរួមពិភាក្សាអំពីសេចក្តីព្រួយបារម្ភ និង អនុសាសន៍ផ្សេងៗ ជាមួយសហគមន៍អន្តរជាតិ តាមរយៈរបាយការណ៍របស់ខ្ញុំ ដាក់ជូនមហាសន្និបាត អ.ស.ប និង គណៈកម្មាធិការសិទ្ធិមនុស្ស ។ ខ្ញុំបានគូសបញ្ជាក់ពីសេចក្តីត្រូវការឱ្យមានការផ្សព្វផ្សាយទាំងស្រុងជាសាធារណៈស្តីពីសម្បទាន និង សម្បទានិក មិនត្រឹមតែអំពីដីសម្បទានគោលដៅសេដ្ឋកិច្ចប៉ុណ្ណោះទេ តែថែមទាំងអំពីរាល់សម្បទានទាំងអស់ ទោះជាគោលដៅអ្វីក៏ដោយ រួមទាំងសម្បទានទាំងឡាយ ដែលមិនស្ថិតក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ ដូចជាសម្បទានគោលដៅទេសចរណ៍ សេដ្ឋកិច្ច និង សម្បទានគោលដៅធ្វើអាជីវកម្មរ៉ែ ។

ក្នុងខណៈដែលខ្ញុំកំពុងសរសេរបញ្ចប់របាយការណ៍នេះ ខ្ញុំមានសេចក្តីពេញចិត្តយ៉ាងខ្លាំងចំពោះសេចក្តីថ្លែងការណ៍ជាសាធារណៈ ដែលលោកនាយករដ្ឋមន្ត្រីបានថ្លែង នៅក្នុងឱកាសនៃវេទិកាជាតិស្តីពីដីធ្លី ដែលបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤។ លោកនាយករដ្ឋមន្ត្រីបានទទួលស្គាល់ពីសារៈសំខាន់ និង ភាពបន្ទាន់បង្ខំ ក្នុងការដោះស្រាយបញ្ហាភាគច្រើនដែលបានលើកឡើងក្នុងរបាយការណ៍នេះ។ លោកបានប្រកាសផ្អាកចុះកិច្ចសន្យាសម្បទានគោលដៅសេដ្ឋកិច្ចរហូតដល់មានច្បាប់សំខាន់ៗ ពាក់ព័ន្ធចូលជាធរមានរួចសិន ហើយលោកបានសុំឱ្យអាជ្ញាធរត្រួតពិនិត្យកិច្ចសន្យាសម្បទានទាំងអស់ដែលបានចុះហត្ថលេខារួចហើយ។ លោកបានសំដែងការសោកស្តាយចំពោះការចាប់យកដីធ្លី និង ការរកចំណេញពីដីធ្លី ហើយលោកគូសបញ្ជាក់ថាត្រូវតែធ្វើការបែងចែកដីធ្លីឱ្យប្រជាពលរដ្ឋក្រីក្រដែលត្រូវការដីធ្លីដើម្បីធ្វើកសិកម្មចិញ្ចឹមជីវិត។

ពិតណាស់ ប្រទេសកម្ពុជាត្រូវចាត់ចែងគ្រប់គ្រងដីធ្លីរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋទាំងមូល គឺមិនមែនដើម្បីជាប្រយោជន៍របស់ជនមួយក្រុមតូចដែលលាក់ខ្លួនមិនឱ្យសាធារណៈជនឃើញនោះទេ ដែលយ៉ាងហោចណាស់ ជនទាំងនោះត្រូវជាប់កាតព្វកិច្ចគោរពច្បាប់ ដូចអ្នកដទៃទៀតដែរ។ ប្រទេស កម្ពុជាត្រូវតែអនុវត្តច្បាប់ភូមិបាលរបស់ខ្លួនឱ្យបានពេញលេញ ស្របតាមសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាជាប់កាតព្វកិច្ចត្រូវអនុវត្តតាម និងដោយមានការជំរុញលើកទឹកចិត្តពីប្រទេសអ្នកផ្តល់ជំនួយ និង ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ដែលទទួលខុសត្រូវក្នុងការលើកស្ទួយសិទ្ធិមនុស្ស និង យុត្តិធម៌ ស្របតាមច្បាប់អន្តរជាតិ។

ខ្ញុំសង្ឃឹមថារបាយការណ៍ និង អនុសាសន៍ដែលបានលើកឡើងក្នុងរបាយការណ៍នេះ នឹងជួយជាវិភាគទានដល់ការយល់ដឹងថែមទៀតអំពីបញ្ហាទាំងនេះ និងជួយធ្វើឱ្យមានការផ្លាស់ប្តូរគោលនយោបាយ និង ទម្លាប់អនុវត្តទាំងឡាយដែលចាំបាច់ជាប្រយោជន៍សំរាប់ប្រទេសកម្ពុជា ប្រជាពលរដ្ឋក្រីក្ររបស់ខ្លួនរស់នៅជនបទ និង ដើម្បីអនាគតអ្នកជំនាន់ក្រោយ។

លោកភីធើលយព្រិច តំណាងពិសេសរបស់លោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។

# សេចក្តីផ្តើម

ប្រជាពលរដ្ឋកម្ពុជាភាគច្រើនរស់នៅក្នុងតំបន់ជនបទ ហើយពួកគេពឹងផ្អែកលើដីធ្លី និង ធនធានធម្មជាតិនៃប្រទេសកម្ពុជា ដើម្បីជីវភាពរស់នៅ និង ចិញ្ចឹមជីវិត ។ [១] បច្ចុប្បន្ននេះ ដោយសារសម្ពាធនៃកំណើនប្រជាពលរដ្ឋ ការបាត់បង់ និង ភាពរិចរិលនៃធនធានធម្មជាតិ និង សិទ្ធិប្រើប្រាស់ដីធ្លី និង ព្រៃឈើត្រូវបានរិតត្បិតកាន់តែខ្លាំងឡើងៗ គឺជាកត្តាដែលនាំឱ្យគ្រោះថ្នាក់ថែមទៀតដល់សុខមាលភាពរបស់ប្រជាពលរដ្ឋក្រីក្រ ។ [២] តើដីធ្លី និងធនធានធម្មជាតិត្រូវបានចាត់ចែង និង គ្រប់គ្រងយ៉ាងដូម្តេច  នរណាជាអ្នកគ្រប់គ្រង ហើយសំរាប់ជាផលប្រយោជន៍របស់នរណានោះគឺជាការសំខាន់បំផុតសំរាប់ស្ថេរភាពនយោបាយ និង សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ។

នៅក្នុងយៈកាលពីរទសវត្សក្រោយពីមានជំលោះ និង សង្គ្រាមស៊ីវិលមក ប្រទេសកម្ពុជាបានការបើកទំព័រថ្មី អមដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ បាននាំមកនូវបែបផែនថ្មីមួយ នៃការកាន់កាប់ការប្រើប្រាស់ និងការចាត់ចែងដីធ្លី ។ នៅក្នុងទសវត្សនៃឆ្នាំ១៩៩០ គេឃើញមានប្រជាពលរដ្ឋជាច្រើនមិនទាន់បានតាំងទីលំនៅពិតប្រាកដ ដែលក្នុងនោះភាគច្រើនជាជនធ្វើមាតុភូមិនិវត្តន៍មកពីជំរុំជនភៀសខ្លួននានា ការបើកឱ្យមានសេដ្ឋកិច្ចទីផ្សារ ការកាន់កាប់ដីធ្លីគ្មានសុវត្ថិភាព ការចាប់យកដីធ្លី និងកើតមានទំនាស់ដីធ្លីជាច្រើន ដោយពុំមានស្ថាប័នណាមួយមានមធ្យោយមានប្រសិទ្ធិភាពអាចដោះស្រាយបានឡើយ ។ ដោយសារដីកាន់តែមានតម្លៃខ្ពស់ជាពិសេស ដីធ្លី ដែលស្ថិតនៅជិតទីផ្សារ ឬ ដីធ្លីដែលមានជីរជាតិល្អ ឬ ដីដែលមានធនធានសំខាន់ៗ ដូចជាព្រៃឈើ ឬ រ៉ែ សេចក្តីត្រូវការដីធ្លី ដោយក្រុមមនុស្សផ្សេងៗ ដែលមានផលប្រយោជន៍បានកើនឡើង ក្នុងនោះរួមមានក្រុម-ហ៊ុនឯកជននានា ដែលភាគច្រើនជាជនបរទេស និងឯកត្តបុគ្គលដែលកាន់តំណែងខ្ពស់ និងមានអំណាចខ្លាំងដូចជាមន្ត្រីអ្នកមុខអ្នកការនៃរដ្ឋាភិបាល និងមន្ត្រីយោធា ។

ប្រទេសកម្ពុជាមានផ្ទៃដីសរុប ១៨,១ លានហិកតា ដែលក្នុងនោះមានផ្ទៃដីដែលចាត់ទុកថាអាចដាំដុះបានមានចំនួន៦,៥ លានហិតា និងអាចឡើងដល់ ២,៧ លានហិកតា ដែលអាចបង្កបង្កើនផលបាន ។ [៣] នៅចន្លោះឆ្នាំ

---

[១] ប្រជាពលរដ្ឋកម្ពុជាប្រមាណជា ៨៥% រស់នៅជនបទ : រដ្ឋាភិបាលកម្ពុជា *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេលប្រាំឆ្នាំលើកទីពីរ* ២០០១-២០០៥ ក្រសួងផែនការ *ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា* ឆ្នាំ ១៩៩៩ ។ ការជំរឿនប្រជាជនទូទៅឆ្នាំ១៩៩៩ បានរកឃើញថា ៧៦.៥% នៃប្រជាពលរដ្ឋកម្ពុជាប្រកបរបរកសិកម្ម ព្រៃឈើ និង នេសាទ ។

[២] មានការយល់ស្របតិចតួចអំពីសុពលភាព និង ការប្រៀបធៀបនៃការអង្កេតផ្សេងៗ ។ យោងតាមការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៩ មានប្រជាពលរដ្ឋចំនួន ១៥,៨% រស់នៅជនបទ ហើយគ្មានដីធ្លី ហើយបើតាមការសិក្សាស្រាវជ្រាវរបស់អង្គការ Oxfam GB ក្នុងឆ្នាំ ១៩៩៩ /២០០០ (LADIT 2000 /183) បានរកឃើញថាប្រជាពលរដ្ឋចំនួន១២ % នឹងគ្មានដីធ្លី ។ ភាពអត់ដីធ្លីនៅក្នុងការអង្កេតថ្មីៗបំផុត LADIT 2004 /120 បានរកឃើញថាមានប្រជាពលរដ្ឋចំនួន ១១.៩ % អត់មានដីធ្លី ។

[៣] សូមមេត្តាអានរបាយការណ៍របស់វិទ្យាស្ថានជាតិស្ថិតិស្ថិតិ *ការជំរឿនប្រជាជនទូទៅនៅក្នុងប្រទេសកម្ពុជា ឆ្នាំ ១៩៩៨ ចំនួនសរុបបណ្តោះអាសន្ននៃប្រជាជន* (1998, UNPF) ទំព័រទី៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) *ការកាន់កាប់ដីនៅក្នុងប្រទេសកម្ពុជា - ការធ្វើបច្ចុប្បន្នភាពទិន្នន័យ-* ឯកសារការងារ ចុះថ្ងៃទី១៩ ខែ តុលា ឆ្នាំ២០០១ បង្ហាញថាមានដីកសិកម្មចំនួន ៣,៩ លានហិកតា ។

១៩៩៣ និង ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានជាងមួយភាគបី (១/៣) នៃដីធ្លីដែលឱ្យជីវជាតិល្អជាងគេទៅឱ្យក្រុមហ៊ុនឯកជននានា ដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្ម ក្នុងនោះរួមមានព្រៃឈើ កសិកម្ម រ៉ែ ទេសចរណ៍ និង នេសាទ។ រាជរដ្ឋាភិបាលក៏បានប្រគល់ដីធ្លីទៅឱ្យយោធា ដើម្បីធ្វើការអភិវឌ្ឍន៍។[៤] បច្ចុប្បន្ននេះ ផ្ទៃដីប្រមាណជា ២,៧ លានហិកតា ស្ថិតក្រោមការចាត់ចែងគ្រប់គ្រងនៃសម្បទាន ចាប់ពីចំណុចកំពូលមកគឺប្រមាណជា ៨ លាន ហិកតា នៅក្នុងអំឡុងទសវត្សនៃឆ្នាំ១៩៩០។ ទិន្នន័យដែលគួរឱ្យជឿបានអំពីទីតាំង និង ទំហំនៃតំបន់អភិវឌ្ឍន៍ យោធាដែលមានបំណងផ្តល់ដីធ្លី និង ការងារដល់យោធិនរំសាយ គឺមិនមានសំរាប់ផ្តល់ឱ្យទេ។

ដីសម្បទានសំរាប់ធ្វើអាជីវកម្មកសិកម្ម និង ពាណិជ្ជកម្ម ត្រូវបានធ្វើចំណាត់ថ្នាក់ ក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ ថា ជា " ដីសម្បទានសំរាប់គោលដៅសេដ្ឋកិច្ច"។ នៅក្នុងរបាយការណ៍នេះ ពាក្យថា "សម្បទានគោលដៅ សេដ្ឋកិច្ច " ត្រូវបានប្រើជាពាក្យបំព្រួយ។ សម្បទានសេដ្ឋកិច្ច រួមមានដីចំការដំណាំសំខាន់ៗ ដូចជាដើមកៅស៊ូ ដើមដូងប្រេង ដើមម៉ៃសាក់ ដើមប្រេងខ្យល់ ដើមដូង និង " ដំណាំកសិឧស្សាហកម្ម " ផលិតកម្មស្បៀងដែលមាន ទ្រង់ទ្រាយធំ ដូចជាដំឡូងមី ស្រូវ ពោត ឬ សណ្តែកសៀង។ បើតាមច្បាប់ភូមិបាល សម្បទានគោលដៅសេដ្ឋកិច្ច ផ្តល់ឱ្យវិនិយោគិននូវសិទ្ធិផ្តាច់មុខ ក្នុងការចាត់ចែងគ្រប់គ្រង និង ការទាញយកផលពីដីនោះ ដែលរយៈពេលរហូត ដល់ ៩៩ ឆ្នាំ។ សម្បទានទាំងនេះ ត្រូវបានផ្តល់ឱ្យវិនិយោគិន ជាថ្នូរសំរាប់ការវិយោគជាក់លាក់មួយចំនួន និង ប្រាក់ ឈ្នួលដី។

កាលពីដើមឆ្នាំ ១៩៩៦[៥] អតីតតំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជាបានលើកឡើងពីការព្រួយបារម្ភអំពីផលប៉ះពាលរបស់សម្បទានទាំងនេះ។ អង្គការសិទ្ធិមនុស្សនានាបាន ចាប់ផ្តើមទទួលពាក្យបណ្តឹងជាច្រើនអំពីការរំលោភសិទ្ធិមនុស្សនៅលើដីសម្បទានានា ក្នុងរយៈពេលជាច្រើន ក្រោយមក។ ដោយមានការព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ដោយមានសេចក្តីរាយការណ៍ ថាមានវិវាទហឹង្សាកើត ឡើងជាញឹកញាប់រវាងសម្បទានិក និង ប្រជាពលរដ្ឋមូលដ្ឋាន ទើបនៅខែមេសា ឆ្នាំ២០០៣ ការិយាល័យឧត្តម ស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) បានចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវ មួយអំពីសម្បទានគោលដៅសេដ្ឋកិច្ច។ គោលបំណងគឺដើម្បីពិនិត្យអំពីផលប៉ះពាល់របស់សម្បទានគោលដៅ

---

[៤] បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៣មក ដីរដ្ឋត្រូវបានដាក់ឱ្យកងទ័ពប្រើប្រាស់ សំរាប់មូលហេតុការពារ និង រក្សាសន្តិសុខជាតិ។ នៅពេលដែល ជំលោះប្រដាប់អាវុធ បានរំកិលបន្តិចម្តងៗ ឆ្ពោះទៅកាន់តំបន់ជនបទដាច់ស្រយាល ផ្ទៃដីដ៏ធំនៅទំនេរសំរាប់ប្រជាពលរដ្ឋតាំងទីលំនៅ និង ធ្វើកសិកម្ម ដោយមាននាយ ទាហានជាន់ខ្ពស់ នៅតែបន្តកាន់កាប់ដីដ៏ធំ ដែលជារឿយៗ តាំងនៅតំបន់ព្រៃ។ នៅក្នុងតំបន់ខ្លះ មានភាពច្របូកច្របល់ និងមានជំលោះកើតឡើងរវាង នាយទាហាន សម្បទានិក និង ប្រជាពលរដ្ឋមូលដ្ឋាន។ សហនាយករដ្ឋមន្ត្រី ត្រូវបានគេរាយការណ៍ថា បានផ្តល់ដី ៥% នៃទឹកដីកម្ពុជា កាលពីខែកក្កដា ឆ្នាំ១៩៩៤ ទៅឱ្យកងយោធពល ខេមរភូមិន្ទ នៅក្នុងខេត្តចំនួនប្រាំពីរគឺ : ខេត្តឧត្តរមានជ័យ កំពង់ស្ពឺ កោះកុង មណ្ឌលគីរី ពោធិសាត់ រតនគីរី និង កំពង់ចាម។ លុះក្រោយមក ក្នុងចំណោះដីទាំងនោះ មានដីខ្លះ ត្រូវបានគេរាយការណ៍ថា បានជួលទៅឱ្យក្រុមហ៊ុននានា ក្រោមរូបភាពជាដីសម្បទាន។ ម៉ាធូ គ្រេនជឺ (Mathew Grainger)

[៥] ការដោះស្រាយដីឱ្យទៅយោធា បានកាត់បន្ថយនូវថវិកាជាតិ *"កាសែតភ្នំពេញប៉ុស្តិ៍"* អត្ថបទលេខ 5/11 ចុះថ្ងៃទី៣១ ខែឧសភា - ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩៦។

សេដ្ឋកិច្ចលើសិទ្ធិមនុស្ស និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលបានទទួលរងផលប៉ះពាល់ អំពីកិរិតប៉ុណ្ណាដែលសម្បទានិកបានគោរពច្បាប់ភូមិបាល ខែសីហា ឆ្នាំ២០០១ និង កិច្ចសន្យារបស់ខ្លួន ហើយនិងអំពីទំហំប៉ុន្មានដែលប្រជាពលរដ្ឋកម្ពុជាទាំងមូលទទួលបានអត្ថប្រយោជន៍ពីសម្បទានទាំងនេះ ជាពិសេសក្នុងការរួមវិភាគទានដល់ប្រាក់ចំណូលរដ្ឋទាំងមូល ។ ការសិក្សាស្រាវជ្រាវបានធ្វើឡើង ដោយយោងតាមលិខិតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និង តាម សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី កាលពីខែឧសភា ឆ្នាំ២០០១ ដែលមានគោលដៅពង្រឹងធានានូវភាពគត់ម៉ត់ដល់ការកាន់កាប់ដីធ្លី និង ទីផ្សារដីធ្លី និង ដើម្បីទប់ស្កាត់ ឬ ដោះស្រាយជំលោះដីធ្លី ចាត់ចែងគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិក្នុងលក្ខណៈសមធម៌ ចិរភាព និង មានប្រសិទ្ធិភាព ព្រមទាំងជំរុញឱ្យមានការបែងចែកដីធ្លីប្រកបដោយសមធម៌ ។ បញ្ហាព្រួយបារម្ភមួយចំនួនទៀតក៏ត្រូវបានពិនិត្យផងដែររួមមាន " ការយល់ច្រឡំជាទូទៅមួយអំពីច្បាប់ សិទ្ធិ និង នីតិវិធីទាក់ទងនឹងដីធ្លី ដោយប្រជាពលរដ្ឋសាមញ្ញ និងមន្ត្រីទទួល ខុសត្រូវក្នុងការចាត់ចែងគ្រប់គ្រង និង ការដោះស្រាយបញ្ហាដីធ្លី "។[៦] វិធីសាស្ត្រនៃការស្រាវជ្រាវដល់ទីកន្លែងត្រូវបានពិពណ៌នានៅក្នុងផ្នែកទី២ ។ មានចំណុចខ្វះខាតមួយគឺការមិនបានដាក់បញ្ចូលនូវសម្បទានមួយដែលបានផ្តល់នៅលើដីដែលជនជាតិដើមភាគតិចកម្ពុជាកំពុងរស់នៅ ។

នៅក្នុងពេលនោះ សម្បទានគោលដៅសេដ្ឋកិច្ច ត្រូវគេយកចិត្តទុកដាក់តិចតួច ផ្ទុយពីសម្បទានព្រៃឈើ ទោះបីជាសម្បទានទាំងពីរនេះមានចំណងទាក់ទងភ្ជាប់គ្នាយ៉ាងជិតស្និទ្ធិក្តី ដោយសារការធ្វើសម្បទានគោលដៅសេដ្ឋកិច្ច គេអនុញ្ញាតឱ្យកាប់ឆ្ការព្រៃឈើលើដីនោះបាន រួមទាំងដីព្រៃផង ដូចនេះជាការបើកច្រកឱ្យមានការកាប់ព្រៃផ្ទុយពីរបបគ្រប់គ្រងព្រៃឈើដែលបានកំណត់តឹងរ៉ឹងជាង ធ្វើនៅពីចុងទសវត្សឆ្នាំ១៩៩០ ។ ច្បាប់ព្រៃឈើបានចូលជាធរមាន កាលពីថ្ងៃ ទី៣១ ខែសីហា ឆ្នាំ២០០២ ដើម្បីធ្វើនិយ័តកម្មដល់ការចាត់ចែងគ្រប់គ្រង និងរដ្ឋបាលព្រៃឈើកម្ពុជាប្រកបដោយចិរភាព ហើយនិងសេចក្តីប្រកាសស្តីពីការផ្អាកជាបណ្តោះអាសន្នរាល់ការកាប់ឈើក្នុងព្រៃសម្បទាន និងការដឹកជញ្ជូនឈើ បានចូលជាធរមានតាំងពីខែមករា និង ខែឧសភា នៃខែនីមួយៗក្នុងឆ្នាំ២០០២ ។ សម្បទានព្រៃត្រូវបានពិពណ៌នាជាលំអិតនៅក្នុងរបាយការណ៍ផ្សេងទៀត ។[៧] របាយការណ៍នេះពិនិត្យ

---

[៥] របាយការណ៍របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, UN Doc., E/CN.4/1996/93, ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ វាក្យខ័ណ្ឌទី៨៤ ។

[៦] ឯកសាររបស់អង្គការ Oxfam GB ដែលមានចំណងជើងថា *តើដីទាំងនោះបាត់ទៅណាអស់ហើយ? សិទ្ធិ និង ការប្រើប្រាស់ដីធ្លីនៅប្រទេសកម្ពុជា* វ៉ុលូម ទី២ ករណីសិក្សា ចុះ ខែឧសភា ឆ្នាំ១៩៩៩ ទំព័រទី២ ។

[៧] ព្រៃសម្បទានត្រូវបានពិពណ៌នាលំអិតបំផុត ។ សាជីវកម្ម ARD inc និង នាយកដ្ឋានរុក្ខាប្រម៉ាញ់ *ឯកសារការងារស្តីពីការផ្លាស់ប្តូរគោលនយោបាយព្រៃឈើនៅប្រទេសកម្ពុជា* ខែឧសភា ឆ្នាំ១៩៩៨ ដោយ Bottomley R, *ការវិភាគពីរច្នាសម្ព័ន្ធនៃការកាប់បំផ្លាញព្រៃឈើនៅក្នុងប្រទេសកម្ពុជា* (ជប៉ុន : អង្គការអ្នកឃ្លាំមើលទន្លេមេគង្គ និង វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក) ខែមីនា/មេសា ឆ្នាំ២០០០ ដោយ Fraser Thomas Associates /ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) (ខែមេសា ឆ្នាំ២០០០) *របាយការណ៍ស្តីពីការត្រួតពិនិត្យព្រៃសម្បទាននៅប្រទេសកម្ពុជា* (ភ្នំពេញ ) អត្ថបទបោះពុម្ពផ្សាយដោយអង្គការ Global Witness ទីក្រុងឡុងដុង : *ព្រៃឈើ ភាពអត់ឃ្លាន និង សង្គ្រាម : ដំណោះស្រាយសំរាប់អនាគតនៃប្រទេសកម្ពុជា* (១៩៩៥) *អំពើពុករលួយ សង្គ្រាម និង គោលនយោបាយព្រៃឈើ : អាជីវកម្មអចិរភាពនៃព្រៃឈើក្នុងប្រទេសកម្ពុជា* (ខែកម្ភះ ឆ្នាំ១៩៩៦ ) (ខែមិថុនា ឆ្នាំ១៩៩៧ ) *តើនេះគ្រាន់តែជាវាលខ្សាច់សំរាប់ប្រទេសកម្ពុជាឬ? ការកាប់ព្រៃឈើ*

ជាសំខាន់លើប្រព័ន្ធសម្បទាន ទាំងមូល ឬដែលសម្បទានទាំងនេះបានផ្តល់នូវចំណុចប្រៀប ធៀបដ៏សំខាន់មួយដល់ការបង្កើតនូវគោលនយោបាយ ស្តីពីសម្បទានគោលដៅសេដ្ឋកិច្ច ។ បច្ចុប្បន្ននេះ ចំការ កៅស៊ូទាំងអស់ ត្រូវបានធ្វើចំណាត់ថ្នាក់ថាជាសហគ្រាស សាធារណៈក៏បានផ្តល់ជាមធ្យោបាយមួយ ដើម្បីគេចវេស ពីរបបគ្រប់គ្រងព្រៃឈើ ហើយបានបង្កើតឱ្យមានបញ្ហា ស្រដៀងគ្នានេះ អំពីផលប៉ះពាល់របស់វាដល់ប្រជាពលរដ្ឋ មូលដ្ឋាន ។[៨] មានករណីសិក្សាមួយទាក់ទង នឹងចំការកៅស៊ូមួយកន្លែង ហើយផលប៉ះពាល់របស់វាក៏បានដាក់បញ្ចូល ក្នុងរបាយការណ៍នេះដែរ ។

ការស្រាវជ្រាវដល់ទីកន្លែង បានឱ្យដឹងថា នៅថ្នាក់មូលដ្ឋាន សកម្មភាពផ្សេងៗ របស់សម្បទានិកតែងបង្កឱ្យមានផលវិបាកធ្ងន់ធ្ងរយ៉ាងច្រើនដល់សង្គមកិច្ច សេដ្ឋកិច្ច និង វប្បធម៌ នាំទៅរកការដកហូតដីធ្លី ធ្វើឱ្យប្រជាពលរដ្ឋមូលដ្ឋានក្រីក្រ ហើយជួនកាលធ្វើឱ្យមានជំលោះច្រើនទៀតផង ។ ប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់ ដែលបានទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ដោយសម្បទានទាំងនេះ បានទទួលរងនូវការរំលោភសិទ្ធិមនុស្សរបស់ខ្លួន ប៉ុន្តែប្រព័ន្ធច្បាប់មិនបានគិតគូរ " ដោះស្រាយបញ្ហាទាំងនោះប្រកបដោយប្រសិទ្ធិភាព " ទេ ។ មានភស្តុតាងតិចតួចដែលបង្ហាញអំពីការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងមានការព្រួយបារម្ភជាច្រើនអំពីការអភិរក្សបរិស្ថានជីវចំរុះ ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងធានាអំពីសិទ្ធិមនុស្សសំខាន់ៗ ហើយបានបញ្ចូលយ៉ាងច្បាស់នៅក្នុងច្បាប់ជាតិនូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង សន្ធិសញ្ញាអន្តរជាតិនានាទាក់ទងនឹងសិទ្ធិមនុស្សដែលប្រទេសកម្ពុជាបានជាប់កាតព្វកិច្ចត្រូវអនុវត្តតាម ។[៩] សន្ធិសញ្ញាស្នូលចំនួនពីរ សំរាប់ការអនុវត្តទូទៅគឺកតិកាសញ្ញាអន្តរ

*និង អច្ច័យទានរបស់សហនាយករដ្ឋមន្ត្រីចំពោះប្រទេសជាតិ* (ខែកុម្ភះ ឆ្នាំ១៩៩៩) *ការបង្ក្រាប ឬការបញ្ឈប់ : ឱកាសសំរាប់ការធ្វើកំណែទម្រង់ព្រៃឈើក្នុងប្រទេសកម្ពុជា ?* (ខែកម្ភះ ឆ្នាំ១៩៩៩ ) *អ្នកដែលមិនអាចប៉ះពាល់បាន : បទល្មើសព្រៃឈើ និង សម្បទានិក - តើប្រទេសកម្ពុជាអាចគ្រប់គ្រងបញ្ហាទាំងនេះបានឬទេ?* (ខែធ្នូ ឆ្នាំ១៩៩៩ ) *ស្នូរសណោអារឈើលាន់ឮខ្លាំងជាងពាក្យសន្យារបស់រដ្ឋាភិបាល ការបំផ្លិចបំផ្លាញព្រៃឈើគ្មានទីបញ្ចប់ - ការដែលរដ្ឋាភិបាលកម្ពុជាមិនបានដោះស្រាយចំពោះអ្នក ដែលមិនអាចប៉ះ ពាល់បាន* (ខែកក្កដា ឆ្នាំ២00២) ដោយ Henderson, D. *វិស័យព្រៃឈើនៅប្រទេសកម្ពុជា - របាយការណ៍ផ្ញើជូនអង្គការ JICA* (ភ្នំពេញ ខែមេសា ឆ្នាំ១៩៩៩) ដោយ Huq, A. *ការប្រមូលផលយ៉ាងជូរចត់ : សម្បទានព្រៃនៅក្នុងប្រទេសកម្ពុជា* (ភ្នំពេញ ឆ្នាំ១៩៩៩) វេទិកានៃអង្គការក្រៅរដ្ឋាភិបាល (NGO forum) ស្តីពីប្រទេសកម្ពុជា *សេចក្តីថ្លែងការណ៍របស់អង្គការក្រៅរដ្ឋាភិបាលដាក់ជូនសម័យប្រជុំក្រុមពិគ្រោះយោបល់ស្តីពីប្រទេសកម្ពុជា ឆ្នាំ១៩៩៩* (ភ្នំពេញ ខែកម្ភៈ  ឆ្នាំ១៩៩៩) ធនាគារពិភពលោក (World Bank) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) *ការវាយតំលៃគោលនយោបាយព្រៃឈើ ដោយអង្គការស្បៀងអាហារ និងកសិកម្ម(FAO) កម្ពុជា* (ភ្នំពេញ ឆ្នាំ១៩៩៦) ។

[៨] ចាប់តាំងពីឆ្នាំ១៩៧៩ ចំការកៅស៊ូទាំងអស់ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនចំការកៅស៊ូរដ្ឋចំនួនប្រាំពីរ ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណជា៦២.000 ហិកតា នៅក្នុងឆ្នាំ២00១ ។ ក្រុមហ៊ុនដែលមានស្រាប់ទាំងប៉ុន្មាននោះ ត្រូវបានធ្វើចំណាត់ថ្នាក់ជា " សហគ្រាសសាធារណៈ" ចាប់ពីឆ្នាំ១៩៩៩ ។ ក្រៅពីនេះ មានក្រុមហ៊ុនតូចៗ ជាច្រើនដែលទទួលបានការឧបត្ថម្ភពីម្ចាស់ជំនួយនានា ជាពិសេស ពីប្រទេសបារាំង ។

[៩] ប្រទេសកម្ពុជាបានផ្តល់សច្ចានុមតិ លើអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រកាន់ពូជសាសន៍ នៅក្នុងឆ្នាំ១៩៨៣ ។ ក្នុងឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ  អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និង ការផ្តន្ទាទោស ឬ ការប្រព្រឹត្តទាំងឡាយណាដែលឃោឃៅអមនុស្សធម៌ ឬ ដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស  អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

ជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ សន្ធិសញ្ញាទាំងនេះ បានផ្តល់នូវសិទ្ធិយ៉ាងច្រើន រួមទាំងសិទ្ធិមានជីវភាពរស់នៅសមរម្យ សិទ្ធិចូលរួមនៅ ក្នុងជីវ-ភាពវប្បធម៌ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់  និង សិទ្ធិទទួលបានកិច្ចការពារស្មើគ្នាដោយច្បាប់ ការការពារមិនឱ្យមានការដកហូតយកដីធ្លីតាមទំនើងចិត្ត សេរីភាពខាងការបញ្ចេញមតិ និង សិទ្ធិបង្កើតសមាគម សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខបុគ្គល និងសិទ្ធិទទួលបាន "ការដោះស្រាយប្រកបដោយប្រសិទ្ធិភាព"។ លទ្ធផលនៃការស្រាវជ្រាវនោះ គឺរាជរដ្ឋាភិបាលត្រូវខិតខំប្រឹងប្រែងឱ្យបានខ្លាំងក្លាថែមទៀត ដើម្បីលើកស្ទួយការគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ដទៃទៀត និង បំពេញកាតព្វកិច្ចសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន។ រាជរដ្ឋាភិបាលត្រូវធានាជីវភាពរស់នៅ និង ការគោរពសិទ្ធិមនុស្សនៃប្រជាពលរដ្ឋ ក្នុងការផ្លាស់ប្តូរពីការធ្វើកសិកម្មជាលក្ខណៈគ្រួសារ ទៅការធ្វើកសិកម្មដើម្បីរកប្រាក់ចំណូល។ ប្រជាពលរដ្ឋក្រីក្រនៅជនបទ នៃប្រទេសកម្ពុជាបានទទួលអត្ថប្រយោជន៍តិចតួចពីការរីកលូតលាស់ខាងសេដ្ឋកិច្ចដ៏ច្រើនសន្ធឹកសន្ធាប់ នៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដែលក្នុងរយៈពេលជាងដប់ឆ្នាំកន្លងមក មានការលូតលាស់គិតជាមធ្យមភាគគឺប្រាំភាគរយ (5%) ក្នុងមួយឆ្នាំ។ នៅក្នុងរយៈពេលនេះដែរប្រជា-ពលរដ្ឋជាច្រើនដែលរស់នៅក្នុងភាពក្រីក្រ មិនបានទទួលអត្ថប្រយោជន៍ច្រើនទេ។[១០] រាជរដ្ឋាភិបាលត្រូវត្រូវចាប់ឱ្យក្រុមហ៊ុនឯកជនទទួលខុសត្រូវចំពោះសិទ្ធិសំខាន់ៗ លើដីសាធារណៈ។ ក្នុងការស្រាវជ្រាវសំរាប់ធ្វើរបាយការណ៍នេះ បានបង្ហាញឱ្យឃើញពីការលំបាកខ្លាំងក្នុងការស្វែងរកពតិមានសំខាន់ៗ ពីមន្ត្រីសាធារណៈ ដូចជាកិច្ចសន្យាសម្បទាន ផែនទី ម្ចាស់ភាគហ៊ុននីមួយៗ។  បញ្ហានេះបានធ្វើ ឱ្យប៉ះពាល់ដល់ភាពក្បោះក្បាយនៃរបាយការណ៍នេះ ។ របាយការណ៍បានគូសបញ្ជាក់ដែរពីសេចក្តីត្រូវការឱ្យមានគោលនយោបាយ និង ការងាររដ្ឋបាលបើកទូលាយជាងនេះ ក៏ដូចជាច្បាប់ស្តីពីសេរីភាពខាងពតិមាន។ ការទទួលបានពតិមានសំខាន់ៗ ជាមូលដ្ឋាន ស្តីពីសម្បទានគោលដៅសេដ្ឋកិច្ច និង ប្រព័ន្ធសម្បទានជាទូទៅ នឹងអាចជួយបង្កើនការទទួលខុសត្រូវ និងការពិភាក្សាផ្លាស់ប្តូរពតិមានពាក់ព័ន្ធការចាត់ចែងគ្រប់គ្រង និងរដ្ឋបាលដីធ្លី។ វាក៏អាចជួយប្រឆាំងអំពើពុករលួយ ដែលជាសេចក្តីព្រួយបារម្ភជាពិសេសមួយ នៅក្នុងប្រទេសកម្ពុជា នៅក្នុងខណៈពេលដែលមិនទាន់មានច្បាប់ណាមួយតម្រូវឱ្យមន្ត្រីរាជការស៊ីវិល និងមន្ត្រីកាន់តំណែងរដ្ឋាភិបាល ធ្វើការប្រកាសទ្រព្យសម្បត្តិរបស់ខ្លួន ហើយនិងមិនទាន់មានការចុះបញ្ជីនៃភាគហ៊ុនរបស់ក្រុមហ៊ុនជាសាធារណៈ ដែលសាធារណៈជនអាចចូលមើលបាន។ នៅទីបញ្ចប់ ប្រសិនបើចង់ឱ្យកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាបានសម្រេចជោគជ័យនោះ សំខាន់គឺត្រូវតែដឹងឱ្យបានច្បាស់ថា តើដីរដ្ឋ និង ធនធានធម្មជាតិនៃប្រទេសកម្ពុជា ប៉ុន្មានត្រូវបានផ្តល់សម្បទានទៅឱ្យក្រុមហ៊ុនឯកជន និង បុគ្គលឯកជនគ្រប់គ្រង។

---

[១០] តាមការប៉ាន់ស្មាន មានប្រជាពលរដ្ឋប្រមាណជាសាមសិបប្រាំមួយភាគរយ (36%) ដែលមានជីវភាពរស់នៅក្រោមបន្ទាត់ភាពក្រីក្រ គឺ ០,៤៦-០,៦៣ ដុល្លារ ដែលក្នុងនោះមានប្រជាពលរដ្ឋក្រីក្រចំនួនកៅសិបប្រាំភាគរយ (95%) រស់នៅជនបទ ដែលក៏រិតភាពក្រីក្ររបស់គេ ស្មើនឹងបួនដងនៃក៏រិតភាពក្រីក្ររបស់ប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញ។

ផ្នែកទីមួយនៃរបាយការណ៍នេះ រៀបរាប់អំពីការវិវឌ្ឍន៍នៃប្រព័ន្ធសម្បទាន បទបញ្ជា និង ច្បាប់ស្តីពីដីធ្លី ។ ផ្នែកនេះពិនិត្យផងដែរអំពីកិច្ចសន្យាសម្បទានគោលដៅសេដ្ឋកិច្ច និង ការគោរពច្បាប់របស់សម្បទានិក ។ ផ្នែកទីពីរ ពិនិត្យអំពីផលប៉ះពាល់នៃសម្បទានគោលដៅសេដ្ឋកិច្ចដល់សិទ្ធិមនុស្ស និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន និង ពិពណ៌នាអំពីផលប៉ះពាល់នៃសម្បទានមួយ ដែលបានជួលទៅឱ្យក្រុមហ៊ុនផលិតម្សៅដំឡូងមី (Flour Manufacturing Company)នៅក្នុងខេត្តស្ទឹងត្រែង ។ របាយការណ៍បានធ្វើការសន្និដ្ឋានថាសម្បទានគោលដៅសេដ្ឋកិច្ចមិនបានគោរពតាមការសន្យាថាបង្កើតសទិទានកម្មរបស់ខ្លួន គឺដើម្បីជំរុញលើកទឹកចិត្តដល់សហគ្រាសឯកជន ការរួមវិភាគទានក្នុងការបង្កើនប្រាក់ចំណូលរដ្ឋ កាត់បន្ថយភាពក្រីក្រនៃប្រជាពលរដ្ឋនៅជនបទ និង ផ្តល់ការងារឱ្យប្រជាពលរដ្ឋមូលដ្ឋាន ។ ឧបសម្ព័ន្ធទី ១ បង្ហាញពីករណីសិក្សាមួយ អំពីចំការកៅស៊ូទីរីង ក្នុងខេត្តកំពង់ធំ ដែលគ្រប់គ្រងដោយចំការកៅស៊ូជុប ។ ឧបសម្ព័ន្ធទី២ បង្ហាញពីប្រវត្តិសាវតានៃក្រុមហ៊ុន ស៊ីជេ កម្ពុជា (CJ Cambodia Company) នៅក្នុងខេត្តកំពង់ស្ពឺ ដែលស្ថិតនៅក្នុងតំបន់អភិវឌ្ឍន៍យោធា ។ ឧបសម្ព័ន្ធទី៣ បង្ហាញនូវបញ្ជីដ៏វែងមួយនៃសម្បទានគោលដៅសេដ្ឋកិច្ច ដែលត្រូវបានធ្វើការចងក្រងផ្អែកលើពត៌មានសំខាន់ៗ ទទួលបានពីប្រភពមួយចំនួនដូចជា : តារាងដែលបានផ្តល់ដោយក្រសួងកសិកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ការិយាល័យជំនាញតាមខេត្ត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលនានា ។ បញ្ជីនោះរួមមានសម្បទាននានាដែលបានអនុវត្តកិច្ចសន្យារួចហើយ និង សម្បទានដែលគណៈរដ្ឋមន្ត្រីបានបែងចែកពីដំបូង ប៉ុន្តែមិនទាន់អនុវត្តកិច្ចសន្យានោះនៅឡើយ និង សម្បទានគោលដៅសេដ្ឋកិច្ចដែលទើបបានស្នើសុំនាពេលថ្មីៗនេះ ។

របាយការណ៍ និង អនុសាសន៍នេះធ្វើឡើងក្នុងគោលបំណងជួយបង្កើនប្រសិទ្ធិភាពដល់ការអនុវត្តន៍សំរាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប និង ដើម្បីឱ្យគោលនយោបាយគ្រប់គ្រងដីធ្លី និង ការអនុវត្តផ្សេងៗទៀត ស្របទៅតាមច្បាប់កម្ពុជា ហើយនិងទទួលស្គាល់សិទ្ធិមនុស្សថាជាកត្តាសំខាន់ជាសារវ័ន្ត សំរាប់ការគ្រប់គ្រងធនធានធម្មជាតិឱ្យបានល្អ ។

## អនុសាសន៍

*ទិសដៅនៃគោលនយោបាយទូទៅ*

- ត្រូវធ្វើការពិចារណាឡើងវិញអំពីប្រព័ន្ធសម្បទាន និង ជំរើសផ្សេងទៀត សំរាប់ការអភិវឌ្ឍន៏វិស័យកសិកម្ម ដែលគួរអនុវត្ត ដើម្បីជាប្រយោជន៏ដល់ប្រជាពលរដ្ឋនៅជនបទនៃប្រទេសកម្ពុជា ។

- រាជរដ្ឋាភិបាល ប្រទេសអ្នកផ្តល់ជំនួយ ទីភ្នាក់ងាររបស់អង្គការសហប្រជាតិ និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា គួរធ្វើការពិចារណាលើបញ្ហាទាំងឡាយដែលកើតឡើងដោយសារសម្បទានគោលដៅសេដ្ឋកិច្ចក្នុងការអនុវត្ត និង ការពិនិត្យឡើងវិញលើយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ ។

- ប្រព័ន្ធអង្គការសហប្រជាជាតិគួរលើកយកមកពិភាក្សាអំពីបញ្ហាសម្បទានគោលដៅសេដ្ឋកិច្ច នៅក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៏របស់អង្គការសហប្រជាជាតិនាពេលខាងមុខ (UNDAF) ។

- រយៈពេលកំណត់ពាក់ព័ន្ធនឹងការអនុវត្ត ដែលបានបង្កើតឡើង នៅក្នុងសម័យប្រជុំក្រុមពិគ្រោះយោបល់នៃប្រទេសអ្នកផ្តល់ជំនួយ កាលពីខែមិថុនា ឆ្នាំ២០០២ គួរតែបានពិនិត្យ និង ប្រកាន់ខ្ជាប់ ។

*ក្របខ័ណ្ឌច្បាប់ និង បទបញ្ជា*

- អនុក្រឹត្យស្តីពីការធ្វើចំណាត់ថ្នាក់ " ដីសាធារណៈរបស់រដ្ឋ " និង " ដីឯកជនរបស់រដ្ឋ " ត្រូវតែអនុម័តឱ្យបានឆាប់រហ័ស ហើយដីនោះទៀតសោតត្រូវតែធ្វើចំណាត់ថ្នាក់ឱ្យបានត្រឹមត្រូវ ។ បញ្ហានេះសំខាន់ខ្លាំងណាស់ យោលទៅលើសម្បទានគោលដៅសេដ្ឋកិច្ចត្រូវបានផ្តល់លើដីឯកជនរបស់រដ្ឋ មិនមែនលើ " ដីសាធារណៈរបស់រដ្ឋ " ដែលមិនអាចលក់ដូរ ឬ ផ្ទេរសិទ្ធិបាននោះឡើយ ។

- រាជរដ្ឋាភិបាលគួរជំរុញការអនុម័តឱ្យបានឆាប់រហ័សនូវអនុក្រឹត្យស្តីពីនីតិវិធីផ្តល់សម្បទានគោលដៅសេដ្ឋកិច្ច ការ កាត់បន្ថយ និង ការលើកលែងជាក់លាក់នៃសម្បទានដែលមានផ្ទៃដីលើសពី ១០.០០០ ហិកតាឡើងទៅ ។ នៅក្នុងខណៈពេលរង់ចាំការអនុម័តអនុក្រឹត្យនេះ មិនគួរផ្តល់សម្បទានថ្មីទៀតឡើយ ។

- អនុក្រឹត្យគួរចែងអំពីនីតិវិធីដាក់ពាក្យសុំជាចំហរ និង ជាសាធារណៈ សំរាប់ដីដែលបានកំណត់ថាមានលក្ខណៈសមស្របសំរាប់ការអភិវឌ្ឍន៏វិស័យកសិកម្ម ប្រសើរជាងការទុកឱ្យក្រុមហ៊ុនឯកជន និង ឯកត្តបុគ្គល ជាអ្នកសំរេចលើសំណើរ ឬ ពាក្យសុំប្រើប្រាស់ដីទាំងនោះ ។

- នីតិវិធីស្តីពីការផ្តល់សម្បទានគោលដៅសេដ្ឋកិច្ច គួរដាក់បញ្ចូលឱ្យមានសវនាការសាធារណៈ ដើម្បីអនុញ្ញាតឱ្យសហគមន៍ពាក់ព័ន្ធ និង អង្គការសង្គមស៊ីវិល ឆ្លើយតបចំពោះផែនការសម្បទាន និង លើកស្នើជាជំរើសផ្សេង សំរាប់ការប្រើប្រាស់ដីសាធារណៈ ។

- យោងតាមមាត្រា៥៩ នៃច្បាប់ភូមិបាល ការលើកលែងជាក់លាក់ណាមួយ ដែលលើសពី ១០.០០០ ហិកតា ត្រូវកាត់បន្ថយ ឬកម្រិតឱ្យបានសមល្មម ។

- រាជរដ្ឋាភិបាលត្រូវអនុម័តបទបញ្ជាមួយ ដែលចែងអំពីប្រាក់ឈ្នួលប្រចាំឆ្នាំ សំរាប់ដីសម្បទានគោលដៅសេដ្ឋ-កិច្ច ដូច្នេះហើយសម្បទានមិនអាចបានទទេរដោយឥតបង់ប្រាក់ឈ្នួលឡើយ ដែលជាការផ្ទុយទៅនឹងមាត្រា ៥១ នៃច្បាប់ភូមិបាល ។

- កិច្ចដំណើរការចេញប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ត្រូវតែធ្វើឱ្យបានចប់សព្វគ្រប់ជាមុនសិន មុននឹងផ្តល់សម្បទានថ្មីណាមួយ ។ អនុក្រឹត្យស្តីពីការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវតែអនុម័តឱ្យបានឆាប់បំផុត ។

- រាជរដ្ឋាភិបាលគួរធ្វើមោឃៈភាពកិច្ចសន្យាទាំងឡាយណាដែលសម្បទានិកបានប្រព្រឹត្តរំលោភធ្ងន់ធ្ងរលើកិច្ច-សន្យា ឬ ច្បាប់ភូមិបាល ស្របតាមមាត្រា៥៥ នៃច្បាប់ភូមិបាលហើយ ត្រូវធានាថារាល់កិច្ចសន្យាដទៃទៀតក្រៅពីនេះត្រូវតែគោរពច្បាប់ជាដាច់ខាត ។

- គួរពង្រឹងការអនុវត្តមាត្រា៦២ នៃច្បាប់ភូមិបាល ។ មាត្រានេះចែងពីការធ្វើមោឃៈភាពរាល់សម្បទានដីដែលខកខានធ្វើអាជីវកម្មរយៈពេល១២ (ដប់ពីរ) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន (ទោះជាសម្បទានដីនោះត្រូវបានផ្តល់នៅមុន ឬក្រោយការអនុម័តច្បាប់ភូមិបាលក៏ដោយ) ហើយថា ក្នុងករណីនៃការដកហូតសម្បទាន "សម្បទានិកគ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើយ " ។

- ប្រទេសអ្នកផ្តល់ជំនួយគួរជំរុញលើកទឹកចិត្ត និង គាំទ្រដល់រដ្ឋាភិបាលក្នុងការត្រួតពិនិត្យកិច្ចសន្យាសម្បទាន និង ការអនុវត្តរបស់ខ្លួន ដើម្បីបញ្ជាក់ថាកិច្ចសន្យាទាំងនោះពិតជាគោរពច្បាប់ភូមិបាល អនុក្រឹត្យពាក់ព័ន្ធ និង លក្ខខណ្ឌនៃកិច្ចសន្យាប្រាកដមែន ។

- លទ្ធផលនៃការត្រួតពិនិត្យនេះគួរពិភាក្សាផ្លាស់ប្តូរពត៌មានអំពីសំណងការខូចខាត ក្នុងបរិបទនៃការកំណត់ជាថ្មី នូវតំបន់មួយចំនួនដែលបច្ចុប្បន្នជាសម្បទានគោលដៅសេដ្ឋកិច្ច ឱ្យទៅជាសម្បទានគោលដៅសង្គមកិច្ចវិញ ។ មិនត្រូវផ្តល់សំណងការខូចខាតដល់សម្បទានិកទាំងឡាយណាបានប្រព្រឹត្តរំលោភលើលក្ខខណ្ឌ នៃកិច្ចសន្យារបស់ខ្លួន និង ច្បាប់ឡើយ ។

- នៅថ្នាក់ជាតិ រដ្ឋាភិបាលគួរធានាថា ឯកសារគ្រប់សព្វទាក់ទងនឹងសម្បទានទាំងអស់ ដែលបានអនុម័តរួច រួមទាំងកិច្ចសន្យាសម្បទាន និង ផែនទីផង ត្រូវរក្សាឱ្យមានសំរាប់សាធារណៈជន។ គួរកំណត់ព្រំប្រទល់ដីសម្បទានទាំងអស់ឱ្យបានច្បាស់លាស់ ទាំងនៅលើផែនទី ទាំងនៅលើដីជាក់ស្តែង មុនពេលចាប់ផ្តើមធ្វើការកាប់ឆ្ការ ឬ ធ្វើអាជីវកម្ម។

- ពត៌មានស្តីពីម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនសម្បទាននានា គួរតែរក្សាឱ្យមានតាមរយៈបញ្ជី ដែលសាធារណៈជនអាចចូលមើលបាន ហើយបញ្ជីនោះទៀតសោតត្រូវធ្វើបច្ចុប្បន្នភាពឱ្យបានយ៉ាងទៀងទាត់ ក្នុងនោះរួមមានសេចក្តីបរិយាយលំអិតអំពីក្រុមហ៊ុនអាណាព្យាបាលនានាផងដែរ។

- រាជរដ្ឋាភិបាលគួរហាមឃាត់ការផ្តល់សម្បទានគោលដៅសេដ្ឋកិច្ច និង ធ្វើមោឃៈភាពសម្បទាន ទាំងឡាយណាដែលស្ថិតនៅក្នុងតំបន់ព្រៃសំខាន់។ រាល់សម្បទានដី ទោះជាគោលដៅសេដ្ឋកិច្ច ឬ គោលដៅសង្គមកិច្ចក្តី គួរផ្តល់តែលើដីណាដែលគ្មានព្រៃឈើប៉ុណ្ណោះ។

*ការគ្រប់គ្រង និង ការអនុវត្តគោលនយោបាយដីធ្លី*

- រាជរដ្ឋាភិបាលត្រូវប្រកាសយ៉ាងទៀតទាត់អំពីប្រាក់ចំណូលដែលបានមកពីសម្បទាន រួមទាំងទិន្នន័យលំអិតផង។

- រាជរដ្ឋាភិបាលគួរពង្រឹងការអនុវត្តន៏បទបញ្ជានានា ដើម្បីបញ្ជាក់ថាសម្បទានិកទាំងអស់ពិតជាគោរពលក្ខខណ្ឌនៃកិច្ចសន្យាប្រាកដមែន។

- សម្បទានិកគួរធ្វើផែនការគ្រប់គ្រងប្រកបដោយចិរភាព និង គោរពតាមនីតិវិធីវាយតំលៃពីផលប៉ះពាល់បរិស្ថានជាចាំបាច់។ ការវាយតំលៃពីផលប៉ះពាល់សង្គមត្រូវតែធ្វើដោយខានមិនបាន ហើយត្រូវបំពាក់គ្រឿងឧបករណ៏ ដល់ស្ថាប័នជំនាញអន្តរវិន័យ ដើម្បីពិនិត្យថាតើរបាយការណ៏វាយតំលៃពីផលប៉ះពាល់សង្គមទាំងនោះត្រឹមត្រូវ ឬទេ និង ដើម្បីបញ្ជាក់ថាក្រុមហ៊ុនទាំងអស់ពិតជាអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានខាងសង្គមប្រាកដមែន។

- គួរពិចារណាបង្កើតឱ្យមានការវាយតំលៃពីផលប៉ះពាល់សេដ្ឋកិច្ច ការវិភាគអំពីតំលៃជាអត្ថប្រយោជន៏មុនពេលអនុម័តសម្បទានអ្វីមួយ។

- រាជរដ្ឋាភិបាលគួរបញ្ឈប់សម្បទានិកពីការកាប់ដើមច្បោះដោយខុសច្បាប់ ហើយទទួលស្គាល់ពីសារៈសំខាន់នៃអនុផលព្រៃឈើ សំរាប់ជីវភាពរស់នៅ និង សន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋនៅជនបទ។

- ដរាបណាប្រព័ន្ធសម្បទាននៅតែបន្ត រដ្ឋាភិបាលគួរតែប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការផ្លាស់ប្តូរទីលំនៅក្នុងស្រុក ក្នុងការផ្តល់ និង គ្រប់គ្រងដីសម្បទាន ។ ជាពិសេស រាជរដ្ឋាភិបាលត្រូវធានាឱ្យមានការជូនដំណឹង និង ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន មុននឹងសំរេចផ្តល់សម្បទានទាំងនេះ ហើយត្រូវគោរពតាមនីតិវិធីត្រឹមត្រូវ និងការការពារផ្នែកនីតិវិធី ។

*អនុសាសន៍ពាក់ព័ន្ធ*

- សេរីភាពនៃច្បាប់ស្តីពីពតិមាន គួរតែបានអនុម័ត និង អនុវត្ត ដើម្បីជួយសំរួលដល់សិទ្ធិអាចចូលមើលបញ្ជីឯកសាររបស់រដ្ឋ និង ដើម្បីបង្កើតឱ្យមានតម្លាភាព និង ការទទួលខុសត្រូវផ្នែករដ្ឋបាលដីធ្លី ជំរុញឱ្យមានការពិភាក្សាផ្លាស់ប្តូរពតិមានជាសាធារណៈ និង ការកាត់បន្ថយអំពើពុករលួយ ។

- ប្រទេសកម្ពុជាគួរចូលជាសមាជិកនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ និងរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ឱ្យស្របទៅនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ ។ យ៉ាងហោចណាស់ ក៏ត្រូវមានបញ្ញត្តិច្បាប់មួយដែលតម្រូវឱ្យអ្នកនយោបាយ និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ប្រកាសទ្រព្យសម្បត្តិទាំងអស់ជាហិរញ្ញវត្ថុ ឬ ជាទ្រព្យសម្បត្តិរបស់គ្រួសារ និង ចំណែកភាគហ៊ុនផ្សេងៗ ដោយត្រូវកំណត់ទោសបញ្ញត្តិឱ្យបានធ្ងន់ធ្ងរចំពោះការមិនព្រមប្រកាសទ្រព្យសម្បត្តិ ។

- ប្រទេសអ្នកផ្តល់ជំនួយគួរបន្តផ្តល់មូលនិធិសំរាប់កម្មវិធីទាំងឡាយ ដែលជួយដល់សហគមន៍មូលដ្ឋាន ដើម្បីយល់ដឹង ពីសិទ្ធិស្របច្បាប់របស់ខ្លួន ហើយជួយពួកគេ និង អ្នកគាំទ្ររបស់ពួកគេឱ្យមានមធ្យោបាយ និងចំណេះដឹង គ្រប់គ្រាន់សំរាប់ពង្រឹងការអនុវត្តច្បាប់ ។

- គួរធ្វើការដកហូតអាវុធពីកម្លាំងសន្តិសុខក្រុមហ៊ុន និង កងសេនាជនទាំងអស់ ដែលបំរើការនៅលើដីសម្បទានគោលដៅសេដ្ឋកិច្ច និង ចំការកៅស៊ូ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រង និង ការត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និង ការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ ។ បទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តដោយកម្លាំងសន្តិសុខ ត្រូវតែធ្វើការស៊ើបអង្កេត និង ចោទប្រកាន់តាមផ្លូវច្បាប់ ។

- រាជរដ្ឋាភិបាលត្រូវតែចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីធានាថាក្រុម និង អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការពាក់ព័ន្ធនិងបញ្ហាដីធ្លីអាចបំពេញភារកិច្ចរបស់ខ្លួន ក្នុងបរិយាកាសដ៏គត់ហ្មត់មួយចាកផុតពីការបំភិតបំភ័យ និង អំពើហឹង្សា ស្របតាមសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិ និង ការទទួលខុសត្រូវរបស់បុគ្គល ក្រុម និង អង្គការសង្គមក្នុងការលើកស្ទួយ និង ការពារសិទ្ធិមនុស្ស និង សេរីភាពមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ។

# ផ្នែកទី ១ : ប្រវត្តិ ច្បាប់ និង ការអនុវត្តន៍បច្ចុប្បន្ន

## ១- ការអភិវឌ្ឍន៍ប្រព័ន្ធសម្បទាន

នៅមុនសម័យអាណានិគម ដីធ្លីត្រូវបានកាន់កាប់តាមរយៈ "ការភ្ជួររាស់" ហើយជានិមិត្តរូប គឺដីធ្លីទាំងនោះជាកម្មសិទ្ធរបស់ស្ដេច ។[១១] ការកាន់កាប់ និង គ្រប់គ្រងដីធ្លីមានប្រវត្តិជាដំណរហូរហែរមក ហើយដីធ្លីគឺមានជាស្រេចសំរាប់អ្នកដែលនឹងទទួលបន្ត ។ ដោយសារប្រជាពលរដ្ឋមានចំនួនតិច ហើយស្ទើរតែមិនមានទីផ្សារដីធ្លីនោះ ទើបមានគ្រួសារប្រជាពលរដ្ឋជាច្រើន អាចផ្លាស់ប្ដូរទីលំនៅរបស់ខ្លួនយ៉ាងងាយពីតំបន់មួយទៅតំបន់មួយទៀត ដើម្បីធ្វើការកាប់ឆ្ការ និង ធ្វើកសិកម្មលើដីដែលពួកគេត្រូវការ ។[១២] មិនមានការកំណត់ព្រំដីជាក់លាក់នោះទេ ។ តម្លៃដីធ្លី គឺអាស្រ័យទៅលើការប្រើប្រាស់ដីធ្លីនោះ មិនមែនដោយសារដីខ្លួនវានោះទេ ហើយគេសង្កេតឃើញថាការធ្វើកសិកម្មមានរូបភាពជាកម្មសិទ្ធិ ។ ពន្ធដារត្រូវបានកំណត់តែនៅពេលប្រមូលផលប៉ុណ្ណោះ ។

បារាំងបានដាក់អាណាព្យាបាលរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា នៅឆ្នាំ១៨៦៣ ហើយបានបង្កើតនូវទស្សនទានស្ដីពីកម្មសិទ្ធិដីឯកជន ។[១៣] នៅសម័យនោះ ប្រទេសកម្ពុជាត្រូវបានគេពិពណ៌នាថាជាប្រទេសមួយដែលមានផ្ទៃដីភាគច្រើនគ្របដណ្ដប់ទៅដោយព្រៃឈើ ហើយមានប្រជាពលរដ្ឋតិច រស់នៅមិនស្មើសាច់គ្នានៅលើទឹកដីនៃប្រទេសនេះ ហើយប្រជាពលរដ្ឋទាំងនេះរស់នៅផ្ដុំគ្នានៅលើតំបន់វាលទំនាបជុំវិញបឹងទន្លេសាប ។[១៤] នៅក្រោមការគ្រប់គ្រងនៃរបបអាណានិគម សិទ្ធិកម្មសិទ្ធិលើដីធ្លីអាចទទួលបានតាមរយៈការប្រកាសថា ដីគឺជាដីធ្វើកសិកម្ម ឬ តាមរយៈប្រព័ន្ធសម្បទាន គោលនយោបាយ និង ការអនុវត្តន៍ដែលកើតមាននៅចុងសតវត្សទី១៩ ។[១៥] ការដែលកសិក

---

[១១] Meijers, Hanneke *ការកាន់កាប់ដី* ឯកសាររៀបចំសំរាប់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីចេនឌ័ និង ការអភិវឌ្ឍន៍ អេអាយធី (AIT) ទីក្រុងបាងកក ខែឧសភា ឆ្នាំ១៩៩៦ ទំព័រទី៣

[១២] នៅតាមដងទន្លេមេគង្គ និង កោះមួយចំនួនដែលមានប្រជាពលរដ្ឋរស់នៅច្រើន មានជាការលើកលែងចំពោះគំរូបែបនេះ ហើយត្រូវបានព្រះមហាក្សត្រជួលឱ្យគ្រួសារអ្នក ភាគច្រើនជាប្រជាពលរដ្ឋដែលមានដើមកំណើតចិន ។ Delvert, Jean ដែលមានចំណងជើងថា *ប្រទេសកម្ពុជា (Le Cambodge),* (ទីក្រុងប៉ារីស, PUF ឆ្នាំ១៩៨៣ ) ។

[១៣] អនុសញ្ញា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ដែលបានបង្កើតអាជ្ញាធរបារាំងមកលើប្រទេសកម្ពុជា ។ មាត្រា IX នៃអនុសញ្ញានេះបានចែងថា " ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ គឺជាកម្មសិទ្ធិផ្ដាច់មុនរបស់ព្រះមហាក្សត្រ ដែលមិនអាចលក់ដូរ ឬផ្ទេរសិទ្ធិបានឡើយ ។ ទឹកដីនេះនឹងត្រូវបានចាត់ចែងគ្រប់គ្រងដោយអាជ្ញាធរបារាំង និង អាជ្ញាធរកម្ពុជា ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញថាជាទ្រព្យសម្បត្តិរបស់ប្រទេសកម្ពុជា" ។

[១៤] តំបន់ឧត្តរ ឮសាន និង នីរតី គ្របដណ្ដប់ទៅដោយព្រៃឈើយ៉ាងក្រាស ។ មានភូមិតូចៗ ខ្លះតាំងនៅត្រង់នេះមួយដុំ ត្រង់នោះមួយដុំ រាយប៉ាយពាសពេញក្នុងតំបន់ព្រៃទាំងនេះ ហើយមានប្រជាពលរដ្ឋតិចតួច (Jean Delvert, ដែលមានចំណងជើងថា *ប្រទេសកម្ពុជា (Le Cambodge)* (១៩៨៣) ១៣0 និង Mouton (១៨៦១) Delatorre (១៨៧៣) Bouillevaux (១៨៧៤) Aymonier (១៨៧៥)/Branda (១៨៨៤) ។ (បានដកស្រង់សំដីរបស់ Jean Delvert នៅក្នុងសៀវភៅដែលមានចំណងជើងថា " កសិករកម្ពុជា " ឆ្នាំ ១៩៩៤ ទំព័រ៤២៦

[១៥] មាត្រា១ នៃក្រឹត្យ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៨៩៩ បានចែងថាសម្បទានបណ្ដោះអាសន្នលើដីសាធារណៈដែលទំនេរ អាចផ្ដល់ដោយឥតគិតថ្លៃទៅឱ្យជនជាតិបារាំងប្រើប្រាស់សំរាប់ធ្វើកសិកម្ម ឬ ចិញ្ចឹមសត្វ ។ Delvert, op cit, ទំព័រទី៥0 ។ ប្រព័ន្ធសំរាប់ផ្ដល់ដីឡូត៍តូចៗ មានលក្ខណៈស្រដៀងគ្នានិងប្រព័ន្ធសម្បទានគោលដៅសង្គមដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ ។

វកម្ពុជាប្រកែកមិនព្រមធ្វើប័ណ្ណកម្មសិទ្ធិ និង ចុះបញ្ជីដីធ្លី ជាទូទៅគឺដើម្បីជៀសវាងការបង់ពន្ធដារ ច្រើន ក៏ដូចជាសំរាប់មូលហេតុវប្បធម៌ដែរ បានន័យថាការព្យាយាមចុះបញ្ជីដី និង បង្កើតនូវសិទ្ធិកម្មសិទ្ធិនៅក្នុង ឆ្នាំ១៨៨៤ ហើយបន្ទាប់មក នៅក្នុងឆ្នាំ១៩០២ និង ឆ្នាំ១៩០៨ គឺមិនបានទទួលជោគជ័យទេ។ មានតែប្រជាពលរដ្ឋ ដែលរស់នៅទីក្រុង និង តំបន់ផ្សេងទៀត ដែលមានប្រជាពលរដ្ឋរស់នៅច្រើន ទើបមានការចាប់ផ្តើមចុះបញ្ជីដី។[១៦] ប្រជាពលរដ្ឋរស់នៅជនបទ បានបន្តធ្វើកសិកម្ម និង កាន់កាប់ដីតាមរយៈ "ការភ្ជួររាស់ "។

គោលបំណងនៃប្រព័ន្ធសម្បទាន គឺដើម្បីកំណត់អំពីសិទ្ធិលើដីធ្លី និង ធ្វើនិយ័តកម្មនូវគំរូជាតំណាងនៃការ ប្រើប្រាស់ដី។ សម្បទានត្រូវបានផ្តល់ជាបណ្តោះអាសន្នតាមការស្នើសុំ ដោយត្រូវបង្ហាញភស្តុតាងថាបានប្រើ ប្រាស់ដីនោះជាប់លាប់រយៈពេលប្រាំ (៥) ឆ្នាំ អាចមានសិទ្ធិសុំកម្មសិទ្ធិបាន ដែលត្រង់ចំណុចនេះ ច្បាប់តម្រូវឱ្យ បង់ពន្ធដីធ្លី។ សម្បទានបណ្តោះអាសន្នអាចត្រូវបានមោឃៈភាព ប្រសិនមិនបានប្រើប្រាស់ដីនោះទេ។ បន្ទាប់ពី គោលការណ៍នេះបានក្លាយទៅជាច្បាប់នៅក្នុងទសវត្សឆ្នាំ១៩២០ ជំរុញឱ្យមានការប្រកួតប្រជែងពីអ្នកជំនួញ ចិន[១៧] មានតែជនជាតិបារាំង ឬ ជនទាំងឡាយដែលរស់នៅក្រោមអាណាព្យាបាលបារាំងនៅឥណ្ឌូចិនទេដែលគេ អនុញ្ញាតឱ្យកាន់កាប់ដីធ្លីតាមរយៈប្រព័ន្ធសម្បទាន។[១៨] សម្បទានត្រូវបានផ្តល់លើដីដែលមានទំហំតូច និង សំរាប់ ធ្វើជាចំការដំណាំ។ អ្នកតាំងលំនៅថ្មីជនជាតិបារាំងបានបង្កើតឱ្យមានចំការដំណាំតូចៗ នៅតំបន់ភាគច្រើន ហើយ បានធ្វើការកាប់ឆ្ការ និង ធ្វើកសិកម្ម ជាពិសេសនៅក្នុងតំបន់ដែលមានព្រៃឈើ។[១៩] នៅឆ្នាំ១៩៣០ សម្បទានភាគ ច្រើនមានទំហំតិចជាងប្រាំ (៥) ហិកតា។[២០]

សម្បទានដែលមានទំហំលើសពី៥០០ ហិតា អាចត្រូវបានផ្តល់តែចំពោះបុគ្គល ឬ អង្គភាពទាំងឡាយណា ដែលអាចបង្ហាញថាខ្លួនមានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់សំរាប់គ្រប់គ្រងដីធ្លីដ៏ធំនោះបាន។[២១] បារាំងបាន

---

[១៦] សូមអានសៀវភៅរបស់លោក R Kleinpeter ដែលមានចំណងជើងថា "*បញ្ហាសំខាន់ៗនៃប្រទេសកម្ពុជា* " (ed Domat-Monchrestien ) ឆ្នាំ១៩៣៧ ។

[១៧] ជនជាតិចិនសកម្មក្នុងកិច្ចការជំនួញនៅក្នុងសតវត្សទី១៩។ ពួកគេបានគ្រប់គ្រងទីផ្សារ និង បានផ្តល់ប្រាក់កម្ចី។ ពួកគេបានដាំដំណាំកប្បាស និង ការដាំដំណាំគ្រប់ប្រភេទដូចជា ដំណាំឆ្លះ ស្លា ពោត សណ្តែក ថ្នាំជក់ និង ម្លូ ព្រមទាំងបានប្រើប្រាស់ដីសម្បទានទៀតផង។ ពួកគេបានគេចវេសពីការ ហាមប្រាមថ្មីៗ នៃច្បាប់ ដោយប្រើប្រាស់ពលរដ្ឋកម្ពុជា ធ្វើជាប្រធានក្រុមហ៊ុននានារបស់ខ្លួន។ Delvert Jean, ដែលមានចំណងជើងថា *ប្រទេសកម្ពុជា "Le Cambodge"* ។

[១៨] ព្រះរាជក្រិត្យលេខ៩៧ និង ៩៨ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩១៦ និងព្រះរាជក្រឹត្យ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩២៩ ដែលបានកំណត់អំពីរបបសម្បទានដីជនបទ។ ការទទួលបានដីតាមរយៈការដេញថ្លៃ ឬ សម្បទានដែលបានផ្តល់ឱ្យដោយឥតគិតថ្លៃ ក្នុងករណីនៃសម្បទានដែលមានទំហំតូច តាមរយៈ : (១) សម្បទានបណ្តោះអាសន្ន (២) សម្បទានស្ថាពរនៃដីផ្នែកណាមួយជាក់លាក់សំរាប់ពីធ្វើអាជីវកម្ម បន្ទាប់ពីរយៈពេលមួយមានកំណត់។ សូមមេត្តាអានសៀវភៅរបស់ Kleinpeter R ដែលមានចំណងជើងថា "*បញ្ហាសំខាន់ៗនៃប្រទេសកម្ពុជា* " (ed Domat-Monchrestien ) ឆ្នាំ១៩៣៧ ។

[១៩] ដោយការកាប់ឆ្ការដី និងការធ្វើឱ្យទៅជាកម្មសិទ្ធិផ្លូវការ នៅក្នុងយុទ្ធនាការជាតិស្តីពីការចុះបញ្ជី និង ចេញបណ្ណ័កម្មសិទ្ធិដីធ្លី តាមរយៈការសុំអនុញ្ញាតកាប់ឆ្ការដីធ្លី ឬ តាមរយៈការបែងចែកដីធ្លី។

[២០] H.S Greve *ការកាន់កាប់ដីធ្លី និង សិទ្ធិលើដីធ្លីនៅក្នុងប្រទេសកម្ពុជា* (ភ្នំពេញ) ឆ្នាំ១៩៩៣

[២១] មាត្រា៤ ចែងថា បញ្ឈប់ការចេញបទបញ្ជាទាំងឡាយទៅលើទម្រង់ និង លក្ខខណ្ឌ ក្នុងការចុះបញ្ជីដីសម្បទានបារាំង នៅក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៨៩៩។(ដកស្រង់ចេញពីរាជកិច្ច បារាំងឥណ្ឌូចិន ១៨៩៩ ទំព័រ១០៥៣) ។

ជំរុញលើកទឹកចិត្តដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម  មានពួកអ្នកមាន និង ធនាគារជាច្រើននៅអឺរ៉ុបបានសំដែងការចាប់អារម្មណ៍ខ្លាំងចំពោះដីដែល "មានទំហំធំ " ហើយដែល "នៅទំនេរ" ដើម្បី "បង្កើនហើយបង្កើនទៀតនូវភោគទ្រព្យ និង ភាពសំបូររុងរឿងនៃប្រទេស"។[២២] ទស្សនទានអំពីចំការកៅស៊ូឧស្សាហកម្មត្រូវបានបង្កើតឡើងនៅក្នុងទសវត្សឆ្នាំ១៩២០ ដែលសម្បទានជាច្រើនត្រូវបានផ្តល់ឱ្យក្រុមហ៊ុនធំៗ។[២៣] " ដីមិនទាន់ប្រើ " ត្រូវបានផ្តល់សម្បទានសំរាប់ធ្វើចំការកៅស៊ូ ហើយព្រៃដែលមានទំហំធំៗជាច្រើន នៅក្នុងតំបន់ខ្ពង់រាបត្រូវបានកាប់ឆ្ការដោយបានជម្លៀសប្រជាពលរដ្ឋមូលដ្ឋានទៅកាន់កន្លែងផ្សេងទៀត។[២៤] ចំការកៅស៊ូនៃ ប្រទេសកម្ពុជាមានកេរ្តិ៍ឈ្មោះថាបានផលិតកៅស៊ូដែលមានគុណភាពខ្ពស់ និងបង្កើនប្រាក់ចំណូលច្រើន។

នៅក្នុងឆ្នាំ១៩៥៦ គឺជារយៈពេលបី (៣) ឆ្នាំបន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យ យើងឃើញមានការហាមឃាត់កម្មសិទ្ធិដីធ្លីតាមរយៈប្រព័ន្ធសម្បទានដែលបានផ្តល់ឱ្យជនបរទេស។ ទោះជាដូច្នេះក្តី ក្រុមហ៊ុនបារាំងជាច្រើនបានបន្តធ្វើចំការកៅស៊ូលើដីរដ្ឋ។[២៥] ផលប៉ះពាល់នៃសម្បទានទ្រង់ទ្រាយធំដល់បរិស្ថាន និង ប្រជាពលរដ្ឋមូលដ្ឋានត្រូវបានគេចាប់ផ្តើមកត់ត្រាថា : មានការពិគ្រោះយោបល់តិចតួចជាមួយប្រជាពលរដ្ឋមូលដ្ឋាន ជារឿយៗមានការជម្លៀសប្រជាពលរដ្ឋក្នុងសហគមន៏ ជីវភាពរស់នៅ និង លក្ខខណ្ឌការងារមិនល្អ និង មិនមានការគិតគូរដល់បរិស្ថាន។[២៦] នៅក្នុងទសវត្សឆ្នាំ១៩៦០ គេឃើញមានការជម្លៀសជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ភាគឦសាននៃប្រទេសកម្ពុជា ដើម្បីទៅធ្វើការនៅចំការកៅស៊ូ។[២៧]

## ចាប់ពីសង្គ្រាមស៊ីវិល រហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១

នៅក្នុងទសវត្សឆ្នាំ១៩៦០ ចំនួន ៧៣ ភាគរយ (73%) នៃទឹកដីប្រទេសកម្ពុជា ត្រូវបានគេពិពណ៌នាថាបានគ្រប់ដណ្តប់ទៅដោយព្រៃឈើ។[២៨] ជាទូទៅមានដីធ្លីនៅទំនេរច្រើន រីឯការប្រើប្រាស់ដីធ្លីទៀតសោធក៏មិនចោទជា

---

[២២] សូមមេត្តាអានសារាចររបស់ *Residence Supérieure* បានដកស្រង់សំដីក្នុងសៀវភៅរបស់លោក ថុង សៀគ (Thion Serge) ដែលមានចំណងជើងថា សំឡឹងមើលប្រទេសកម្ពុជា "*Watching Cambodia*" (ទីក្រុងបាងកក ឈូកស ឆ្នាំ១៩៩៣ ទំព័រទី២៩ )

[២៣] សៀវភៅរបស់ Jean Delvert ដែលមានចំណងជើងថា " ប្រទេសកម្ពុជា " *(Le Cambodge)*, op. cit, ទំព័រទី ៥៨៩ ។

[២៤] សូមមេត្តាអានសៀវភៅរបស់ Mathieu Gurérin ដែលមានចំណងជើងថា *"អ្នកភ្នំ ឬ ជនជាតិភាគតិច"( Des montagnards aux minorities ethniques)* L'harmattan, អ៊ីរ៉ាសិច " IRASEC" ឆ្នាំ ២០០៣ )

[២៥] ជាអាទិ គឺចំការកៅស៊ូដែលបានបង្កើតឡើងនៅក្នុងខេត្តកំពង់ចាម ដោយក្រុមហ៊ុននៃកម្ពុជា *(Compagnie du Cambodge)* ក្នុងនោះ ក្រុមហ៊ុនមួយដែលធំជាងគេបំផុត គឺក្រុមហ៊ុនចំការកៅស៊ូជុប។

[២៦] M Gurérin , *op.* cit fn ២២ , ទំព័រទី៣៣ ដោយលោកស្រី Sara Colm, " ប៉ុល ពត : ផែនការសំងាត់លេខ៦០ ការធ្វើ " សង្គ្រាមប្រជាជន" ក្នុងចំណោមសហគមន៏កុលសម្ព័ន្ធ" *កាសែតភ្នំពេញប៉ុស្តិ៍* ចុះថ្ងៃទី២៤ ខែមេសា - ៧ ខែឧសភា ឆ្នាំ១៩៩៨។

[២៧] ដោយលោកស្រី Sara Colm, " ផលប៉ះពាល់នៃការអភិវឌ្ឍន៏ចំការដូងប្រេងដល់សហគមន៏ជនជាតិដើមភាគតិច ក្នុងខេត្តរតនគិរី ក្នុងប្រទេសកម្ពុជា ខែឧសភា ឆ្នាំ ១៩៩៦ ", *op.* cit fn ២៥ ។

[២៨] ព្រៃឈើនៃសាធារណៈរដ្ឋខ្មែរ សេវាកម្មទឹក ព្រៃឈើ និង រុក្ខាប្រម៉ាញ់ ឆ្នាំ១៩៧២

បញ្ហាអ្វីដែរ ។ ផលិតកម្មធុនតូចមានជាទូទៅ ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ នៅក្នុងសម័យលន់ ណល់ ចាប់ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ១៩៧៥ មានអ្នកមានជនជាតិខ្មែរ ខ្លះបានបង្កើតចំការតូចៗ សំរាប់ដាំដើមឈើស៊ីផ្លែ ។[២៩] នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនៃជំលោះ និង សង្គ្រាមស៊ីវិល គឺចាប់ពីឆ្នាំ១៩៧២ មក ទឹកដីដ៏ធំនៃប្រទេសកម្ពុជាបានស្ថិតក្រោមការត្រួតត្រារបស់ខ្មែរក្រហមបន្តិចម្តងៗ ហើយប្រព័ន្ធគ្រប់គ្រងដីធ្លីត្រូវបានផ្លាស់ប្តូរទាំងស្រុងនៅក្នុងតំបន់ទាំងនោះ ។ នៅដើមឆ្នាំ១៩៧៥ ខ្មែរក្រហមបានត្រួតត្រាទឹកដីមួយភាគធំនៃប្រទេសកម្ពុជា លើកលែងតែទីរួមខេត្ត និង តំបន់ជិតខាងទីនោះ ។

នៅពេលដែលខ្មែរក្រហមកាន់កាប់អំណាចទាំងស្រុងនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ពួកគេបានដាក់ដីធ្លីទាំងអស់ជាកម្មសិទ្ធិសមូហភាព ដកហូតទ្រព្យសម្បត្តិ បំផ្លិចបំផ្លាញឯកសារដីធ្លី និង បំបាត់ចោលសិទ្ធិដីធ្លីដែលជាប្រពៃណីរបស់ប្រជាពលរដ្ឋទូទៅ ។

ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៨៩ ច្បាប់មិនបានចែងពីដីកម្មសិទ្ធិឯកជនទេ ។ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំនៃការកសាងជាតិឡើងវិញ បន្ទាប់ពីមានការឈ្លានពានពីប្រទេសវៀតណាមនៅដើមឆ្នាំ១៩៧៩ ឃើញថាដីធ្លីទាំងអស់ត្រូវបានប្រកាសថាជាដីរដ្ឋ ។ ការប្រើប្រាស់ដីរដ្ឋជាលក្ខណៈឯកជនត្រូវបានអនុញ្ញាត តាមរយៈការបែងចែកជាដីឡូត៍ទៅឱ្យគ្រួសារនីមួយៗ ។ ចំការកៅស៊ូស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរដ្ឋ តាមរយៈអគ្គនាយកដ្ឋានចំការកៅស៊ូ ។ ការកាប់ឈើទ្រង់ទ្រាយធំកើតមាននៅក្នុងចន្លោះឆ្នាំ១៩៧៩ និង ឆ្នាំ១៩៨៩ ដើម្បីផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ការបន្តធ្វើសង្គ្រាម និង ដើម្បីការពារទឹកដី បានបង្កើតជាឧបករណ៍មួយដ៏សំខាន់ ។[៣០]

បន្ទាប់ពីការធ្វើមាតុភូមិនិវត្តន៍របស់កងទ័ពវៀតណាម នៅក្នុងឆ្នាំ១៩៨៩ រដ្ឋកម្ពុជាបានធ្វើមោឃៈភាពនូវសិទ្ធិកម្មសិទ្ធិទាំងអស់ដែលមាននៅមុនឆ្នាំ១៩៧៥ ប៉ុន្តែបានបង្កើតឱ្យមានជាថ្មីនូវទស្សនៈទានស្តីពីសិទ្ធិឯកជនរួមទាំងសិទ្ធិលើសម្បទានដីផងដែរ ។[៣១] វិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ បានគត់សំគាល់ពីការចាប់ផ្តើមនៃប្រព័ន្ធដីធ្លីឯកជន ដែលមាត្រា១៥ ចែងថា "ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិពេញលេញក្នុងការធ្វើជាម្ចាស់ ប្រើប្រាស់

---

[២៩] R. Blanadet *"ប៉ៃលិនជាតំបន់សំបូរទៅដោយត្បូងមានតម្លៃ* (និក្ខេបទរបស់និស្សិតជំនាន់ទី៣ ទីក្រុងប៉ារីស IV ឆ្នាំ១៩៧១), បានដកស្រង់សំដីរបស់ Delvert ឆ្នាំ១៩៨៣ ទំព័រទី៧៥ ។

[៣០] រឹងផែនការការពារព្រំដែន ក៥ ដែលមានប្រជាពលរដ្ឋកម្ពុជារាប់ពាន់នាក់ត្រូវបានបញ្ជូនទៅកាន់ព្រំដែនថៃ ដើម្បីកាប់ព្រៃ និង ធ្វើជាចំការមីុន ដែលគេហៅថា "ដីដែលគ្មានម្ចាស់" ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម ។ សូមមេត្តាអានសៀវភៅរបស់ Esmeralda Luciolli ដែលមានចំណងជើងថា: ជញ្ជាំងឫស្សី : ប្រទេសកម្ពុជាក្រោយរបបប៉ុល ពត *(Le Mur de bamboo :leCambodge après Pol Pot)* (បោះពុម្ពផ្សាយដោយ Régine Desforges, អង្គការគ្រូពេទ្យគ្មានព្រំដែន ឆ្នាំ១៩៨៨) ។

[៣១] ការធ្វើដូច្នេះ ដោយបទបញ្ជារបស់អង្គនីតិប្រតិបត្តិ ។ សេចក្តីណែនាំលេខ៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃរដ្ឋកម្ពុជា សេចក្តីណែនាំអនុវត្តគោលការណ៍ស្តីពីកម្មសិទ្ធិ និងការប្រើប្រាស់ដី ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៨៩ អនុក្រឹត្យលេខ២៥ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើផ្ទះសម្បែងជូនប្រជាពលរដ្ឋនៃរដ្ឋកម្ពុជា ។ នីត្យានុកូលភាពនៃអនុក្រឹត្យនេះបានចោទជាបញ្ហា យោលដោយអនុក្រឹត្យនេះចេញមួយសប្តាហ៍មុនការអនុម័តនៃវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលចែងផ្តល់សិទ្ធិលើដីធ្លីឯកជនឡើងវិញជាលើកដំបូង ។

ដីធ្លីដែលរដ្ឋបានផ្តល់ឱ្យសំរាប់ជីវភាពរស់នៅ និង ធ្វើអាជីវកម្ម" ។ ទោះជាដូច្នេះក្តី ដីធ្លីមិនមែនសំរាប់លំនៅដ្ឋាន មិនអនុញ្ញាតឱ្យមានកម្មសិទ្ធិឡើយ ។ ទោះជាច្បាប់ភូមិបាលឆ្នាំ១៩៩២ បានអនុញ្ញាតឱ្យមានសិទ្ធិលើដីឯកជនក្តី ក៏មានប្រជាពលរដ្ឋភាគច្រើនមិនបានទទួលការបែងចែកដីធ្លី ឬ ប័ណ្ណកម្មសិទ្ធិជាផ្លូវការនៅឡើយទេ ។

ទោះជាមានការព្យាយាមយ៉ាងច្រើន ដើម្បីធ្វើនិយ័តកម្មដីធ្លីនៅក្នុងចន្លោះឆ្នាំ១៨៨៤ និង ឆ្នាំ១៩៨៩ ក៏ដោយការចុះបញ្ជី និង ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី មិនទាន់អនុវត្តបានជោគជ័យនៅឡើយទេ ។ ការប្រើប្រាស់ដីធ្លីជាដំណរ បានអនុញ្ញាតឱ្យមានវិធីក្នុងការបន្តកាន់កាប់ដីជាប្រពៃណី ហើយកសិករភាគច្រើនបានទទួលសិទ្ធិលើដីធ្លីក្នុងមូលដ្ឋាន ទោះបីជាមិនមានប័ណ្ណកម្មសិទ្ធិក៏ដោយ ។

## នៅទសវត្សឆ្នាំ១៩៩០

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅឆ្នាំ១៩៩៣ បានកត់សំគាល់ពីការវិវឌ្ឍន៍ទៅរកសេដ្ឋកិច្ចទីផ្សារ ។ រដ្ឋធម្មនុញ្ញបានចែងអំពី "កម្មសិទ្ធិឯកជនស្របច្បាប់" និងអំពីដីរដ្ឋ មាត្រា៥៨ ចែងពី "ការគ្រប់គ្រង ការប្រើប្រាស់ និង ការចាត់ចែង" ដីរដ្ឋត្រូវបានការពារដោយច្បាប់ ។

នៅក្នុងទសវត្សឆ្នាំ១៩៩០ រដ្ឋាភិបាលបានប្រកាសពីរបៀបវារៈស្តីពីកំណែទម្រង់ ដើម្បីលើកស្ទួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ចប្រកបដោយចិរភាព និងបានជំរុញលើកទឹកចិត្តដល់វិនិយោគិនជាបន្តបន្ទាប់ ។ ការអភិវឌ្ឍន៍វិស័យកសិកម្ម គឺជាបញ្ហាអាទិភាព ដើម្បីធានាសន្តិសុខស្បៀង និង ពន្លឿនដល់ការរីកលូតលាស់ នៃវិស័យដទៃទៀត ជាពិសេស តាមរយៈការផ្តល់វត្ថុធាតុដើមសំរាប់ឧស្សាហកម្មកែច្នៃ បង្កើនការនាំទំនិញចេញ និង បង្កើតការងារ ។[៣៣] សនិទានកម្មសំរាប់ការផ្តល់ព្រៃឈើ និង ដីរដ្ឋដទៃទៀត ទៅឱ្យក្រុមហ៊ុនឯកជនសំរាប់ធ្វើអាជីវកម្ម គឺដើម្បីជំរុញលើកទឹកចិត្តដល់សហគ្រាសឯកជន ដើម្បីរួមវិភាគទានដល់ប្រាក់ចំណូលរដ្ឋ និង កាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ។ មានការទាក់ទាញ តាមរយៈការសន្យាថានឹងទទួលបានប្រាក់ចំណូលយ៉ាងឆាប់រហ័ស ទើបមានក្រុមហ៊ុនជាច្រើនបានមកធ្វើទំនាក់ទំនងជាមួយមន្ត្រីកម្ពុជា ទាំងនៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន ដើម្បីទទួលបានសម្បទានដី និង ព្រៃឈើ សេចក្តីត្រូវការនេះបានកើនឡើងយ៉ាងឆាប់រហ័សហួសពីការដែលរដ្ឋាភិបាលអាចផ្តល់ឱ្យបាន ។ កិច្ចដំណើរការនេះ បានធ្វើឡើងក្រៅច្បាប់នៅពេញមួយទសវត្សនេះតែម្តង ។

បទបញ្ជាពាក់ព័ន្ធតែមួយគត់ គឺសេចក្តីណែនាំរបស់គណៈរដ្ឋមន្ត្រី ចាប់ពីឆ្នាំ១៩៨៩ ដែលតាមបទបញ្ជានោះ រដ្ឋមន្ត្រីក្រសួងកសិកម្មអាចផ្តល់ដីសម្បទានដែលមានទំហំធំជាងប្រាំ (៥) ហិកតាសំរាប់បង្ករបង្កើនផល ដើម្បី

[៣៣] ដូចបានគូសបញ្ជាក់នៅក្នុងវេទិកានយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រកាសដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ នាសម័យប្រជុំលើកទី១ នៃរដ្ឋសភានីតិកាលទី២ ។

ទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ។[៣៤] ច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានគេចាត់ទុកថាជាសៀវភៅណែនាំអំពីការឈាន ទៅរកការ "មានបានឆាប់រហ័ស" មិនបានធ្វើនិយ័តកម្មដល់ការផ្តល់សម្បទានដីនេះទេ។[៣៥] ក្នុងរយៈពេលប្រាំមួយ (៦) ឆ្នាំ បន្ទាប់ពីការអនុម័តច្បាប់នេះ "ផ្ទៃដីនៃប្រទេសកម្ពុជាជាងមួយភាគបីត្រូវបានលក់ដូរ ឬ ផ្ទេរសិទ្ធិនៅក្រៅ បញ្ញត្តិច្បាប់ភូមិបាល (១៩៩២) ក្នុងករណីខ្លះគឺខុសច្បាប់តែម្តង ដោយការផ្តល់សម្បទាន"[៣៦] នាំឱ្យខ្ទះដីធ្លីសំរាប់ ធ្វើកសិកម្ម។ មិនមានការចុះបញ្ជីដីឯកជនក្នុងកិច្ចដំណើរការនេះទេ។

ច្បាប់ស្តីពីវិនិយោគត្រូវបានអនុម័តនៅឆ្នាំ ១៩៩៤។[៣៧] នៅចន្លោះថ្ងៃទី១ ខែសីហា ឆ្នាំ១៩៩៤ និង ថ្ងៃ ទី៣០ ខែមិថុនា ឆ្នាំ២០០៣ ក្រុមប្រឹក្សាវិនិយោគកម្ពុជាបានអនុម័តគំរោងចំនួន៨៥ នៅក្នុងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និង កសិដ្ឋានចិញ្ចឹមសត្វ។[៣៨] មាត្រា១៦ នៃច្បាប់នេះចែងថា "អ្នកវិនិយោអាចប្រើប្រាស់ដីធ្លីតាម រយៈការជួលសំរាប់រយៈពេលវែងរហូតដល់៧០ ឆ្នាំ ហើយអាចស្នើសុំជួលបន្ត"។ ច្បាប់នេះមិនបានធ្វើការណែនាំ ផ្សេងទៀតអំពីនីតិវិធីសំរាប់ផ្តល់សម្បទានទេ ដោយទុកសិទ្ធិនេះឱ្យអង្គនីតិប្រតិបត្តិជាអ្នកសំរេច។[៣៩] បទបញ្ជា ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងដីសាធារណៈបានព្យាយាមចែងអំពីក្របខ័ណ្ឌច្បាប់មួយចំនួន ដោយរួមទាំងតាមរយៈ ការដាក់ពាក្យសុំជាសាធារណៈ ហើយបានធ្វើប្រតិភូកម្មអំណាចចេញបទបញ្ជាផ្សេងៗ ទៅឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ អក្សរសាស្ត្រដែលមាន បង្ហាញថាបទបញ្ជាទាំងនោះមិនត្រូវបានគេអើពើគោរពតាមនោះទេ។ អាស្រ័យដោយមានច្បាប់ប្រតិភូកម្មអំណាចច្រើននៅក្នុងប្រទេសកម្ពុជា ទើបកើតមានការមន្ទិលសង្ស័យអំពី សុពលភាពនៃបទបញ្ជាផ្សេងៗ ដោយសារច្បាប់របស់រដ្ឋសភាមិនបានធ្វើប្រតិភូកម្មអំណាចឱ្យអង្គនីតិប្រតិបត្តិ ។

---

[៣៤] សេចក្តីណែនាំលេខ៣ សេចក្តីណែនាំអនុវត្តគោលការណ៍ស្តីពីកម្មសិទ្ធិ និង ការប្រើប្រាស់ដី របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៨៩ មាត្រា១ (គ) ។ ចំពោះសិទ្ធិ " ភោគៈ " និង សិទ្ធិ " ប្រើបាស់" រហូតដល់៥ ហិកតានៃផ្ទៃដីកសិកម្ម នឹងត្រូវបានផ្តល់ឱ្យគ្រួសារទាំងឡាយណាដែលមានប្រវត្តិធ្វើ ស្រែចំការនៅក្នុងមូលដ្ឋានសំរាប់រយៈពេលយ៉ាងហោចណាស់មួយ (១) ឆ្នាំមុនការចេញសេចក្តីណែនាំនេះ។

[៣៥] ដោយលោក Shaun William ការត្រួតពិនិត្យលើសេចក្តីស្នើច្បាប់ភូមិបាលបច្ចុប្បន្ន (Oxfam GB ខែឧសភា ឆ្នាំ១៩៩៩ ) ទំព័រទី៦ ដែលជាឧបសម្ព័ន្ធរបស់ លោក Williams ដែលមានចំណងជើងថា *តើដីទាំងនោះបាត់ទៅណាអស់ហើយ? សិទ្ធិ និង ការប្រើប្រាស់ដីធ្លីនៅក្នុងប្រទេសកម្ពុជា* វ៉ូលីមទី I (Oxfam GB ខែឧសភា ឆ្នាំ១៩៩៩) ។

[៣៦] ដោយលោក Shaun Willaim ការត្រួតពិនិត្យលើសេចក្តីស្នើច្បាប់ភូមិបាលបច្ចុប្បន្ន (Oxfam GB ខែឧសភា ឆ្នាំ១៩៩៩ ) ទំព័រទី ៣។

[៣៧] មាត្រា១២ ចែងថារដ្ឋាភិបាលត្រូវផ្តល់ការលើកទឹកចិត្ត ដើម្បីជំរុញវិនិយោគក្នុងវិស័យដូចជាកសិឧស្សាហកម្ម។ មាត្រា១៣ ចែង ផ្តល់ការលើកលែងពន្ធគយ និងពន្ធអាករទាំងស្រុង ឬ មួយផ្នែក ហើយមាត្រា១៤ ចែងលើកលែងពន្ធគយ និងពន្ធអាករនាំចេញ និង នាំចូល ១០០% ។ បន្ទាប់ពីច្បាប់នោះ មានអនុក្រិត្យាស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា (ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥) និង ស្តីពីការអនុវត្តច្បាប់វិនិយោគនៅក្នុងប្រទេសកម្ពុជា (ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ១៩៩៧ ) ។

[៣៨] បញ្ជីដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានផ្តល់ឱ្យ កាលពីខែ កញ្ញា ឆ្នាំ ២០០៣។

[៣៩] នៅក្នុងខែកុម្ភៈ ឆ្នាំ ២០០៣ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងអំពីសម្បទានដី : " អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈដីសម្បទាន ឬការជួលរយៈពេលមិនកំណត់ និងការជួលរយះពេលមានកំណត់ដែលអាចបន្តជាថ្មីបាន ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ភូមិបាល។"

ទោះជាផ្ទៃដីភាគច្រើនបំផុតត្រូវបានផ្តល់នៅក្នុងអំឡុងទសវត្សឆ្នាំ១៩៩០ គឺសំរាប់ព្រៃសម្បទានក៏ដោយ មានដីចំនួន ៦៨៨.១១២ ហិកតាត្រូវបានធ្វើការបែងចែកសំរាប់សម្បទានគោលដៅកសិកម្ម នៅក្នុងចន្លោះឆ្នាំ ១៩៩៤ និង ឆ្នាំ ១៩៩៧។[៤០] មិនយូរប៉ុន្មានបានលេចឡើងនូវការព្រួយបារម្ភអំពីផលប៉ះពាល់របស់វា ហើយអង្គការសិទ្ធិមនុស្សនានាបានចាប់ផ្តើមទទួលពាក្យបណ្តឹងអំពីការរំលោភសិទ្ធិមនុស្សនៅលើដីសម្បទាន។[៤១] អតីតតំណាងពិសេស លោក ម៉ៃឃើល ឃឺប ប៊ី (Michael Kirby) បានទៅទស្សនាដីសម្បទានមួយកន្លែងនៅក្នុង ខេត្តរតនគីរី កាលពីខែមករា ឆ្នាំ១៩៩៦។ នៅក្នុងរបាយការណ៍ជាបន្តបន្ទាប់របស់លោក ផ្ញើជូនគណៈកម្មាធិការ សិទ្ធិមនុស្ស លោកបានលើកជាអនុសាសន៍ថា "ពាក្យបណ្តឹងរបស់ភូមិនានាអំពីការមិនបានពិគ្រោះយោបល់ ការប្រើប្រាស់កម្លាំងសន្តិសុខប្រដាប់អាវុធ ការបង្ខំឱ្យចុះហត្ថលេខាលើកិច្ចសន្យាដោយមិនពន្យល់ពីមូលហេតុ ច្បាស់លាស់ការបាញ់សំលាប់សត្វគោដែលដើរលើដីសម្បទាន និង ការភ័យខ្លាចមានគ្រោះថ្នាក់ដល់ជីវិត និង សន្តិសុខនៅកន្លែងកប់ខ្មោចជាប្រពៃណី វាលស្មៅសំរាប់សត្វស៊ី និង ដីកសិកម្ម ត្រូវតែដោះស្រាយដោយមិនត្រូវពន្យាពេល ដោយយុត្តិធម៌ និងស្របតាមច្បាប់ "។[៤២] សេចក្តីព្រួយបារម្ភ និង អនុសាសន៍ផ្សេងៗ ជាទូទៅមិន ត្រូវបានអ្នកធ្វើគោលនយោបាយយកចិត្តទុកដាក់ឡើយ។ នាយករងនៃនាយកដ្ឋានផែនការ និង សហប្រតិបត្តិការ នៃក្រសួងកសិកម្ម ត្រូវបានគេដកស្រង់សំដីនៅក្នុងរបាយការណ៍ពត៌មានមួយនៅឆ្នាំ១៩៩៨ ដែលនិយាយថាបញ្ហា ដែលធំបំផុតនោះគឺការស្វែងរកដីដែលមានទំហំធំតាមការស្នើសុំរបស់វិនិយោគិន។[៤៣]

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានចងក្រងនីតិវិធីមួយចំនួនសំរាប់ការផ្តល់ដីសម្បទាន បន្ទាប់ពីការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១។[៤៤] ក្នុងនោះមាននីតិវិធីមួយដែលតម្រូវឱ្យក្រុមហ៊ុនធ្វើការទាក់ទង និងស្វែងរកការយល់ព្រមជាមុនពីអាជ្ញាធរមូលដ្ឋាន ហើយបន្ទាប់មកក្រសួងកសិកម្មត្រូវធ្វើការសិក្សាស្រាវជ្រាវពីលទ្ធភាព និង ស្នើសុំការយល់ព្រមជាគោលការណ៍ពីគណៈរដ្ឋមន្ត្រី។ ក្រោយពីមានការអនុម័តយល់ព្រមពីគណៈរដ្ឋ មន្ត្រីរួចហើយ ត្រូវរៀបចំតាក់តែងកិច្ចសន្យាមួយរវាងក្រុមហ៊ុន និងក្រសួងកសិកម្ម។ នីតិវិធីនេះត្រូវបានគេហៅថាជាការ "ចំណាយពេលវេលា និង លុយកាក់ច្រើន"។ នីតិវិធីចំនួនពីរទៀត ដែលបានចងក្រងពាក់ព័ន្ធ និងការចូលជួបទាក់ទងការងារដោយផ្ទាល់ជាមួយគណៈរដ្ឋមន្ត្រី ឬ តាមរយៈការស្នើសុំការលើកទឹកចិត្តផ្នែកវិនិយោគជាមុនពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបន្ទាប់មកក្រុមប្រឹក្សានេះនឹងធ្វើការទាក់ទងជាមួយ

[៤០] វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ ដើម្បីអភិវឌ្ឍនកម្ពុជា (CDRI) ឯកសារពិភាក្សាសារទំព័រទី ២៣។

[៤១] សូមអានរបាយការណ៍របស់លោកស្រី Sara Colm ដែលមានចំណងជើងថា " ផលប៉ះពាល់នៃការអភិវឌ្ឍន៍ចំការដូងប្រេងដល់សហគមន៍ជនជាតិដើមភាគតិច" ខេត្តរតនគីរី ប្រទេសកម្ពុជា " ខែឧសភា ឆ្នាំ១៩៩៦ ដោយអង្គការ Global Witness ដែលមានចំណងជើងថា *កន្លែងដែលត្រូវទៅ* , ខែមីនា ឆ្នាំ១៩៩៨។

[៤២] ឯកសាររបស់អ.ស.ប E/CN.4/1996/93 ចុះថ្ងៃទី២៦ ខែកម្ភះ ឆ្នាំ១៩៩៦ វាក្យខ័ណ្ឌទី៨៤។

[៤៣] អត្ថបទសារព័ត៌មាន ដែលមានចំណងជើងថា " ដីជាច្រើនកន្លែងត្រូវបានត្រៀមរៀបចំជាស្រេចសំរាប់ជួលឱ្យជនបរទេស"។ *កាសែតភ្នំពេញប៉ុស្តិ៍* អត្ថបទចុះថ្ងៃទី ១០-២៣ ខែ មេសា ឆ្នាំ ១៩៩៨ ដោយលោក ភីធឺ សាន់ប៊ឺរី (Peter Sainsbury) និង ជា សុធាជាតិ ។

[៤៤] វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ ដើម្បីអភិវឌ្ឍនកម្ពុជា (CDRI) ឯកសារពិភាក្សាលេខ ១៩ ទំព័រទី១៩។

ក្រសួងកសិកម្ម ដើម្បីពិចារណាលើគំរោង និង សំរេចលើលទ្ធភាពរបស់ខ្លួន ។[៤៥] មិនមានលក្ខណៈវិនិច្ឆ័យជាក់លាក់ណាមួយសំរាប់កំណត់អំពីលទ្ធភាពនោះទេ ។ ក្រោយពីបានអនុម័តលើគំរោងនេះហើយ ក្រសួងកសិកម្មនឹងធ្វើការសិក្សាស្រាវជ្រាវលើទិដ្ឋភាពបច្ចេកទេស និង ដីធ្លីដែលខ្លួនមាន ។ បន្ទាប់មកក្រសួងនឹងធ្វើការទំនាក់ទំនងជាមួយមន្ទីរខេត្តពាក់ព័ន្ធ ហើយបញ្ជូនមន្ត្រីមួយក្រុម ដើម្បីធ្វើការវាយតំលៃលើដីដែលបានជ្រើសរើស អំពីប្រភេទ និង គុណភាពដី សារពើ រុក្ខជាតិ ប្រជាពលរដ្ឋ ការធ្វើកសិកម្ម ហេត្ថារចនាសម្ព័ន្ធ ហើយដាក់ចេញជាអនុសាសន៍ ។ បន្ទាប់មកប្រធានមន្ទីរ ខេត្តអនុម័តយល់ព្រម និង ចុះហត្ថលេខាលើរបាយការណ៍ ហើយបញ្ជូនទៅក្រសួងកសិកម្ម បន្ទាប់មក ក្រសួងនេះត្រូវផ្ញើរបាយការណ៍ និងអនុសាសន៍នេះទៅគណៈរដ្ឋមន្ត្រី ។

បើតាមពត៌មានបានឱ្យដឹងថាការផ្តល់អនុសាសន៍ និង ការវាយតម្លៃផ្សេងៗ ជានិច្ចកាលគឺមិនមានលក្ខណៈគ្រប់គ្រាន់ ឬ មិនត្រូវបានគេអើពើទេ ឬ ជួនកាលពត៌មានដែលបានផ្តល់នោះ គឺមិនត្រឹមត្រូវសំរាប់ការបែងចែកដីធ្លីតាមអនុសាសន៍ឡើយ ។[៤៦] ដូចជាករណីនៃសម្បទានដីរបស់ក្រុមហ៊ុនភាពីម៉ិច នៅក្នុងខេត្តកំពង់ឆ្នាំង មន្ទីរខេត្តបានដាក់ចេញជាអនុសាសន៍សុំឱ្យមានការកាត់បន្ថយសម្បទានដីនោះមកនៅត្រឹមតែ ១៤០.០០០ ហិកតា ហើយសុំឱ្យធ្វើការដកហូត "ដីវាលស្មៅសាធារណៈ ហើយធ្វើការកាប់ឆ្ការ និង ដុតដីកសិកម្មទាំងនោះ" ពីតំបន់សម្បទាន ប៉ុន្តែអនុសាសន៍ទាំងនេះមិនត្រូវបានគេអនុវត្តតាមឡើយ ហើយក្រសួងកសិកម្មបានធ្វើការបែងចែកដីចំនួន១៧៦.០៦៥ ហិកតា តាមការស្នើសុំពីខាងដើម ។[៤៧]

## ២- ច្បាប់ភូមិបាលបច្ចុប្បន្ន និង បទបញ្ជាស្តីពីដីសម្បទានសំរាប់គោលដៅសេដ្ឋកិច្ច

រដ្ឋសភាបានអនុម័តច្បាប់ភូមិបាលថ្មីមួយ កាលពីខែសីហា ឆ្នាំ២០០១ ។ ច្បាប់នេះមានគោលដៅធ្វើនិយ័តកម្មដីដែលរហូតមកដល់ពេលនេះមិនទាន់បានធ្វើនិយ័តកម្មនៅឡើយ ដូចជាកិច្ចសន្យាជួល សម្បទានដី ដីសហគមន៍ជនជាតិដើមភាគតិច សហកម្មសិទ្ធិ ការស្ទង់សុរិយោដី បញ្ជី និង ប័ណ្ណកម្មសិទ្ធិដីធ្លី និង ការដោះស្រាយជំលោះដីធ្លី ។ ច្បាប់នេះបានចែងអំពីប្រព័ន្ធមួយដែលមានលក្ខណៈទូទៅស្តីអំពីការធ្វើចំណាត់ថ្នាក់ដីធ្លី និង សិទ្ធិកម្មសិទ្ធិលើដីធ្លី ធ្វើការប្រៀបធៀបមួយជាមូលដ្ឋានរវាងដីសាធារណៈរបស់រដ្ឋដូចជាព្រៃឈើ និង ដីធ្លីត្រូវបានការពារដែលរដ្ឋធ្វើការអភិរក្សធនធាន និងដីឯកជនរបស់រដ្ឋ ដែលបានផ្តល់ដីធ្លីសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។ ច្បាប់តម្រូវឱ្យអនុម័តអនុក្រឹត្យជាច្រើន ដើម្បីឱ្យបទបញ្ញត្តិនៃច្បាប់នេះចូលជាធរមានយ៉ាងពេញលេញ ។[៤៨]

---

[៤៥] នៅក្នុងកិច្ចពិភាក្សាមួយ ដែលបានធ្វើឡើងកាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៣ អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម សុខ ចិន្តា សោភា បានគូសបញ្ជាក់ថា តួនាទីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គឺផ្តល់ការលើកទឹកចិត្ត មិនមែនការផ្តល់សម្បទាននោះទេ ។

[៤៦] សូមលើកជាឧទាហរណ៍ មន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង មានពាក្យបណ្តឹងមួយ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០១ ស្តីពីការកំណត់ព្រំប្រទល់ដីសម្បទានរបស់ក្រុមហ៊ុនគ្រីនស៊ី ។

[៤៧] ការស្ទង់មតិ និង វាយតំលៃលើការប្រើប្រាស់ដីកសិកម្ម ប្រធានមន្ទីរកសិកម្ម ខេត្តពោធិសាត់ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ។

[៤៨] នេះក៏ជាការពិត នៃច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ។

ជំពូកទី ៩ នៃច្បាប់ភូមិបាលបានធ្វើនិយ័តកម្មដីសម្បទានគោលដៅសេដ្ឋកិច្ច ។ មាត្រា៤៨ កំណត់និយមន័យសម្បទានថាជា " សិទ្ធិស្របច្បាប់ដែលបង្កើតឡើងដោយលិខិតគតិយុត្តិចេញតាមអំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធរមានសមត្ថកិច្ច....សំរាប់កាន់កាប់ និង ប្រើប្រាស់ដីធ្លីតាមសិទ្ធិដែលច្បាប់បានកំណត់ " ហើយអាចផ្តល់តែដីណាដែលជាផ្នែកនៃ " ដីឯកជនរបស់រដ្ឋ" ប៉ុណ្ណោះ ។ សម្បទានមានបីប្រភេទគឺ : សម្បទានគោលដៅសេដ្ឋកិច្ច សម្បទានគោលដៅអាជីវកម្មកសិកម្ម និងពាណិជ្ជកម្ម សម្បទានគោលដៅសង្គមកិច្ច សម្បទានគោលដៅសង់លំនៅដ្ឋាន ឬ សម្បទានគោលដៅធ្វើកសិកម្មសំរាប់ចិញ្ចឹមជីវិត និង " សម្បទានដទៃទៀត " ដូចជា សម្បទានគោលដៅរុករករ៉ែ សម្បទានគោលដៅកំពង់ផែ ឬ សម្បទានគោលដៅនេសាទ ដែលស្ថិតនៅក្រៅបទបញ្ញត្តិនៃច្បាប់ភូមិបាល ។

សម្បទានសេដ្ឋកិច្ចមិនអាចក្លាយជាកម្មសិទ្ធិបានឡើយ ហើយបើតាមន័យច្បាប់វាបង្កើតបានត្រឹមសិទ្ធិធម្មតា តាមរយៈកិច្ចសន្យាតែប៉ុណ្ណោះ ។ ទោះជាដូច្នោះក្តី សិទ្ធិរបស់សម្បទានិក មានលក្ខណៈស្រដៀងគ្នាទៅនឹងសិទ្ធិរបស់កម្មសិទ្ធិករដែរ ខុសគ្នាតែត្រង់សិទ្ធិលក់ដូរ និងផ្ទេរកម្មសិទ្ធប៉ុណ្ណោះ ។ សម្បទានសេដ្ឋកិច្ចមានរយៈពេល *អតិបរិមា ៩៩* ឆ្នាំ លើផ្ទៃដីអនុញ្ញាតជាអតិបរិមា ១០.០០០ ហិកតា ។ សម្បទានដែលមានទំហំធំជាងនេះ ត្រូវបន្ថយមកនៅត្រឹមតែ ១០.០០០ ហិកតា ទោះជាអាចមានការលើកលែងខ្លះក៏ដោយ ។ ប្រសិនបើសម្បទានិកស្លាប់ សន្តតិករនៃសពអាចបន្តប្រើប្រាស់សិទ្ធិសម្បទានិកសំរាប់រយៈពេលដែលនៅសល់ ។

បើតាមបទបញ្ជាព្រៃឈើដែលនៅជាធរមាន សម្បទានព្រៃចាស់មិនអាចផ្លាស់ប្តូរទៅជាសម្បទានសេដ្ឋកិច្ចបានឡើយ ។[៤៩]

នៅក្នុងពេលធ្វើរបាយការណ៍នេះ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ បានធ្វើជាក្រសួងសំខាន់ជាងគេក្នុងការអភិវឌ្ឍន៏កសិកម្ម ដែលមានភារកិច្ចទទួលខុសត្រូវត្រួតពិនិត្យលើសម្បទានគោលដៅសេដ្ឋកិច្ច ។ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់ទទួលខុសត្រូវក្នុងការគ្រប់គ្រងដីធ្លី និង សុរិយោដី ។ ការទទួលខុសត្រូវរបស់ក្រសួងនេះ រួមទាំងការបង្កើតគោលនយោបាយដីធ្លី និង ក្របខ័ណ្ឌច្បាប់សំរាប់សិទ្ធិដីធ្លី ការចុះបញ្ជីដី ការលើកស្ទួយដល់ការគ្រប់គ្រងដីរដ្ឋ ការផ្តល់សម្បទានគោលដៅសង្គមកិច្ច ការធ្វើកំណែទម្រង់ពន្ធដីធ្លី ការបង្កើតនីតិវិធីផែនការប្រើប្រាស់ដីធ្លី កំណត់តំបន់សេដ្ឋកិច្ចសំខាន់ៗ សំរាប់ការអភិវឌ្ឍន៏ និង សំរាប់គោលនយោបាយលំនៅស្ថាន និងការតាំងលំនៅថ្មី ។ ក្រសួងបរិស្ថានទទួលខុសត្រូវការពារ និង គ្រប់គ្រងតំបន់ដែលងាយទទួលរងផល

[៤៩] មាត្រា ៥.៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ចែងថាសម្បទានព្រៃដែលត្រូវបានមោឃៈភាព ឬ ដកហូតវិញត្រូវត្រឡប់ទៅជា " តំបន់ព្រៃជាធម្មជាតិទទួលការការពារ" ហើយមិនអាចផ្តល់ឱ្យក្រុមហ៊ុនដទៃទៀតបានឡើយ ។

ប៉ះពាល់បរិស្ថាន និងធ្វើការវាយតម្លៃ និង ការកាត់បន្ថយផលប៉ះពាល់ជាសក្តានុពលដល់បរិស្ថាន ។[៥០] បើតាមរបាយការណ៍របស់ក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យ ដែលបានបោះពុម្ពផ្សាយកាលពីខែឧសភា ឆ្នាំ២០០៤ មានសេចក្តីថា:

*" បច្ចុប្បន្ននេះមិនមានយន្តការសកម្មណាមួយ ដើម្បីសម្របសម្រួលរវាងក្រសួងទាំងនេះ និង អភិបាលខេត្ត មិនមានផែនការលំអិតស្តីពីការប្រើប្រាស់ដីធ្លី ដើម្បីជាមគ្គុទ្ទេសន៍សំរាប់ការធ្វើសេចក្តីសំរេចអំពីការគ្រប់គ្រងដីធ្លី និងមានសមត្ថភាពតិចតួចសំរាប់ត្រួតពិនិត្យលើការប្រើប្រាស់ និង ប្រាក់ចំណូល ។"*[៥១]

សេចក្តីត្រូវការឱ្យមានការចេញបទបញ្ជាជាច្រើន ដើម្បីអនុវត្តច្បាប់ភូមិបាលឱ្យបានពេញលេញ ។[៥២] កន្លងមកមានអនុក្រឹត្យ និង ប្រកាសជាច្រើនត្រូវបានអនុម័ត ទាក់ទងនឹងការចុះបញ្ជីដីធ្លី ការរៀបចំ សមាសភាព និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី និង អនុក្រឹត្យស្តីពីសម្បទានដីគោលដៅសង្គមកិច្ច ដែលបានអនុម័តនៅ ក្នុងខែមីនា ឆ្នាំ២០០៣ ដែលកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី និង យន្តការ ក្នុងការផ្តល់សម្បទានគោលដៅសង់លំនៅស្ថាន និងធ្វើកសិកម្មសំរាប់ចិញ្ចឹមជីវិត ។[៥៣] ដីឯកជនរបស់រដ្ឋជាច្រើនមានលក្ខណៈសមស្របសំរាប់សម្បទានគោលដៅសង្គមកិច្ច ដែលបច្ចុប្បន្ននេះត្រូវបានផ្តល់ក្រោមរូបភាពជាសម្បទានគោលដៅសេដ្ឋកិច្ច ។ គោលបំណងគឺដើម្បីបង្វែរដីធ្លី ដែលបានកាត់ចេញពីសម្បទានទាំងនេះ ទៅជាសម្បទានគោលដៅសង្គមកិច្ចវិញ ។

អនុក្រឹត្យមួយ ដែលមានចែងក្នុងមាត្រា១៧ និង ៥៩ នៃច្បាប់ភូមិបាល គឺមានលក្ខណៈចាប់បង្ខំខ្លាំង ។ អនុក្រឹត្យនេះតម្រូវឱ្យបង្កើតនីតិវិធីស្តីពីការផ្តល់សម្បទានគោលដៅសេដ្ឋកិច្ច និង ការកាត់បន្ថយសម្បទានដែលមានស្រាប់មកនៅត្រឹម ១០.០០០ហិកតា តាមច្បាប់កំណត់ ដោយមានការលើកលែងខ្លះ ។ អនុក្រឹត្យសំខាន់មួយទៀត ស្តីពីការគ្រប់គ្រងដីរដ្ឋ និង ការធ្វើចំណាត់ថ្នាក់ " ដីសាធារណៈរបស់រដ្ឋ" និង " ដីឯកជនរបស់រដ្ឋ " ។ បច្ចុប្បន្ននេះ ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និង សំណង់កំពុងរៀបចំព្រាងអនុក្រឹត្យស្តី ពីសម្បទានគោលដៅសេដ្ឋកិច្ច ការគ្រប់គ្រងដីរដ្ឋ និង សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ។

---

[៥០] នៅពេលកំពុងធ្វើរបាយការណ៍នេះ តួនាទីរបស់ក្រសួងនានាដែលទទួលខុសត្រូវគ្រប់គ្រងដីរដ្ឋ កំពុងត្រូវបានត្រួតពិនិត្យ ។

[៥១] របាយការណ៍ការចុងក្រោយ របស់ក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យ មានចំណងជើងថា *" វិស័យព្រៃឈើនៅប្រទេសកម្ពុជា "* ជំពូកទី១០ ទំព័រទី៣ ។

[៥២] ទាំងអស់នេះរួមមាន (យោងតាមមាត្រា និងលេខវាក្យខ័ណ្ឌនៃច្បាប់ភូមិបាល ) : បទបញ្ជា និង នីតិវិធីសំរាប់គ្រប់គ្រងអចលនទ្រព្យរបស់រដ្ឋ (មាត្រា៣.៣) ការផ្ទេរដីសាធារណៈរបស់រដ្ឋ ទៅជាដីឯកជនរបស់រដ្ឋ (មាត្រា១៦.៥) លក្ខខណ្ឌ និង នីតិវិធីស្តីពីការលក់ និង ការគ្រប់គ្រងដីឯកជនរបស់នីតិបុគ្គលសាធារណៈ ឬ រដ្ឋ (មាត្រា១៧.២) ការផ្តល់ដីសម្បទានគោលដៅសេដ្ឋកិច្ច (មាត្រា១៧.៤) នីតិវិធីសំរាប់ការកាត់បន្ថយ និង ការលើកលែងសម្បទានដីដែលមានទំហំលើសពី ១០.០០០ ហិកតា (មាត្រា៥៩.១) បែបបទនៃការជួលអចលនទ្រព្យសំរាប់គោលដៅធ្វើជាលំនៅដ្ឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម និង កសិកម្ម (មាត្រា១១៣) បែបបទសំរាប់ការសាងសង់ និង វាល់លក្ខខណ្ឌដែលបានកំណត់ចំពោះកម្មសិទ្ធិករ (មាត្រា១១៥) ការតាំងទីលំនៅថ្មី ឬ សិទ្ធិ (នៃរដ្ឋាភិបាល ) យកដីមកប្រើប្រាស់ជាសាធារណៈ (មាត្រា១៤៧) ទម្រង់បែបបទក្នុងការចុះបញ្ជី និង កិច្ចសន្យាហ៊ីប៉ូតែក (មាត្រា២០១) ។

[៥៣] ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់ បានបង្កើតគំរោងមួយសំរាប់ពិសោធមើល នៅក្នុងខេត្តមួយចំនួន ដើម្បីចាប់ផ្តើមអនុវត្តអនុក្រឹត្យនេះ ។

ការកំណត់ព្រំប្រទល់ដីឱ្យបានច្បាស់លាស់ តាមច្បាប់ភូមិបាល និង ច្បាប់ស្តីពីព្រៃឈើ គឺជាការសំខាន់ដែរ ហើយត្រូវអនុវត្តតាមលំដាប់លំដោយដ៏ត្រឹមត្រូវ :

*" ប្រសិនបើគ្មានភាពច្បាស់លាស់ និង កិច្ចព្រមព្រៀងជុំវិញកិច្ចដំណើរការ និង លក្ខណៈវិនិច្ឆ័យដ៏ទូលំទូលាយសំរាប់ការបែងចែកដីធ្លីទេនោះ ភាពអសន្តិសុខនឹងចេះតែបន្តកើតមាន ហើយអនុញ្ញាតឱ្យមានការលក់ដូរ ឬ ផ្ទេរសិទ្ធិ ដីធ្លី ដោយអ្នកមានអំណាចខ្លាំង និង ដោយអ្នកមាននិន្នាការនយោបាយ "* ។[៥៤]

## ៣- សម្បទាន និង សម្បទានិក

យោងតាមបញ្ជីដែលក្រសួងកសិកម្មបានផ្តល់ឱ្យការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) កាលពីខែកុម្ភៈ ឆ្នាំ២០០៣។ គណៈរដ្ឋមន្ត្រីបានអនុម័តយល់ព្រមផ្តល់សម្បទានគោលដៅសេដ្ឋកិច្ចចំនួន៤០ ដែលគ្របដណ្តប់លើផ្ទៃដី ៨០៩.២៩៦ ហិកតា ឬ ជាងបួនភាគរយនៃទឹកដីនៃប្រទេសកម្ពុជា។[៥៥] ចំពោះសម្បទានព្រៃវិញ តួលេខនេះបានធ្លាក់ចុះពីចំណុចកំពូលនៅក្នុងឆ្នាំ១៩៩៩ នៅពេលដែលសម្បទានគោលដៅសេដ្ឋកិច្ចសរុបចំនួន៥៦ ដែលបានចុះបញ្ជីរួច មានផ្ទៃដី ៩៣៤.៩២៦ ហិកតា។[៥៦] សម្បទានទាំងនោះត្រូវបានផ្តល់ជាសំខាន់សំរាប់ដាំដើមអាកាស្យា ដូងប្រេង ដំឡូងមី  កៅស៊ូ និង ដើមស្វាយចន្ទី។ មានតែក្រុមហ៊ុនចំនួន២៦ នៅក្នុងបញ្ជីប៉ុណ្ណោះ ដែលបានចុះកិច្ចព្រមព្រៀង ឬ កិច្ចសន្យាជាមួយក្រសួងដែលក្នុងនោះមាន កិច្ចសន្យាចំនួន២២ ដែលបានអនុវត្តនៅក្នុងអំឡុងពេលបីឆ្នាំមុនការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១។ មាន កិច្ចព្រមព្រៀងចំនួន១៦ ("ការអនុម័តយល់ព្រម") ត្រូវបានធ្វើមោឃៈភាព ក្នុងឆ្នាំ២០០០ ដែលគ្របដណ្តប់លើផ្ទៃដីសរុបចំនួន១២៣.៦៨០ ហិកតា ប៉ុន្តែកិច្ចសន្យាទាំងនោះមិនទាន់បានអនុវត្តនៅឡើយទេ នៅក្នុងករណីទាំងនេះ ដូច្នេះហើយក្រុមហ៊ុនទាំងនេះមិនដំណើរការទេ។ ចាប់តាំងពីចាប់ផ្តើមសិក្សាស្រាវជ្រាវមកមានលិខិត

---

[៥៤] សូមអានជំពូកទី១០ នៃរបាយការណ៍ចុងក្រោយ របស់ក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យ ដែលបានស្នើសុំអនុវត្តនូវជំហ៊ានដូចខាងក្រោមនេះ : និយមន័យ ការកំណត់អត្តសញ្ញាណ និង ការព្រមព្រៀងនៃ : ក- តើអ្វីខ្លះដែលបង្កើតបានជាដីសាធារណៈរបស់រដ្ឋ , ខ- ដីរបស់សហគមន៍ជនជាតិដើមភាគតិច , គ- តំបន់ស្នូលនៃព្រៃឈើដែលគួរតែដាក់ឱ្យនៅក្រោមប្រព័ន្ធនៃតំបន់ទទួលការការពារ និង តំបន់ដែលមានមុខងារបំរើសេវាកម្មបរិស្ថានខ្ពស់ (ឧទាហរណ៍ដូចជាតំបន់ទឹកធ្លាក់), ឃ- តំបន់ព្រៃ ដែលអាចត្រូវបានគ្រប់គ្រងក្រោមរូបភាពនៃផលិតកម្ម (ឧទាហរណ៍ដូចជា តាមរយៈសហគមន៍ ឃុំ/សង្កាត់ ព្រៃឈើ " ឧស្សាហកម្ម" ទ្រង់ទ្រាយតូច  សម្បទាន ការគ្រប់គ្រងដោយផ្ទាល់ដោយវិស័យសាធារណៈ) , ង- ដីសំរាប់ធ្វើកសិកម្ម ឧទាហរណ៍ កសិដ្ឋានសំរាប់គ្រួសារកសិដ្ឋាន " ឧស្សាហកម្ម" ទ្រង់ទ្រាយតូច  សម្បទានកសិកម្ម ទ្រង់ទ្រាយធំ។

[៥៥] ទោះបីជារបាយការណ៍រៀបរាប់របស់ក្រសួងកសិកម្មគូសបញ្ជាក់ថាមានសម្បទានចំនួន៤០ ត្រូវបានអនុម័ត និង សម្បទានចំនួន៤១ ទៀត ត្រូវបានចុះបញ្ជីក៏ដោយ ក៏តួលេខដូចគ្នានេះ ត្រូវបានក្រសួងកសិកម្មផ្តល់ឱ្យអង្គការបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI) ថាជាតួលេខថ្មីបំផុត ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១។

[៥៦] លិខិតរបស់ក្រសួងកសិកម្មផ្ញើជូនការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) កាលពី ខែកុម្ភះ ឆ្នាំ២០០៣។ កិច្ចសម្ភាសន៏ដែលបានធ្វើឡើងដោយអង្គការបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI) ក្នុងឆ្នាំ២០០១ គូសបញ្ជាក់ថាចំនួនដីសម្បទានគោលដៅសេដ្ឋកិច្ចបានធ្លាក់ចុះ ដោយសារការធ្វើមោឃភាព និង ការដកហូតសម្បទាន : CDRI ឆ្នាំ ២០០១, op cit, ទំព័រទី១៩។

យល់ព្រមលើសម្បទានចំនួនប្រាំត្រូវបានដកហូតមកវិញ ដោយមានផ្ទៃដី ៣៦.៦០០ ហិកតា ។[៥៧] យោងតាមព័ត៌មានដែលការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) ទទួលបានមិនមានកិច្ចសន្យាដែលបានចុះហត្ថលេខារួចហើយត្រូវបានដកហូតមកវិញនោះទេ ។

នៅពេលដែលច្បាប់ភូមិបាលត្រូវបានអនុម័ត សម្បទានចំនួន១៤ នៃសម្បទានដែលបានចុះបញ្ជីរួចមានទំហំលើសពី ១០.០០០ ហិកតា ។ សម្បទានធំជាងគេបំផុតដែលបានផ្តល់នៅក្នុងឆ្នាំ២០០០ ទៅឱ្យក្រុមហ៊ុនព្រៃសម្បទានភាពីម៉ិច : សម្បទានពីររួមគ្នាសំរាប់ធ្វើចំការដើមប្រេងខ្យល់ ដើម្បីផ្គត់ផ្គង់ដល់រោងម៉ាស៊ីនកិនផ្លែឈើ ដែលគ្របដណ្តប់លើផ្ទៃដី ៣១៥.០២៨ ហិកតា លាតសន្ធឹងកាត់ខេត្តពោធិសាត់ និង ខេត្តកំពង់ឆ្នាំង ។ រយៈពេលបីខែបន្ទាប់ពីការអនុម័តច្បាប់ភូមិបាល ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០១ មក រដ្ឋាភិបាលបានចុះកិច្ចសន្យាមួយជាមួយក្រុមហ៊ុនគ្រីនស៊ី អ៊ីនដាស់ស្រ្ទល ចំកាត់ (Green Sea Industrial Co Ltd) ដើម្បីធ្វើចំការម៉ៃសាក់ ដែល មានផ្ទៃដី ១០០.៨៥២ ហិកតា នៅក្នុងខេត្តស្ទឹងត្រែង គឺជាការរំលោភយ៉ាងច្បាស់ក្រឡែតលើការកំណត់ទំហំដី ១០.០០០ ហិកតា ។[៥៨] សម្បទានខ្លះ ដូចជាសម្បទានដែលបានផ្តល់ឱ្យក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ (Flour Manufacturing Company) នៅក្នុងខេត្តស្ទឹងត្រែង និងក្រុមហ៊ុនគ្រីនរិច (Green Rich Company) ក្នុងខេត្តកោះកុង ត្រូវបានផ្តល់ឱ្យនៅក្នុង តំបន់ដែលគ្របដណ្តប់ដោយព្រៃឈើសំខាន់ជាងគេ ។ កាលពីដំបូង ក្រុមហ៊ុនគ្រីនរិច (Green Rich Company) ត្រូវបានផ្តល់សម្បទានដីចំនួន៦០.២០០ ហិកតា ដែល ស្ថិតនៅក្នុងតំបន់ទទួលការពារចំនួនបីនៅក្នុងខេត្តកោះកុង ហើយ បន្ទាប់មកនៅក្នុងឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានកាត់ បន្ថយទំហំដីនោះមកនៅត្រឹម ១៨.៣០០ ហិកតា ។ ទោះជា ដូច្នោះក្តី តំបន់សម្បទាននោះនៅតែស្ថិតនៅក្នុងព្រំប្រទល់នៃសួនឧទ្យានជាតិបុទុមសាគរជាដដែល ដែលផ្ទុយនឹងព្រះរាជក្រឹត្យឆ្នាំ១៩៩៣ ស្តីពីការចាត់តាំង និងការបង្កើតតំបន់ទទួលការពារក៏ដូចជាសេចក្តីប្រកាសរបស់ក្រសួងស្តីពីតំបន់ទទួលការពារ និង ច្បាប់ភូមិបាល ។ តាមប្រភពពត៌មានពីអង្គការក្រៅរដ្ឋាភិបាល ដីសម្បទាននោះត្រូវបានកាប់ឆ្ការ ដើម្បីដាំដើមអាកាស្យា ។ កាលពីខែមេសា ឆ្នាំ ២០០៤ ក្រុមហ៊ុនបានដាក់ពាក្យសុំដីចំនួន ៣០០.០០០ ហិកតាថែម ទៀត ដែលនៅក្នុងពេលធ្វើរបាយការណ៍នេះ រាជរដ្ឋាភិបាលកំពុងតែពិចារណាលើពាក្យសុំនោះនៅឡើយ ។

យោងតាមបញ្ជីដែលបានផ្តល់ឱ្យដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) កាលពីខែកញ្ញា ឆ្នាំ២០០៣ ភាគីនៃកិច្ចសន្យា រួមទាំងក្រុមហ៊ុននានាដែលខ្មែរជាម្ចាស់ទាំងស្រុង ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលភាគច្រើនជាជន

[៥៧] រដ្ឋមន្ត្រីក្រសួងកសិកម្មបានជំរាបប្រាប់លោកតំណាងពិសេស នៅក្នុងសម័យប្រជុំមួយ កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៣ ថា ក្រសួងរំពឹងថានឹងធ្វើមោឃភាពដីសម្បទានចំនួនដប់មួយ (១១) កន្លែងទៀត ដែលបានអនុម័តយល់ព្រមជាគោលការណ៍រួចហើយ ។

[៥៨] ក្រសួងកសិកម្មបានពន្យល់ថា " ដោយសារតែសំណើរបានដាក់ជូនរដ្ឋាភិបាលរយៈពេលប្រាំខែមុនពេលរដ្ឋសភាអនុម័តច្បាប់ [ភូមិបាល] ។ " លិខិតលេខ ២៧៤៣/៦៨០ កសកផផក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ ។

ជាតិចិន តៃវ៉ាន់ ម៉ាឡេស៊ី និងកូរ៉េខាងត្បូង និងក្រុមហ៊ុនដែលបរទេសជាម្ចាស់ទាំងស្រុង មកពីសាធារណៈរដ្ឋចិន និង សហរដ្ឋអាមេរិក ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដោយមន្ត្រីការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) និងមន្ត្រីនានាក្តី ក៏គេបានដឹងតិចតួចពីក្រុមហ៊ុនទាំងនេះ រួមទាំងអត្តសញ្ញាណនៃក្រុមហ៊ុនអាណាព្យាបាល តំណាងក្រុមហ៊ុន និង ម្ចាស់ភាគហ៊ុនធំៗ ដទៃទៀត ។ យោងតាមព័ត៌មានមិនគ្រប់គ្រាន់ ដែលការិយាល័យបានទទួល គឺដំបូងក្រុមហ៊ុនគ្រីនរិច (Green Rich Company) បានអះអាងថា ខ្លួនជាតំណាងក្រុមហ៊ុនជីនហ្វុងគ្រុប (Chinfon Group)[៥៩] ហើយបន្ទាប់មកជាតំណាងក្រុមហ៊ុនគ្រីន អេលីត គ្រុប (Green Elite Group)[៦០] ខណៈនោះដែរ ក្រុមហ៊ុនហេងប្រាឌឺ ចំកាត់ (Heng Brothers Co. Ltd.) ក៏បានអះអាងថាខ្លួនជាតំណាងក្រុមហ៊ុនគ្រីនរិច (Green Rich Company) និង ជាអតីតបុគ្គលិកក្រុមហ៊ុនគ្រីនរិច បាននិយាយថាក្រុមហ៊ុនហៃនិញ (Haining Company) បានផ្ទេរសម្បទានមកឱ្យក្រុមហ៊ុនខ្លួន។ ក្រុមហ៊ុននេះក៏មានទំនាក់ទំនងគ្នាជាមួយក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ (Flour Manufacturing Company) នៅក្នុងខេត្តស្ទឹងត្រែង ដោយសារលោកវរសេនីយទោ កែវ វុទ្ធី ជានាយកក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ ហើយជាតំណាងក្រុមហ៊ុនគ្រីនរិចផងនោះ ។ បើតាមរបាយការណ៍ថ្មីៗ ក្រុមហ៊ុនគ្រីនរិច មានទំនាក់ទំនងជាមួយក្រុមហ៊ុនឥណ្ឌូនេស៊ី ភីធី អារ៉ារ៉ា អាដាប៊ី (Indonessian Compnay PT Arara Adabi) ដែលគ្រប់គ្រងដោយក្រុមហ៊ុនផលិតក្រដាស (Asia Pulp and Paper) ដែលជាក្រុមហ៊ុនធំមួយ ក្នុងចំណោមក្រុមហ៊ុនផលិតក្រដាសដទៃទៀតនៅលើពិភពលោក ។ ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម បានរាយការណ៍ កាលពីខែ សីហា ឆ្នាំ២០០៣ នេះថា គេមិនអាចកោះអញ្ជើញសម្បទានិកនៃសម្បទានដីចំនួនប្រាំបី មកចូលរួមប្រជុំបានទេ ពីព្រោះក្រសួងមិនមានអាស័យដ្ឋានរបស់ក្រុមហ៊ុន ។[៦១] ស្ថិតក្នុងបរិយាកាស ដែលច្បាប់មានភាពធូររលុងបែបនេះ ការដែលចាប់ឱ្យក្រុមហ៊ុននានាទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួននោះ គឺជាការលំបាកខ្លាំងណាស់ ។

បញ្ជីដែលក្រសួងកសិកម្ម និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានផ្តល់ឱ្យ មិនបានកត់ត្រាលំអិតអំពីសម្បទានគោលដៅសេដ្ឋកិច្ចទាំងអស់ នៅក្នុងប្រទេសកម្ពុជានោះទេ ។ មិនមានកំណត់ត្រាផ្លូវការណាមួយស្តីពីសម្បទានដីដែលបានផ្តល់នៅមុនការអនុម័តច្បាប់ភូមិបាលឆ្នាំ១៩៩២ ឡើយ ។ ការស្រាវជ្រាវដល់ទីកន្លែងសំរាប់ធ្វើរបាយការណ៍នេះ បានបញ្ជាក់ថា មានរច្ចនាសម្ព័ន្ធស្របគ្នាមួយនៅថ្នាក់ខេត្ត ដែលអាជ្ញាធរមូលដ្ឋានបានផ្តល់សម្បទានគោលដៅសេដ្ឋកិច្ចលើផ្ទៃដីដែលមានទំហំតូច នៅក្នុងតំបន់អភិវឌ្ឍន៍យោធា ។

---

[៥៩] លិខិតលេខ ៦៧៤ បស្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ ចុះហត្ថលេខាដោយបណ្ឌិត ម៉ុក ម៉ារ៉េត ។

[៦០] លិខិតរបស់លោកវ៉ាំងសង់ចាន់ (Vincent Chan) តំណាងក្រុមហ៊ុនគ្រីន រិច ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ ផ្ញើរជូនអភិបាលខេត្តកោះកុង ស្នើសុំបុគ្គលិកសន្តិសុខដើម្បីការពារដីសម្បទាន ។

[៦១] លិខិតលេខ១០០៨ ផផក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៣ ចុះហត្ថលេខាដោយលោកជ័យ សាគុណ ។

ករណីបែបនេះ ក៏មាននៅតំបន់មួយចំនួន នៅស្រុកភ្នំស្រួច ក្នុងខេត្តកំពង់ស្ពឺ ដូចបានបង្ហាញក្នុងផែនទីឆ្នាំ ១៩៩៤ ដែលគូសដោយលោកឧត្តមសេនីយឯក កែ គីមយ៉ាន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ។ ផែនទីឆ្នាំ២០០២ ដែលគូសដោយលោកឧត្តមសេនីយត្រី ឈុំ ចុង ហេង មេបញ្ជាការនៃតំបន់អភិវឌ្ឍន៍យោធា សំរាប់ដីសម្បទាននៃក្រុមហ៊ុនហ្គោលដេន លេន ចំកាត់ (Golden Land Co Ltd.) បង្ហាញឱ្យឃើញថាយោធានៅតែបន្តត្រួតត្រាតំបន់ទាំងនោះជាដដែល។[៦២] ក្រុមហ៊ុនហ្គោលដេន លេន ចំកាត់ ជាក្រុមហ៊ុនសហកម្មសិទ្ធិករ រវាងក្រុមហ៊ុនតៃវ៉ាន់ និង រាជរដ្ឋាភិបាលកម្ពុជា ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅពីឆ្នាំ១៩៩៤ ហើយក្រោយមកទៀត នៅឆ្នាំ១៩៩៧ ។ ក្រុមហ៊ុននេះមិនឃើញមានឈ្មោះនៅក្នុងបញ្ជី ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានផ្តល់ឱ្យនោះទេ ប៉ុន្តែតួលេខបានបង្ហាញថា ក្រុមហ៊ុននេះមានសម្បទានដី ២.១០០ ហិកតា នៅស្រុកភ្នំស្រួចក្នុងបញ្ជីក្រុមហ៊ុនរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ក្រុមហ៊ុននេះចាប់ដំណើរការនៅក្នុងឆ្នាំ២០០០ កន្លងមកនេះ។ ក្រុមហ៊ុនចំនួន១៦ ទៀត នៅក្នុងបញ្ជីនេះ មិនមានឈ្មោះនៅក្នុងបញ្ជីដែលបានផ្តល់ដោយក្រសួងកសិកម្ម ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទេ។ ក្រសួងកសិកម្ម ទំនងជាបានដឹងអំពីក្រុមហ៊ុនហ្គោលដេន លេន ចំកាត់ នេះ ព្រោះកាលពីខែកញ្ញា ឆ្នាំ២០០៣ សម្តេចនាយករដ្ឋមន្ត្រីបានចេញលិខិតប្រតិភូកម្មអំណាចឱ្យក្រសួងនេះ ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនហ្គោលដេន លេន ចំកាត់។ កិច្ចសន្យានេះ បានចុះនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៤ សំរាប់សម្បទានគោលដៅសេដ្ឋកិច្ចលើផ្ទៃដី ៤.៩០០ ហិកតា នៅក្នុងខេត្តកំពង់ស្ពឺ ដើម្បីដាំដំណាំកសិឧស្សាហកម្ម ដែលមិនមានបញ្ជាក់ឈ្មោះរុក្ខជាតិជាក់លាក់។

## ៤- ការអនុវត្ត

### *កិច្ចសន្យា*

ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (COHCHR/Cambodia) បានទទួលអត្ថបទចំលងនៃកិច្ចសន្យាសម្បទានចំនួន១៥ ពីប្រភពផ្សេងៗ ដែលកិច្ចសន្យាទាំងនោះមានរាយឈ្មោះនៅក្នុងបញ្ជីដែលក្រសួងកសិកម្មបានផ្តល់ឱ្យ។ តារាងខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីកិច្ចសន្យាដែលការិយា-ល័យទទួលបាន :

| **សម្បទានិក** | **ទំហំដីគិតជាហិកតា** | **ទីតាំង** | **ការបរិច្ឆេទនៃការអនុវត្តកិច្ចសន្យា** | **ថ្ងៃផុតកំណត់** | **គោលបំណង** |
|---|---|---|---|---|---|
| ក្រុមហ៊ុនហៃនិញកម្ពុជា (Cambodia Haining Company) | ២១.២៥០ | ខេត្តកំពង់ស្ពឺ | ២៣ កក្កដា ១៩៩៨ | ២៣ កក្កដា ២០៦៨ | ដំឡូងមី ដូងប្រេង ចិញ្ចឹមសត្វ និង បង្កាត់ពូជសត្វ |

[៦២] ផែនទី ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០២ ចុះហត្ថលេខាដោយអភិបាលខេត្តកំពង់ស្ពឺ និង លោកឧត្តមសេនីត្រី ជុំ ចុង ហេង។

| | | | | | |
|---|---|---|---|---|---|
| ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ (Flour Manuafacturing Co.Ltd.) | ៧.៤០០ | ខេត្តស្ទឹងត្រែង | ១៣ កញ្ញា ១៩៩៩ | ១៣ កញ្ញា ២០៦៩ | ដើមម៉ៃសាក់ |
| ក្រុមហ៊ុនភាពីម៉ិច ចំកាត់ (Pheapimex Co. Ltd) | ១៣៨.៩៦៣ | ខេត្តពោធិសាត់ | ៨ មករា ២០០០ | ២០៧០ | ដើមប្រេងខ្យល់ |
| ក្រុមហ៊ុនភាពីម៉ិច ចំកាត់ (Pheapimex Co. Ltd) | ១៧៦.០៦៥ | ខេត្តកំពង់ឆ្នាំង | ៨ មករា ២០០០ | ២០៧០ | ដើមប្រេងខ្យល់ |
| ក្រុមហ៊ុនខាំបូវិចទ័រវិនិយោគ និង អភិវឌ្ឍន៍ ចំកាត់[៦៣] (Cambo Victor Investing and Developing Co. Ltd) | ៥.០០០ | ខេត្តកំពង់ស្ពឺ | ១៣ សីហា ២០០១ | ១៣ សីហា ២០៧១ | ស្រូវ ពោត ដំឡូងមី សណ្តែកដី និង សណ្តែកសៀង |
| ក្រុមហ៊ុនគ្រីនស៊ី អ៊ីនដាស្ទ្រី ចំកាត់ (ម៉ុង ឫទ្ធី គ្រុប) (Green Sea Industry Co. Ltd. (Mong Reththy Group) | ១០០.៨៥២ | ខេត្តស្ទឹងត្រែង | ២៣ វិច្ឆិកា ២០០១ | ២៣ វិច្ឆិកា ២០៧១ | ដើមម៉ៃសាក់ |
| ក្រុមហ៊ុនស៊ីជេ កម្ពុជា ចំកាត់[៦៤] (CJ Cambodia Co.Ltd) | ៥.០០០ | ខេត្តកំពង់ស្ពឺ | ២០ មេសា ២០០១ | ២០ មេសា ២០៧១ | ដំឡូងមី |
| ក្រុមហ៊ុនអភិវឌ្ឍន៍ឧស្សាហ-កម្ម អ៊ុក ឃុន ចំកាត់ (Development Industrial Ouk Khun Co. Ltd) (ADUOK) | ១២.៥០៦ | ខេត្តកំពង់ស្ពឺ | ២៥ ឧសភា ២០០១ (កិច្ចសន្យាលើកទី១: មេសា ១៩៩២) | ២៥ ឧសភា ២០៧១ | ដើមស្វាយចន្ទី |
| ក្រុមហ៊ុនហេណាន់ តំបន់ អភិវឌ្ឍន៍ សេដ្ឋកិច្ច និង ពាណិជ្ជកម្ម (Henan Economic and Trade Development Zone) | ៤.១០០ | ខេត្តកំពង់ស្ពឺ | ២៩ កក្កដា ១៩៩៩ | ២៩ កក្កដា ២០៦៨ | ដំឡូងមី ដូងប្រេង ចិញ្ចឹមសត្វ និង បង្កាត់ពូជសត្វ |
| ក្រុមហ៊ុនគ្រីនរិច ចំកាត់ (Green Rich Co. Ltd) | ៦០.២០០ បាន បន្ថយមកនៅ ត្រឹម ១៨.៣០០ | ខេត្តកោះកុង | ២៥ វិច្ឆិកា ១៩៩៨ | ២៥ វិច្ឆិកា ២០៦៨ | ដូងប្រេង និង អាកាស្យា |

[៦៣] កិច្ចសន្យាសម្បទាននេះ បានបាត់ទំព័រទី១។

[៦៤] ក្រុមហ៊ុនស៊ីជេ កម្ពុជា មានដីសម្បទានមួយកន្លែងទៀត ដែលមានផ្ទៃដីទំហំ ៣.០០០ ហិកតា ប៉ុន្តែយើងមិនអាចទាក់ទងរកកិច្ចសន្យារបស់ក្រុមហ៊ុននេះបានទេ។

| | | | | | |
|---|---|---|---|---|---|
| ក្រុមហ៊ុនគីមស្វីល (Kimsville Company) | ៣.២០០ | ខេត្តកំពង់ស្ពឺ | ២៤ តុលា ២០០០ | ២៤ តុលា ២០៧០ | ដំឡូងមី |
| ក្រុមហ៊ុនហ្គោលដេន លេន អភិវឌ្ឍន៍ ចំកាត់ (Golden Land Development Co. Ltd) | ២.១០០ បាន កើនឡើងដល់ ៤.៩០០ | ខេត្តកំពង់ស្ពឺ | ០៥ មីនា ២០០៤ | ០៥ មីនា ២០៧៤ | អាកាស្យា និង ដើមប្រេងខ្យល់ |
| ក្រុមហ៊ុនវិនិយោគអាក្រូស្តា (Agro Star Investmen) | ២.៤០០ | ខេត្តកំពង់ចាម | មករា ១៩៩៥ | មករា ២០៦៥ | ដើមស្វាយចន្ទី និង ចិញ្ចឹមសត្វ |
| ក្រុមហ៊ុនអភិវឌ្ឍន៍កសិកម្ម អន្តរជាតិកាមឈី (Camchi International Agriculture) | ២៦.៥០០ | ខេត្តកំពង់ធំ | ០៣ មីនា ២០០០ | ០៣ មីនា ២០៧០ | ដំឡូងមី ពោត ដំណាំឈើ ហូបផ្លែ និង ចិញ្ចឹមសត្វ |
| ក្រុមហ៊ុនលាងហួរហុង នីអារណ៏ អារបាណ៏ និងអភិវឌ្ឍន៍ កសិឧស្សា-ហកម្ម និង ចំរាញ់ស្ករ (Leang Hour Hong Import- Export and Agro-industrial Development and Refinery) | ៨.០០០ | ខេត្តបាត់ដំបង | ០៧ មិថុនា ២០០០ | ០៧ មិថុនា ២០៧០ | ដើមអំពៅ និង ដំឡូងមី |

ដោយការិយាល័យទទួលបានអត្ថបទចម្លងនៃកិច្ចសន្យាសម្បទានតែចំនួន១៥ នោះ ដូច្នេះការធ្វើវិភាគអំពីការអនុវត្តកិច្ចសន្យាទាំងនោះមិនបានទូលំទូលាយទេ ។ ប៉ុន្តែដោយកិច្ចសន្យាមានលក្ខណៈខុសប្លែកគ្នាតិចតួច អំពីចរិតលក្ខណៈជាគន្លឹះ របស់វាទៅតាមចំការធំ ឬ តូច និង អំពីប្រភេទដំណាំកសិកម្ម កិច្ចសន្យាទាំងនោះត្រូវបានគេរំពឹងថាជាប្រភេទកិច្ចសន្យាដែលបានអនុវត្តហើយ ។ ជាទូទៅលក្ខខណ្ឌ នៃកិច្ចសន្យាផ្តល់ផលប្រយោជន៍ច្រើនដល់សម្បទានិក ហើយពិតណាស់ កិច្ចសន្យាទាំងនេះត្រូវបានអនុវត្តតាមរបៀបបែបនេះ ។[៦៥] ក្នុងចំណោមកិច្ចសន្យាទាំងអស់ មានកិច្ចសន្យាពីរ គឺ កិច្ចសន្យារបស់ក្រុមហ៊ុនគ្រីនស៊ី និង ក្រុមហ៊ុនហ្គោលដេន លេន ត្រូវបានចុះហត្ថលេខានៅមុនការអនុម័តច្បាប់ភូមិបាល ឆ្នាំ២០០១ ហើយកិច្ចសន្យាទាំងនេះមានរយៈពេលកំណត់ ៧០ ឆ្នាំ តាមច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ ។

[៦៥] អង្គការបណ្តុះបណ្តាល និង ស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ឯកសារពិភាក្សាលេខ២៣ ទំព័រទី៨២ សំរាប់ផ្តល់អនុសាសន៍ដល់កិច្ចសន្យាសម្បទានសេដ្ឋកិច្ច ។ កិច្ចសន្យាទាំងនេះប្រហែលជា មិនផ្តល់ផលប្រយោជន៍ច្រើនដូចជាកិច្ចសន្យាព្រៃសម្បទានមួយចំនួននោះទេ គេអាចនិយាយបានថា ផ្តល់ផលប្រយោជន៍ខ្លាំងទៅឱ្យសម្បទានិក " នេះបានចោទជាបញ្ហាថាតើគេអាចចាត់ទុកថា ដើម្បីមូលហេតុពាណិជ្ជម្មដែរឬទេ" ពណិស និង ករណើ ឆ្នាំ១៩៩៨ ។

*ការចុះកិច្ចសន្យា*

រាល់សម្បទានដីគោលដៅសេដ្ឋកិច្ចទាំងអស់ ក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ននេះ ត្រូវបានផ្តល់ដោយមិនមាននីតិវិធីណាមួយច្បាស់លាស់ទេ។ សម្បទានដីទាំងនោះត្រូវបានផ្តល់តាមសំណើរបស់ក្រុមហ៊ុនឯកជន ជាជាងតាមការកំណត់ពីអាជ្ញាធរជាមុន ថាជាដីសមស្របសំរាប់ធ្វើអាជីវកម្មកសិកម្ម និង ពាណិជ្ជកម្ម ហើយបន្ទាប់មកទើបស្វែងរកអ្នកវិនិយោគទុន។ កាលពីខែកុម្ភៈ ឆ្នាំ២០០៤ មានឧទាហរណ៍ថ្មីមួយ ពាក់ព័ន្ធនឹងសំណើរបស់ក្រុមហ៊ុនវិនិយោគ និង អភិវឌ្ឍន៍ដូងប្រេងម៉ាឡេស៊ី (កម្ពុជា) ចំកាត់ (the Cambodia Malaysia Palm Oil Investment and Development Co. Ltd), ក្រុមហ៊ុនម៉ុង ឫទ្ធី គ្រុប (Mong Riththy Group Company) ដែលបានដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីក្នុងសមត្ថកិច្ចលោកជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមហ៊ុនបានស្នើសុំជំនួយពីលោកនាយករដ្ឋមន្ត្រី ដើម្បីជួយសម្រួលដល់ការផ្តល់សម្បទានសេដ្ឋកិច្ចដែលមានផ្ទៃដីច្រើនជាង ៨.២៣៥ ហិកតា ស្ថិតនៅក្នុងស្រុកកំពង់សិលា ក្នុងខេត្តកោះកុង សំរាប់ធ្វើវិនិយោគចំការដូងប្រេង រោងចក្រចំរាញ់ដូងប្រេង។ ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR/Cambodia) បានសំដែងនូវការព្រួយបារម្ភជំរាបប្រាប់សម្តេចនាយករដ្ឋមន្ត្រី នៅក្នុងលិខិតមួយចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៤ ក្នុងនោះមានការមិនបានពិគ្រោះយោបល់ឱ្យបានល្អិតល្អន់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និងការព្រួយបារម្ភ ថាសម្បទានដែលបានស្នើសុំនោះទំនងជា ការពង្រីកសម្បទានគោលដៅសេដ្ឋកិច្ចពីរ ដែលកន្លងមកបានផ្តល់ឱ្យក្រុមហ៊ុនម៉ុង ឫទ្ធី គ្រុប សំរាប់ដាំដូងប្រេង និង ដំឡូងមី ដែលមានផ្ទៃដី ១២.៨០០ ហិកតា។ ដូច្នេះ សម្បទានដែលបានស្នើសុំនឹងកើនឡើងដល់ជាង ២០.០០០ ហិកតា គឺមានចំនួនទ្វេរដងនៃផ្ទៃដីដែលបានកំណត់ក្នុងច្បាប់ភូមិបាល។ អាជ្ញាធរមូលដ្ឋានមានការស្ទាក់ស្ទើរចំពោះផែនការនេះ ហើយមេឃុំម្នាក់បានស្នើថា បើសិនជាមានការចុះកិច្ចសន្យាសម្បទានណាមួយ គាត់សុំឱ្យដកយកដីតែ២០០០ ហិកតា តែប៉ុណ្ណោះពីឃុំរបស់គាត់។

*ការអនុវត្តន៍ច្បាប់ភូមិបាល និង កិច្ចសន្យា*

ដីសម្បទានគោលដៅសេដ្ឋកិច្ច ត្រូវអនុវត្តស្របតាមច្បាប់ភូមិបាល និង លក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាសម្បទាន ហើយសម្បទាននោះអាចដកហូតវិញបាន។ មាត្រា១៨ នៃច្បាប់ភូមិបាលចែងថា រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី៥ ត្រូវទុកជាមោឃៈ និង គ្មានសុពលភាពអនុវត្ត។

កិច្ចសន្យាសម្បទានមិនបានតម្រូវឱ្យបង់ប្រាក់ឈ្នួលប្រចាំឆ្នាំទៅឱ្យរាជរដ្ឋាភិបាលទេ រហូតដល់ច្បាប់គ្រប់គ្រងប្រាក់ឈ្នួលត្រូវបានបង្កើតឡើង។[៦៦] នេះមានន័យថាសម្បទានត្រូវបានផ្តល់រួចហើយៗ មិនមានបង់ប្រាក់ឈ្នួល

[៦៦] ឧទាហរណ៍ៈ ក្រុមហ៊ុនគ្រីន ស៊ី អ៊ីនដាស្ទ្រី ចំកាត់ ខចែងចំណុច ៤.៥ : " ក្រុមហ៊ុនត្រូវបង់ប្រាក់ឈ្នួលប្រចាំឆ្នាំ ស្របទៅតាមអាត្រាជួលដីសម្បទានដែលបានកំណត់នៅក្នុងសេចក្តីជូនដំណឹងលេខ៨០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ និងការកំណត់អំពីប្រាក់ឈ្នួល (sic) ដោយរាជរដ្ឋាភិបាល។ ប្រាក់ឈ្នួលត្រូវបង់ ក្នុងខែមករា

ដែលជាការរំលោភទៅនឹងមាត្រា៥១ នៃច្បាប់ភូមិបាល ដែលចែងថាដីសម្បទានមិនអាចផ្តល់ដោយ ឥតគិតថ្លៃបានទេ។ កិច្ចសន្យាខ្លះចែងផាកពិន័យចំពោះការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួល ការរឹបអូសយកប្រាក់កក់ និង ការធ្វើមោឃៈភាពកិច្ចព្រមព្រៀងដោយមិនមានការទូទាត់សងដល់ក្រុមហ៊ុនពាក់ព័ន្ធ ប៉ុន្តែបញ្ញត្តិទាំងនេះមិនមានប្រយោជន៍ទេ ប្រសិនបើគ្មានច្បាប់ណាមួយចែងច្បាស់លាស់ទេនោះ។[៦៧]

ប្រាក់កក់ដែលបានតម្រូវនៅក្នុងកិច្ចសន្យាភាគច្រើន គឺមួយដុល្លារក្នុងមួយហិកតា ដែលត្រូវបង់នៅក្នុងអំឡុងពេលបី (៣) ខែ ចាប់ពីថ្ងៃចុះហត្ថលេខា។ កិច្ចសន្យាចែងពីការទូទាត់សងវិញ នៅពេលដែលសម្បទានិកបានដាំដំណាំពេញលើផ្ទៃដីនោះរួចហើយ ស្របតាមផែនការប្រើប្រាស់ដីធ្លីដែលមានចែងនៅក្នុងកិច្ចសន្យាសម្បទាន។ កិច្ចសន្យាខ្លះមានចែងអំពីប្រាក់កក់សរុប។ ឧទាហរណ៍ កិច្ចសន្យារបស់ក្រុមហ៊ុនភាពីម៉ិច នៅក្នុងខេត្តពោធិសាត់ ចែងថាក្រុមហ៊ុនត្រូវបង់ ២០.០០០ ដុល្លារ សំរាប់ផ្ទៃដីសរុប ១៣៨.៩៦៣ ហិកតា ការដែលក្រុមហ៊ុននេះបង់តែ ០.១៤ ដុល្លា ក្នុងមួយហិកតា គឺស្មើនឹង ៧ ដង តិចជាងកិច្ចសន្យាសម្បទានដទៃទៀត។ ទឹកប្រាក់កក់ដែលតម្រូវឱ្យដាក់ធានាមានចំនួនតិចបំផុត ការដែលក្រុមហ៊ុនទាំងនោះនៅតែអាចបន្តដំណើរការធ្វើអាជីវកម្មរបស់ខ្លួនបាន គឺជាការគួរឱ្យមន្ទិលសង្ស័យយ៉ាងខ្លាំងចំពោះរាជរដ្ឋាភិបាល។ ក្រុមហ៊ុនចំនួន១៦ ដែលបានអនុវត្តកិច្ចសន្យាសម្បទានរួចហើយ នៅមិនទាន់បានបង់ប្រាក់កក់នៅឡើយ  បញ្ហាដែលគួរឱ្យព្រួយបារម្ភបំផុតនោះគឺការដាំដុះបានចាប់ផ្តើមធ្វើហើយ ដូចជាករណីសម្បទានរបស់ក្រុមហ៊ុនអាក្រូស្តា (Agrostar) និង ចំការម៉ុង ឫទ្ធីទាំងពីរកន្លែងនៅក្រុងព្រះសីហនុ។

មាត្រា៦២ នៃច្បាប់ភូមិបាលចែងថា រាល់សម្បទានគោលដៅសេដ្ឋកិច្ចត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល១២ (ដប់ពីរ) ខែ បន្ទាប់ពីការផ្តល់សម្បទាន បើពុំដូច្នោះទេ " នឹងត្រូវទុកជាមោឃៈ" ។[៦៨] មាត្រា៦២ ក៏បានចែងដែរថាសម្បទានិកគ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើង។ មានតែក្រុមហ៊ុន១០ (ដប់) ប៉ុណ្ណោះ នៅ

---

នៃឆ្នាំទីមួយ៧ ហើយមិនត្រូវឱ្យហួសថ្ងៃទី៣១ ខែមករាឡើយ "ក្រុមហ៊ុនគីម ស្វីល ខចែងចំណុច៤.២ មានបញ្ញត្តិមួយស្រដៀងគ្នានឹងបញ្ញត្តិរបស់ក្រុមហ៊ុនគ្រីន ស៊ី ដែរ, ក្រុមហ៊ុនហេណាន់ ខចែងចំណុច ៤.២  : ភាគី ខ ត្រូវបង់ប្រាក់ឈ្នួលសម្បទានប្រចាំឆ្នាំ គិតជាដុល្លារសហរដ្ឋអាមេរិក/ក្នុងមួយហិកតា..... អាត្រាប្រាក់ត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល។ ប្រាក់ឈ្នួលត្រូវបង់នៅក្នុងខែមករា ហើយកាលបរិច្ឆេទបង់ប្រាក់ចុងក្រោយគឺនៅថ្ងៃទី ៣១ ខែមករា នៃឆ្នាំទីមួយ៧ " ក្រុមហ៊ុនកម្ពុជាហៃនិញគ្រុម ចំកាត់ " អត្រាប្រាក់ឈ្នួល និងពេលវេលាសំរាប់បង់ប្រាក់ត្រូវបានកំណត់ និងអនុម័តដោយរដ្ឋាភិបាល។ ការបង់ប្រាក់មិនត្រូវឱ្យហួសថ្ងៃទី៣១ ខែមករា នៃឆ្នាំទីមួយ៧ទេ " ក្រុមហ៊ុនភាពីម៉ិច : " កិច្ចព្រមព្រៀងមិនបានកំណត់នូវអាត្រាប្រាក់ឈ្នួលប្រចាំឆ្នាំទេ ពីព្រោះអាត្រាប្រាក់ឈ្នួលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ទើបបច្ចុប្បន្នរាជរដ្ឋាភិបាលមិនបានរក្សាសិទ្ធិ ដើម្បីប្រមូលថ្លៃឈ្នួលប្រចាំឆ្នាំពីដីសម្បទាននេះទេ។ ប្រសិនបើមានច្បាប់នេះនៅថ្ងៃអនាគត កិច្ច-ព្រមព្រៀងនេះត្រូវតែស្របតាមច្បាប់ និងសេចក្តីសំរេចនានារបស់រាជរដ្ឋាភិបាលដែលបានអនុម័ត ហើយកិច្ចព្រមព្រៀងត្រូវតែបានចុះហត្ថលេខាជាថ្មី សំរាប់ប្រាក់ឈ្នួលដែលបានកំណត់លើកក្រោយនេះ" ។

[៦៧] ឧទាហរណ៍ : ខចែងចំណុច៤.៤ ក្នុងកិច្ចសន្យាក្រុមហ៊ុនហេណាន់ និង ខចែងចំណុច ៤.៤ នៃក្រុមហ៊ុនគីមស្វីល។

[៦៨] បញ្ញត្តិច្បាប់ហាក់ដូចជាមិនតម្រូវឱ្យអាជ្ញាធរធ្វើសកម្មភាពជាវិជ្ជមានណាមួយ ចំពោះសម្បទានដែលបានផ្តល់បន្ទាប់ពីការអនុម័តច្បាប់ភូមិបាល។ រាល់សម្បទានដីទាំងអស់ ដែលបានផ្តល់មុនច្បាប់ភូមិបាលចូលជាធរមាន ហើយដែលចែងថា " ការមិនបានធ្វើអាជីវកម្មរយៈពេល១២ ខែ គឺជាមូលហេតុនៃការធ្វើមោឃភាព " ក៏ដូចជាការខកខានធ្វើអាជីវកម្មរយៈពេលលើសពី១២ (ដប់ពីរ) ខែ " ពុំមានមូលហេតុត្រឹមត្រូវ " ផងដែរ។

ក្នុងបញ្ជី ដែលបានផ្តល់ដោយក្រសួងកសិកម្ម ដែលបានចាប់ផ្តើមសកម្មភាពដាំដុះដំណាំ ដែលស្មើនឹងចំនួនតិចជាងបីភាគរយ (3%) នៃផ្ទៃដីសម្បទានសរុប ។[៦៩] តាមការស្រាវជ្រាវដល់ទីកន្លែងបានបង្ហាញឱ្យឃើញថា មានករណីខ្លះក្រុមហ៊ុនបានដាំដំណាំប្រភេទផ្សេងពីដំណាំដែលបានកំណត់នៅក្នុងកិច្ចសន្យាសម្បទានរបស់ខ្លួន ។ ឧទាហរណ៍ ក្រុមហ៊ុនហៃនិញ (Haining Company) បានចុះកិច្ចសន្យាសម្បទានមួយ ក្នុងឆ្នាំ ១៩៩៨ លើផ្ទៃដី ២១.២៥០ ហិកតា ក្នុងខេត្តកំពង់ស្ពឺ ដើម្បីដាំដើមដំឡូងមី អាកាស្យា ដូងប្រេង និង ចិញ្ចឹមសត្វ ។ នៅក្នុងឆ្នាំ ២០០២ ក្រុមហ៊ុននេះបានកាប់ ឆ្ការដីចំនួន ៣ (បី) ហិកតា ដើម្បីដាំដើមល្ហុងខ្វង សណ្តែក និង បន្លែបង្ការគ្រប់មុខ ។ ក្រុមហ៊ុនផលិតម្សៅដំឡូងមីនៅក្នុងខេត្តស្ទឹងត្រែង បានចាប់ផ្តើមដាំដុះដើមម៉ៃសាក់ហើយ ប៉ុន្តែដោយខ្វះការថែទាំឱ្យបានត្រឹមត្រូវ ទើបបណ្តាលឱ្យកូនម៉ៃសាក់ងាប់អស់ជាច្រើនដើម ។

រាល់កិច្ចសន្យាតម្រូវឱ្យសម្បទានិកបង់ពន្ធតាមច្បាប់កំណត់ ប៉ុន្តែមិនមានតួលេខផ្លូវការណាមួយបញ្ជាក់ថាក្រុមហ៊ុនទាំងអស់នោះបានបង់ពន្ធសម្បទាន ឬ ចំណូលដែលបានមកពីដីសម្បទាននោះទេ ។ ដូចជាករណីនៃក្រុមហ៊ុនហៃនិញ មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន នាយកដ្ឋានរុក្ខាប្រម៉ាញ់ និង មន្ត្រីត្រួតពិនិត្យព្រៃឈើឯករាជ្យអង្គការ Global Witness បានទៅទស្សនាដីសម្បទាន កាលពីឆ្នាំ២០០២ ហើយបានឃើញថាក្រុមហ៊ុននេះ កំពុងកាប់រំលំ និង ប្រមូលឈើហ៊ុបដែលបានជ្រើសសម្រាំងនៅក្នុងព្រៃជិតនោះ ។ ឈើហ៊ុបដែលទើបកាប់រួចថ្មីៗ ចំនួនប្រាំពាន់ (៥.០០០) ដើម ដែលគ្មានស្លាកសញ្ញារ បង្ហាញថាឈើហ៊ុបទាំងនោះមិនទាន់បានបង់ពន្ធជូនរដ្ឋនៅឡើយទេ ។ ក្រុមហ៊ុនហៃនិញត្រូបត្រូវបានគេចោទប្រកាន់ថាលួចកាប់ឈើ និងគេចពន្ធ ហើយត្រូវបានបញ្ជាឱ្យបញ្ឈប់រាល់សកម្មភាពទាំងនោះជាបន្ទាន់ ហើយត្រូវបង់ពន្ធដែលមិនទាន់បង់ទៅឱ្យរាជរដ្ឋាភិបាល តាមការបញ្ជាឱ្យបង់នូវទឹកប្រាក់ចំនួន ៤៧០.០០០ ដុល្លារអាមេរិក ។[៧០] ក្នុងខែកញ្ញា ឆ្នាំ២០០២ គណៈរដ្ឋមន្ត្រីមិនបានធ្វើមោឃៈភាពកិច្ចសន្យាសម្បទាននោះទេ ផ្ទុយទៅវិញបានយល់ស្របចំពោះអនុសាសន៍របស់ក្រសួងកសិកម្មដែលថា គួរតែធ្វើការប្រមាន ដល់ក្រុមហ៊ុនហៃនិញជាមុនសិន ។ របាយការណ៍បង្ហាញថាក្រុមហ៊ុនមិនបានគោរពតាមសេចក្តីតម្រូវនៅឡើយទេ ។[៧១] កិច្ចសន្យាសម្បទាននោះមិនទាន់បានធ្វើមោឃៈភាពនៅឡើយទេ ។

---

[៦៩] ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ឯកសារយោងលេខ : ៨៤៩ /២៣២ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ ។

[៧០] អង្គការ Lutheran World Federation , *របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ ២០០២* ផ្នែកដែលមានចំណងជើងថា " ការតស៊ូមតិ - ករណីនៃសិទ្ធិដីធ្លី " http://www.lwfcam.org.kh .

[៧១] សារាចរលេខ១៤០៩ សចនសរ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ រំលឹកក្រុមហ៊ុនកម្ពុជាហៃនិញ គ្រុប ថាក្រុមហ៊ុននេះត្រូវតែធ្វើសំណើរដើម្បីបង្កើតរោងម៉ាស៊ីនអារឈើ និងរោងចក្រកែច្នៃឈើ ដោយគោរពតាមនីតិវិធីដែលបានតម្រូវឱ្យក្រុមហ៊ុនបង់ពន្ធឈើ និងប្រាក់ឈ្នួលដាំឈើឡើងវិញចំពោះឈើហ៊ុបដែលមានបរិមាណ ៦.៩៧៦ ដើម ស្មើនឹង ៣.៨៤៣.៩១១ ម៉ែត្រគុប តម្រូវឱ្យក្រុមហ៊ុនកំណត់ព្រំដីសម្បទាន ហើយដាក់ស្នើរបាយការណ៍លំអិតស្តីពីការអភិវឌ្ឍន៍ដើមល្ហុងខ្វង ។ ប្រសិនបើក្រុមហ៊ុននេះ មិនព្រមអនុវត្តតាមសេចក្តីតម្រូវខាងលើ ឬ ប្រព្រឹត្តកំហុសជាលើកទីពីរ កិច្ចព្រមព្រៀងនឹងត្រូវបានមោឃភាព ដើម្បីជាមេរៀនសំរាប់ក្រុមហ៊ុនដទៃទៀត ។

ទោះបីជាមាត្រា៦២ នៃច្បាប់ភូមិបាលចែងថា សម្បទានត្រូវបានដកហូតវិញតាមរយៈសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ក្នុងករណីដែលសម្បទានិកមិនបានបំពេញតាមសេចក្តីតម្រូវរបស់ច្បាប់ ។ បើតាមព័ត៌មានដែលការិយាល័យទទួលបានថា បទបញ្ញត្តិច្បាប់ភូមិបាលមិនត្រូវបានគេយកមកអនុវត្តឡើយ ។ ហើយក៏មិនមានកិច្ចសន្យាសម្បទានដែលបានចុះហត្ថលេខាហើយត្រូវបានធ្វើមោឃៈភាពដែរ ទោះជាមានការប្រព្រឹត្តល្មើសច្បាប់ធ្ងន់ធ្ងរក្តី ។ ជាការសំខាន់ខ្លាំងណាស់ ដែលត្រូវតែធ្វើមោឃៈភាពកិច្ចសន្យាសម្បទានទាំងឡាយណាដែលរំលោភច្បាប់ មុននឹងធ្វើការកាត់បន្ថយទំហំសម្បទានគោលដៅសេដ្ឋកិច្ចមកនៅត្រឹម ១០.០០០ ហិកតា តាមច្បាប់កំណត់ ហើយសម្បទានិកទាំងអស់ត្រូវតែគោរពតាមច្បាប់ភូមិបាល និង កិច្ចសន្យាសម្បទានរបស់ខ្លួន ហើយត្រូវពិភាក្សាផ្តល់ព័ត៌មានអំពីសំណងការខូចខាត ក្នុងករណីធ្វើការបែងចែកដីសំរាប់គោលដៅសង្គមកិច្ច ។

## ការការពារបរិស្ថាន និង ផលប៉ះពាល់សង្គម

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ បានតម្រូវឱ្យធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថានសំរាប់រាល់គំរោង ឬ សកម្មភាពឯកជន ឬ សាធារណៈទាំងអស់ ហើយតម្រូវឱ្យធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថានមុន និងក្រោយ រួមទាំងសំរាប់គំរោង និង សកម្មភាពទាំងឡាយណាដែលមិនទាន់បានវាយតំលៃនៅឡើយ ។ រាល់ការវាយតំលៃទាំងអស់ ស្ថិតក្រោមការពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន និង នាយកដ្ឋានវាយតំលៃពីផលប៉ះពាល់បរិស្ថានជាមុនសិន មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។ អនុក្រឹត្យស្តីពីការវាយតំលៃផលប៉ះពាល់បរិស្ថានឆ្នាំ១៩៩៩ ចែងកំណត់អំពីជំហ៊ានដែលត្រូវអនុវត្ត ដើម្បីធ្វើការវាយតំលៃគំរោងនានាដែលមានស្រាប់ និង ដែលបានស្នើរួចហើយ ។

ការវាយតំលៃពីផលប៉ះពាល់បរិស្ថាន មិនត្រូវបានគេធ្វើនៅក្នុងពេលសិក្សាស្រាវជ្រាវពីសម្បទាននោះទេ ។ កិច្ចដំណើរការវាយតម្លៃមួយ ដែលស្ថិតក្រោមការពិនិត្យពិច័យជាសាធារណៈ បានធ្វើឡើងនៅក្នុងឆ្នាំ២០០២ នៅពេលដែលសម្បទានិកព្រៃ បានដាក់ស្នើរបាយការណ៍វាយតម្លៃរបស់ខ្លួន ដើម្បីសុំការអនុម័តយល់ព្រម ។ កិច្ចការនេះបានលាតត្រដាងអំពីចំណុចខ្វះខាតជាច្រើន រួមទាំងការមិនបានពិនិត្យផ្ទៀងផ្ទាត់ដោយផ្ទាល់នៅនឹងកន្លែងផងដែរ ។

កាលពីខែឧសភា ឆ្នាំ២០០៤ ក្រសួងបានសំរេចផ្អាកសកម្មភាពរបស់ក្រុមហ៊ុនគ្រីនរិច នៅក្នុងខេត្តកោះកុង ដោយរង់ចាំការវាយតំលៃពីផលប៉ះពាល់បរិស្ថានចប់សព្វគ្រប់សិន ។[៧២] ក្រុមហ៊ុនគ្រីនរិច ត្រូវបានគេរកឃើញថាបានកាប់រំលំព្រៃឈើជាច្រើន សាងសង់ផ្លូវ និង អាគារដោយគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ ។ មន្ត្រីក្រសួង

[៧២] លិខិតលេខ១១៩ សចទបស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៤ ចុះហត្ថលេខាដោយបណ្ឌិត ម៉ុក ម៉ារ៉េត ។

បរិស្ថានអមដំណើរដោយលោក ជៀម ហ៊ុម អភិបាលរងខេត្តកោះកុង បានទៅទស្សនាដល់ទីកន្លែង កាលពីថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០០៤ ហើយបានជួបជាមួយតំណាងក្រុមហ៊ុនគ្រីនរិចគ្រុប ។ នៅក្នុងពេលជួបប្រជុំនេះ ប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងនេះ បានគូសបញ្ជាក់ថាក្រុមហ៊ុនត្រូវតែធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថានឱ្យបានចប់សព្វគ្រប់នៅចុងខែតុលា ឆ្នាំ២០០៤ បើពុំដូច្នោះទេ អ្វីៗគ្រប់យ៉ាងនឹងត្រូវបញ្ចប់ ។[៧៣]

ការវាយតំលៃពីផលប៉ះពាល់សង្គមមិនបានតម្រូវឱ្យធ្វើសំរាប់សម្បទានគោលដៅសេដ្ឋកិច្ចទេ ។ ការតម្រូវឱ្យសម្បទានព្រៃធ្វើការវាយតំលៃពីផលប៉ះពាល់សង្គម ត្រូវបានកំណត់តាមរយៈអនុក្រឹត្យ និង ច្បាប់នីមួយៗ ក្នុងឆ្នាំ ២០០០ និង ឆ្នាំ២០០២ ។ ការស្វែងរករបាយការណ៍វាយតំលៃពីផលប៉ះពាល់សង្គម គឺមានការលំបាក ទោះជាយ៉ាងណាក៏ដោយ មិនមានសម្បទានព្រៃណាមួយត្រូវបានធ្វើមោឃៈភាព ដោយ សារតែការវាយតំលៃដែលអវិជ្ជមាននោះទេ ។ ប្រសិនបើការវាយតំលៃពីផលប៉ះពាល់សង្គម តម្រូវឱ្យសម្បទានគោលដៅសេដ្ឋកិច្ចគួរតែធ្វើនោះស្ថាប័នជំនាញ ខាងអន្តរវិន័យមួយ ដើម្បីវាយតំលៃថាតើរបាយការណ៍ទាំងនោះអាចទទួលយកបាន ឬទេ ហើយដើម្បីធានាថាក្រុមហ៊ុនអនុវត្តវិធានការបន្ថយផលប៉ះពាល់អវិជ្ជមាន ។ ពិតណាស់ នេះគឺជាសេចក្តីព្រួយបារម្ភមួយ មិនត្រឹមតែ ចំពោះសម្បទានគោលដៅសេដ្ឋកិច្ចប៉ុណ្ណោះទេ តែថែមទាំងចំពោះការអភិវឌ្ឍន៍គំរោងដែលប៉ះពាលដល់ប្រជាពលរដ្ឋច្រើន ។

## សម្បទាន : សំរាប់គោលបំណងអ្វី?

រហូតដល់អនុក្រឹត្យមួយត្រូវបានអនុម័ត សម្បទានគោលដៅសេដ្ឋកិច្ចទាំងអស់ មិនស្ថិតនៅក្រោមសេចក្តីតម្រូវការនៃការគ្រប់គ្រងដូចគ្នានឹងសម្បទានព្រៃឈើនោះទេ ។ មាត្រា៤៩ នៃច្បាប់ភូមិបាលចែងពីការផ្តល់សិទ្ធិឱ្យសម្បទានិកកាប់ឆ្ការព្រៃឈើលើដីសម្បទាន ដោយតម្រូវឱ្យបង់ប្រាក់ថ្លៃឈើដែលបានកាប់រួច ស្របតាមមាត្រា៥២ នៃច្បាប់ព្រៃឈើ ។ ដោយសារដីកសិកម្មសំរាប់ដំណាំភាគច្រើនមានតម្លៃខ្ពស់ ហើយដីសម្បទានតូចៗកំពុងស្ថិតក្នុងការដំាដុះដាក់ស្តែង ទំហំដីសម្បទានបានចោទជាបញ្ហាអំពីថាតើវាពិតជាផ្តល់នូវមធ្យោបាយ ដើម្បីគេចវេសពីការអនុវត្តន៍ដែលតឹងតែងជាងនេះ នៅក្នុងបទបញ្ញត្តិស្តីពីការគ្រប់គ្រងព្រៃឈើ ឬទេ ។[៧៤]

---

[៧៣] លិខិតលេខ៥0/0៤ បសនផ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៤ នៃស្ថានីយសួនឧទ្យានជាតិបុទុមសាគរ ផ្ញើរជូននាយកអង្គការជំនួយផ្នែកសត្វព្រៃ (Wild Aid) ។

[៧៤] របាយការណ៍បោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០០០ ពិពណ៌នាអំពីរច្នាសម្ព័ន្ធព្រៃសម្បទានថាជា " ប្រព័ន្ធមួយដែលខូចខាតទាំងស្រុង" ដែលហៅការកាប់ឈើខុសច្បាប់ ការអនុវត្តន៍ និង ទិន្នផលអចិរភាព ការយកចិត្តទុកដាក់តិចតួច ឬ មិនយកចិត្តទុកដាក់ទាល់តែសោះចំពោះសុខមាលភាព និង សិទ្ធិប្រើប្រាស់របស់ប្រជាពលរដ្ឋមូលដ្ឋានឡើយ ។ អ្នកនិពន្ធបានធ្វើនិទស្សន៍ថា ប្រសិនបើគ្មានការកែប្រែទេនោះ ព្រៃឈើអាជីវកម្មនៃប្រទេសកម្ពុជា នឹងត្រូវកាប់អស់នៅក្នុងឆ្នាំ២០០៥ ។ រដ្ឋាភិបាលបានឆ្លើយតបចំពោះរបាយការណ៍ និង កង្វល់របស់ប្រទេសអ្នកផ្តល់ជំនួយ ដោយបានអនុម័តរបៀបវារៈស្តីពីកំណែទម្រង់គោលនយោបាយព្រៃឈើរួមមានការរៀបចំរច្នាសម្ព័ន្ធប្រព័ន្ធសម្បទានឡើងវិញ ដោយដាក់បញ្ចូលនូវសេចក្តីតម្រូវផ្សេងៗ សំរាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយចិរភាព និង ការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និង សង្គម ។ របាយការណ៍ត្រួតពិនិត្យព្រៃសម្បទានក្នុងប្រទេសកម្ពុជា ដែលបានធ្វើឡើងនៅក្នុងឆ្នាំ១៩៩៨ - ១៩៩៩ ដោយលោកហ្វ្រាស័រថូម៉ាស់ (Fraser Thomas) GFA-AGRAR និង ANZDEC ។

ក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យមួយបានពិពណ៌នាពីការបង្វែរសម្បទានព្រៃ តាមរយៈសម្បទានគោលដៅសេដ្ឋកិច្ចដូចខាងក្រោមនេះ ៖

*" រឿងរ៉ាវជាច្រើនកើតចេញពីការបង្វែរដី គឺមានភាពស្មុគស្មាញ ហើយជារឿយៗបានផ្តោតការយកចិត្តទុកដាក់លើសិទ្ធិប្រើប្រាស់ដើមឈើមានតម្លៃ នៅលើដីដែលបានបង្វែរទាំងនោះ ។ ដីចំការកសិកម្មដែលមានរូបភាពជាអាជីវកម្មបានដើរតួនាទីដ៏សំខាន់នៅក្នុងការបង្វែរសម្បទានព្រៃ តាមរយៈសម្បទានគោលដៅសេដ្ឋកិច្ច ។ សម្បទានទាំងនេះត្រូវបានបែងចែកតាមរយៈ កិច្ចដំណើរការមួយដែលលាក់លៀម ។ ប្រជាពលរដ្ឋមូលដ្ឋានដែលបានប្តឹងទាមទារដីទាំងនោះ ពីមុនមក ( ទោះស្រប ឬមិនស្របច្បាប់ក្តី ) ត្រូវបានគេដកហូតសិទ្ធិហេតុនេះហើយទើបពួកគេ បានប្តឹងសាទុក្ខ ។ តាមការអនុវត្តន៍ជាក់ស្តែង មានភាគរយតិចតួចនៃផ្ទៃដីសរុបដែលបានបែងចែកទៅឱ្យសម្បទានិកត្រូវបានបញ្ជាក់ថាត្រឹមត្រូវ ឬ បានធ្វើការដាំដុះ ។ អត្ថប្រយោជន៍ភាគច្រើន ដែលសម្បទានិកទទួលបានកន្លងមក គឺបានពីការកាប់ឈើនៅលើដីសម្បទាននោះ " ។*[៧៥]

ការស្រាវជ្រាវសំរាប់ធ្វើរបាយការណ៍នេះ បានបរិយាយអំពីបញ្ហាទាំងនេះ ។ ការស្រាវជ្រាវដល់ទីកន្លែងក៏បានបញ្ជាក់ផងដែរថា ទីតាំងសំខាន់ៗនៃសម្បទានគោលដៅសេដ្ឋកិច្ច ត្រូវបានធ្វើការបែងចែកនៅលើដីដែលមានព្រៃឈើល្អ ហើយព្រៃនោះត្រូវបានគេធ្វើការកាប់ឆ្ការ ។ បញ្ហាទាំងនេះកើតមានលើដីសម្បទាននៅទីរីងក្រុមហ៊ុនភាពីម៉ិចនៅក្នុងខេត្តពោធិសាត់ ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ ក្រុមហ៊ុនគ្រីនរិច និងក្រុមហ៊ុនហៃនិញ ។ ការស្រាវជ្រាវដល់ទីកន្លែងក៏បានបញ្ជាក់ថាមានការកាប់ឈើខុសច្បាប់នៅក្រៅដែនដីសម្បទានដូចជាករណីរបស់ ក្រុមហ៊ុនហៃនិញជាដើម ។

ការបង្កើតឡើងនូវចំការកៅស៊ូក្នុងឃុំទីរីង គឺជាករណីនៃការបង្វែរសម្បទានព្រៃយ៉ាងច្បាស់ក្រឡែត ។ ព្រៃឈើទំហំ ៦.២០០ ហិកតា ត្រូវបានកាត់ចេញពីក្រុមហ៊ុនព្រៃសម្បទានចំនួន៣ (បី) ក្នុងខែសីហា ឆ្នាំ២០០១ ហើយត្រូវបានធ្វើចំណាត់ថ្នាក់ជាថ្មីដោយអនុក្រឹត្យថាជាផ្នែកមួយនៃ " ចំការកៅស៊ូនៃគ្រឹះស្ថានសាធារណៈរបស់រដ្ឋ " ដែលបានកាន់កាប់ដោយក្រុមហ៊ុនចំការកៅស៊ូជុប ។[៧៦] មានសម្បទានិក ៣ (បី) គឺសហគ្រាសកូឡិចស៊ីម ក្រុមហ៊ុនមៀង លី ហេង (Mieng Ly Heng) និង ក្រុមហ៊ុន GAT (Grand Atlantic Timber International) ត្រូវបានក្រុមហ៊ុនចំការកៅស៊ូជុបជួលបន្តឱ្យធ្វើការកាប់ឆ្ការព្រៃនៅក្នុងចំការកៅស៊ូ នៅមុនពេលធ្វើការឈូសឆាយដី

---

[៧៥] របាយការណ៍មេរបស់ក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យ មានចំណងជើងថា *វិស័យព្រៃឈើនៅក្នុងប្រទេសកម្ពុជា* ជំពូក៣.៦.៤។

[៧៦] អនុក្រឹត្យស្តីពីការដកហូតដីក្រហមពីក្រុមហ៊ុនព្រៃសម្បទាន សំរាប់ធ្វើចំការកៅស៊ូ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១។

នោះ។ ដោយហេតុថាដីនោះ លែងជាផ្នែកមួយនៃព្រៃសម្បទានតទៅទៀតហើយ ទើបសេចក្តីប្រកាសស្តីពីការផ្អាកជាបណ្តោះអាសន្នរាល់ការកាប់ឈើក្នុងព្រៃសម្បទាន ដែលចូលជាធរមានកាលពីខែមករា ឆ្នាំ២០០២ កន្លងមកនេះមិនត្រូវបានយកមកអនុវត្តចំពោះព្រៃសម្បទាននោះឡើយ។[៧៧]

ការដែលច្បាប់ស្តីពីព្រៃឈើមិនបានចែងពីភាពខុសគ្នារវាងកសិដ្ឋានដាំកូនឈើ (Tree planatations) និងព្រៃឈើ វាបានធ្វើឱ្យមានការភន្តច្រឡំដែលអាចនាំឱ្យមានការប្រើប្រាស់មិនបានត្រឹមត្រូវ។ មាត្រា២ នៃច្បាប់ដដែលនេះ កំណត់និយមន័យនៃពាក្យ "ព្រៃឈើ" ដោយរួមបញ្ចូលទាំងប្រព័ន្ធបរិស្ថានជីវចំរុះនៃព្រៃឈើសិប្បនិមិត្ត និង ព្រៃឈើធម្មជាតិ ហើយធ្វើឱ្យក្រុមហ៊ុន នានាទាមទារ "ដាំព្រៃឈើឡើងវិញ" ដែលតាមការពិតពួកគេកំពុងកាប់ឆ្ការព្រៃទៅវិញទេ។[៧៨] ការអះអាងថាធ្វើ ការដាំព្រៃឈើឡើងវិញ គ្រាន់តែជាពាក្យដោះសាររបស់ក្រុមហ៊ុនសម្បទានគ្រីនស៊ី នៅក្នុងខេត្តស្ទឹងត្រែង កាល ពីខែវិច្ឆិកា ឆ្នាំ២០០១ តែប៉ុណ្ណោះ។[៧៩]

មានការចោទជាសំណួរថា តើដីនេះមានតំលៃខ្ពស់ប៉ុណ្ណា ទើបបានជារដ្ឋផ្តល់ដីសម្បទានដែលមានទំហំធំបែបនេះទៅឱ្យក្រុមហ៊ុន ហើយហេតុអ្វីបានជាក្រុមហ៊ុនធ្វើការដាំដំណាំតែលើផ្ទៃដីតិចតួចនៃផ្ទៃដីសម្បទានទាំងមូលដូច្នេះទៅវិញ។ ការផ្តល់ដីសម្បទានដែលមាន រយៈពេលរហូតដល់៩៩ ឆ្នាំ ដូចនេះ នឹងធ្វើឱ្យដីកាន់តែមានភាពកម្រថែមទៀត នៅក្នុងប្រទេសកម្ពុជា ដូចនេះនឹង ធ្វើឱ្យដីសម្បទានឡើងថ្លៃ ហើយបង្កើនអត្ថប្រយោជន៍ដល់សម្បទានិក តាមរយៈការយក ដីនោះទៅជួលបន្តឱ្យក្រុមហ៊ុន ឬ អាជីវករតូចតាចធ្វើកសិកម្មដើម្បីចិញ្ចឹមជីវិត។ កិច្ចសន្យាក្រុមហ៊ុនគ្រីនស៊ីចែងថា ក្រុមហ៊ុនអាចជួលបន្ត ឬ លក់កិច្ចសន្យាទៅឱ្យតតីយជន បន្ទាប់ពីបានទទួលការយល់ព្រមពីរាជរដ្ឋាភិបាល។[៨០] សម្បទានប្រាំបីនៅក្នុងបញ្ជីដែលក្រសួងកសិកម្មបានផ្តល់ឱ្យតាំងនៅទាំងស្រុងឬមួយផ្នែកក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលមានផ្ទៃ ដី ៩៤.៣០០ ហិកតា។[៨១] ស្រុកភ្នំស្រួចលាតសន្ធឹងតាមបណ្តោយសងខាងផ្លូវជាតិលេខ៤ ស្ថិតនៅចន្លោះពីភ្នំពេញ ទៅកាន់ក្រុងព្រះសីហនុដែលធ្វើឱ្យតំបន់នោះទាក់ទាញដល់ការជួញដី។ នាយកដ្ឋានកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ បានចុះបញ្ជីដី ២២៥.១៥៥ ហិកតា

---

[៧៧] ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ប្រកាសលេខ៥៧២១ កសករន ស្តីពីការផ្អាកសកម្មភាពកាប់ឈើក្នុងព្រៃសម្បទាន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១។ សេចក្តីប្រកាសស្តីពីការផ្អាកជាបណ្តោះអាសន្នរាល់ការដឹកជញ្ជូនឈើ ចុះខែឧសភា ឆ្នាំ២០០២។ នៅពេលសរសេររបាយការណ៍នេះ បទបញ្ជាទាំងពីរកំពុងអនុវត្តនៅឡើយ។

[៧៨] Lang, op cit, ទំព័រទី៥ ដកស្រង់សំដីពីអង្គការ Carrere ឆ្នាំ១៩៩៩ :លេខ ៧-៩ ។

[៧៩] លិខិតលេខ២៧៤៣/៦៨០ កសកផផក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ បញ្ជាក់ថា " សម្បទានដីអាចផ្តល់ឱ្យក្រុមហ៊ុនទាំងឡាយណា ដែលលើកស្ទួយដល់តំលៃព្រៃរិចរិល ដែលមានតំលៃទាបខាងសេដ្ឋកិច្ច ដើម្បីឱ្យព្រៃឈើនោះមានតំលៃខ្ពស់ខាងសេដ្ឋកិច្ចវិញ ដើម្បីជំនួសឱ្យតំបន់ព្រៃរិចរិលទាំងនោះ។

[៨០] កិច្ចសន្យាសម្បទានរបស់ក្រុមហ៊ុនគ្រីន ស៊ី ចំកាត់ ខចែងចំណុច ៥.៣

[៨១] ក្រុមហ៊ុនស៊ីជេ កម្ពុជា (៣.០០០ ហិកតា), ក្រុមហ៊ុនស៊ីជេ កម្ពុជា (៥.០០០ ហិកតា), ក្រុមហ៊ុនគីមស៊ីល (៣.២០០ ហិកតា), ក្រុមហ៊ុនកម្ពុជាហៃនិញ គ្រុប ចំកាត់ (៣២.០០០ ហិកតា), ក្រុមហ៊ុនADUOK (១២.៥០៦ ហិកតា), ក្រុមហ៊ុនហេណាន់ កម្ពុជា (៤.១០០ ហិកតា), ក្រុមហ៊ុន Cambo Victor Investing & Development Co (២៦.៥៥០ ហិកតា), ក្រុមហ៊ុនសាជីវកម្មចិនសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ចក្រៅប្រទេស (៨.០០០ ហិកតា)។

នៃទឹកដីខេត្តកំពង់ស្ពឺ ស្ថិតក្រោមកិច្ចព្រមព្រៀង សម្បទាន ក្នុងនោះមានផ្ទៃដី ១៥៦.៤៥៥ ហិកតានៅក្នុងស្រុកភ្នំស្រួច ។[៨២]

## ៥- ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា

ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជាមានប្រវត្តិរស់នៅជាក្រុមតូចៗ នៅរាយពាសពេញតំបន់ភាគឧត្តរ និង ភាគឦសាននៃប្រទេសកម្ពុជា ។ រហូតមកដល់ពេលនេះ តំបន់ទាំងនោះគ្របដណ្តប់ទៅដោយព្រៃឈើដ៏ក្រាស់ ។[៨៣] ប្រជាពលរដ្ឋទាំងនេះមានលំនៅស្ថានជាប្រពៃណីនៅតាមព្រំដែននៃប្រទេសលាវ ថៃ និង វៀតណាម ហើយគេឃើញមានក្រុមជនជាតិដើមភាគតិចជាច្រើនរស់នៅសងខាងព្រំដែននៃប្រទេសទាំងនោះ ។[៨៤] ពួកគេចាត់ទុកការធ្វើកសិកម្មពនេចរមានសារៈសំខាន់ជាវប្បធម៌ និង សំរាប់ជីវភាពរស់នៅ ហើយដីគឺជាកត្តាសំខាន់សំរាប់អង្គការសង្គមនោះ សម្បទានគោលដៅសេដ្ឋកិច្ចអាចមានផលប៉ះពាល់អវិជ្ជមានជាពិសេសដល់ពួកគេ ។ សិទ្ធិប្រើប្រាស់ព្រៃឈើសហគមន៍ និង អនុផលព្រៃឈើរបស់ជនជាតិដើមភាគតិច ក៏ជាបញ្ហាដែលគួរឱ្យព្រួយបារម្ភខ្លាំងណាស់ដែរ ។

ច្បាប់អន្តរជាតិផ្តល់កិច្ចការពារជាពិសេសដល់ជនជាតិដើមភាគតិច ហើយនៅក្នុងឆ្នាំ១៩៩៨ និង ឆ្នាំ១៩៩៩ មានស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួនពីរបានផ្តល់អនុសាសន៍ជាក់លាក់មួយចំនួនដល់ប្រទេសកម្ពុជាស្តីពីប្រព្រឹត្តកម្មលើជនទាំងនោះ ។[៨៥] អនុសាសន៍ទាំងនោះនៅមិនទាន់អនុវត្តតាមពេញលេញនៅឡើយទេ ។ បើតាមការកត់សំគាល់ខាងលើ មានពាក្យបណ្តឹងជាច្រើនទាក់ទងនឹងអំពើរំលោភសិទ្ធិមនុស្សនៅលើដី និង ព្រៃ

---

[៨២] សូមមើលផែនទីរបស់ក្រុមហ៊ុននានា នៅក្នុងខេត្តកំពង់ស្ពឺ ដែលមិនទាន់ដំណើរការការងារនៅឡើយ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០០ ។

[៨៣] ខេត្តបួននៅភាគឦសាននៃប្រទេសកម្ពុជា មានខេត្តក្រចេះ មណ្ឌលគីរី រតនគីរី និងស្ទឹងត្រែង មានប្រជាពលរដ្ឋច្រើនរស់នៅ ។ តាមការជំរឿនប្រជាជនទូទៅចុងក្រោយក៏បានបង្ហាញថាមានជនជាតិដើមភាគតិចតំបន់ខ្ពង់រាប ដែលមានភិនភាគស្រដៀងគ្នានឹងប្រជាជនរស់នៅខេត្តភាគឦសាន ក៏មានរស់នៅក្នុងខេត្តដទៃទៀតដែរ រួមមានខេត្តព្រះវិហារ ខេត្តកំពង់ធំ និង នៅតាមបណ្តុំភ្នំនៃខេត្តកោះកុង ខេត្តពោធិសាត់ ខេត្តកំពង់ស្ពឺ និង ក្រុងព្រះសីហនុ : ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជនជាតិដើមភាគតិច / *ជនជាតិភាគតិច និង ការកាត់បន្ថយភាពក្រីក្រ* – កម្ពុជា ខែមិថុនា ឆ្នាំ២០០២ ។

[៨៤] ការកំណត់ព្រំដែនលើកដំបូងត្រូវបានធ្វើឡើងក្រោមរដ្ឋាភិបាលអាណានិគមនិយមបារាំង នៅដើមសតវត្សទី២០ បានធ្វើការបែងចែកក្រុមទាំងនេះ តាមបែបសិប្បនិម្មិត ដោយបានដាក់កំហិតដល់សេរីភាពក្នុងការដើរហើរ ។

[៨៥] ក្នុងឆ្នាំ១៩៩៨ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រកាន់ពូជសាសន៍បានផ្តល់ជាអនុសាសន៍ថាប្រទេស កម្ពុជាត្រូវទទួលស្គាល់ " ការប្រើប្រាស់ដីព្រៃ និងធនធានធម្មជាតិ អត្តសញ្ញាណ វប្បធម៌ និង របៀបរបបរស់នៅប្លែក និងមានតែមួយគត់របស់ជនជាតិដើមភាគតិច" ។ គណៈកម្មាធិការនេះក៏បានផ្តល់ជាអនុសាសន៍ថាប្រទេសកម្ពុជាត្រូវ " ចាត់វិធានការដើម្បីអនុវត្តឱ្យបានពេញលេញនូវអនុសាសន៍ទូទៅរបស់ខ្លួនលេខ XXIII ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលមានចែងក្នុងអនុសញ្ញានេះ ។ សេចក្តីសន្និដ្ឋានសរុប ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨, CERD/C/Add.54, វាក្យខ័ណ្ឌទី១៩ ។ ក្នុងឆ្នាំ១៩៩៩ គណៈកម្មាធិការសិទ្ធិមនុស្សបានសំដែងសេចក្តីកង្វល់ពីសិទ្ធិរបស់ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា ក្នុងការប្រើប្រាស់ប្រពៃណីជាវប្បធម៌ រួមមាន សកម្មភាពកសិកម្មរបស់ពួកគេ ត្រូវបានគោរព ស្របតាមមាត្រា ២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និង សិទ្ធនយោបាយ ។ សេចក្តីសន្និដ្ឋានសរុបរបស់ គណៈកម្មាធិការសិទ្ធិមនុស្ស, កម្ពុជា, ឯកសាររបស់អង្គការសហប្រជាជាតិ U.N.Doc. CCPR/C/79/Add. 108 (1999) ។

សម្បទាន ប៉ះពាល់ដល់ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា ដែលនេះគឺជាបញ្ហាមួយដំបូងគេដែលលោកតំណាងពិសេស ម៉ៃឃើលឃើប៊ី (Michael Kirby) ចាប់អារម្មណ៍ជាងគេ ហើយបានរៀបចំចងក្រងថាជាបញ្ហាដែលគួរឱ្យព្រួយបារម្ភ កាលពីឆ្នាំ១៩៩៦។[៨៦] បីឆ្នាំក្រោយមក របាយការណ៍របស់លោកឆ្នាំ១៩៩៩ លោក ថូម៉ាស់ ហាំម៉ាប៊ឺក (Thomas Hammarberg) អតីតតំណាងពិសេសបានដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សដែលមានសេចក្តីថា :

*" សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ខាងដីធ្លី និង ធនធានធម្មជាតិ ដែលពួកគេពឹងអាស្រ័យសំរាប់ជីវភាពរស់នៅ កំពុងស្ថិតក្នុងការគំរាមកំហែងមិនត្រឹមតែដោយសារការកាប់ឈើ និង ការធ្វើចំការប៉ុណ្ណោះទេ តែថែមទាំងដោយសារការចាប់យកដីធ្លី ក្នុងទ្រង់ទ្រាយផ្សេងៗដូចជា : ការសូកប៉ាន់សមាជិកសហគមន៍ដែលទន់ខ្សោយបំផុត ការសន្យាក្លែងក្លាយ ការល្បួងលួងលោម ឬ ការបំភិតបំភ័យ និងអំពើហិង្សាជាដើម "។*[៨៧]

មាត្រា២៣-២៨ នៃច្បាប់ភូមិបាលបានដាក់បញ្ចូលនូវទស្សនៈទាននៃដីសហគមន៍ជនជាតិដើមភាគតិចក្នុងរូបភាពជាកម្មសិទ្ធិដីសហគមន៍ គឺមិនមែនជាដីកម្មសិទ្ធិរបស់បុគ្គលណាម្នាក់ឡើយ ហើយបានទទួលស្គាល់ថានីតិបុគ្គលគឺជាម្ចាស់ដីនោះ។ ក្នុងការទទួលស្គាល់កម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច ច្បាប់ភូមិបាលបានកំណត់សិទ្ធិស្របច្បាប់របស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការធ្វើកសិកម្មពនេចរ និង ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់ជនជាតិដើមភាគតិច។

*" ប័ណ្ណកម្មសិទ្ធិដីជនជាតិដើមភាគតិច នាំឱ្យការប្តឹងទាមទារសិទ្ធិប្រើប្រាស់ធនធានដីដែលមានរូបភាពជាដីព្រៃ និង ដីកសិកម្ម ត្រូវតែបានដោះស្រាយមុនការបណ្តឹងទាមទារដទៃទៀតទាក់ទងនិងដីធ្លី "*[៨៨]

អ្វីដែលជាបញ្ហានោះគឺការកំណត់ថាតើនរណាខ្លះជាជនជាតិដើមភាគតិច និង ការកំណត់ព្រំដីរបស់ពួកគេបានអូសបន្លាយរយៈពេលយូរពេក ទើបនាំឱ្យជនជាតិដើមភាគតិចនៃប្រទេសកម្ពុជាបានក្លាយជាជនដែលងាយទទួលរងគ្រោះថែមទៀត ដោយការរឹបអូសយកដី និង ការលក់ដូរ ឬ ការផ្ទេរសិទ្ធិស្របច្បាប់នៃដីធ្លីរបស់ពួកគេ។[៨៩] បច្ចុប្បន្ននេះ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់កំពុងធ្វើការសិក្សាគំរោងសាកល្បង ដើម្បីគាំទ្រដល់ពង្រាងអនុក្រឹត្យ និង កិច្ចដំណើរការចេញប័ណ្ណកម្មសិទ្ធិសមូហភាព។ ទោះជាដូច្នេះក្តី គេមានការព្រួយ

---

[៨៦] របាយការណ៍របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស (ឯកសាររបស់អ.ស.ប U.N Doc., E/CN.4/1996/93 ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៦)។

[៨៧] របាយការណ៍របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅប្រទេសកម្ពុជា ដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស ឯកសាររបស់អ.ស.ប UN Doc., E/CN.4/1999/101 ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ១៩៩៨ វាក្យខ័ណ្ឌទី១៣២។

[៨៨] ក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យ ផ្នែកទី ១ ការជ្រើសរើសគោលនយោបាយ បញ្ហា និង ជំរើស ទំព័រទី៥។

[៨៩] មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) របាយការណ៍ស្តីពីការបាត់ដីសហគមន៍ នៅក្នុងខេត្តរតនគីរី ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣។

បារម្ភជាខ្លាំងថា ដីនៅសេសសល់តិចតួចដើម្បីផ្តល់កម្មសិទ្ធិ នៅពេលដែលអនុក្រឹត្យត្រូវបានព្រាង និងចាប់ផ្តើមដំណើរការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ។

កាលពីខែ សីហា ឆ្នាំ ២០០៤ រាជរដ្ឋាភិបាលបានអនុម័តគោលការណ៍ផ្តល់សម្បទានគោលដៅសេដ្ឋកិច្ច ដែលមានផ្ទៃដី ១៩៩.៩៩៩ ហិកតា ទៅឱ្យក្រុមហ៊ុន វ៉ូហ្សីសាន់ អិល អេស គ្រុម (Wuzhishan L.S. Group) សំរាប់ធ្វើ ចំការស្រល់ ដែលស្ថិតនៅទីតាំងពីរផ្សេងគ្នា នៅក្នុងខេត្តមណ្ឌលគីរី ។ ក្នុងខណៈពេលរង់ចាំការពិភាក្សាជាមួយប្រទេសអ្នកផ្តល់ជំនួយ រាជរដ្ឋាភិបាលបានអនុម័តផ្តល់ដី ១០.០០០ ហិកតា សំរាប់អាជីវកម្មពិសោធនៅក្នុងស្រុកអូរាំង ដែលជាដីលំនៅដ្ឋានរបស់ជនជាតិដើមភាគតិចភ្នង ។[៩០] សម្បទានផ្សេងទៀត ត្រូវបានគេរាយការណ៍ថាកំពុងតែត្រៀមអនុវត្ត ។

ក្នុងឆ្នាំ១៩៩៧ គណៈកម្មាធិការអន្តរក្រសួងសំរាប់ការអភិវឌ្ឍន៍តំបន់ជនជាតិភាគតិច បានដាក់ចេញនូវពង្រាងគោលនយោបាយរយៈពេលវែងមួយសំរាប់ការអភិវឌ្ឍន៍ប្រជាពលរដ្ឋដែលរស់នៅតំបន់ខ្ពង់រាប ។ ប្រសិនបើគោលនយោបាយនោះត្រូវបានអនុម័ត និង អនុវត្ត វានឹងផ្តល់ជាគោលនយោបាយជាតិដែលផ្សាភ្ជាប់គ្នាសំរាប់ជនជាតិដើមភាគតិច ។ ប្រទេសកម្ពុជាគួរចូលជាសមាជិកនៃអនុសញ្ញាលេខ១០៩ របស់អង្គការពលកម្មអន្តរជាតិដែលជាលិខិតុបករណ៍ដែលមានលក្ខណៈទូលំទូលាយនៃច្បាប់អន្តរជាតិ ដែលការពារសិទ្ធិរបស់ជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធ ដើម្បីរក្សាច្បាប់ និង ទំនៀមទំលាប់របស់ខ្លួននៅក្នុងសង្គមជាតិដែលពួកគេកំពុងរស់នៅ ។

## ៦- អំពើពុករលួយ សិទ្ធិទទួលបានពតិមាន និង ការចូលរួមពីសាធារណៈជន

មានការលំបាកជាច្រើន ក្នុងការស្វែងរកព័តិមានសំរាប់ធ្វើរបាយការណ៍នេះ ដែលជាធម្មតាការលំបាកនេះតែងជួបប្រទះជាទូទៅនៅក្នុងប្រទេសកម្ពុជា ក្នុងការទទួលបានព័តិមានដែលអាជ្ញាធរសាធារណៈគ្រប់គ្រង ។ "ភារកិច្ចរក្សាការសំងាត់" ដល់សម្បទានិក បានចោទឡើងជាសំណួរថាហេតុអ្វីបានជាគេមិនព្រមផ្តល់ព័តិមានបង្ហាញឱ្យឃើញពីភាពលំអៀងនៃស្ថាប័នមួយទៅដល់ផលប្រយោជន៍សាជីវកម្មឯកជន ។[៩១] បទពិសោធន៏ក៏ជាតួយ៉ាងមួយដែរ គឺកន្លងមកព័តិមានដែលទទួលបាន ជារឿយៗគឺបានតាមរយៈទំនាក់ទំនងជាបុគ្គល ។

---

[៩០] សចទន៨៤៨ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៤ ។

[៩១] ក្រុមហ៊ុនឯកជននានា ក៏មិនបានស្វាគមន៏ចំពោះការលាតត្រដាងព័តិមាននេះដែរ ។ ប្រធានក្រុមហ៊ុនឧស្សាហកម្មឈើកម្ពុជា CTIA ក្នុង ខែតុលា ឆ្នាំ២០០២ បានបញ្ជាក់នៅ ក្នុងបរិបទនៃការចុះផ្សាយជាសាធារណៈនូវផែនការគ្រប់គ្រងព្រៃឈើរយៈពេល២៥ ឆ្នាំខាងមុខ និងការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និង សង្គម : " ឯកសារពិនិត្យ ផ្ទៀងផ្ទាត់នៃ ESIA និង ផែនការគ្រប់គ្រងព្រៃឈើ (…) នឹងដកស្រង់យកអនុសាសន៏ដែលមិនស្វាគមន៏ ការទិទាន ការស្នើយោបល់ និង សេចក្តីត្រូវការ ហើយនិង អនុសាសន៏ភាគច្រើនទំនងជាបានមកពីអង្គការក្រៅរដ្ឋាភិបាល (NGOs) និង
សាធារណៈជនដែលមិនមានចំណេះដឹងគ្រប់គ្រាន់អំពីការគ្រប់គ្រងធនធានធម្មជាតិ ។ មានការផ្តល់ពតិមានមិនគ្រប់គ្រាន់ និង អវិជ្ជមានជាច្រើន ដែលប្រើប្រាស់សំរាប់ហេតុផលនយោបាយ ហើយអាចផ្តល់នូវផលអាក្រក់ ច្រើនជាងផលល្អ ចំពោះកិច្ចដំណើរ ការពិនិត្យឡើងវិញនេះ

រីឯវិស័យដទៃទៀតពាក់ព័ន្ធនឹងការធ្វើសេចក្តីសំរេចចិត្តរបស់រាជរដ្ឋាភិបាល ត្រូវចាត់វិធានការផ្សេងៗ ដើម្បីជំនះខាងតែបានចំពោះរាល់ការសំងាត់ជុំវិញសម្បទានគោលដៅសេដ្ឋកិច្ច និង ប្រព័ន្ធសម្បទានជាទូទៅ។ វប្បធម៌ នៃសេវាសាធារណៈ និង ការយល់ដឹងរបស់មន្ត្រីរាជរដ្ឋាភិបាលថាព័ត៌មានដែលអាជ្ញាធរសាធារណៈគ្រប់គ្រងនោះ គឺសំរាប់បំរើផលប្រយោជន៍សាធារណៈ ហើយព័ត៌មាននោះពិតជាអាចជួយកែតម្រូវដល់បញ្ហាមួយចំនួនដែលបានជួបប្រទះ។ ទោះជាដូច្នេះក្តី ប្រទេសកម្ពុជាមិនទាន់មានច្បាប់ចែងអំពីសិទ្ធិទទួលព័ត៌មានផ្សេងៗ ដែលគ្រប់គ្រងដោយអាជ្ញាធរសាធារណៈ ខុសប្លែកពីប្រទេសផ្សេងទៀតនៅក្នុងតំបន់ដូចជានៅប្រទេសថៃ។ ប្រសិនបើច្បាប់ស្តីពីសេរីភាពខាងព័ត៌មានត្រូវបានអនុម័ត នឹងចែងអំពីសិទ្ធិស្របច្បាប់ក្នុងការទទួលព័ត៌មានអំពីបញ្ហាដែលជាសេចក្តីព្រួយបារម្ភរបស់សាធារណៈជន និង ជួយលើកកំពស់ដល់ការគ្រប់គ្រងដោយចំហរ និងមានការទទួលខុសត្រូវ។ ការទទួលបានពត៌មានក៏អាចជួយប្រឆាំងការរំលោភបំពាន និង ការធ្វើសេចក្តីសំរេចចិត្តមិនត្រឹមត្រូវជំរុញឱ្យមានការពិភាក្សាផ្លាស់ប្តូរពត៌មានគ្នាទៅវិញទៅមក និង ការធ្វើគោលនយោបាយ និង សេចក្តីសំរេចបានល្អព្រមទាំងជួយសំរបសំរួលរវាងក្រសួងនានា។ វាក៏អាចឱ្យប្រទេសអ្នកផ្តល់ជំនួយ និង ទីភ្នាក់ងារអភិវឌ្ឍន៍នានាអាចកំណត់ជំនួយរបស់ខ្លួនបានចំទិសដៅ និង មានប្រសិទ្ធិភាពថែមទៀត។ សំខាន់បំផុតនោះគឺ អាចឱ្យប្រជាពលរដ្ឋកម្ពុជាចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តផ្សេងៗពាក់ព័ន្ធនឹងជីវិតដែលជាកម្មសិទ្ធិរបស់គេ និង ក្នុងការអភិវឌ្ឍន៍ដែលជាផលប្រយោជន៍ដ៏សំខាន់ដល់ប្រជាពលរដ្ឋ។

ការដែលសាធារណៈជនមិនមានសិទ្ធិមើលឯកសាររបស់ម្ចាស់ភាគហ៊ុន នៃក្រុមហ៊ុនសម្បទាននានា និង សេចក្តីបរិយាយលំអិតអំពីក្រុមហ៊ុនអាណាព្យាបាលនោះ[៩២] បាននាំឱ្យអំពើពុករលួយកើនឡើង នៅក្នុងប្រទេសកម្ពុជា ក្នុងខណៈដែលស្ថាប័ននានាដែលមានភារកិច្ចគ្រប់គ្រង ឬ ធ្វើសវនកម្មមិនទាន់ដំណើរបានល្អ ហើយការត្រួតពិនិត្យស្ថាប័នមានភាពទន់ខ្សោយ ឬ គ្មានតែម្តង។[៩៣] អំពើពុករលួយនាំឱ្យមានការបែងចែកធនធានសាធារណៈមិនស្មើភាព ហើយធ្វើឱ្យអន្តរាយដល់សមិទ្ធិផលសិទ្ធិមនុស្សជាច្រើន។ បញ្ហាដែលបានលើកឡើងអំពីស្ថាប័ន និង តួអង្គសាធារណៈនៅក្នុងវិស័យព្រៃឈើ ត្រូវអនុវត្តឱ្យបានស្មើគ្នាចំពោះដីដែលកំពុងគ្រប់គ្រងទាំងនោះ :

---

គោលដៅសំខាន់នោះគឺដើម្បីជ្រៀសវាងការពន្យាពេលដែលមិនចាំបាច់ និង ភាពស្មុគ្រស្មាញ។ [៩៣] " យោងលិខិតលេខ CTIA/NGO/02/02 ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០២ ចុះហត្ថលេខាដោយលោក ហិនរី គង់ (Henry Kong) ។

[៩២] ប្រាក់កម្ចីថ្មី ពីធានាគារអភិវឌ្ឍន៍អាស៊ី ត្រូវគេរំពឹងថានឹងបានអនុម័តនៅក្នុងឆ្នាំ២០០៤ ដែលនឹងត្រូវប្រើប្រាស់សំរាប់ដោះស្រាយបញ្ហានេះ។ ត្រូវមានកម្មវិធីអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម ដែលនេះគឺជាផ្នែកមួយនៃលក្ខខណ្ឌទូទៅ ហើយដែលក្រសួងពាណិជ្ជកម្មត្រូវបង្កើតទិន្នន័យមួយសំរាប់ប្រើប្រាស់ជាសាធារណៈដែលដាក់បញ្ចូលព័ត៌មានប្រភេទនេះ។

[៩៣] តាន់ស៊ី, វីតូ , ដេវូដឌី, ហាមីដ រីហ្សា (Tanzi, Vito, Davoodi, Hamid Reza) អង្គការរូបិយវត្ថុអន្តរជាតិ (IMF) ឯកសារសំរាប់ពិភាក្សា ឆ្នាំ១៩៩៧។

*" មានចំណុចសំខាន់ៗដែលមិនឯកភាពគ្នា (កើតមាន) រវាងរបៀបវារៈឯកជននៃតួអង្គសាធារណៈសំខាន់ៗ និងរបៀបវារៈសាធារណៈជាផ្លូវការរបស់ខ្លួន... (ជាមួយ) កិច្ចប្រតិបត្តិការសើរតសម្រាំងនៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាននោះ គឺការត្រួតពិនិត្យយ៉ាងតឹងតែងបំផុតលើធនធាន ឱកាស និង អត្ថប្រយោជន៍សេដ្ឋកិច្ចដែលរដ្ឋបានផ្តល់ឱ្យ "។*[៥៤]

ការមិនបានតម្រូវឱ្យអ្នកនយោបាយ មន្ត្រីរាជការជាន់ខ្ពស់ប្រកាសទ្រព្យសម្បត្តិ ជាពិសេសការប្រកាសជាសាធារណៈនូវផលកំរៃអាជីវកម្ម ក៏ធ្វើឱ្យខូចដល់ការអនុវត្តភារកិច្ច និង នាំឱ្យមានការឆ្លៀតឱកាសយកប្រយោជន៍ពីប្រភេទនៃផលកំរៃដែលពួកគេអាចទទួលបានពីក្រុមហ៊ុនសម្បទាន ។[៥៥] បញ្ហានេះគួបផ្សំ នឹងការដែលប្រទេសកម្ពុជាមិនទាន់បានអនុវត្តឱ្យបានពេញលេញនូវបទបញ្ជាគ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុ និយាមគណនេយ្យ ឬ ប្រព័ន្ធសំរាប់ស្នើសុំធ្វើកិច្ចសន្យាសាធារណៈ ។ សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយចែងអំពីការប្រកាសទ្រព្យសម្បត្តិ ប៉ុន្តែមិនបានចែងអំពីការដាក់ទណ្ឌកម្មជាក់លាក់ណាមួយទៅលើមន្ត្រីដែលមិនព្រមប្រកាសទ្រព្យសម្បត្តិ ឬ ដែលប្រកាសទ្រព្យសម្បត្តិ និងបំណុលមិនបានត្រឹមត្រូវនោះទេ ។ ប្រទេសកម្ពុជាត្រូវបានស្នើសុំឱ្យចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិប្រឆាំងអំពើពុករលួយ ដែលបច្ចុប្បន្ននេះមានជាង១០០ ប្រទេសហើយបានចុះហត្ថលេខា ដោយរួមទាំងប្រទេសប្រ៊ុយណេ ហ្វីលីពីន វៀតណាម ឥណ្ឌូណេស៊ី ម៉ាឡេស៊ី លាវ និង ថៃ ។

សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ គួរតាក់តែងឱ្យបានស្របតាមបទបញ្ញត្តិនៃអនុសញ្ញាអន្តរជាតិ ។ សេចក្តីព្រាងច្បាប់នេះ ចែងនៅខ្វះច្រើនចំណុចណាស់ ហើយគ្មានបទបញ្ញត្តិស្តីពីការប្រកាសទ្រព្យសម្បត្តិដែលមាននៅក្រៅដែនសមត្ថកិច្ចជាតិ ការមានបានដោយខុសច្បាប់ និង កំណើនខុសប្រក្រតីនៃទ្រព្យសម្បត្តិរបស់មន្ត្រីសាធារណៈដែលមិនអាចធ្វើការពន្យល់ឱ្យបានសមហេតុសមផល ។ មិនមានបញ្ញត្តិចែងហាមឃាត់ការលាងលុយក្រខ្វក់ ការលាក់កំបាំងនូវចំណូលដែលបានមកពីអំពើឧក្រិដ្ឋ ឬ សកម្មភាពត្រៀមរៀបចំប្រព្រឹត្តអំពើពុករលួយ ឬ ការប៉ុនប៉ងប្រព្រឹត្តអំពើពុករលួយ ។ សេចក្តីព្រាងច្បាប់នេះមិនបានចែងអំពីវិធានការការពារសាក្សី និង អ្នកផ្តល់ព័ត៌មានឡើយ ទណ្ឌកម្មចំពោះការមិនព្រមប្រកាសទ្រព្យសម្បត្តិ ឬ អំពីស្ថាប័នហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ពីអត្តសញ្ញាណនៃអតិថិជន និង ពិនិត្យពិច័យគណៈនីដែលគ្រប់គ្រងដោយមន្ត្រីទាំងឡាយដែលកាន់តំណែងក្នុងមុខងារសាធារណៈសំខាន់ៗ ។[៥៦] សេចក្តីព្រាងច្បាប់នេះមិនបានធ្វើនិយ័តកម្មសកម្មភាពផ្សេងៗ នៃស្ថាប័នហិរញ្ញ

---

[៥៤] ក្នុងសៀវភៅដដែល ទំព័រទី៣ ។

[៥៥] អង្គការ Global Witness *តំលាតនៃការដែលអាចជឿទុកចិត្តបាន - និងសេចក្តីត្រូវការ ដើម្បីផ្សាភ្ជាប់គ្នានូវតំលាតនោះ* ខែឧសភា ឆ្នាំ២០០១ " ក្នុងករណីខ្លះមានទំនាក់ទំនងគ្នារវាងបញ្ហាហិរញ្ញវត្ថុ និង បញ្ហាគ្រួសារ ជាមួយអ្នកនយោបាយជាន់ខ្ពស់ មន្ត្រីរាជការស៊ីវិល ក្រុមហ៊ុនសម្បទាននានា និង បុគ្គលដែលប្រើប្រាស់សម្បទានទាំងនោះ ដែលគេបានស្គាល់ ឬ សង្ស័យជាទូទៅ ប៉ុន្តែពិបាករកភស្តុតាងមកបញ្ជាក់ ។ "

[៥៦] សូមអានមាត្រា ២០, ២៣, ២៤, ២៧, ៣២, ៣៣, ៥២ ។

វត្ថុទេ ឬ ទទួលស្គាល់ប្រភេទនៃអំពើពុករលួយឆ្លងដែន និង អំពីសារៈសំខាន់នៃសហប្រតិបត្តិការអន្តរជាតិនោះក៏ទេដែរ ។

## ផ្នែកទី២ : ផលប៉ះពាល់សិទ្ធិមនុស្ស និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន

ការសិក្សា និង ការស្រាវជ្រាវដល់ទីកន្លែង បានធ្វើឡើងនូវសម្បទានគោលដៅសេដ្ឋកិច្ចចំនួនដប់ (១០) កន្លែង និង ចំការកៅស៊ូមួយកន្លែងទៀត ដើម្បីស្វែងយល់អំពីផលប៉ះពាល់សិទ្ធិមនុស្ស និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន ។[៩៧] ការស្រាវជ្រាវដល់ទីកន្លែងពិស្តារមួយបានធ្វើឡើងនៅសម្បទានមួយដែលមានផ្ទៃដី ២១.២៥០ ហិកតា ។ សម្បទានពីរ (២) កន្លែង ដែលមានផ្ទៃដី ៥.000 ហិកតា និង ៣.000 ហិកតា របស់ក្រុមហ៊ុនស៊ីជេ (CJ Cambodia Company) នៅក្នុងខេត្តកំពង់ស្ពឺ និង សម្បទានមួយកន្លែងទៀតដែលមានផ្ទៃដី ៧.៤00 ហិកតា កាន់កាប់ដោយក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ (Flour Manufacturing Company) នៅក្នុងខេត្តស្ទឹងត្រែង និង ចំការមួយកន្លែង ដែលកាន់កាប់ដោយក្រុមហ៊ុនចំការកៅស៊ូជុប នៅឃុំទីរឹង ក្នុងខេត្តកំពង់ធំ ។[៩៨]

នៅក្នុងពេលស្រាវជ្រាវដល់ទីកន្លែង ឃើញមានបញ្ហាកើតមានជាញឹកញាប់ រួមមានការមិនបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ការមិនបានវាយតំលៃពីផលប៉ះពាល់បរិស្ថាន ការបដិសេធសិទ្ធិប្រើប្រាស់ដីជាប្រពៃណី ហើយនិងការមិនអនុញ្ញាតឱ្យប្រមូលអនុផលព្រៃឈើ ការជម្លៀសប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន និង ដីកសិកម្មរបស់ពួកគេ ការបាត់បង់របរចិញ្ចឹមជីវិតជាប្រពៃណី ជាគុណប្រយោជន៍ដល់ការបង្កើតការងារមួយចំនួនដែលមានប្រាក់ឈ្នួលទាប ទំនាស់កើតមានរវាងក្រុមហ៊ុននានា និង ប្រជាពលរដ្ឋមូលដ្ឋាន ហើយនិងមានការបំភិតបំភ័យពីកងសន្តិសុខប្រដាប់អាវុធ ហើយជួនកាលពីយោធិននៃកងយោធពលខេមរភូមិន្ទ ។ ទាំងរចនាសម្ព័ន្ធគណៈកម្មការស៊ើរយោជដីដែលបានបង្កើតឡើងកាលពីខែកក្កដា ឆ្នាំ២00២ ទាំងតុលាការនៅក្នុងប្រទេសកម្ពុជាមិនទាន់ដំណើរការប្រកបដោយប្រសិទ្ធិភាពក្នុងការដោះស្រាយជំលោះ ឬ ការផ្ដល់សំណងការខូចខាតចំពោះការ

---

[៩៧] ចំការទាំងនេះត្រូវបានកាប់កាប់ដោយក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់ (Flour Manufacturing Company) នៅខេត្តស្ទឹងត្រែង, ប្រទេសកម្ពុជា ក្រុមហ៊ុនហៃនិញ គ្រុប (Haining Group Company) នៅខេត្តកំពង់ស្ពឺ ក្រុមហ៊ុនភាពីម៉ិច (Pheapimex Company) នៅខេត្តពោធិសាត់ និង ខេត្តកំពង់ឆ្នាំង ក្រុមហ៊ុនម៉ុង ឫទ្ធី វិនិយោគដូងប្រេងកម្ពុជា និង ក្រុមហ៊ុនម៉ុង ឫទ្ធីវិនិយោគដំឡូងមីកម្ពុជា (Mong Reththy Investment Cambodia Palm Oil Company and Mong Reththy Investment Cambodia Cassava Company) នៅក្រុងព្រះសីហនុ, ក្រុមហ៊ុនអាក្រូស្តារវិនិយោគ (Agro Star Investment Company) នៅខេត្តកំពង់ចាម, ក្រុមហ៊ុនស៊ីជេ កម្ពុជា (CJ Cambodia) មានសម្បទាដីពីរកន្លែងផ្សេងគ្នានៅក្នុងខេត្តកំពង់ស្ពឺ , ក្រុមហ៊ុន ADUOK នៅក្នុងខេត្តកំពង់ស្ពឺ, ក្រុមហ៊ុនចំការកៅស៊ូជុបរបស់រដ្ឋ (Chup State Rubber Plantation Company) នៅក្នុងខេត្តកំពង់ធំ ។

[៩៨] គោលការណ៍ណែនាំសំរាប់ធ្វើសម្ភាសន៍បានផ្តោតលើចំណុច : ក- ប្រវត្តិសាវតា ដើម្បីធ្វើការប្រៀបធៀបពីស្ថានភាពរស់នៅបច្ចុប្បន្ន សកម្មភាពសេដ្ឋកិច្ច និង ប្រជាពលរដ្ឋ, ខ- សភាពការណ៍បច្ចុប្បន្ន : ចំការកសិកម្ម និងផលប៉ះពាល់របស់វា, លំដាប់លំដោយនៃព្រឹត្តិការណ៍, សកម្មភាពរបស់ក្រុមហ៊ុន, ផលប៉ះពាល់សង្គម, ផលប៉ះពាល់សេដ្ឋកិច្ច, ផលប៉ះពាល់បរិស្ថាន, សកម្មភាពរបស់អ្នកភូមិ, គំនិតសំរាប់ថ្ងៃអានាគត, អនុសាសន៍ ។ ការសម្ភាសន៍នីមួយៗ មានរយៈ ពេលពីកន្លះម៉ោងទៅបីម៉ោង ។ ក្នុងករណីនីមួយៗ ភូមិមួយចំនួនត្រូវបានជ្រើសរើស ដោយការជួយជ្រោមជ្រែងពីអង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលមានសមាសភាព បុរស ស្ត្រី អ្នកមាន អ្នកក្រ ត្រូវបានជ្រើសរើសមកធ្វើជាគំរូ ។

រំលោភសិទ្ធិមនុស្ស ។ ក្នុងសម្បទានជាច្រើន ការដកហូតកម្មសិទ្ធិនាំឱ្យបាត់បង់នូវជំនឿទុកចិត្តលើស្ថាប័នសាធារណៈ ការភ័យខ្លាច ការព្រួយបារម្ភអំពីអានាគតរបស់អ្នកជំនាន់ក្រោយ និង ការបាត់បង់ សេរីភាព សេចក្តីថ្លៃថ្នូរ និង សេចក្តីសង្ឃឹម ។

**កម្មសិទ្ធិដីធ្លី និង ការយល់ដឹងអំពីសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋនៅជនបទ**

នៅតំបន់ជនបទនៃប្រទេសកម្ពុជា ប្រជាពលរដ្ឋពឹងផ្អែកលើការទទួលស្គាល់សិទ្ធិក្រៅផ្លូវការក្នុងមូលដ្ឋាន និង លិខិតទាក់ទងអាជីវកម្ម ដែលចុះហត្ថលេខាដោយប្រធានភូមិ ។ ពួកគេគ្មានលទ្ធភាពបង់ប្រាក់ធ្វើប័ណ្ណកម្មសិទ្ធិទេ ហើយតាមធម្មតា គេយល់ឃើញថាមិនមែនជាការចាំបាច់នោះទេ ។ ការគ្មានទម្លាប់ចុះបញ្ជីដីឯកជនបានបើកច្រកឱ្យមានការរឹបអូសយកដីធ្លី និង បានសំរួលដល់ការលក់ដូរ ឬ ការផ្ទេរកម្មសិទ្ធិតាមរយៈសម្បទាន ។ ការមិនបានកែតម្រូវចំពោះភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់កម្ពុជា ដែលមិនបានផ្តល់កិច្ចការពារស្មើគ្នាតាមផ្លូវច្បាប់ចំពោះអ្នកក្រ គឺជាការគួបផ្សំឱ្យមានបញ្ហានេះឡើង ។ អង្គនីតិប្រតិបត្តិបានជ្រៀតជ្រែកក្នុងកិច្ចការតុលាការ និងការបើកច្រកឱ្យទទួលសំណូកពីភាគីដែលមានផលប្រយោជន៍ ជាពិសេសពីអ្នកដែលមានឥទ្ធិពលខាងសេដ្ឋកិច្ច និង នយោបាយ ។ រដ្ឋមិនបានផ្តល់មូលនីធិសំរាប់គំរោងមេធាវីការពារជនក្រីក្រទេ ហើយជនដែលមានឥទ្ធិពលខាងសេដ្ឋ កិច្ច និង នយោបាយអាចប្រព្រឹត្តល្មើសច្បាប់បានដោយមិនបានធ្វើការផ្តន្ទាទោសតាមច្បាប់ឡើយ (និទណ្ឌភាព) ។

មាត្រា៣០នៃច្បាប់ភូមិបាលចែងថា បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី៥ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះ ។ ទោះបីជាមិនបានចុះបញ្ជីក្តី សិទ្ធិនេះត្រូវបានច្បាប់ទទួលស្គាល់ ។ តាមមាត្រា៣១ ចែងថា បុគ្គលដែលបានអាស្រ័យផលនៃភោគៈស្របច្បាប់ ហើយមិនបានបំពេញគ្រប់រយៈពេល៥ ឆ្នាំ អាចត្រូវបានអនុញ្ញាតឱ្យបន្ថែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលស្របច្បាប់៥ (ប្រាំ) ឆ្នាំ និងបានប័ណ្ណកម្មសិទ្ធិជាស្ថាពរ ។ បន្ទាប់មកគេអាចសុំចុះបញ្ជីជាកម្មសិទ្ធិករបាន ។ បុគ្គលណាដែលបានអាស្រ័យផលនៃភោគៈពិតប្រាកដគ្រប់រយៈពេល៥ (ប្រាំ) ឆ្នាំ អាចសុំចុះបញ្ជីជាកម្មសិទ្ធិករបាននៅពេលដែលប្រព័ន្ធចុះបញ្ជីត្រូវបានបង្កើតឡើង ។

បញ្ហានោះគឺ មានប្រជាពលរដ្ឋមូលដ្ឋានមួយចំនួនតូចប៉ុណ្ណោះ ដែលមានការយល់ដឹងពីសិទ្ធិទាំងនេះ ហើយមន្ត្រីរាជរដ្ឋាភិបាលបានអះអាងថា កិច្ចដំណើរការចុះបញ្ជីរអាចត្រូវប្រើរយៈពេលរហូតដល់២០ឆ្នាំឯណោះ ។ ប្រជាជនភាគច្រើន មិនបានអះអាងថាខ្លួនមានសិទ្ធិកម្មសិទ្ធិចំពោះមុខការលក់ដូរ ឬ ការផ្ទេរសិទ្ធិស្របច្បាប់តាមរយៈសម្បទានគោលដៅសេដ្ឋកិច្ចទេ ។ ប្រជាពលរដ្ឋទាំងនោះ មានជំហរទន់ខ្សោយក្នុងការអះអាងថាខ្លួនមានសិទ្ធិស្របច្បាប់ជាអាទិភាព ស្ថិតក្នុងស្ថានភាពមួយដែលសម្បទានិកកំពុងព្យាយាមតាំងខ្លួនជាកម្មសិទ្ធិករលើដីមួយកន្លែង ដែលមានការយល់ព្រមពីអាជ្ញាធរ ។

សិទ្ធិលើដីធ្លីឯកជនត្រូវបានការពារដោយមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញ បានចែងថា ការដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌ ។ កន្លងមកមិនឃើញមានការផ្តល់សំណងសមរម្យ និង យុត្តិធម៌ដល់សហគមន៍ ដូចក្នុងកាលៈទេសៈទាំងនេះទេ ។

ទោះជាករណីប្រព្រឹត្តរំលោភច្បាប់ភាគច្រើនមិនទាន់បានធ្វើការដោះស្រាយប្រកបដោយប្រសិទ្ធិភាពក្តី មានសហគមន៍ខ្លះបានធ្វើការតវ៉ាអំពីករណីរបស់ខ្លួនយ៉ាងជោគជ័យ ទោះជារឿងក្តីទាំងនោះមិនបានធ្វើការដោះស្រាយនៅចំពោះមុខតុលាការក៏ដោយ ។[៩៩] រឿងក្តីទាំងឡាយណា ដែលបានចាត់ចែងទប់ទល់ ឬ កាត់បន្ថយជាអប្បបរិមានូវផលអាក្រក់នៃសម្បទាន ជាទូទៅត្រូវបានរៀបចំបានល្អ និង ធ្វើឡើងដោយមានការគាំទ្រពីអង្គការមេធាវីការពារជនក្រីក្រ និង អង្គការតស៊ូមតិផ្សេងៗទៀត ។ នេះបានបង្ហាញឱ្យឃើញពីសេចក្តីត្រូវការឱ្យមានកម្មវិធីអប់រំច្បាប់ ដើម្បីជួយសហគមន៍មូលដ្ឋានឱ្យមានការយល់ដឹងអំពីសិទ្ធិស្របច្បាប់របស់ខ្លួន[១០០] ដើម្បីជួយ

[៩៩] នៅពេលដែលសម្បទានក្រុមហ៊ុនភាពីម៉ិច ក្នុងខេត្តពោធិសាត់ បានទទួលការអនុញ្ញាតក្នុងការកាប់ឆ្ការដីដំបូង ដែលមានទំហំ ៦៨០០ ហិកតា នៅក្នុងឃុំអន្សរចំបក់ ស្រុកក្រគរ, គឺជាតំបន់មួយដែលមានប្រជាពលរដ្ឋ១០៣១គ្រួសាររស់នៅ, ប្រជាពលរដ្ឋ ៧០៣ គ្រួសារបានប្តឹងមកអង្គការក្រៅរដ្ឋាភិបាល (NGOs) , អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (Legal Aid Cambodia) ។ ជាយថាហេតុ គ្រួសារប្រជាពលរដ្ឋទាំងនោះ ត្រូវបានអនុញ្ញាតឱ្យរស់នៅលើដីនោះ ហើយគំរោងកាប់ឆ្ការព្រៃក៏ត្រូវបានបញ្ឈប់ ឬ ត្រូវបានពន្យាពេល ។ នៅក្នុងឆ្នាំ២០០១ ប្រជាពលរដ្ឋស្រុកទឹកផុស និងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង បានធ្វើញត្តិមួយផ្ញើជូនស្ថាប័នរដ្ឋាភិបាល និងតំណាងធនាគារអភិវឌ្ឍន៏អាស៊ី (ADB) ដើម្បីតវ៉ាទៅនឹងផែនការវិនិយោគរបស់ក្រុមហ៊ុនភាពីម៉ិច ។ អង្គការជំនួយផ្នែកច្បាប់ នៃកម្ពុជា (Legal Aid Cambodia) និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត បានដាក់ស្នើឯកសារស្តីពីក្រុមហ៊ុនភាពីម៉ិច ជូនស្ថានទូតនានាប្រចាំនៅរាជធានីភ្នំពេញ ដើម្បីសុំជួយធ្វើអន្តរាគម ។ ទោះជាដូច្នោះ ក្តីក្រុមហ៊ុននេះនៅតែបន្តធ្វើការកាប់ឆ្ការ និង ដាំដុះនៅលើដីសម្បទានរបស់ខ្លួននៅក្នុងខេត្តកំពង់ឆ្នាំងជាដដែល ។

[១០០] ធនាគារអភិវឌ្ឍន៏ (ADB) បានផ្តល់មូលនីធិសំរាប់កម្មវិធីស្តីពីការយល់ដឹងពីប្រព័ន្ធពតិមាន និង យុទ្ធនាការផ្សព្វផ្សាយពតិមានជាសាធារណៈ : TA 4181 និងតំណាក់កាលទី១ របស់ខ្លួន (CAM TA 3577) ។ តំណាក់កាលនេះ បានរួមបញ្ចូលទាំងការផលិតជាខ្សែវិដេអូ ស្តីពីការយល់ដឹងពីសិទ្ធិរបស់ខ្លួន ដែលមានចែងក្នុងច្បាប់ភូមិបាល និងការដោះស្រាយជំលោះដីធ្លី ។ កម្មវិធីវីដេអូនេះ នឹងធ្វើការផ្សព្វផ្សាយយ៉ាងទ្សៀងទាត់ តាមរយៈទូរទស្សន៍ ហើយឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវិធីទាំងនេះ ត្រូវបានផ្តល់ជូនការិយាល័យភូមិនានា នៅថ្នាក់ស្រុក និងខេត្ត នៅទូទាំងប្រទេសកម្ពុជា ។ សៀវភៅរូបកំប្លែងត្រូវបានរៀបចំឡើង និង បានធ្វើការចែកចាយ ។ សិក្ខាសាលាជាច្រើន ត្រូវបានរៀបចំធ្វើ ដើម្បីហ្វឹកហ្វឺនដល់អង្គការក្រៅរដ្ឋាភិបាលនានា អំពីរបៀបប្រើប្រាស់ឯកសារស្តីពីការយល់ដឹងរបស់សាធារណជននៅក្នុងកម្មវិធីផ្សព្វផ្សាយរបស់ខ្លួន ។

ពួកគេ និង អ្នកតំណាងរបស់គេ ឱ្យមានមធ្យោបាយ និង ចំណេះដឹងគ្រប់គ្រាន់អាចការពារសិទ្ធិរបស់ខ្លួនបាន និង ដើម្បីរៀបចំចងក្រងធ្វើរបាយការណ៏ស្តីពីករណីរំលោភផ្សេងៗ ។

**ដីជាមូលដ្ឋានគ្រឹះសំរាប់ការរៀបចំសង្គម និង វប្បធម៌ព្រមទាំងជីវភាពរស់នៅ**

ដីគឺជាមូលដ្ឋានគ្រឹះសំរាប់ការរៀបចំសង្គមនៅតំបន់ជនបទនៃប្រទេសកម្ពុជា ។ តំបន់ជនបទភាគច្រើន គ្រប់គ្រងដោយព្រំប្រទល់ក្រៅផ្លូវការ អាស្រ័យទៅតាមតំបន់ដែលសហគមន៏មូលដ្ឋានប្រើប្រាស់ជាទៀងទាត់ ។ ព្រំប្រទល់ទាំងនេះអាចមានសារសំខាន់ខាងជំនឿសាសនា ដោយសារដីនោះត្រូវបានត្រួតត្រាដោយអ្នកតាម្ចាស់ដី ។ ព្រះអាទិទេព ដែលគេហៅថា" អ្នកតា " ដែលចំណែកដីសំខាន់ខ្លាំងណាស់នៅក្នុងទំនៀមទំលាប់នៃប្រទេសកម្ពុជា ។ ជម្ងឺដង្កាត់ និង ជោគវាសនាអាក្រក់ ជារឿយៗត្រូវបានគេជឿថាកើតមកពីទង្វើរបស់អ្នកទាំងនោះ : អ្នកតាបានធ្វើការសងសឹកវិញ នៅពេលដែលមាននរណាម្នាក់បានធ្វើរំខានដល់របៀបរបបសង្គម ប្រព្រឹត្តល្មើសនឹងក្រមសីលធម៌ ឬ បានចូលរុករានទន្ទ្រានក្នុងតំបន់របស់ខ្លួនដោយមិនបានសុំការអនុញ្ញាតជាមុន ។

ដីធ្លីគឺជាកន្លែងតំកល់ទុកនូវការចងចាំអំពីប្រវត្តិអតីតកាល ប្រសិនមិនមានការរៀបចំចងក្រងប្រពៃណីទំនៀមទំលាប់ពីមុនមកនោះទេ ។ គេចាត់ទុកដីថាជាសៀវភៅប្រវត្តិសាស្ត្រមួយដែលបើកចំហរ ហើយជនគ្រប់រូបអាចអាន និងសិក្សាអំពីប្រវត្តិផ្សេងៗដែលបានកើតមាននៅក្នុងមូលដ្ឋាន ដូចជាឈ្មោះទីកន្លែង ផ្លូវចាស់ សញ្ញាសំគាល់លើដី និងប្រវត្តិរឿងរ៉ាវផ្សេងៗ ដែលជាប់ទាក់ទងនឹងទីកន្លែងនោះ ។ ប្រជាពលរដ្ឋមូលដ្ឋានយល់ថា ការឈូសឆាយដី គឺជាទិដ្ឋភាពមួយដែលបង្ហាញពីជាការលុបបំបាត់ចោលនូវប្រវត្តិសាស្ត្រ រំខានដល់អង្គការសង្គម និង ប្រពៃណីរបស់ខ្លួនទៀតផង ។

ជាទូទៅគ្រួសារនីមួយៗមានដីឡូត៏មួយឡូត៏ៗរៀងខ្លួន សំរាប់សង់ផ្ទះសម្បែង និង ដីដែលមានទំហំមួយ ឬច្រើនកន្លែងទៀត ដែលប្រើប្រាស់សំរាប់ធ្វើស្រែចំការ ។ ជារឿយៗ នៅតំបន់ព្រៃ ប្រជាពលរដ្ឋធ្វើកសិកម្មពនេចរ ។[១០១] ការប្រើប្រាស់ដី និងព្រៃឈើនៅជុំវិញលំនៅស្ថានបានជួយឱ្យគេ អាចទ្រទ្រង់ជីវិតបាន ។ នេះគឺអាស្រ័យទៅតាមប្រភេទដី និង សារពើរុក្ខជាតិ ទោះបីព្រៃនោះជាព្រៃរិចរិល ព្រៃរបោះ ឬ ក៏ជាព្រៃស្រោងក្តី ក៏អ្នកស្រុកអាចរកប្រាក់កំរៃបន្ទាប់បន្សំពីការប្រមូលអនុផលព្រៃឈើនោះបានដែរ ។ ក្រៅពីការប្រមូល រុក្ខជាតិរាប់រយមុខសំរាប់ធ្វើជាថ្នាំដង្កូវ និង ចំណីសត្វ ប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅក្នុង និង ជុំវិញតំបន់ ព្រៃបានប្រមូលស្បៀង ដើម្បី

[១០១] ការធ្វើកសិកម្មពនេចរ អាចធ្វើឱ្យព្រៃឈើដុះលូតលាស់ឡើងវិញបានបន្ទាប់ពីប្រើប្រាស់បានមួយរយៈមក ហើយទាមទារឱ្យមានព្រៃដែលមានទំហំធំ ។ ដោយសារមានការកាប់ឈើជាលក្ខណៈឧស្សាហកម្ម និង ការកាប់ឈើខុសច្បាប់ ទើបនាំឱ្យអន្តរាយដល់ព្រៃឈើយ៉ាងច្រើន ។ ជនទាំងឡាយណាដែលធ្វើកសិកម្មពនេចរ ត្រូវបានគេស្តីបន្ទោសថាបានកាប់បំផ្លាញព្រៃឈើ ហើយតាមពិតទៅប្រជាពលរដ្ឋដែលរស់នៅតំបន់ព្រៃមានទំលាប់ធ្វើកសិកម្មពនេចរប្រកបដោយនិរន្តរភាពសំរាប់រយៈពេលរាប់រយ ឆ្នាំទៅមុខ ។

បន្ថែមលើអាហារប្រចាំថ្ងៃ ឬ រក្សាទុកប្រើប្រាស់នៅពេលអត់ឃ្លាន ឬ នៅពេល ប្រមូលផលបានតិច ។ ក្លួចព្រៃ ផ្លែឈើ ផ្សិត រុក្ខជាតិជាអាហារ និងត្រីសាច់ គឺជាប្រភពនៃជាតិប្រូតេអ៊ីន ដ៏សំខាន់សំរាប់អ្នកស្រុកព្រៃ ដែលគេតែងចាត់ទុកថាជាអាហារសំរាប់បំពេញបន្ថែមលើអាហារដែលជាបាយ គេ ស្ទើរតែចាត់ទុកជាអាហារមួយដាច់ដោយឡែកទៅហើយ ។ ការរកជ័រច្បោះ ការប្រម៉ាញ់សត្វព្រៃ  និង ការ ចិញ្ចឹមសត្វពាហនៈបានផ្តល់ឱ្យគេនូវប្រាក់ចំណូលយ៉ាងច្រើន ។ នៅឃុំទីរីង ប្រជាពលរដ្ឋមូលដ្ឋានពឹងផ្អែកទាំង ស្រុងទៅលើការចោះឈើយកជ័រ គ្រួសារខ្លះមានដើមឈើផ្ទាល់ខ្លួនរហូតដល់ជាង១០០ដើមឯណោះ ។ គ្រួសារ នីមួយៗ អាចរកប្រាក់ចំណូលបាន ១០០ ដុល្លារក្នុងមួយខែពីការដងយកជ័រ ។

### ការមិនពិគ្រោះយោបល់ ការបដិសេធសិទ្ធិប្រកបរបរចិញ្ចឹមជីវិតជាប្រពៃណី និង ការភ័យខ្លាច

ការមិនបានពិគ្រោះយោបល់ ឬ ពិភាក្សាគ្រប់គ្រាន់ជាមួយសហគមន៍មូលដ្ឋាន ដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីឆន្ទៈ ឬ សមត្ថភាពរបស់ពួកគេ ក្នុងការផ្លាស់ប្តូរពីការងារជាប្រពៃណីមកការងារកសិកម្មអតិផល ឬ ពលកម្ម ដែលមានប្រាក់ឈ្នួល ជារឿយៗ គេឃើញថាសកម្មភាពដំបូងរបស់សម្បទានិកគឺជាការរំលោភ ការឈ្លានពាន ឬ ការចាប់យកដី ។ ក្នុងករណីខ្លះ ប្រធានភូមិត្រូវបានគេគាបសង្កត់ឱ្យចុះហត្ថលេខាលើឯកសារ យល់ព្រមតាមសំណើរ របស់ក្រុមហ៊ុនលើសម្បទានណាមួយ ។

សហគមន៍ខ្លះអាចការពារផលប្រយោជន៍របស់ខ្លួនបាន តាមរយៈការតវ៉ា ពាក្យបណ្តឹង និង ការធ្វើបាតុកម្ម ។ នៅកន្លែងផ្សេងទៀត ដែលអ្នកស្រុកងាយទទួលរងគ្រោះជាងនេះ ពួកគេមានការលំបាកក្នុងការលើក យកកង្វល់របស់ខ្លួនមកធ្វើការដោះស្រាយ ។

ក្នុងសភាពការណ៍នៃទំនាស់នេះ មន្ត្រីសាធារណៈគ្រប់ជាន់ថ្នាក់ ជាធម្មតាបានបង្ហាញពីភាពលំអៀងទៅរកពួកក្រុមហ៊ុន ។ នៅពេលមានទំនាស់កើតឡើង ឧទាហរណ៍រវាងក្រុមហ៊ុនផលិតម្សៅដំឡូងមី និងប្រជាពលរដ្ឋមូលដ្ឋានក្នុងឃុំអូរស្វាយ កាលពីខែមីនា ឆ្នាំ២០០០ មន្ត្រីមួយក្រុម --រួមមានអភិបាលខេត្ត មេបញ្ជាការកងរាជអាវុធហត្ថ ស្នងការនគរបាល និង អភិបាលស្រុក--បានមកមន្ទីរឃុំ ប្រាប់អ្នកស្រុកឱ្យឈប់ប្តឹងក្រុមហ៊ុន ហើយថាពាក្យបណ្តឹងរបស់ពួកគេ ប្រៀបបាននឹងការទិះទៀនដល់រាជរដ្ឋាភិបាលអញ្ចឹងដែរ ។ មានរឿង រ៉ាវស្រដៀងគ្នានេះ កាលពីខែមករា ឆ្នាំ២០០៤ មានមន្ត្រីជាន់ខ្ពស់មួយរូបនៃរាជរដ្ឋាភិបាល ត្រូវបានគេ រាយការណ៍ ថាបានទៅទស្សនា នៅឃុំត្រែងត្រយឹង ក្នុងខេត្តកំពង់ស្ពឺ ជាកន្លែងក្រុមហ៊ុនស៊ីជេប្រើប្រាស់សម្បទានរបស់ខ្លួន ។ មន្ត្រីរូបនោះបានប្រាប់អ្នកស្រុកថា ពួកគេត្រូវប្រុងប្រយ័ត្នឱ្យមែនទែនចំពោះពាក្យបណ្តឹងរបស់ខ្លួន  ហើយបានស្តីបន្ទោសដល់អង្គការសិទ្ធិមនុស្សក្នុងស្រុកថា ជាអ្នកញុះញង់ឱ្យមានពាក្យបណ្តឹងនេះ ។ ហេតុការណ៍នេះកើតមាន បន្ទាប់ពីលោកតំណាង

ពិសេសបានផ្ញើរញ្ញត្តិរបស់ប្រជាពលរដ្ឋចំនួន ២២២គ្រួសារនៅឃុំត្រែងត្រយឹង ជូនសម្តេចនាយករដ្ឋមន្ត្រីដោយផ្ទាល់ក្នុងខែធ្នូ ឆ្នាំ២០០៣ ដែលបានលើកឡើងពីកង្វល់មួយចំនួន។

ក្រុមហ៊ុនបានកាប់ឆ្ការ និងឈូសឆាយព្រៃ ដែលប្រជាពលរដ្ឋមូលដ្ឋានពឹងពាក់។ ក្រុមហ៊ុនទាំងនោះបានបដិសេធមិនឱ្យប្រជាពលរដ្ឋចូលក្នុងព្រៃ ដើម្បីប្រកបរបរចិញ្ចឹមជីវិត។ សកម្មភាពរបស់ក្រុមហ៊ុនផលិតម្សៅដំឡូងមី នៅស្ទឹងត្រែង បានបំផ្លិចបំផ្លាញព្រៃស្រោង និងព្រៃសំខាន់ៗ  ប្រភពទឹក និង សត្វព្រៃដែលរស់នៅទីជិតខាងតំបន់សហគមន៍ និងធ្វើឱ្យផ្នែកខ្លះនៃដីសម្បទានក្លាយទៅជាដីដែលគ្មានប្រយោជន៍។ ការកាប់រំលំព្រៃឈើ និងដើមច្បោះនៅឃុំទីរីង គឺជាការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន  ហើយការកាប់ឈើចេះតែបន្ត ដោយមិនគិតគូរអើពើពីការហាមប្រាមការកាប់ដើមច្បោះ និង សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីការផ្អាកជាបណ្តោះអាសន្នរាល់ការកាប់ឈើក្នុងព្រៃសម្បទានឡើយ។[១០២] ក្រុមហ៊ុនស៊ីជេ បានជីកប្រឡាយមួយខ្សែ នៅឆ្នាំ២០០២ ព័ទ្ធជុំវិញដីសម្បទានរបស់ខ្លួន ដើម្បីកុំឱ្យប្រជាពលរដ្ឋមូលដ្ឋានចូលក្នុងតំបន់សម្បទានរបស់ខ្លួនបាន ដែលនេះគឺជាការបដិសេធសិទ្ធិរបស់ពួកគេ ក្នុងការចូលរកអុសដុត និង ស្មៅសំរាប់ឱ្យសត្វពាហនៈធ្វើជាអាហារ។ ការហាមចូលព្រៃ ក្នុងដីសម្បទាននៃ ក្រុមហ៊ុនហៃនិញបានបង្ករឱ្យមានការលំបាកជាច្រើនដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការដុតធ្យូង និង ការប្រមូលអុសដុត ដែលជាប្រភពចំណូលមួយដ៏សំខាន់របស់ពួកគាត់បន្ទាប់ពីរយៈពេល៣ ឆ្នាំ នៃគ្រោះរាំងស្ងួត និង ការធ្វើស្រែមិនបានផលមក។[១០៣]

ក្រុមហ៊ុនបាននាំមកនូវការភ័យខ្លាចដល់សហគមន៍ ដោយការជួលកំលាំងសន្តិសុខប្រដាប់អាវុធ - ហើយជារឿយៗ ពួកគេគឺជាអតីតនាយទាហាន ឬ យោធិនរំសាយ ឬ យោធិន " អសកម្ម " ដែលទទួលប្រាក់បៀវត្សពីកងយោធពលខេមរភូមិន្ទ។[១០៤] សំរាប់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល កំលាំងសន្តិសុខប្រដាប់អាវុធ បង្ហាញជាពិសេស ពីវត្តមាននៃអំណាច និង ការបំភិតបំភ័យ។ ប្រជាពលរដ្ឋមូលដ្ឋាន ក៏បានរាយការណ៍ដែរថា ក្រុមហ៊ុនបានកាប់ឈើ ជំរិតយកប្រាក់ពីប្រជាពលរដ្ឋមូលដ្ឋាន  និង ចាប់យកដីឱ្យគ្រួសារខ្លួន។ ជារឿយៗ សម្បទានិក និងកំលាំងសន្តិសុខបានប្រព្រឹត្តក្រៅច្បាប់ រំលោភលើអនុក្រឹត្យឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង និង ការត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និង ការប្រើអាវុធជាតិផ្ទុះគ្រប់ប្រភេទ។ វត្តមាននៃកង

[១០២] មាត្រា២៩ នៃច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ចែងហាមឃាត់ការប្រមូលផល " ឈើគ្រប់ប្រភេទដែលប្រជាជនមូលដ្ឋានកំពុងចោះយកជ័រជាប្រពៃណី "។ នៅមុនការអនុម័តច្បាប់ព្រៃឈើ មាត្រា១៧ នៃវិធានស្តីពីការប្រើប្រាស់ព្រៃឈើ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៨ បានចែងថា " ការកាប់រំលំដើមច្បោះ ត្រូវហាមឃាត់"។ មាត្រា១៥នៃសៀវភៅស្តីពីការប្រើប្រាស់ព្រៃគុបចែង : " *ហាមកាប់ដើមច្បោះដែលប្រជាជនកំពុងចោះយកជ័រ។ ដើមច្បោះដែលមានទទឹងមុខកាត់ (បន្ទាត់ផ្ចិត) លើស ពី១,២០ ម៉ែត្រ ឬ ដែលមិនមានការចោះយកជ័រ ឬ ដែលម្ចាស់បានបោះបង់ចោល អាចកាប់រំលំបាន*"។ មាត្រា២៩ នៃច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ចែងហាមឃាត់ ការប្រមូលផល " ឈើគ្រប់ប្រភេទដែលប្រជាជនមូលដ្ឋានកំពុងចោះយកជ័រជាប្រពៃណី "។

[១០៣] គ្រួសារនីមួយៗ អាចរកប្រាក់ចំណូលបានរវាងពី២០- ៤៥ ដុល្លារ ក្នុងមួយខែពីការលក់ធ្យូង។

[១០៤] " អសកម្ម " គឺជាពាក្យមួយដែលបានប្រើប្រាស់នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ។

សន្តិសុខ និង អាវុធនៅលើដីសម្បទានអាចនាំឱ្យមានអំពើហិង្សាដែលមិនអាចគ្រប់គ្រងបាន ។ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៣ ជាអាទិ៍ មានបុគ្គលិកម្នាក់នៃក្រុមហ៊ុនផលិតម្សៅដំឡូងមី ក្នុងខេត្តស្ទឹងត្រែងបានសំលាប់បងថ្លៃរបស់ខ្លួន ដោយប្រើកាំភ្លើងអាកា៤៧ របស់សន្តិសុខក្រុមហ៊ុន ហើយនៅខែឧសភា ឆ្នាំ២០០៣ សន្តិសុខម្នាក់ត្រូវបានគេរាយការណ៍ថា ត្រូវអ្នកភូមិសម្លាប់ដោយសារសន្តិសុខរូបនោះបានជំរិតយកប្រាក់ពីអ្នកភូមិមួយរូប ។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិធ្វើការជាមួយសហគមន៍នានាដែលទទួលរងផលប៉ះពាល់ ក៏ត្រូវបានទទួលរងផលប៉ះពាល់ដែរ ។ អង្គការលូថេរ៉ាន់បំរើពិភពលោក (Lutheran World Federation) មានគំរោងអភិវឌ្ឍន៍មួយចំនួន នៅខេត្តកំពង់ស្ពឺ ដើម្បីជួយដល់ប្រជាពលរដ្ឋមូលដ្ឋាន ក្នុងការតាំងលំនៅ ចាប់ពីឆ្នាំ១៩៩៧ គឺនៅមុនពេលដែលក្រុមហ៊ុនស៊ីជេ ត្រូវ បានផ្តល់សម្បទានរបស់ខ្លួនម្ល៉េះ ។ អង្គការនេះបានសាងសង់លំនៅដ្ឋានសហគមន៍នៅភូមិអូរកូនត្រុំ [១០៥] ស្ថិតនៅ ក្បែរដីសម្បទានដំបូងរបស់ក្រុមហ៊ុនស៊ីជេ ត្រូវបានជនមិនស្គាល់ឈ្មោះដុតបំផ្លាញ កាលពីខែមិថុនា ឆ្នាំ២០០៣ ក្នុងពេលមួយដ៏ខ្លីបន្ទាប់ពីមានការប្រជុំជាមួយប្រជាពលរដ្ឋ ។ គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួនក្នុងការដុតបំផ្លាញ នេះទេ ។

ស្រុកជាច្រើន នៅក្នុងខេត្តកំពង់ស្ពឺ ក្នុងនោះមានស្រុកភ្នំស្រួច គឺជាតួយ៉ាងមួយនៃជំលោះហឹង្សា ដែលកើតមានចំពោះការផ្តល់សម្បទានដី នៅក្នុងតំបន់អភិវឌ្ឍន៍យោធា ។ តំបន់ទាំងនេះពីមុនមក គឺជាតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម នៅដើម ឆ្នាំ១៩៩០ លុះក្រោយមក តំបន់នោះបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់កំលាំងយោធានៃរដ្ឋាភិបាល ។ នៅក្នុងខែតុលា ឆ្នាំ១៩៩៦ កងពលលេខ៣០៥ របស់ខ្មែរក្រហម បានរត់ចោលជួរចូលមករាជរដ្ឋាភិបាល ។ នៅក្នុងពិធីធ្វើសមាហរណកម្ម កាលពីខែមេសា ឆ្នាំ១៩៩៧ មានទាហានខ្មែរក្រហមរត់ចោលជួរ ៣០០ នាក់ ត្រូវបានរាជរដ្ឋាភិបាលសន្យាថានឹងផ្តល់ដីធ្លីសំរាប់ធ្វើផ្ទះសម្បែង និង ធ្វើចំការក្រោមរូបភាពជា " តំបន់សមាហរណកម្មជាថ្មី " ដែលមានផ្ទៃដីប្រមាណជា ១០០០ហិកតា ។ បច្ចុប្បន្ននេះ ភាគច្រើននៃដីទាំងនេះ ស្ថិតនៅក្រោមការត្រួតត្រារបស់ក្រុមហ៊ុនហ្គោលដេនលេន ចំកាត់ ដែលរាជរដ្ឋាភិបាលបានផ្តល់ដីសម្បទាននេះ កាលពីខែមីនា ឆ្នាំ២០០៤ ដូចបានពិពណ៌នានៅផ្នែកខាងដើមនៃរបាយការណ៍នេះ ។ ប្រជាពលរដ្ឋមូលដ្ឋានបានអះអាងថាពួកគេ បានដឹងតិចតួចណាស់ពីក្រុមហ៊ុននេះ សូម្បីតែឈ្មោះកម្មសិទ្ធិករ និងប្រភេទដំណាំដែលក្រុមហ៊ុននោះមានបំណងចង់ដាំក៏ពួកគេមិនបានដឹងផងដែរ ។ តាមការស្ទង់មតិរបស់មន្ត្រីអធិការកិច្ចមួយក្រុម ដែលបានធ្វើឡើងកាលពី ខែមករា ឆ្នាំ២០០៣ លើដីសម្បទានដែលបានស្នើមួយកន្លែង បន្ទាប់ពីមានសេចក្តីរាយការណ៍ថា មានដីជាង ៤០០ ហិកតា ជារបស់ប្រជាពលរដ្ឋមូលដ្ឋានត្រូវបានកាត់ចេញពីតំបន់ដីសម្បទានដែលបានស្នើ ។ កាលពីខែសីហាឆ្នាំ ២០០៣ មេឃុំដែលបានចូលរួមក្នុងការស្ទង់មតិបានលក់ដីជាង២០០ហិកតា នៃដីដែលបានគ្រោងទុកសំរាប់ផ្តល់ឱ្យក្រុមហ៊ុនហ្គោលដេល លេន ចំកាត់ ទៅឱ្យគ្រួសារប្រជាពលរដ្ឋមកពីរាជធានីភ្នំពេញ ។ គ្រួសារប្រជាពលរដ្ឋទាំង

---

[១០៥] កាលពីខែឧសភា ឆ្នាំ២០០១ ក្រុមហ៊ុនបានធ្វើការឈូសឆាយដីកសិកម្មរបស់ប្រជាពលរដ្ឋចំនួន ៤៧ គ្រួសារ នៅក្នុងភូមិអូរកូនត្រុំ ។

នោះបានអះអាងថា ពួកគេមិនដឹងថាមានក្រុមហ៊ុននៅទីនោះទេ រហូតដល់មានកងសន្តិសុខចាប់ផ្តើមធ្វើការហាមឃាត់មិនឱ្យដាំដុះ កាប់ឆ្ការ ឬ អភិវឌ្ឍន៍ដីនោះ ។ ទាហានប្រដាប់អាវុធ២ក្រុម ត្រូវបានបញ្ជូនពីនាយកដ្ឋានអភិវឌ្ឍន៍នៃកងយោធពលខេមរភូមិន្ទ ដើម្បីការពារកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុន ។ [១០៦] នៅខែកក្កដា ឆ្នាំ២០០៤ មានពាក្យបណ្តឹងមួយដែលមានរាយឈ្មោះប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ចំនួន ៥១៨ នាក់ ត្រូវបានដាក់ស្នើទៅខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី ។

## លក្ខខណ្ឌការងារ និង ពលកម្ម

ប្រជាពលរដ្ឋនៅតំបន់ជនបទមានទម្លាប់ប្រកបការងារកសិកម្ម ដែលមានរូបភាពជាគ្រួសារស្វ័យត ការផ្លាស់ប្តូរពីការងារកសិកម្ម ទៅជាការងារមានប្រាក់ឈ្នួល ត្រូវបានគេយល់ថាជាការងារដោយបង្ខំ :

*" ខ្ញុំធ្លាប់តែចូលព្រៃ នៅពេលណាដែលខ្ញុំចង់ ឬ ត្រូវការអ្វីមួយ ។ ខ្ញុំមានសេរីភាពក្នុងការសំរេច ចិត្តថាទៅថ្ងៃ ណា ។ ក្រុមហ៊ុននឹងបង្ខំខ្ញុំឱ្យធ្វើការនៅពេលដែលគេចង់ ។ ខ្ញុំជាមនុស្សចូលចិត្តសេរីភាព ។ ប្រសិនបើខ្ញុំចង់ទិញ ឬដូររបស់អ្វីមួយ ខ្ញុំចូលទៅក្នុងព្រៃ ដើម្បីប្រមូលយកជ័រ ។ នៅព្រឹកណាមួយ ដែលខ្ញុំចង់សំរាកនៅផ្ទះ គឺខ្ញុំសំរាក ខ្ញុំអាចសំរាកបានភ្លាម ។ ខ្ញុំមានសេរីភាព ។ ខ្ញុំមិនចង់ក្លាយខ្លួនជាទាសកររបស់ក្រុមហ៊ុនទេ ។"* [១០៧]

មនោសញ្ចេតនាស្រដៀងគ្នានេះត្រូវបានបង្ហាញក្នុងការសិក្សាស្រាវជ្រាវផ្សេងទៀត ។ [១០៨]

បញ្ជីដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានផ្តល់ឱ្យបង្ហាញថា ក្រុមហ៊ុនហៃនិញ បានគ្រោងជួលកម្មករចំនួន ៤៦៦៩ នាក់ ចំណែកឯក្រុមហ៊ុនផលិតម្សៅដំឡូងមីវិញ បានគ្រោងជួលកម្មករចំនួន៧៧៤ នាក់ ។ រហូតមកដល់ពេលនេះ មានប្រជាពលរដ្ឋមូលដ្ឋានមួយចំនួនតូច ត្រូវបានជួលឱ្យធ្វើការងារ ហើយជាទូទៅ កម្មករទាំងនោះបានទទួលប្រាក់ ឈ្នួលតិចជាងមួយដុល្លារក្នុងមួយថ្ងៃ ។ នៅដីសម្បទានរបស់ក្រុមហ៊ុនហៃនិញ ប្រជាពលរដ្ឋមូលដ្ឋានបានបញ្ជាក់ប្រាប់ថា ក្រុមហ៊ុនបានជួលប្រជាពលរដ្ឋមូលដ្ឋានប្រមាណជា ២០នាក់ ហើយបើតាមសេចក្តីរាយការណ៍អ្នកទាំង នោះគ្រាន់តែជាអ្នកនាំផ្លូវចូលក្នុងព្រៃ ដើម្បីជួយបង្ហាញប្រាប់ពីធនធានឈើដែលមានគុណភាពខ្ពស់តែ

---

[១០៦] លិខិតបេសកកម្ម ដែលបានចុះហត្ថលេខាដោយលោកវរសេនីយទោ ហង្ស ចំរ៉ុង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤ ។

[១០៧] អ្នកភូមិម្នាក់រស់នៅក្នុងភូមិរន្ទះ, ចំការកៅស៊ូទីរីង ។

[១០៨] ឧទាហរណ៍ របាយការណ៍ស្តីពីទិដ្ឋភាពនៃការរស់នៅ និង ការងាររបស់អ្នកភូមិ នៅក្នុងចំការកៅស៊ូមួយ នាខេត្តកំពង់ចាម ។ " នៅពេលធ្វើការសាកសួរសុំឱ្យធ្វើការប្រៀបធៀបពីជីវភាពរស់នៅរបស់ពួកគេជាមួយកសិករដែលក្រីក្រ អ្នកភូមិភាគច្រើនបាននិយាយថាពួកគេចង់ធ្វើជាកសិករជាង បើទោះបីជាគេផ្តល់ផ្ទះសម្បែង ទឹកភ្លើង ដោយឥតគិតថ្លៃនៅក្នុងចំការកៅស៊ូក្តី ។ អ្នកភូមិភាគច្រើនបានរអ៊ូរទាំពីការងារធ្ងន់ គ្មានពេលសំរាក ហើយគ្មានសេរីភាព នៅក្នុងចំការកៅស៊ូ ។ ជារឿយៗ ពួកគេបានធ្វើការប្រៀបប្រដូចទៅនឹងទាសករ និង លក្ខខណ្ឌការងារនៅក្នុងរបបប៉ុល ពត ហើយវាខុសគ្នាត្រង់ការមានប្រាក់ឈ្នួល និង ការហូបចុកគ្រប់គ្រាន់តែប៉ុណ្ណោះ ។" ការសិក្សាស្រាវជ្រាវរបស់អង្គការ CAS ឆ្នាំ២០០១ វាក្យខ័ណ្ឌទី៦.៦ ស្តីពីទិដ្ឋភាពនៃការការងារ និង ជីវិតរស់នៅនាពេលបច្ចុប្បន្ន និង នៅថ្ងៃអានាគត ។

ប៉ុណ្ណោះ ។ ចំណែកក្រុមហ៊ុនផលិតម្សៅដំឡូងមី វិញ បានជួលប្រជាពលរដ្ឋមូលដ្ឋានចំនួនពី៣០ ទៅ៨០ នាក់ឱ្យធ្វើការងារម្តងម្កាល ដើម្បីដាំដើមម៉ៃសាក់ ។

ជានិច្ចកាលសម្បទានិកតែងមានការងាយស្រួល ក្នុងការស្វែងរកជួលកម្មករនៅក្រៅសហគមន៍មូលដ្ឋានច្រើនជាង ពីព្រោះកម្មករទាំងនោះត្រូវបានគេចាត់ទុកថាមានជំនាញ មានការទាមទារតិច ឬ ហាក់ដូចជាបង្ករបញ្ហាតិចជាងប្រជាពលរដ្ឋមូលដ្ឋាន ។ ជាឧទាហរណ៍ នៅចំការកៅស៊ូទីរ៉ង ក្រុមហ៊ុននឹងជួលកម្មករជំនាញពីខេត្តកំពង់ចាម ដើម្បីបំបាក់កម្មករមូលដ្ឋានដែលគេគិតថាធ្វើការយឺតយ៉ាវពេក ។ នៅឃុំអូរស្វាយ ក្រុមហ៊ុនបានជួលប្រជាជនក្រីក្របំផុតពីឃុំនានាដែលនៅជិតទីនោះ ព្រោះក្រុមហ៊ុនមានទំនាស់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ហើយដោយសារប្រាក់ឈ្នួល ៥០០០រៀល ($១.២៥) មិនអាចទាក់ទាញទឹកចិត្តអ្នកភូមិដែលធ្លាប់រកបានប្រាក់ចំណូលច្រើនជាងនេះ ។ ក្រុមហ៊ុនស៊ីជេ ជៀសវាងមិនជួលកម្មករពីឃុំត្រែងត្រយឹងទេ ផ្ទុយទៅវិញ គេបានរៀបចំការដឹកជញ្ជូនកម្មករដោយឥតគិតថ្លៃពីឃុំមហាសុង ដែលនៅជិតទីនោះ ព្រមទាំងជៀសវាងមិនឱ្យកម្មករតាំងទីលំនៅៗក្នុងតំបន់ដីសម្បទាននោះទៀតផង ។ កម្មករបានទទួលប្រាក់ឈ្នួល ៣០០០រៀល ($០.៧៥) ក្នុងមួយថ្ងៃ បើកជាប្រាក់ថ្ងៃ ឬ សំរាប់ការងារមួយចំណែក គឺការដាំដំណាំ ឬ ការសំអាតស្មៅ ។

ទីណាដែលមានជួលកម្មករមូលដ្ឋាន ការជ្រើសរើសអាចជាយានសំរាប់ការធ្វើជំនួញ និង ការសូកប៉ាន់ ។ តាមធម្មតាក្រុមហ៊ុនទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន ដូចជាមេឃុំ និង ប្រធានភូមិ ហើយអ្នកដែលមានទំនាក់ទំនងជាមួយអាជ្ញាធរ អាចជាសាច់ញាតិ ជាមិត្តភ័ក្ត្រ ឬ មានទំនាក់ទំនងខាងនយោបាយ ងាយស្រួលរកការងារភាគច្រើនដែលផ្តល់កម្រៃខ្ពស់ ។

នៅចំការដូងប្រេងរបស់ក្រុមហ៊ុនម៉ុង ឬទ្ធី នៅក្រុងព្រះសីហនុ ការងារត្រូវបានរៀបចំជាក្រុមដែលមានកម្មករចាប់ពី២០ ទៅ ៣០នាក់ ដែលដឹកនាំដោយប្រធានក្រុមមួយរូប ។ អាស្រ័យលើការងារដែលសំរេចបាន ប្រធានក្រុមទទួលប្រាក់កំរៃពី១០.០០០ រៀល ទៅ២០.០០០រៀល ចំណែកកម្មករវិញទទួលប្រាក់កំរៃពី ២០០០ រៀល ទៅ ៥០០០រៀលក្នុងមួយថ្ងៃ គឺគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតមួយថ្ងៃតែប៉ុណ្ណោះ ។

កាលពីខែកញ្ញា ឆ្នាំ២០០២ មានកម្មករចំនួន៨៥ នាក់ មកពីសាធារណរដ្ឋប្រជាមានិតចិន ដែលបានជ្រើសរើសឱ្យបំរើការងារដោយ ក្រុមហ៊ុនហេណាន់តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច និងពាណិជ្ជកម្ម (Henan Economic and Trade Development Zone) បានបោះជំរុំនៅខាងក្រៅស្ថានទូតចិន ក្នុងរាជធានីភ្នំពេញ ស្រែកតវ៉ាថាក្រុមហ៊ុនបានដកហូតយកលិខិតឆ្លងដែនរបស់ពួកគេ មិនបង់ប្រាក់ឈ្នួល និង ឈប់ផ្គត់ផ្គង់អាហារឱ្យខ្លួន ។ កម្មករទាំងនោះបាន

និយាយថាពួកគេបានជំពាក់បំណុលដើម្បីបង់ឱ្យថ្លៃឈ្នួលអ្នកជ្រើសរើសមនុស្សធ្វើការនៅឯស្រុកកំណើតរបស់ ហើយ បានស្នើសុំឱ្យស្ថានទូតជួយដល់ពួកគេក្នុងការធ្វើមាតុភូមិនិវត្តន៍វិញ ។[១០៩]

នាពេលថ្មីៗនេះ មានរបាយការណ៍គួរឱ្យព្រួយបារម្ភជាច្រើន បង្ហាញឱ្យឃើញអំពីលក្ខខណ្ឌនៃក្រុមហ៊ុនសម្បទានហ្គ្រីនរិច នៅខេត្តកោះកុង ។ ក្រុមហ៊ុនបានជ្រើសរើសកម្មករ តាមរយៈអ្នកម៉ៅការបន្ត ។ កម្មករក្រុមទីមួយបានមកដល់តំបន់ដីសម្បទាននោះ នៅពាក់កណ្តាលខែមីនា ឆ្នាំ២០០៤ កម្មករទាំងនោះត្រូវបានជ្រើសរើសពីខេត្តផ្សេងៗ ដូចជាខេត្តកំពត តាកែវ កំពង់ចាម និងខេត្តក្រចេះ ។ កម្មករទាំងនោះ ត្រូវបានផ្តល់ប្រាក់កម្ចីសំរាប់ជាប្រាក់ឈ្នួលការងារ ថ្លៃធ្វើដំណើរ និងប្រាក់កាសមួយចំនួនទៀត សំរាប់ទុកឱ្យគ្រួសារចិញ្ចឹមជីវិត ។ ក្រោយពេលជ្រើសរើសរួចហើយ ក្រុមហ៊ុនបានប្រាប់ថានឹងបង់ប្រាក់ឱ្យពួកគេក្នុងម្នាក់ៗចំនួន ១០.០០០រៀល ក្នុងមួយថ្ងៃ ប៉ុន្តែនៅពេលមកដល់ ទើបពួកគេបានដឹងថាការបង់ប្រាក់ឈ្នួល គឺធ្វើទៅតាមចំនួនឈើដែលបាននាំយកមកគរទុកនៅ " កន្លែងស្តុកឈើ " ក្នុងអាត្រាប្រាក់ ៤.០០០រៀល ក្នុងមួយតោន ។ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៤ មានកម្មករចំនួន២០ នាក់បានលួចរត់ចេញពីដីសម្បទាន ហើយបានស្នើសុំឱ្យនគរបាលជួយការពារពួកគេ ។ រហូតមកទល់ថ្ងៃទី១០ ខែឧសភា មិនទាន់មានកម្មករណាម្នាក់បានទទួលប្រាក់ឈ្នួលនៅឡើយទេ ។ អ្នកម៉ៅការបន្តទាំងអស់បានគ្រប់គ្រងលើគ្រឿងផ្គត់ផ្គង់ និង ថ្លៃអាហារ ដោយយល់ថាមិនមានស្បៀងអាហារអាចរកបាននៅកន្លែងនោះ ។ កម្មករត្រូវតែខ្ចីបុលពីអ្នកទាំងនោះ ដើម្បីទិញម្ហូបអាហារ ហើយត្រូវតែសងវិញ នៅមុនពេលចេញពីតំបន់នោះ ។ ទាហានប្រដាប់អាវុធ កងរាជអាវុធហត្ថ និង នគរបាល ត្រូវបានក្រុមហ៊ុនជួលឱ្យផ្តល់ការការពារ ។[១១០] អ្នកម៉ៅការបន្ត និង ក្រុមហ៊ុនឆ្លើយដាក់គ្នាអំពីការទទួលខុសត្រូវលើលក្ខខណ្ឌរបស់កម្មករ ទោះបីជាដឹងច្បាស់ថា សម្បទានិកជាអ្នកទទួលខុសត្រូវចុងក្រោយក៏ដោយ ។[១១១]

## ការជម្លៀស

ការជម្លៀសប្រជាពលរដ្ឋកើតមាននៅតំបន់ដីសម្បទានខ្លះ ។ ករណីនេះ មាននៅដីសម្បទាននៃក្រុមហ៊ុនស៊ីជេកម្ពុជា ។ ក្នុងកំឡុងឆ្នាំ១៩៩៧ មានប្រជាពលរដ្ឋចំនួន៥៦ គ្រួសារបានតាំងទីលំនៅៗក្នុងភូមិក្រោលទន្សោងចាស់ ឃុំត្រែងត្រយឹង ។ ប្រជាពលរដ្ឋទាំងនោះបានទទួលលិខិតបញ្ជាក់ថា ពួកគេត្រូវបានផ្តល់ជាផ្ទះសម្បែង និង ដី

[១០៩] ជាយកថាហេតុ ស្ថានទូតបានផ្តល់ការជួយឧបត្ថម្ភចាំបាច់ដល់ពួកគេ ដើម្បីវិលត្រលប់ទៅស្រុកវិញ ដកស្រង់ពីកាសែតខាំបូឌាដេលី អត្ថបទ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០២ ដែលមានចំណងជើងថា "កម្មករជនជាតិចិនដែលមានកំហឹងបានស្នើរសុំអោយស្ថានទូតជួយ" ដោយលោក សាំង សឿងរិទ្ធិ ។

[១១០] លិខិតចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ របស់លោកវ៉ាំងសង់ ចាន់ (Vincent Chan) តំណាងក្រុមហ៊ុនគ្រីនរិច ផ្ញើជូនអភិបាលខេត្តកោះកុង ស្នើសុំបុគ្គលិកសន្តិសុខដើម្បីការពារដីសម្បទាន ។

[១១១] សូមអានកាសែតខាំបូឌៀដេលី ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ និង ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៤ ។

កសិកម្ម ។ ពួកគេបានកាប់ឆ្ការដី និង ដាំស្រូវ ។ នៅខែឧសភាឆ្នាំ២០០១ គេបានអញ្ជើញអ្នកភូមិ ដើម្បីចូលរួមប្រជុំជាមួយអភិបាលស្រុក មេឃុំ មន្ត្រីយោធា និងតំណាងក្រុមហ៊ុនស៊ីដេកម្ពុជា ។ ការប្រជុំនោះមានទាហានប្រដាប់ដោយអាវុធព័ទ្ធជុំវិញ ។ គេបានប្រាប់ប្រជាពលរដ្ឋថា ឥឡូវនេះដីទាំងនេះ គឺជាដីរបស់ក្រុមហ៊ុនហើយៗ ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងដែនដីសម្បទាននេះត្រូវរុះរើចេញ ។ ដោយមានការភ័យខ្លាចកំលាំងសន្តិសុខប្រដាប់អាវុធប្រើអំពើហឹង្សាមកលើរូបខ្លួន ទើបមានប្រជាពលរដ្ឋចំនួន៣៤គ្រួសារបានយល់ព្រមរុះរើចេញទៅនៅភូមិថ្មីមួយទៀត គឺភូមិក្រោលទន្សោងថ្មី ។ គេបានផ្តល់ឱ្យជាសម្ភារៈមានទូរអង្ករ៥០ គីឡូក្រាម ដែកគោល៣ គីឡូក្រាម ឈើ បង្គង់១០០ដើម ដីដែលបានឈូសឆាយរួចមួយកន្លែងមានទំហំ៣០ម៉ែត្រ គុណនឹង៤០០ម៉ែត្រ និងការដឹកជញ្ជូនទៅកាន់ភូមិថ្មី ។ នៅពេលមកដល់ គ្រួសារទាំងនោះនិយាយថា គេបានទទួលដីមួយកន្លែងទំហំ៣០ ម៉ែត្រ គុណ និង៥០ ម៉ែត្រតែប៉ុណ្ណោះ ហើយដីនោះទៀតសោធ គឺជាដីដែលមានគុណភាពទាបជាងដីភូមិរបស់គេពីមុន ។ ចំណែកប្រជា ពលរដ្ឋចំនួន២២គ្រួសារទៀត ដែលប្រកែកមិនព្រមចាកចេញពីទីនោះ ត្រូវបានបុគ្គលិកសន្តិសុខបំភិតបំភ័យ ។ [១១២] នៅ ពេលដែលគ្រួសារប្រជាពលរដ្ឋទាំងនេះ សុំជួបជាមួយនឹងតំណាងក្រុមហ៊ុនស៊ីដេកម្ពុជា ដើម្បីពិភាក្សាអំពីការទទួលស្គាល់សិទ្ធិកម្មសិទ្ធិរបស់គេ សន្តិសុខបានប្រាប់ថា "ពួកអ្នកឯងជាជនសាមញ្ញ គ្មានសិទ្ធិចូលជួបតំណាងក្រុមហ៊ុនទេ" ។

ដីសម្បទានរបស់ក្រុមហ៊ុនហៃនិញ នៅស្រុកភ្នំឱរ៉ាល់ និងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ស្ថិតនៅក្នុងតំបន់ដែលមានប្រជាពលរដ្ឋជាង៨៩០០នាក់រស់នៅ ។ ពួកគេរស់នៅក្នុងភូមិចំនួន២៦ ដែលភាគច្រើនគឺជាប្រជាពលរដ្ឋដែលបានវិលត្រឡប់មកស្រុកភូមិខ្លួនវិញ នៅឆ្នាំ១៩៩៧ និង១៩៩៨ ក្រោយពេលសង្គ្រាមត្រូវបានបញ្ចប់ ។ ប្រជាពលរដ្ឋសព្វថ្ងៃនេះ មានសមាសភាពអ្នកភូមិចាស់ដែលត្រូវគេជម្លៀសក្នុងស្រុក អតីតគ្រួសារខ្មែរក្រហម និងគ្រួសារប្រជាពលរដ្ឋដែលគ្មានដីធ្លីមកពីតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ។ ក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋានបានបញ្ជាឱ្យពួកគេឈប់ប្រើដីកសិកម្ម និង ព្រៃឈើនៅក្នុងដីសម្បទាន ហើយគ្រួសារខ្លះត្រូវបានគេប្រាប់ឱ្យចាកចេញពីផ្ទះរបស់ខ្លួន ។ នៅភូមិអូរថ្កៅ មានទីស្នាក់ការក្រុមហ៊ុនហៃនិញស្ថិតនៅ នៅពេលចាប់ផ្តើមធ្វើការឈូសឆាយដី នៅឆ្នាំ ២០០២ ក្រុមហ៊ុនបានប្រាប់ប្រជាពលរដ្ឋមូលដ្ឋានឱ្យឈប់ប្រើប្រាស់ដីនៅក្នុងតំបន់សម្បទាននោះតទៅទៀត ហើយត្រូវចាកចេញពីទីនោះ ។ ក្រុមហ៊ុនបានដៅចំពោះជនណាដែលបានសាងសង់ផ្ទះ ក្រោយពេលចុះកិច្ចសន្យាសម្បទានក្នុងឆ្នាំ១៩៩៨ ។ អ្នកស្រុកបានទាមទារឱ្យមន្ត្រីថ្នាក់ភូមិ ឃុំ និងស្រុកអនុញ្ញាតឱ្យពួកគេ កាន់កាប់ដីធ្លី មុនពេលគេចាប់ផ្តើមសាងសង់ផ្ទះសម្បែង ។ អ្នកស្រុកខ្លះ ត្រូវបានគេផ្តល់ដីផ្សេងទៀតជាជំរើស ប៉ុន្តែអ្នកស្រុក ភាគច្រើន

---

[១១២] ឧទាហរណ៍ គោរបស់ប្រធានភូមិត្រូវគេបាញ់សំលាប់ ហើយក្បាល និង ពោះវៀនរបស់វាត្រូវគេយកទៅដាក់លើរបងផ្ទះ ។

និយាយថាដីនោះមិនសមស្រប អាចជាដីចំការមីន គ្មានប្រភពទឹកនៅជិតនោះ គ្មានសាលារៀន និង គ្មានមជ្ឈមណ្ឌលសុខភាព។ ក្រុមហ៊ុនមិនបានបង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធ ឬ ការផ្ទេរផ្ទះសម្បែងឡើយ។

គេព្រួយបារម្ភថា គ្រួសារប្រជាពលរដ្ឋដែលបានជម្លៀសជាច្រើនគ្រួសារទាំងនោះ នឹងមិនមានជំរើសផ្សេងក្រៅតែពីការធ្វើដំណើររសាត់អណ្តែតទៅកាន់ទីក្រុងភ្នំពេញ ដើម្បីចូលរួមបង្កើនចំនួនជនក្រីក្រនៅទីក្រុង និងក្រុមកសិករដែលគ្មានដីធ្លី ឬ ស្វែងរកដីផ្សេងទៀត ដើម្បីទន្ទ្រានយកដី។

## ការទន្ទ្រានយកដី

បើតាមក្រសួងកសិកម្ម មានសម្បទានិកចំនួន១៦ រូបបានប្តឹងថាមានអ្នកតាំងទីលំនៅថ្មី បានរុករានទន្ទ្រានលើដីសម្បទានរបស់ខ្លួន និង អំពីជំលោះផ្សេងៗ ព្រមទាំងការប្តឹងផ្តល់របស់ប្រជាពលរដ្ឋមូលដ្ឋាន។ ជារឿយៗ ការប្រកាសថានឹងមានដីសម្បទាននៅពេលអនាគត បានទាក់ទាញប្រជាពលរដ្ឋក្រីក្រជាពិសេស ចំពោះតំបន់ដីសម្បទាន ដោយសង្ឃឹមថានៅពេលអានាគតពួកគេនឹងមានការងារធ្វើ  ឬ ដោយមានជំនឿថាប្រសិនបើគេកាប់ឆ្ការដី ក្រុមហ៊ុននឹងទិញដីនោះពីពួកគេ។ អ្នកតាំងទីលំនៅថ្មី បង្កើតបញ្ហា និងជម្លោះជាច្រើន។ គេសង្កេតឃើញថាអាជ្ញាធរមូលដ្ឋានមានឥរិយាបទពឹងផ្អែកលើទំនាក់ទំនងរបស់ខ្លួនជាមួយសម្បទានិក : អាជ្ញាធរទាំងនោះអាចបន្តអនុញ្ញាតឱ្យប្រជាពលរដ្ឋតាំងទីលំនៅលើដីរបស់ក្រុមហ៊ុនទៅទៀត ឬ គេអាចឃាត់ឃាំងអ្នកតាំងទីលំនៅថ្មី ។

មានករណីខ្លះ ខ្វះតម្លាភាពជុំវិញការប្រើប្រាស់ដីសម្បទាន ការធ្វើផ្លូវដោយគ្មានការត្រួតពិនិត្យ មិនមានការចូលរួម និង ពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋមូលដ្ឋាន ទាំងអស់នេះគឺជាការដែលត្រូវស្តីបន្ទោសដល់សម្បទានិក :

ខាងក្រោមនេះគឺជាប្រសាសន៍របស់ស្ត្រីម្នាក់នៅភូមិអូរផ្តៅ ឃុំរស្មីសាមគ្គី :

*"ខ្ញុំអាយុ៥៧ ឆ្នាំហើយ។ ប្តីខ្ញុំអាយុ៦៨ ឆ្នាំ ជាជនពិការ។ យើងបានចាកចេញពីស្រុកសំរោងទងរយៈពេលមួយឆ្នាំហើយ ព្រោះខ្ញុំមានជីវភាពរស់នៅលំបាកពេក។ យើងមកទីនេះពីព្រោះយើងមានបងប្អូន សាច់ញាតិរស់នៅទីនេះ ហើយគេប្រាប់យើងថានៅទីនេះងាយស្រួលរកស៊ីដុតធ្យូង ព្រោះនៅមានព្រៃឈើសំរាប់កាប់នៅឡើយ។ ខ្ញុំមកទីនេះ ហើយសុំដីពីប្រធានភូមិ។ ប្រធានភូមិក៏បានឱ្យដីយើងធ្វើផ្ទះនៅ។ ក្រុមហ៊ុនបានប្រាប់ឱ្យយើងចាកចេញហើយថាដីនេះគឺជាដីជារបស់ពួកគេ ក៏ប៉ុន្តែយើងនឹងរស់នៅលើដីដែលប្រធានភូមិបានឱ្យយើង ។ យើងគ្មានកន្លែងផ្សេង ទៀតដែលយើងអាចទៅរស់នៅបានទេ។ ខ្ញុំត្រូវចិញ្ចឹមចៅប្អូននាក់ ព្រោះកូនស្រីខ្ញុំមិនអាចចិញ្ចឹមពួកវាបាន"។*

ក្រុមហ៊ុនដីសម្បទានហេណាន់ តំបន់អភិវឌ្ឍន៍ សេដ្ឋកិច្ច ពាណិជ្ជកម្ម កម្ពុជា (Henan Cambodia Economic Trade Development Zone) មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍យោធា ខេត្តកំពង់ស្ពឺ គឺជាតួយ៉ាង នៃបញ្ហានានាដែលអាចកើតមានពីការរុករានដីធ្លី និង របបគ្រប់គ្រងមិនច្បាស់លាស់ ។ រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានមួយកន្លែង នៅស្រុកភ្នំស្រួច កាលពីខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលមានផ្ទៃដី ៤១០០ហិកតា ហើយបានចាប់ផ្តើមធ្វើការដាំដុះនៅឆ្នាំ២០០២ ។ ដូចបានកត់សំគាល់ខាងលើ មានកម្មករភាគច្រើនដែលជាជនជាតិចិនបានវិលត្រឡប់ទៅស្រុកវិញ កាលពីខែកញ្ញា ឆ្នាំ២០០២ ដោយអះអាងថាការគ្រប់គ្រងរបស់ក្រុមហ៊ុននេះតឹងតែងខ្លាំងពេក ។ សព្វថ្ងៃនេះការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុនហេណាន់នៅសេសសល់តិចតួច គឺមានតែចំការឪឡឹកមួយហិកតា កម្មករ និងទីប្រឹក្សាបច្ចេកទេសចិនមួយក្តាប់តូច ផ្លូវដី និង ស្លាកភ្លោះនៅតាមដងផ្លូវនោះផង ។ នៅពេលធ្វើរបាយការណ៍នេះ យ៉ាងហោចណាស់ក៏មានប្រជាពលរដ្ឋចំនួន៤ក្រុម កំពុងតែទាមទារដីធ្លីនៅក្នុងតំបន់ដីសម្បទាននោះ ។ អ្នកស្រុកដែលបានតាំងទីលំនៅ ក្នុងឆ្នាំ១៩៩៣ និង ឆ្នាំ១៩៩៤ បច្ចុប្បន្ននេះ ពួកគេកំពុងរស់នៅតាមបណ្តោយផ្លូវ ជាតិលេខ៤ និយាយថាពួកគាត់ត្រូវបានគេបង្ខំឱ្យលក់ដីរបស់ខ្លួនទៅឱ្យលោកជំទាវ យូ អយ រដ្ឋលេខាធិការក្រសួង កិច្ចការនារី ក្នុងតម្លៃពី៣០ ទៅ ៨០ដុល្លារ ក្នុងមួយហិកតា ។ តាមប្រសាសន៍របស់លោកជំទាវ យូ អយ ការងារជំនួញនេះគឺមានភាពទៀងត្រង់ និង ត្រឹមត្រូវ ។ ចាប់តាំងពីឆ្នាំ២០០២ មានអ្នកតាំងទីលំនៅថ្មីៗ ជាច្រើនមកពីគ្រប់ មជ្ឈដ្ឋាននៅទូទាំងប្រទេសកម្ពុជាបានធ្វើការកាប់ឆ្ការដីឡូតិ៍នៅតាមដងផ្លូវនានា ហើយបានបង្កើតភូមិថ្មីមួយនៅ ទីនោះ ឈ្មោះភូមិសាមគ្គីអភិវឌ្ឍន៍ថ្មី ដែលមានប្រជាពលរដ្ឋចំនួន៣០៦ គ្រួសាររស់ នៅ ។ មានការចុះកិច្ចសន្យា មួយរវាងលោកជំទាវ យូ អយ និងតំណាងក្រុមហ៊ុនតុងណាំអា ចំកាត់ (Tong Nam A Co., Ltd) កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០០២ ដើម្បីបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មមួយ និងមន្ទីរពេទ្យមួយ លើផ្ទៃដី ៣០៤ ហិកតា ។ ទោះជាមានការគំរាមកំហែងជាប្រចាំ[១១៣] ជំលោះប្រដាប់អាវុធ[១១៤] និង ការគំរាមចោទប្រកាន់តាមផ្លូវច្បាប់យ៉ាងណាក្តី[១១៥] អ្នកស្រុកនិយាយថាពួកគេគ្មានជំរើសអ្វីផ្សេង ក្រៅតែពីការបន្តរស់នៅទីនោះ ព្រោះពួកគេមិនដឹងថាត្រូវ ទៅកន្លែងណាទៀតទេ ។ កាលពីខែកក្កដា ឆ្នាំ២០០៤ ជំនួយការរបស់លោកជំទាវ យូ អយ និងមេឃុំបានព្យាយាម ចុះបញ្ជីដីឡូតិ៍សំរាប់អ្នកតាំងទីលំនៅចាស់ ហើយយកដីដែលអ្នកតាំងទីនៅថ្មីបានកាប់ឆ្ការរួចប្រគល់ឱ្យពួកគេ ។ លុះក្រោយមក នៅខែសីហា ចំណងសាមគ្គីភាពរវាងអ្នកតាំងទីលំនៅចាស់ និង អ្នកតាំងទីលំនៅថ្មីត្រូវប្រេះស្រាំ ហើយជម្លោះក៏បានកើតឡើង ។ អ្នកស្រុកបានធ្វើបាតុកម្ម នៅខាងមុខសាលាខេត្តកំពង់ស្ពឺ

[១១៣] អ្នកភូមិបានឱ្យដឹងថា ការគំរាមកំហែងចុងក្រោយធ្វើឡើងនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៤ នៅពេលដែលទាហានប្រាំពីរនាក់ មកពីតំបន់អភិវឌ្ឍន៍យោធាដែលនៅជិតនោះ មានសំលៀកបំពាក់ឯកសណ្ឋានចេញធ្វើចម្បាំង ក្នុងនោះមានយោធាបីនាក់ប្រដាប់ដោយអាវុធ អាកា ៤៧ បានដើរចូលទៅក្នុងភូមិ ហើយសុំឱ្យអ្នកភូមិបង្ហាញប័ណ្ណកម្មសិទ្ធិដីធ្លី ។ នៅពេលដែលអ្នកភូមិឆ្លើយថាគ្មានទាហានទាំងនោះបានបញ្ជាឱ្យពួកគេចាកចេញពីភូមិនោះជាបន្ទាន់ ។

[១១៤] បើតាមពត៌មានពីអ្នកភូមិ កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៤ មានបុរស១០ នាក់ប្រដាប់ដោយអាវុធអាកា៤៧ បានចូលអុកឡុកក្នុងភូមិ បាញ់ឡើងលើជាច្រើនគ្រាប់ និង ដុតផ្ទះ (ខ្ទម)ចំនួន៥២ ខ្នង ។

[១១៥] តុលាការខេត្តកំពង់ស្ពឺ បានចេញដីកាមួយ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៤ កោះអញ្ជើញអ្នកភូមិមកធ្វើការសាកសួរ ។ ករណីរឿងព្រហ្មទណ្ឌលេខ ២១ ។

ក្រោយមកមានអ្នកភូមិ ខ្លះ ដែលគេសង្ស័យថាជាអ្នកមេក្លោង ត្រូវនគរបាលខេត្តកំពង់ស្ពឺចាប់ឃុំខ្លួនភ្លាមៗ នៅមុនពេលបន្តក្បួននោះចំនួន ១០ឡាន ទៅកាន់រដ្ឋសភាជាតិ។ នៅទីនោះ ប្រជាពលរដ្ឋបានទទួលការធានាជាពាក្យសំដីពីលោកជំទាវ យូ អយ ថានឹងផ្តល់ដី ១០០ ហិកតា ដើម្បីអភិវឌ្ឍន៍សហគមន៍។ នៅពេលធ្វើរបាយការណ៍នេះជំលោះនៅតែមានមិនទាន់អាចដោះស្រាយបាននៅឡើយ។

## ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន

សម្បទានគោលដៅសេដ្ឋកិច្ចមានផលប៉ះពាល់ខ្លាំងជាអវិជ្ជមាន។ គេបានកាប់ឆ្ការព្រៃឈើ ដើម្បីដាំដើមឈើថ្មីនៅលើដីសម្បទានជាច្រើន បានបំផ្លិចបំផ្លាញប្រព័ន្ធបរិស្ថានជីវចំរុះ ធ្វើឱ្យដំណាំ និង សត្វគ្រប់ប្រភេទថយចុះ។ ការសិក្សាស្រាវជ្រាវនៅប្រទេសម៉ាឡេស៊ី និង ប្រទេសឥណ្ឌូណេស៊ីបង្ហាញថា រវាងពី៨០ ទៅ ១០០ ភាគរយនៃពពួកសត្វព្រៃក្នុងតំបន់ត្រូពិក មិនអាចមានជីវិតរស់នៅក្នុងចំការដូងប្រេងតែមួយមុខនោះ បានទេ។[១១៦] សំរាមដែលបំពុលបរិស្ថាន ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និង ជីរក៏ជាការព្រួយបារម្ភមួយដែរ។ ការព្រួយបារម្ភពីករណីនេះ ក៏មានចំពោះក្រុមហ៊ុនហៃនិញផងដែរ ដែលក្រុមហ៊ុននេះបានផ្តើមដាំដុះដើមល្ហុងខ្វង ដែលយល់ថាអាចបង្កឱ្យមានកាកសំណល់ដែលមានជាតិពុលខ្ពស់។ គេបានដាំដើមប្រេងខ្យល់នៅលើដីសម្បទានភាពីម៉ិច ក្នុងខេត្តកំពង់ឆ្នាំង ដើម្បីផ្គត់ផ្គង់ដល់រោងចក្រផលិតក្រដាសនាពេលអនាគត។[១១៧] ការដាំដើមប្រេងខ្យល់ ក្នុងទ្រង់ទ្រាយធំ បានបង្ហាញឱ្យឃើញពីការបំផ្លិចបំផ្លាញបរិស្ថានយ៉ាងធ្ងន់ធ្ងរ ដូចជាការធ្វើឱ្យស្ទឹងបឹងបួរ រីងហួត ធ្វើឱ្យរ៉ីតទឹកក្រោមដីចុះទាប ធ្វើឱ្យដីមានជាតិអាស៊ីដ កាត់បន្ថយប្រព័ន្ធបរិស្ថានជីវចំរុះនៅមូលដ្ឋាន និង ធ្វើឱ្យបាត់បង់គុណភាពដី។[១១៨] គេបានលើកឡើងនូវកង្វល់អំពីការខូចខាតដ៏ធ្ងន់ធ្ងរដល់បូរណភាពបរិស្ថាននៃបឹង ទន្លេសាប ដែននេសាទ និង ធនធានទឹកសាបដែលមានសារៈសំខាន់សំរាប់សេដ្ឋកិច្ច និង សង្គមកិច្ច នៃប្រទេស កម្ពុជា។ រោងចក្រកិនទឹកផ្លែឈើបានបញ្ចេញចោលនូវកាកសំណល់ជាតិពុល និង ជាតិគីមី ដែលធ្វើឱ្យក្រខ្វក់ទឹក បឹង និងនាំឱ្យមានទឹកជំនន់ជនលេចព្រៃ ទន្លេ បឹងបួរ និង ទឹកក្រខ្វក់ហូរចាក់ទៅក្នុងសមុទ្រ ព្រមទាំងបំផ្លិចបំផ្លាញ ផលដំណាំរបស់ប្រជាពលរដ្ឋទៀតផង។ ទោះបីជាមានកង្វល់ទាំងនេះក្តី ក្រុមហ៊ុនភាពីម៉ិច មិនបានធ្វើការសិក្សា ពីផលប៉ះពាល់បរិស្ថានសំរាប់គំរោងធ្វើចំការ ដើមប្រេងខ្យល់ និង រោងចក្រកិនទឹកផ្លែឈើនោះទេ។

---

[១១៦] វេគឃឺ (Wakker) ឆ្នាំ២០០០ បានដកស្រង់អត្ថបទរបស់អង្គការ Carrere, op cit, ទំព័រទី៣។

[១១៧] នៅក្នុងដែនដីសម្បទានរបស់ក្រុមហ៊ុនភាពីម៉ិច ក្នុងស្រុកសាមគ្គីមានជ័យ មានចំការដើមប្រេងខ្យល់មួយកន្លែង គ្រប់គ្រងដោយនាយកដ្ឋានរុក្ខាប្រម៉ាញ់ នៅរាជធានីភ្នំពេញ។ យោលតាមមន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង ចំការនោះមានផ្ទៃដី២០.០០០ ហិកតា។ ក្នុងនោះ បើតាមសេចក្តីរាយការណ៍ មានដើមប្រេងខ្យល់លើផ្ទៃដី ២០០០ ហិកតា ត្រូវបានដាំដុះតាំងពីឆ្នាំ២០០០ មកម្ល៉េះ។

[១១៨] ទឹកធ្លាក់ វ៉ូលូមទី ៨ លេខ១ ខែកក្កដា - ខែ តុលា ឆ្នាំ ២០០១ ដោយ TERRA.

ករណីនៃដីសម្បទានរបស់ក្រុមហ៊ុនសម្បទានគ្រីនិរិច នៅខេត្តកោះកុង ប្រជាពលរដ្ឋមូលដ្ឋានបានរាយការណ៍ថា ដីសម្បទាននោះស្ថិតក្នុងតំបន់ព្រៃលិចទឹក នៅរដូវវស្សាជាជំរកដ៏សំខាន់សំរាប់ត្រីពង ។ ការបង្កើតឱ្យមានវប្បធម៌តែមួយនូវប្រភេទរុក្ខជាតិកម្របាននាំឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងក្នុងចំណោមប្រជាពលរដ្ឋមូលដ្ឋាន ដែលជីវភាពរស់នៅ និង សេដ្ឋកិច្ចរបស់គេពឹងផ្អែកទាំងស្រុងលើរបរនេសាទត្រី ហើយទិន្នផលនេសាទបានថយចុះ ដោយសារតែមានការបំផ្លិចបំផ្លាញជំរកសត្វត្រី ។ វប្បធម៌តែមួយ ឬវប្បធម៌នៃជំពូករុក្ខជាតិសំខាន់មួយចំនួនអាចផ្តល់នូវគ្រោះថ្នាក់ដល់តុល្យភាពម្ហូបអាហារ ដែលធ្វើឱ្យប៉ះពាល់ជាសក្តានុពលសំរាប់រយៈពេលយូរអង្វែងដល់ការលូតលាស់ និង ប្រព័ន្ធការពារសេរីរាង្គកាយមនុស្ស ។ ដូចបានកត់សំគាល់កន្លងមក ក្រុមហ៊ុនគ្រីនិរិចមានដីសម្បទានមួយកន្លែង នៅក្នុងតំបន់ការពារ ក្នុងឧទ្យានជាតិបុទុមសាគរ ដែលនេះគឺជាការរំលោភលើច្បាប់ទាំងស្រុង ។ ការដែលក្រុមហ៊ុនបានសំរេចដាំដើមអាកាស្យា បាននាំឱ្យមានកង្វល់ថែមទៀត ព្រោះថាព្រៃធម្មជាតិគ្រប់ប្រភេទស្រូបយកទឹកភ្លៀងមូស្សុង និងការពារដីមិនឱ្យមានការសឹកច្រោះ ដែលផ្ទុយពីដើមអាកាស្យា ដែលមានតែសំបកដ៏ស្តើង ។ ដើមអាកាស្យាក៏ជាជំពូករុក្ខជាតិរាតត្បាតមួយប្រភេទដែរនៅសហរដ្ឋអាមេរិក (រដ្ឋហាវ៉ៃ) និង នៅកោះប៉ាស៊ីហ្វិកភាគខ្លះ រុក្ខជាតិប្រភេទនេះបានធ្វើឱ្យអន្តរាយដល់រុក្ខជាតិក្នុងស្រុក ។

## ដីសម្បទានរបស់ក្រុមហ៊ុនផលិតម្សៅដំឡូងមីចាំកាត់ ខេត្តស្ទឹងត្រែង : ករណីសិក្សា

នេះជាសំដីរបស់លោកយាយម្នាក់ អាយុ៨១ ឆ្នាំ មកពីភូមិអូររ៉ុន :

*" ខ្ញុំចាស់ណាស់ទៅហើយ។ នៅទីនេះខ្ញុំបានកាប់ឆ្ការដីមួយកន្លែង អស់រយៈពេល៤០ ឆ្នាំមកហើយ ។ កាលពីមុន ខ្ញុំមានជីវភាពធូរធា ដោយសារថាទីនេះសំបូរព្រៃឈើ ដីក៏មានជីវជាតិល្អ ហើយនៅទំនេរច្រើន រីឯត្រីសាច់វិញក៏សំបូរដែរ "។ ខ្ញុំមានផ្ទះសម្បែងរស់នៅសមរម្យ ។ លុះក្រោយមក ខ្ញុំឃើញតែការបំផ្លិចបំផ្លាញនៅក្នុងភូមិខ្ញុំ និងការបំផ្លិចបំផ្លាញព្រៃឈើ និង សត្វព្រៃ ។ ឥឡូវនេះដីល្អៗ នៅជុំវិញភូមិខ្ញុំកំពុងតែធ្វើការដាំដុះ ហើយពេលនេះអស់លោក លោកស្រី ឃើញតែដីលិចទឹក និង ថ្មតែប៉ុណ្ណោះ ។ នៅមានដីល្អខ្លះដែរ នៅអូរបី និង អូរប្រាំ ប៉ុន្តែដីនោះវានៅក្នុងដីសម្បទាន ។ ចៅៗរបស់ខ្ញុំបានកាប់ឆ្ការដីមួយកន្លែងនៅទីនោះដែរ ប៉ុន្តែក្រុមហ៊ុនបានប្រាប់វាឱ្យឈប់កាប់ឆ្ការបន្តទៀត ។ យើងមិនយល់ទេ ថាហេតុអ្វី បានជាយើងជួបសំណាងអាក្រក់បែបនេះ ហើយ ឥឡូវនេះ គេបានប្រាប់យើងថា ដីនេះជាដីរបស់អ្នកក្រៅដែលជាខ្មែរអ្នកធំ ។ យើងជាអ្នកតូចតាច ហើយអ្វីដែលយើងធ្វើនឹងធ្វើឱ្យយើងខាតបង់ជាក់ជាមិនខាន "*។

កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៩ ក្រសួងកសិកម្មបានចុះកិច្ចសន្យាសម្បទានមួយសំរាប់រយៈពេល ៧០ ឆ្នាំ ជាមួយក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ លើដីសម្បទានមួយកន្លែងមានផ្ទៃដី៧៤០០ហិកតា ដែលជាដីព្រៃនៅខេត្តស្ទឹងត្រែង ។ ក្នុងកិច្ចសន្យានោះ ក្រុមហ៊ុនត្រូវដាំដើមម៉ៃសាក់ ដើមស្វាយចន្ទី ដំណាំកសិកម្មផ្សេងទៀត និង

ចិញ្ចឹមសត្វ ។ កិច្ចសន្យាអនុញ្ញាតឱ្យក្រុមហ៊ុនកាប់ឆ្ការដីនោះ ។ បើតាមច្បាប់ស្តីពីព្រៃឈើ ក្រុមហ៊ុននេះត្រូវបង់ពន្ធឈើដែលបានកាប់រំលំរួច និង ពន្ធសំរាប់ការដឹកជញ្ជូនឈើមូលគ្រប់ប្រភេទ ក្រុមហ៊ុនបានបង់ប្រាក់កក់ និងបានកំណត់ព្រំប្រទល់ដីរបស់ខ្លួនរួចហើយ ។

ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ មានដើមទុនដែលបានចុះបញ្ជីរួចចំនួន ១.២០០.០០០ ដុល្លារ ។ បើតាមប្រភពព័ត៌មានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមហ៊ុននេះ ជាប្រភេទក្រុមហ៊ុនចំរុះ ខ្មែរ-ចិន ដែលមានភាគហ៊ុន ៥០% -៥០% ស្មើគ្នា ។

*ទីតាំងដី និង ប្រជាពលរដ្ឋ :*

ដីនេះមានទីតាំងភូមិសាស្ត្រ នៅឃុំអូរស្វាយ ក្នុងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង មានចម្ងាយ៦០ គីឡូម៉ែត្រ ភាគខាងជើងទីរួមខេត្តស្ទឹងត្រែង និងមានចំងាយ៥ គីឡូម៉ែត្រពីព្រំប្រទល់ខ្មែរ-លាវ ហើយឃុំនេះជាឃុំដាច់ស្រយាលពីគេ ។

ដីសម្បទានរបស់ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ ស្ថិតនៅក្នុងតំបន់មួយដែលចំរុះដោយព្រៃស្បាត និង ព្រៃស្រោង ដែលក្នុងនោះមានភូមិចំនួនប្រាំបួន និងឃុំចំនួនបី : ប្រាំភូមិ នៅក្នុងឃុំអូរស្វាយ បីភូមិនៅក្នុងឃុំព្រះរំកិល ហើយមួយភូមិទៀតនៅក្នុងឃុំកោះស្នែង ។ ឃុំអូរស្វាយជាឃុំដែលទទួលរងនូវផលប៉ះពាល់ច្រើនជាងគេ ព្រោះឃុំនេះស្ថិតនៅតាមបណ្តោយទន្លេមេគង្គ និង ដីសម្បទាន ។ ភូមិទាំងប្រាំដែលបង្កើតបានជាឃុំអូរស្វាយនោះមាន : ភូមិ កោះព្នៅ ភូមិអូរស្វាយ ភូមិអូររុន ភូមិវីនស៊ាន និង ភូមិកោះហិប ដែលមានប្រជាពលរដ្ឋទាំងអស់ ៤៤៥ គ្រួសារ ឬ មានប្រជាពលរដ្ឋប្រមាណជា ២៣៤០ នាក់ ។

*ប្រវត្តិដី :*

នៅក្នុងទសវត្សឆ្នាំ១៩៦០ សម្តេចព្រះនរោត្តមសីហនុ មានព្រះរាជគំនិតផ្តួចផ្តើមនូវគម្រោងមួយឈ្មោះថា " អាណានិគមន៍លើដីថ្មី " ដោយព្រះមហាក្សត្រទ្រង់មានព្រះរាជបំណងអភិវឌ្ឍន៍តំបន់ជនបទ និង កាត់បន្ថយភាពក្រីក្រនៅបណ្តារខេត្តដាច់ស្រយាល នៅក្នុងប្រទេសកម្ពុជា ដូចជា : ខេត្តមណ្ឌលគីរី រតនគីរី និង ស្ទឹងត្រែង ។ ប៉ុរី អូរស្វាយត្រូវបានបង្កើតឡើង កាលពីដើមទសវត្សឆ្នាំ១៩៦០ ស្ថិតនៅជាប់ព្រំដែននៃប្រទេសលាវ ដែលជាផ្នែកមួយនៃគំរោងនេះ ដែលបង្ហាញពីការកង្វល់អំពីឈ្មួញ និង អ្នកនេសាទលាវរុករានទន្រ្ទានចូលទឹកដីកម្ពុជា ។ រាជរដ្ឋាភិបាលបានបញ្ជូនទាហានទៅកាប់ឆ្ការព្រៃ និង ធ្វើផ្លូវមួយខ្សែ សាងសង់ផ្ទះថ្មចំនួន៥០ ខ្នង សាលារៀនមួយខ្នង មន្ទីរពេទ្យមួយខ្នង ផ្សារមួយ វត្តមួយ បន្ទាយទាហានមួយ និង រោងចក្រស្សូសមួយកន្លែង ។ នៅក្នុងឆ្នាំ ១៩៦៤ យោធិននិវត្តន៍ ពលទាហាន និង គ្រួសារជនក្រីក្រដែលភាគច្រើនមកពីខេត្តតាកែវ ព្រៃវែង ស្វាយរៀង

និង ខេត្ត កណ្តាល ព្រមទាំងជនភៀសខ្លួនមកពីកម្ពុជាក្រោម ត្រូវបានផ្តល់ជាផ្ទះសម្បែង ដីធ្លី គោក្របី គ្រាប់ពូជ និង ដើម ឈើសំរាប់សង់លំនៅដ្ឋាននៅទីនោះ ។ ព្រះអង្គម្ចាស់នរោត្តម សីហនុ ព្រះអង្គផ្ទាល់បានបើកសម្ពោធឱ្យប្រើប្រាស់បុរីអូរស្វាយនេះ ក្នុងឆ្នាំ១៩៦៧ ។ នៅពេលនោះមានព្រៃស្រោងជាច្រើនស្ថិតនៅជិតវាលស្រែ និង ផ្ទះប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋមិនដែលដើរចូលព្រៃទេ លុះណាតែគេមានអាវុធ ព្រោះខ្លាច ខ្លា ដំរី និង សត្វព្រៃផ្សេងៗទៀត ។ ជម្ងឺគ្រុនចាញ់ គឺជាការព្រួយបារម្ភណ៍មួយ ព្រោះថាពេលនោះពុំមានថ្នាំពេទ្យដែលមានប្រសិទ្ធិភាពសំរាប់ព្យាបាលជម្ងឺនោះឡើយ ។

ប្រជាពលរដ្ឋនៅភូមិអូរស្វាយ មានជីវភាពរស់នៅជាប្រពៃណីពឹងផ្អែកលើការធ្វើស្រែចំការ និង ការដាំបន្លែបង្ការលើដីស្ងួត (ចំការ) និង ការនេសាទត្រី ។ ចំពោះប្រជាពលរដ្ឋក្រីក្របំផុតវិញ ការប្រមូលអនុផលព្រៃឈើភាគច្រើនគឺជាការងារបន្ទាប់បន្សំ ។ ប្រជាពលរដ្ឋបោចវល្លិ៍ ដកផ្សិត បេះផ្លែពោន និង រុក្ខជាតិសំរាប់ធ្វើជាថ្នាំសង្កូវដូចជា គ្រាប់ស្លែង សំរាប់ធ្វើថ្នាំព្យាបាលជម្ងឺគ្រុនចាញ់ និង ការបរបាញ់សត្វព្រៃ មានសត្វក្តាន់ រមាស ជ្រូកព្រៃ ពពួក សត្វរមូន អណ្តើក និង កាំប្រម៉ា ។ ប្រជាពលរដ្ឋលក់ ឬ ដោះដូរអនុផលព្រៃឈើ ដែលភាគច្រើននៅផ្សារវឹនកាំ ស្ថិតនៅជាប់ព្រំដែននៃប្រទេសលាវ ។ នៅក្នុងទសវត្សឆ្នាំ១៩៦០ ឃុំនេះ គេបានចាត់ទុកថាជាឃុំអ្នកមានមួយដែរ ប៉ុន្តែក្រោយមក ដោយសារមានសង្គ្រាម និង ជម្លោះក្នុងស្រុកជាបន្តបន្ទាប់បានធ្វើឱ្យបុរីនេះ ទទួលរងនូវការខូចខាត យ៉ាងធ្ងន់ធ្ងរ ។

ក្នុងឆ្នាំ១៩៧០ រយៈពេលដ៏ខ្លី បន្ទាប់ពីរដ្ឋប្រហារ លោកឧត្តមសេនីយ លន់ ណុល បានឡើងកាន់អំណាច ពេលនោះ ទាហានវៀតកុង និង ទាហានខ្មែរក្រហមបានកាន់កាប់បុរីអូរស្វាយនេះទាំងមូល ។ ក្នុងឆ្នាំ១៩៧៣ មួយភាគធំនៃភូមិអូរស្វាយត្រូវទទួលរងការទំលាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក ។ ក្នុងឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមកាន់អំណាចទាំងស្រុកក្នុងប្រទេសកម្ពុជា មានប្រជាពលរដ្ឋជាច្រើនគ្រួសាររស់នៅទីក្រុងភ្នំពេញ ត្រូវគេជម្លៀសទៅភូមិអូរស្វាយ ដើម្បីរស់នៅជាមួយប្រជាពលរដ្ឋមូលដ្ឋាន ។ បើតាមព័ត៌មាន មានប្រជាពលរដ្ឋជាច្រើននាក់ បានស្លាប់ក្នុងរយៈពេលមួយឆ្នាំក្រោយមក ដោយជម្ងឺគ្រុនចាញ់ ដោយទទួលទានអាហារមិនគ្រប់គ្រាន់ ឬ ដោយជម្ងឺផ្សេងៗ ។ ប្រជាពលរដ្ឋខ្លះទៀត ត្រូវគេសំលាប់ ដោយចោទថាជាភ្នាក់ងារសំងាត់ (CIA) របស់សហរដ្ឋ-អាមេរិក ។ ក្នុងចំណោមប្រជាពលរដ្ឋមូលដ្ឋាន គេដៅសំខាន់លើទាហាន និងគ្រូបង្រៀន ហើយត្រូវគេសំលាប់ ដោយចោទថាជាខ្សែរយៈលន់ ណល់ ។ ក្នុងឆ្នាំ១៩៧៩ គេបានបង្ខំអ្នកស្រុកឱ្យចាកចេញពីភូមិ ដើម្បីទៅកាប់ឆ្ការដីស្រែថ្មី ដែលមានចំងាយប្រមាណជា៤០ គីឡូម៉ែត្រពីភូមិ ។ ក្នុងឆ្នាំ១៩៧៦ នៅពេលដែលកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា ហើយបានផ្តួលរំលំរបបខ្មែរក្រហម អ្នកស្រុកបានវិលត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញ ហើយបានឃើញផ្ទះសម្បែងរបស់ខ្លួនត្រូវបាក់បែកខូចខាតអស់ ។ ក្នុងទសវត្ស ឆ្នាំ១៩៨០ អ្នកស្រុកបានកសាង

ជីវភាពរស់នៅរបស់ខ្លួនជាថ្មី ។ ពេលនោះមានអ្នកចំណូលថ្មីខ្លះដែរ ប៉ុន្តែអ្នកទាំងនោះគឺជាបងប្អូនសាច់ញាតិរបស់អ្នកភូមិអូរស្វាយដែលមកពីខេត្តផ្សេងៗ ។

កាលពីចុងទសវត្សឆ្នាំ១៩៨០ នៅមានព្រៃក្រាស និង សំបូរសត្វព្រៃច្រើន ហើយងាយស្រួលធ្វើការកាប់ឆ្ការដីថ្មី ដើម្បីធ្វើស្រែចំការនៅតាមជើងព្រៃជិតភូមិ ។ ទោះជាយ៉ាងណាក្តី អាស្រ័យដោយគ្មានការត្រួតពិនិត្យលើការប្រើប្រាស់ និង ការគ្រប់គ្រងធនធានធម្មជាតិ និង ដោយសារតែប្រជាពលរដ្ឋមូលដ្ឋានបានប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ជាច្រើនឆ្នាំមក ទើបធនធានត្រី និង ព្រៃឈើបានថយចុះយ៉ាងឆាប់រហ័ស ក្នុងទសវត្ស ឆ្នាំ១៩៩០ ហើយក៏ជាពេលមានកំណើនប្រជាពលរដ្ឋដែរ ។ នៅដើមទសវត្សឆ្នាំ១៩៩០ មានមន្ត្រី " ជាន់ខ្ពស់ " ជាច្រើនរូប ដែលភាគច្រើនគឺជាមន្ត្រីយោធា បានផ្តើមធ្វើអាជីវកម្មឈើមូលក្នុងទ្រង់ទ្រាយធំ ។ ការកាប់ឈើប្រណិត និង ឈើប្រភេទលេខមួយ ដូចជា ឈើបេង នាងនួន កកោះ និង គគីរ មានសភាពខ្លាំងក្លា ។ ឈើភាគច្រើនត្រូវបាននាំចេញទៅប្រទេសលាវ ។ បើតាមពតិមាន ការកាប់ឈើមូលបានថយចុះ នៅពេលក្រោយឆ្នាំ១៩៩៥ ។ ធនធានព្រៃឈើ និង សត្វព្រៃត្រូវហិនហោចយ៉ាងធ្ងន់ធ្ងរ ប៉ុន្តែប្រជាពលរដ្ឋមូលដ្ឋាន នៅតែអាចរកប្រាក់ចំណូលបន្ទាប់បន្សំខ្លះពីធនធានទាំងនោះ ។ នេះគឺជាស្ថានការណ៍មួយ ដែលបង្ហាញឱ្យឃើញថា នៅពេលដែលក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ មកដល់ សកម្មភាពរបស់ក្រុមហ៊ុននេះបានធ្វើឱ្យស្ថានភាពលំបាកស្រាប់ កាន់តែលំបាកឡើងថែមទៀត ។

*ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ និង ផលវិបាករបស់ក្រុមហ៊ុននេះ :*

នៅចុងឆ្នាំ១៩៩៩ ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ បានបោះតង់នៅក្នុងព្រៃមួយ ដែលមានចម្ងាយប្រមាណជា១០ គីឡូម៉ែត្រ ស្ថិតនៅភាគខាងកើតនៃភូមិអូរស្វាយ ហើយក្រុមហ៊ុននេះបានចាប់ផ្តើមកាប់រំលំដើមឈើមានតម្លៃជាច្រើនដើម ។ ក្រុមហ៊ុននេះក៏បានសាងសង់អាគារមួយចំនួន រោងម៉ាស៊ីនអារឈើពីរ បានបង្កើតកន្លែងបណ្តុះកូនម៉ៃសាក់មួយកន្លែង កាប់រំលំដើមឈើ និង ឈូសឆាយដីចំនួន ១០០ហិកតាលើតំបន់ព្រៃសំខាន់ៗ ដើម្បីធ្វើចំការម៉ៃសាក់ ។ ទោះជាដូច្នេះក្តី ក្រុមហ៊ុនមិនបានយកចិត្តទុកដាក់ថែទាំឱ្យបានល្អទេ ទើបបណ្តាលឱ្យងាប់កូនម៉ៃសាក់ជាច្រើន ។ ប្រជាពលរដ្ឋមូលដ្ឋានមានការមន្ទិលសង្ស័យថា ការធ្វើចំការម៉ៃសាក់នេះ គ្រាន់តែជាលេសសំរាប់កាប់ឈើមូលតែប៉ុណ្ណោះ ។ ក្រុមហ៊ុននេះបានជួលអតីតទាហាន ឬ ទាហានផ្តាច់ខ្លួន ធ្វើជាសន្តិសុខប្រដាប់អាវុធ ដើម្បីការពារក្រុមហ៊ុនរបស់ខ្លួន ។

ដោយការកាប់ដើមឈើ និង កំណើនប្រជាពលរដ្ឋបានបង្កើនសម្ពាធថែមទៀត ទៅលើដីចំការនៅក្បែរផ្ទះ ទើបមានគ្រួសារថ្មីថ្មោងខ្លះ ត្រូវស្វែងរកដីថ្មីដែលនៅឆ្ងាយពីផ្ទះ ។ មានប្រជាពលរដ្ឋហាសិបប្រាំពីរគ្រួសារបានកាប់ឆ្ការដីនៅភូមិអូរបី និង ភូមិអូរប្រាំ ហើយភូមិទាំងពីរនេះ ស្ថិតនៅក្នុងដែនដីសម្បទាន ។ ក្រុមហ៊ុនបានបិទសិទ្ធិប្រជាពលរដ្ឋមូលដ្ឋានមិនឱ្យចូលចំការ និង ធ្វើដំណើរលើផ្លូវរទេះទៅកាន់ចំការរបស់ខ្លួនឡើយ ។ ក្នុងខែមីនា

ឆ្នាំ២០០០ មានប្រជាពលរដ្ឋ៤៣៧ គ្រួសារបានចុះហត្ថលេខា ហើយដាក់ពាក្យបណ្តឹងមកអង្គការសិទ្ធិមនុស្សនានា និងក្រសួងពាក់ព័ន្ធ។ កាលពីពាក់កណ្តាល ឆ្នាំ២០០០ លោកអភិបាល និង អភិបាលរងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថ ស្នងការនគរបាល ប្រធានការិយាល័យស្រុកនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងអភិបាលស្រុកបានទៅទស្សនាដល់ទីកន្លែង ហើយបានប្រាប់ប្រជាពលរដ្ឋឱ្យឈប់ប្តឹងក្រុមហ៊ុន។ មន្ត្រីទាំងនោះបាននិយាយថាពាក្យបណ្តឹងនេះជារឿង "នយោបាយ" ប្រឆាំងនឹងរាជរដ្ឋាភិបាល។ កាលពីឆ្នាំ២០០១ ក្រុមហ៊ុនបានឈូសឆាយដីរបស់ប្រជាពលរដ្ឋប្រាំបីគ្រួសារ នៅភូមិអូរបី ។

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ មានប្រជាពលរដ្ឋ២១០គ្រួសារបានធ្វើបាតុកម្មនៅខាងមុខការិយាល័យ និង រោងចក្រអារឈើរបស់ក្រុមហ៊ុននេះ ដោយទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការកាប់ឈើ និង ឈូសឆាយដី។ ពីរថ្ងៃក្រោយមក មន្ទីរកសិកម្មខេត្តបានបង្កើតក្រុមការងារមួយ ដែលបានធ្វើការស្វែងយល់ និង បានកំណត់ព្រំប្រទល់ដីចំនួន៣៨ ឡូត៍ លើផ្ទៃដី១០២ ហិកតា សំរាប់ប្រជាពលរដ្ឋហាសិបប្រាំពីរគ្រួសារ ហើយដើម្បីឱ្យប្រជាពលរដ្ឋមានសិទ្ធិប្រើប្រាស់ដីឡើងវិញ។ ទោះជាដូច្នេះក្តី ក្រុមហ៊ុនបានហាមមិនឱ្យពង្រីកដីកសិកម្មថែមទៀត ហើយក្រុមហ៊ុននេះបានបន្តឈូសឆាយដីជាដដែល។ មានអ្នកស្រុកខ្លះត្រូវទទួលរងការគំរាមកំហែងពីសន្តិសុខក្រុមហ៊ុន ដើម្បីឱ្យប្រជាពលរដ្ឋមានការរារែកក្នុងការតវ៉ាតទៅទៀត សូម្បីតែក្រុមអ្នកតស៊ូមតិប្រចាំខេត្តដែលបានព្យាយាមជួយប្រជាពលរដ្ឋឃុំអូរស្វាយ ក៏ត្រូវបានអាជ្ញាធរគំរាមកំហែងដែរ ហើយអង្គការអភិវឌ្ឍន៍ក្នុងស្រុកមួយត្រូវគេប្រាប់ឱ្យបញ្ឈប់សកម្មភាពក្នុងឃុំនេះ ហើយបានចោទអង្គការនេះថា មានគណៈបក្សប្រឆាំគាំទ្រពីក្រោយខ្នង ។

លោកអ៊ិត នឌី អនុរដ្ឋលេខាធិការក្រសួងកសិកម្ម បានទៅទស្សនានៅឃុំអូរស្វាយ កាលពីខែមករា ឆ្នាំ២០០៣ ដោយមានតំណាងខុទ្ទកាល័យសាលាខេត្តជាច្រើនរូបចូលរួមផង។ លោកបានជំរាបប្រាប់អ្នកស្រុកមិនឱ្យតវ៉ាទាមទារយកដីនោះមកវិញទេ។ លោកបានជំរាបប្រាប់ប្រជាពលរដ្ឋទៀតថា រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទាននេះឱ្យក្រុមហ៊ុនរួចហើយៗ មានតែរាជរដ្ឋាភិបាលទេដែលមានអំណាចដោះស្រាយបញ្ហានេះ ប្រជាពលរដ្ឋមិនអាចដោះស្រាយបានទេ។

*ការងារ និង ការសន្យាផ្សេងទៀត :*

បើតាមតំណាងក្រុមហ៊ុនម្នាក់បាននិយាយថា មានប្រជាពលរដ្ឋប្រមាណជា៣០ ទៅ ៨០ នាក់ប៉ុណ្ណោះត្រូវគេជួលឱ្យធ្វើការតាមរដូវ ដើម្បីដាំដើមម៉ៃសាក់ និងកាប់ឈើ ផ្ទុយនឹងតួលេខដែលបានប៉ាន់ស្មានដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ថាមានប្រជាពលរដ្ឋ៧៧៤ នាក់ ត្រូវបានជួលឱ្យធ្វើការដូចខាងលើនេះ។ ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ បានជួលកម្មករម្នាក់តម្លៃ៥០០០រៀលក្នុងមួយថ្ងៃ ។ ដោយសារមានទំនាស់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ទើបធ្វើឱ្យក្រុមហ៊ុនងាកទៅរកជួលកម្មករពីខាងក្រៅវិញ ហើយមានប្រជាពលរដ្ឋក្នុងឃុំអូរស្វាយ

តែមួយចំនួនតូចប៉ុណ្ណោះ ដែលធ្វើការលើដីសម្បទាន ។ ក្រុមហ៊ុននេះ បានចុះកិច្ចសន្យាបន្តជាមួយក្រុមហ៊ុនកាប់ឈើមួយទៀត ដើម្បីកាប់រំលំដើមឈើ ហើយប្រើប្រាស់ក្រុមហ៊ុនម៉ៅការបន្តនោះ ឱ្យជួលកម្មករមកធ្វើការ ។ ក្រុមហ៊ុនអាចត្រួតពិនិត្យបានតិចតួច លើលក្ខខណ្ឌជ្រើសរើសកម្មករចូលធ្វើការ និង ប្រាក់ឈ្នួល ។ ក្នុងខែកក្កដា ឆ្នាំ២០០៣ កម្មករបានប្ដឹងទៅអង្គការក្រៅរដ្ឋាភិបាលប្រចាំខេត្ត ប្រាប់ថាប្រាក់ឈ្នួលរបស់ខ្លួនទាបជាងអ្វីដែលក្រុមហ៊ុនបានសន្យា ឬមិនបានបើកប្រាក់ឈ្នួលឱ្យខ្លួនទាល់តែសោះ ។ កម្មករជាច្រើននាក់បានចាកចេញពីក្រុមហ៊ុន ។ ក្រុមហ៊ុនមិនបានគោរពពាក្យសន្យាថា សង់សាលារៀន និង មណ្ឌលសុខភាពទេ ទោះបីជាក្រុមហ៊ុននេះ បានជួយជួសជុលស្ពានតូចមួយសំរាប់ដើរឆ្លងកាត់ទៅមកពីភូមិអូររុន និង ភូមិអូរស្វាយក៏ដោយ ។

នេះជាសំដីរបស់អ្នកភូមិម្នាក់ អាយុ ៧៥ឆ្នាំ មកពីភូមិអូរស្វាយ :

*" កាលពីទសវត្សឆ្នាំ៦០ នៅទីនេះមានព្រៃក្រាស ហើយមានសត្វខ្លា និង ដំរីច្រើន ។ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដទៃទៀតដែលបានមកដល់ទីនេះមុនគេ ហើយបានកាប់ឆ្ការព្រៃ ធ្វើផ្លូវ និង សង់ផ្ទះនៅ ។ គេបានបញ្ជូនយើងមកទីនេះ ដើម្បីការពារព្រំដែនលាវ និង ដើម្បីរៀបចំបុរីថ្មីសំរាប់ប្រជាពលរដ្ឋថ្មីមករស់នៅបន្តទៀត ។ ខ្ញុំបានធ្វើការដើម្បីសុខមាលភាពរបស់ប្រជាពលរដ្ឋ ដើម្បីការអភិវឌ្ឍន៍ និង ការការពារប្រទេសយើង ។ អ្វីដែលខ្ញុំបានឃើញសព្វថ្ងៃនេះ គឺគេមិនមែនធ្វើដើម្បីប្រជាពលរដ្ឋទេ គឺគេធ្វើសំរាប់តែអ្នកមានអំណាចពីរបីនាក់តែប៉ុណ្ណោះ ហើយអ្នកទាំងនោះឯងដែលមិនយកចិត្តទុកដាក់ដល់យើង ។ បញ្ហានេះលំបាកខ្លាំងណាស់ ហើយខ្ញុំមិនដឹងថា តើអនាគតរបស់កូនចៅខ្ញុំនឹងទៅជាយ៉ាងណាទេ ។ កាលពីខ្ញុំកសាងបុរីនេះ ខ្ញុំមានសង្ឃឹមយ៉ាងខ្លាំងសំរាប់ពេលអនាគត តែឥឡូវនេះខ្ញុំគ្មានសង្ឃឹមអ្វីទៀតទេ ។ យើងហាក់មានអារម្មណ៍ថា ត្រូវគេបោះបង់ចោលដូចជាកូនមាន់ដែលត្រូវមេវាបោះបង់ចោល ដូច្នោះដែរ ។*

### *ការវិវឌ្ឍន៍ក្នុងពេលថ្មីៗនេះ*

កាលពីដើមខែមីនាឆ្នាំ២០០៣ លោកតំណាងពិសេសបានទៅទស្សនាបុរីអូរស្វាយ ។ ដំបូង លោកបានមើលឃើញផលប៉ះពាល់ជាច្រើន ដែលកើតចេញពីសកម្មភាពរបស់ក្រុមហ៊ុននេះ ដូចជា :ការកាប់បំផ្លាញព្រៃឈើ ការឈូសឆាយដី ការធ្វើឱ្យអន្តរាយដល់ជីវិតសត្វព្រៃ ការធ្វើឱ្យងាប់ដើមម៉ៃសាក់ រោងម៉ាស៊ីនអារឈើ ហើយប្រជាពលរដ្ឋមូលដ្ឋានភាគច្រើនមានជីវភាពរស់នៅលំបាកតោកយ៉ាកខ្លាំង ។ លោកបានលើកពីកង្វល់របស់លោកប្រាប់អាជ្ញាធរមូលដ្ឋាន អាជ្ញាធរខេត្ត និង អាជ្ញាធរថ្នាក់ជាតិ នៅពេលដែលលោកអញ្ជើញត្រឡប់មកទីក្រុងភ្នំពេញវិញ លោកបានព្យាយាមសុំជួបតំណាងក្រុមហ៊ុនដែរ តែមិនបានជួប ទោះបើមានបុគ្គលិកការិយាល័យប្រចាំកម្ពុជា (OHCHR/Cambodia) អាចបានជួបនៅមុន ឬ ក្រោយពេល នៃដំណើរទស្សនកិច្ចរបស់លោកក៏ដោយ ។

ក្រុមហ៊ុននេះបានអះអាងថា ខ្លួនមិនបានទទួលអត្ថប្រយោជន៍អ្វីទេ ហើយថែមទាំងជិតតែនឹងក្ស័យធនទៀតផង ព្រោះខ្លួនត្រូវបង់លុយក្រៅផ្លូវការ (លុយក្រោមតុ ) យ៉ាងច្រើនសន្ធឹកសន្ធាប់លើកិច្ចការរដ្ឋបាលនៅគ្រប់លំដាប់ថ្នាក់ ។ បើតាមរបាយការណ៍មិនច្បាស់ការបានបង្ហាញថា នៅពេលថ្មីៗនេះ ភាគហ៊ុនរបស់ក្រុមហ៊ុននេះអាចមានការប្រែប្រួល ហើយចប្ចុប្បន្ននេះ ក្រុមហ៊ុនទាំងមូលត្រូវបានគ្រប់គ្រងដោយម្ចាស់ភាគហ៊ុនដែលជាជនជាតិខ្មែរ ក្នុងនោះម្ចាស់ភាគហ៊ុនធំជាងគេ គឺជាមន្ត្រីយោធាជាន់ខ្ពស់មួយរូប ។

កាលពីខែមេសា ឆ្នាំ២00៤ មានការបើកឱ្យប្រើប្រាស់ផ្លូវលំមួយខ្សែដែលភ្ជាប់ពីឃុំអូរស្វាយ ទៅផ្លូវជាតិដែលជាវិភាគទានរបស់សាលាខេត្ត និងកម្មវិធីសីលា ។ [១១៩] ក្នុងខែដដែលនេះដែរ តំណាងក្រុមហ៊ុនបានទៅទស្សនាឃុំអូរស្វាយ ដើម្បីជូនដំណឹងអ្នកស្រុកអំពីឱកាសរកការងារធ្វើ ព្រោះក្រុមហ៊ុនបាន និងកំពុងជ្រើសរើសបុគ្គលិកកម្មករ ឱ្យចូលបំរើការងារនៅរោងចក្រក្តាបន្ទះ ក្រុមហ៊ុនមានបំណងបង្កើតគំរោងថ្មីមួយទៀត នាពេលដ៏ខ្លីខាងមុខនេះ។ បើតាមសេចក្តីរាយការណ៍ ក្រុមហ៊ុននេះកំពុងធ្វើការឈូសឆាយពង្រីកដីមួយកន្លែង ដើម្បីធ្វើរោងចក្រអារឈើ ។

ដោយសារតែការកាប់រំលំព្រៃឈើ និង ការឈូសឆាយដីនៅក្បែរៗ ភូមិ ទើបបច្ចុប្បន្ននេះអ្នកស្រុកត្រូវធ្វើដំណើរយ៉ាងឆ្ងាយទើបដល់ព្រៃ បង្កឱ្យមានការលំបាកខ្លាំងដល់ប្រជាពលរដ្ឋក្រីក្រ ដែលពឹងពាក់ទាំងស្រុងលើអនុផលព្រៃឈើ ហើយប្រជាពលរដ្ឋទាំងនោះ មិនហ៊ានជួបសន្តិសុខក្រុមហ៊ុនទេ ដោយគេនិយាយថា សន្តិសុខទាំងនោះនឹងទារលុយ ឬ ដកហូតយកអនុផលព្រៃឈើរបស់ខ្លួន ។

នេះជាសំដីរបស់អ្នកភូមិម្នាក់អាយុ៧៤ ឆ្នាំ មកពីភូមិរុន :

*" កាលពីក្នុងទសវត្សឆ្នាំ៦0 ព្រះមហាក្សត្របានយាងមកទីនេះ ។ ព្រះអង្គបានមានព្រះរាជបន្ទូលថា ដីនេះជាដីរបស់ព្រះអង្គ ព្រះរាជបិតារបស់យើង ហើយយើង ជាកូនចៅរបស់ព្រះអង្គ ត្រូវគេបញ្ជូនមកការពារទឹកដីនេះ ។ នៅពេលដែលក្រុមហ៊ុនបានរំលោភយកដីនេះ ខ្ញុំបានធ្វើបាតុកម្មតវ៉ា ព្រោះខ្ញុំនៅទីនេះគឺដើម្បីរក្សា និងការពារដីឱ្យព្រះមហាក្សត្ររបស់យើង ។ ឥឡូវនេះអ្នកធំកំពុងតែសោយរាជ្យលើទឹកដីយើងហើយ ។ តើហេតុអ្វីបានជាដូច្នេះ? ខ្ញុំនៅតែដង្ហែរតាមព្រះមហាក្សត្រជានិច្ច ហើយខ្ញុំបន្តការពារទឹកដីយើងជាដរាប ។*

[១១៩] កម្មវិធីសំរួល និង ស្វែងរកជំនួយដើម្បីទ្រទ្រង់ដល់កំណែទម្រង់កម្មវិធីវិមជ្ឈការ និង សហមជ្ឈការ

# សេចក្តីសន្និដ្ឋានរួម

ក្រោយពីមានកំហុសនៅក្នុងទសវត្សកន្លងមក ក្នុងការចាត់ចែងគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិ នៅក្នុងប្រទេសកម្ពុជា នៅមិនទាន់រកឃើញវិធីដោះស្រាយនៅឡើយ ។ បើទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលប្រទេស អ្នកផ្តល់ជំនួយ និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ បច្ចុប្បន្ននេះកំពុងធ្វើការចោទសួរអំពីគំរូនៃការអភិវឌ្ឍន៍សម្បទាន និង ការស្វែងរកគំរូជំរើសផ្សេងទៀត សំរាប់ធ្វើកំណែទម្រង់វិស័យកសិកម្ម ។ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និង គំរោងចាត់ចែងគ្រប់គ្រងរដ្ឋបាលដីធ្លី បានព្យាយាមដោះស្រាយបញ្ហាជាច្រើនដូចបានលើកឡើង ក្នុងរបាយការណ៍នេះ ។ បច្ចុប្បន្ននេះ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីអាចចេញបានក្នុងអាត្រា ២០,០០០ ប័ណ្ណក្នុងមួយខែ ហើយគេរំពឹងថាឆ្នាំក្រោយ អាត្រានេះនឹងកើនឡើងរហូតដល់៣០.០០០ ប័ណ្ណក្នុងមួយខែ ។ ក្រុមការងារមួយដែល មានភារៈពិនិត្យសម្បទានគោលដៅសេដ្ឋកិច្ចឡើងវិញ ត្រូវបានបង្កើតឡើងក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និង សំណង់ ហើយមានបំណងបញ្ជូនសេចក្តីព្រាងអនុក្រឹត្យស្តីពីសម្បទានគោលដៅសេដ្ឋកិច្ច ទៅក្រុមប្រឹក្សាគោលនយោបាយដីធ្លីនៅចុងឆ្នាំនេះ ។ ពង្រាងសេចក្តី ណែនាំស្តីពីការកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ បច្ចុប្បន្នកំពុងដំណើរការរៀបចំ តាមការកំណត់នៅក្នុងមាត្រា១៨ នៃច្បាប់ភូមិបាល ។ នៅពេលដែលពង្រាងនេះ និង ឯកសារផ្សេងទៀត ត្រូវបានរៀបចំចប់សព្វគ្រប់ហើយមានគំរោងបន្ថែមមួយទៀត ដែលបច្ចុប្បន្នកំពុងដំណើរការ រៀបចំ ដែលមានឈ្មោះថា " គំរោងបែងចែកដីធ្លីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ច " ដែលគំរោងនេះនឹង ត្រូវផ្តើមធ្វើនៅពេលដ៏ខ្លីខាងមុខនេះ ។ កិច្ចខំប្រឹងប្រែងជាច្រើនកំពុងធ្វើ ដើម្បីធានាឱ្យមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ការវាយតំលៃពីផលប៉ះពាល់សង្គម និងបរិស្ថាន ការបើកឱ្យដេញថ្លៃជាសាធារណៈ ការធ្វើរបាយការណ៍ ការងារ ការសង្កេតមើលពីខាងក្រៅ និង ការបង្កើតចំណូលរដ្ឋ ។ គំរោងនេះដែរ បានចាប់ផ្តើមបង្កើតនីតិវិធីស្តីពីការកំណត់ដីរដ្ឋ ក្នុងស្រុកចំនួនពីរ ដែលត្រូវធ្វើក្នុងទ្រង់ទ្រាយធំនៅឆ្នាំ២០០៥ ។ គំរោងនេះមានគោលដៅកំណត់រាល់សម្បទានទាំងអស់ចាប់ពីសម្បទានគោលដៅសេដ្ឋកិច្ច រហូតដល់សម្បទានគោលដៅនេសាទ សម្បទានគោលដៅរ៉ែ និងតំបន់ការពារនៅក្នុងប្រព័ន្ធទិន្នន័យមួយ ។ គំរោងនេះនឹងរួមគ្នាផ្តល់ជាហិរញ្ញវត្ថុសំរាប់គំរោងថតពីលើអាកាស លើទឹកដីនៃប្រទេសកម្ពុជាទាំងមូលដែលនឹងបានទិន្នន័យជាលេខ ងាយស្រួលស្វែងរកព័ត៌មានទាក់ទងនឹងដីធ្លី ។

គេសង្ឃឹមថា នៅពេលដែលគំរោងទាំងនេះត្រូវបានដាក់ឱ្យអនុវត្ត វានឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ។ មានវិស័យជាច្រើន ដែលគួរឱ្យព្រួយបារម្ភណ៏ជាងបរិបទជាក់លាក់នៃគោលនយោបាយដីធ្លី និង ការអភិវឌ្ឍន៏វិស័យកសិកម្មទៅទៀត ដែលចាំបាច់ត្រូវតែដោះស្រាយ ប្រសិនបើចង់គ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិនៃប្រទេសកម្ពុជា សំរាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនោះ ។ បញ្ហាទាំងនោះ រួមមានបញ្ហាទាក់ទងនឹងប្រព័ន្ធច្បាប់ និង អំពើពុករលួយផងដែរ ។

សម្បទានគោលដៅសេដ្ឋកិច្ចគ្រាន់តែជាផ្នែកមួយនៃរូបភាពមួយផ្ទាំងធំតែប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងការចាត់ចែងគ្រប់គ្រងដីធ្លីនៅប្រទេសកម្ពុជា ។ លទ្ធផលទាំងមូលនៃរបាយការណ៍នេះ ជួយបន្ថែមលើលទ្ធផលដែលក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យបានរកឃើញ :

*តាមរយៈការវិភាគត្រួសៗ ជាងមួយទសវត្សកន្លងមកនេះ តាមព្រឹត្តន័យហាក់បង្ហាញឱ្យឃើញថារាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការប្រើប្រាស់ដីធ្លីជាឧបករណ៍សារពើព័ន្ធ ។ ដោយសារតែបរិយាកាសអភិបាលកិច្ចប្រព្រឹត្តទៅមិនបានល្អ រដ្ឋអាចទាញយកបានអត្ថប្រយោជន៍មានកំរិត ពីការប្រើប្រាស់ដីធ្លីតាមមធ្យោបាយបែបនេះ មានតែបុគ្គលឯកជនមួយចំនួនតូចប៉ុណ្ណោះ ដែលអាចទាញយកប្រយោជន៍បានច្រើន ។*[១២០]

ការស្រាវជ្រាវដល់ទីកន្លែងបានបង្ហាញឱ្យឃើញពីបទពិសោធន៍នៃប្រទេសនានាដែលបានប្រើប្រាស់គំរូចំការដំណាំខ្នាតធំ :

*ផលប៉ះពាល់ធំបំផុតមួយ គឺសិទ្ធិអាស្រ័យផលលើផ្ទៃដីធំៗ ដែលរហូតមកទល់ពេលនេះ ស្ថិតក្នុងដៃរបស់ជនជាតិដើមភាគតិច ឬ កសិករ ហើយដីនេះទៀតសោតបានផ្តល់នូវជីវភាពរស់នៅរបស់ពួកគេ ។ ការដកហូតដីធ្លីទាំងនេះ ជាទូទៅតែងបណ្តាលឱ្យមានការតស៊ូប្រឆាំងពីប្រជាពលរដ្ឋមូលដ្ឋាន ដែលបានប្រឈមមុខនឹងការបង្ក្រាបដោយកងកំលាំងសាធារណៈ ក៏ដូចជា ...របស់ក្រុមហ៊ុនខ្លួនឯង ។ ការរំលោភសិទ្ធិដីធ្លី គឺជាតួយ៉ាង ដែលបន្ទាប់ពីនោះមានការរំលោភសិទ្ធិមនុស្សផ្សេងទៀត រួមមានសិទ្ធិរស់រានមានជីវិតជាដើម្បី ។*[១២១]

ជារឿយៗ សម្បទានគោលដៅសេដ្ឋកិច្ចត្រូវបានផ្តល់នៅលើដីធ្លីដែលប្រជាពលរដ្ឋមូលដ្ឋានកំពុងប្រើប្រាស់ ហើយដែលជាទូទៅ ប្រជាពលរដ្ឋមានសិទ្ធិកម្មសិទ្ធិតាមច្បាប់ភូមិបាល ឆ្នាំ២០០១ ។ មានករណីជាច្រើនដែលជាផ្នែកនៃការស្រាវជ្រាវដល់ទីកន្លែង បានបង្ហាញឱ្យឃើញថា សម្បទានិកទាំងឡាយ ជានិច្ចកាលបានធ្វើដូចជាគេធំជាងច្បាប់ ហើយទង្វើរបស់ពួកគេតែងទទួលបានការគាំទ្រជាផ្លូវការ ។ សម្បទានិកទាំងនោះបានសំដែងនូវការយកចិត្តទុកដាក់តិចតួចចំពោះការងារដែលមានចរិតលក្ខណៈបរិស្ថានប្រកបដោយនិរន្តរភាព ហើយមានការគិតគូតិចតួចអំពី ផលប្រយោជន៍ សិទ្ធិ និង សុខមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋានដែលជាអ្នកទទួលរងនូវផលប៉ះពាល់ ។ ការគ្រប់គ្រង សម្បទានរបស់គេបាននាំឱ្យមានការដកហូតដីធ្លី និង ធ្វើឱ្យប្រជាពលរដ្ឋមូលដ្ឋានមានជីវភាពក្រីក្រ និង នាំឱ្យមានជម្លោះ ក៏ដូចជាការព្រួយបារម្ភអំពីបរិស្ថានជីវចំរុះ ។ ប្រជាពលរដ្ឋមូលដ្ឋានត្រូវបានគេបដិសេធសិទ្ធិជាប្រពៃណី ក្នុងការប្រើប្រាស់ដីធ្លី និង សិទ្ធិកម្មសិទ្ធិលើដីធ្លី ព្រមទាំងសិទ្ធិធ្វើស្រែចំការដែលសំខាន់ចាំបាច់បំផុតសំរាប់

---

[១២០] ក្រុមត្រួតពិនិត្យព្រៃឈើឯករាជ្យ ជំពូក១០ ទំព័រទី១៤

[១២១] R. Carrere, " ការបំពុលនៃផ្លែដូងប្រេង " , (អង្គការ World Rainforest Movement, 2002)

ទ្រទ្រង់ជីវភាពរស់នៅ និង សំរាប់មនុស្សជំនាន់ក្រោយ ។ ព្រៃឈើដែលគេពឹងពាក់អាស្រ័យ ត្រូវគេកាប់រំលំអស់ ហើយដើមឈើធំៗត្រូវគេកាប់ដោយបំពានច្បាប់ ។ មានការកាប់ឈើខុសច្បាប់ ហើយនៅតែបន្តកាប់ នៅក្រៅព្រំដីសម្បទាន ។ ការសិក្សាលើករណីសម្បទានមួយ មិនបានធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និង ការពិគ្រោះយោល់ឱ្យបានល្អិតល្អន់ជាមួយប្រជាពលរដ្ឋមូលដ្ឋានដែលជាអ្នកទទួលរងនូវផលប៉ះពាល់នោះទេ ។ គឺគ្រាន់តែបានបង្កើតឱ្យមានការងារមួយចំនួន ហើយការងារទាំងនោះទៀតសោតក៏បានប្រាក់ឈ្នួលទាប ។ វាដូចជាមិនឃើញថាសម្បទានទាំងនេះបានផ្តល់អត្ថប្រយោជន៍អ្វីដល់ប្រជាពលរដ្ឋនៅមូលដ្ឋាននោះទេ ។

វាលំបាកនឹងឃើញផងដែរថា ប្រជាពលរដ្ឋកម្ពុជាទាំងមូលបានទទួលអត្ថប្រយោជន៍អ្វីពីសម្បទានទាំងនោះ ព្រោះវាមិនបានបង្កើតប្រាក់ចំណូលអ្វីធំដុំដល់រាជរដ្ឋាភិបាល ក្រៅតែពីថ្លៃ ឈ្នួល ប្រាក់កក់ និង ពន្ធអាករផ្សេងៗ តែប៉ុណ្ណោះ ។ មានតែចំនួនភាគរយដ៏តិចតួចបំផុត នៃផ្ទៃដីសរុបដែលបានបែងចែកទៅឱ្យសម្បទានិកដែលបានធ្វើការដាំដំណាំ ហើយបើតាមការស្រាវជ្រាវដល់ទីកន្លែងឃើញថា ដំណាំដែលបានដាំដុះរួចហើយ មិនបានធ្វើការថែទាំបានត្រឹមត្រូវទេ ។ ប្រាក់កម្រៃសំខាន់ដែលសម្បទានិកទទួលបាន គឺបានមកពីការកាប់ឈើ ។ បើទោះដូច្នេះក្តីវាមិនទំនងថា ការកាប់ឈើបានផ្តល់ប្រាក់ចំណូលធំដុំចូលថវិការដ្ឋទេ បើតាមរបាយការណ៏ថាមានការកាប់ឈើខុសច្បាប់ និង មានករណីជាក់ស្តែង ដែលក្រុមហ៊ុនហៃនិញ គ្រុប (Haining Group) បានគេចពន្ធជាដុំកំភួន ។

ស្ថាប័នរដ្ឋពាក់ព័ន្ធមិនបានសំដែងឱ្យឃើញពីការត្រៀមខ្លួនជាស្រេចក្នុងការពង្រឹងអនុវត្តច្បាប់ ដើម្បី ធានាថា សម្បទានិកទាំងអស់គោរពច្បាប់ និង លក្ខខណ្ឌនៃកិច្ចសន្យារបស់ខ្លួន ឬ ដោយការធ្វើមោឃៈភាពកិច្ចសន្យាក្នុងករណីមានការរំលោភធ្ងន់ធ្ងរ ។

កង្វល់ និងបញ្ហានានាដែលបានគូសបញ្ជាក់ក្នុងរបាយការណ៏នេះ ក៏អនុវត្តផងដែរចំពោះប្រភេទសម្បទានផ្សេងៗទៀត ដែលជាទូទៅពាក់ព័ន្ធនឹងតំបន់ដីធំៗ ដូចជាតំបន់ទំនប់វារីអគ្គិសនី តំបន់រ៉ែ ត្បូង និង តំបន់អភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៏ ។ គ្មានច្បាប់ណាមួយធ្វើនិយ័តកម្មការផ្តល់សម្បទានបែបនេះទេ ព្រោះសម្បទានទាំងនេះ មិនត្រូវបានរាប់បញ្ចូលក្នុងលក្ខខណ្ឌនៃមាត្រា៥០ នៃច្បាប់ភូមិបាលឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់តម្រូវឱ្យធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថានសំរាប់គំរោងភាគច្រើន ។ តាមពតិមានដែលទទួលបាន មានករណីភាគច្រើន ដែលសេចក្តីតម្រូវខាងលើនេះមិនត្រូវបានគេអនុវត្តទេ ។ ការស្រាវជ្រាវរហូតមកទល់ពេលនេះ បង្ហាញថា លំនាំដដែលនេះត្រូវបានគេយកមកអនុវត្តសំរាប់ចុះកិច្ចសន្យានានា ដោយមានការគិតគូរតិចតួច ដល់ប្រជាពលរដ្ឋមូលដ្ឋាន មានការពិគ្រោះយោបល់ជាសាធារណៈបន្តិចបន្តួច ឬ គ្មានទាល់តែសោះ និង ខ្វះតម្លាភាព ។

មានឧទាហរណ៏ថ្មីមួយ គឺសម្បទានមួយដែលបានអនុម័តយល់ព្រមផ្តល់ឱ្យក្រុមហ៊ុន ញូកូស្មូ (New Cosmo) ដែលជាក្រុមហ៊ុនចិនមួយ ដែលបានចុះបញ្ជីនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៣ ក្នុងរាជធានីភ្នំពេញ នៅ

ឧទ្យានជំរកសត្វ ព្រៃភ្នំឱរាល ក្នុងខេត្តកំពង់ស្ពឺ ក្នុងគោលដៅធ្វើជាតំបន់កសិទេសចរណ៍ និង ទេសចរណ៍ធម្មជាតិ ។ សម្បទាននេះ បានបង្កឱ្យមានកង្វល់ដល់សាធារណជនគ្រប់ទិសទី ។ សម្បទាននេះគំរាមកំហែង ប្រមាថដល់ទីសការៈបូជាផ្នែកសាសនាដ៏ពិសិដ្ឋិបំផុតរបស់ជនជាតិភាគតិចសួយ ដោយសាងសង់រមណីយដ្ឋាន ហាងលក់តវ៉ាន់ កាស៊ីណូ កន្លែងស្ទុងខ្លួន សួនកំសាន្ត និង បង្កើតភូមិបុរាណជាច្រើនកន្លែង ។ ក្រុមហ៊ុនក៏មានគំរោងបង្វែរ និង ធ្វើទំនប់ទប់ស្ទឹងតាសោងផងដែរ ដើម្បីផ្គត់ផ្គង់ទឹកទៅព្រែកជីក និង យកទឹកសំរាប់ស្រោចស្រប់លានវាយកូនហ្គោល មួយកន្លែង ដែលមានផ្ទៃដី ២០០ហិកតា ។ ជនជាតិភាគតិចសួយពឹងអាស្រ័យលើរបបរនេសាទត្រីក្នុងស្ទឹង នៅពេលរដូវប្រាំង ដើម្បីផ្គល់ជីវជាតិប្រូតេអ៊ីនសំរាប់ពួកគេ ។[១២២]

ក្នុងខែមីនា ឆ្នាំ២០០៤ រដ្ឋមន្ត្រីក្រសួងបរិស្ថានបានចុះហត្ថលេខាលើអនុសារណៈស្តីពីការយោគយល់មួយជាមួយក្រុមហ៊ុនឧទ្យានជំរកសត្វព្រៃកម្ពុជាមួយ ដើម្បីធ្វើសួនសត្វ (ចិញ្ចឹមដាក់ទ្រុង ) និង សួនសត្វ (ចិញ្ចឹមលែងឱ្យដើរសេរី) លើផ្ទៃដី ៤០២.០០០ហិកតាក្នុងឧទ្យានជំរកសត្វព្រៃគូលេនព្រហ្មទេព ក្នុងខេត្ត ឧត្តរមានជ័យ ព្រះវិហារ និង សៀមរាប ។ តាមការប៉ាន់ប្រមាណថ្មីៗនេះឃើញថា មានប្រជាពលរដ្ឋប្រមាណជា២០.០០០នាក់ រស់នៅក្នុង និង ជុំវិញតំបន់ជំរកសត្វព្រៃ ដែលភាគច្រើនជាអ្នកប្រើប្រាស់ព្រៃនេះ ។ របាយការណ៍ជាច្រើនបញ្ជាក់ថា តំណាងក្រុមហ៊ុនបានស្នើសុំធ្វើរបងអគ្គីសនីព័ទ្ធជុំវិញសួនសត្វ ដើម្បីរារាំងអ្នកកាប់ឈើ និង អ្នកលួចចូលបរបាញ់សត្វក្នុងតំបន់នោះ ។

នាយកដ្ឋានវារីអគ្គីសនីនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលបានបង្ហាញគំរោងទំនប់ទឹកធំៗចំនួន ៦៣ កន្លែង នៅទូទាំងប្រទេសកម្ពុជា រួមមានទំនប់ទឹកខ្នាតធំចំនួន១៥ ផង ។[១២៣] ផែនការណ៍ធ្វើទំនប់ទឹកនេះមិនបានដឹងជាសាធារណៈទេ ប៉ុន្តែមានសេចក្តីព្រួយបារម្ភថា ប្រសិនបើមានគំរោងសំរាប់ការតាំងទីលំនៅថ្មី នឹង មិនមានផ្ទៃដីគ្រប់គ្រាន់ទេ ហើយរាជរដ្ឋាភិបាលគួរតែអនុវត្តតាមវិធីដោះស្រាយដ៏ប្រសើរបំផុត ដែលគណៈកម្មាធិការទំនប់ទឹកពិភពលោកបានផ្តល់ជាអនុសាសន៍ ។

---

[១២២] នៅពេលសរសេររបាយការណ៍នេះ យើងមិនទាន់ដឹងច្បាស់ថាតើរដ្ឋាភិបាលបានសំរេចផ្តល់សម្បទាននេះហើយ ឬ នៅ។ ឡើយទេ ។

[១២៣] របាយការណ៍របស់គណៈកម្មាធិការទំនប់ទឹកពិភពលោក *ទំនប់ទឹក និង ការអភិវឌ្ឍន៍ : ក្របខ័ណ្ឌថ្មីសំរាប់ធ្វើសេចក្តីសំរេចចិត្ត* ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០០ ចាត់ថ្នាក់ទំនប់ធំ ថាជា " ទំនប់ធំ គឺជាទំនប់ដែលមានកំពស់១៥ម៉ែត្រ ឬ ខ្ពស់ជាងនេះ ( គិតចាប់ពីបាតទំនប់ ) ។ ប្រសិនបើទំនប់នោះមាន កំពស់ពី៥ ទៅ ១៥ម៉ែត្រ ហើយមានជលដ្ឋាន (អាងទឹក) ដែលអាចផ្ទុកទឹកបានចំណុះច្រើនជាង ៣លានម៉ែត្រគូបឡើងទៅ ទំនប់នោះក៏ចាត់ទុកថាជាទំនប់ធំដែរ " ។ ទំនប់ដែលបានចាត់ចូលជាអាទិភាពរួមមាន ទំនប់គិរីរម្យ III ( នៅខេត្តកោះកុង ) ទំនប់កំចាយ ( នៅសួនឧទ្យានជាតិបូកគោ ) ទំនប់បាត់ដំបង II ( នៅក្បាលហុងទឹកស្ទឹងសង្កែ ) ទំនប់បាត់ដំបង I ( នៅស្ទឹងសង្កែ ) ទំនប់ស្ទឹងអាតៃ ( នៅភ្នំក្រវ៉ាញកណ្តាល ) ទំនប់ស្ទឹងឬស្សីជ្រុំកណ្តាល ( នៅភ្នំក្រវ៉ាញកណ្តាល) ទំនប់ស្ទឹង ឬស្សីជ្រុំក្រោម ( នៅភ្នំក្រវ៉ាញកណ្តាល ) ទំនប់ស្ទឹងឬស្សីជ្រុំលើ ( នៅភ្នំក្រវ៉ាញកណ្តាល ) ទំនប់ស្ទឹងជាយអារេង ( នៅភ្នំក្រវាញកណ្តាល ) ទំនប់ស្ទឹងតាតៃ ( នៅភ្នំក្រវ៉ាញកណ្តាល ) ទំនប់ស្ទឹងសំបូរ ( នៅដងទន្លេមេគង្គ ខេត្តក្រចេះ ) ទំនប់ស្រែពកក្រោម II ( នៅខេត្តស្ទឹងត្រែង ) និង ទំនប់សេសានក្រោម II ( នៅខេត្ត ស្ទឹង ត្រែង ) ។

រាជរដ្ឋាភិបាលបានកំណត់តំបន់រ៉ែមាសចំនួន១៩ កន្លែងនៅក្នុងប្រទេសកម្ពុជា ។ កន្លងមក យ៉ាងហោចណាស់ មានអាជ្ញាប័ណ្ណធ្វើអាជីវកម្មចំនួន៦ ដែលបានផ្តល់ជាថ្មី នៅក្នុងចន្លោះខែមីនា និង ខែកក្កដា ឆ្នាំ២00៤ នេះ ។[១២៤] តាមព័ត៌មានដែលទទួលបានបង្ហាញថា ពួកអាជីវករបានប្រើប្រាស់អាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែខុសទិសដៅ ដើម្បី គេចវេសពីការបង់ថ្លៃអាជ្ញាប័ណ្ណខ្ពស់ សំរាប់ការរុករករ៉ែជាក់ស្តែង ព្រមទាំងបានគេចវេសមិនបង់ពន្ធអាករផ្សេងៗ ប៉ុន្តែរហូតមកទល់ពេលនេះ មិនទាន់មានការចាត់វិធានការតាមផ្លូវច្បាប់ ណាមួយ ចំពោះជនដែលបានប្រព្រឹត្តរំលោភលើលក្ខខណ្ឌដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណទាំងនេះនៅឡើយទេ ។ តាមសេចក្តីរាយការណ៍បានឱ្យដឹងថាមានការបំពុលបរិស្ថាន និង ការបដិសេធមិនឱ្យប្រជាពលរដ្ឋមូលដ្ឋានប្រមូលអនុផលព្រៃឈើ នៅក្នុងតំបន់ជីកយករ៉ែ ។ ប្រការដែលគួរឱ្យព្រួយបារម្ភខ្លាំងនោះគឺ ការប្រើប្រាស់ជាទូទៅនូវជាតិគីមី ដែលបង្កគ្រោះថ្នាក់សំរាប់ការទាញយក និង ការលាងសំអាតរ៉ែមាស ដូចជាជាតិបារត និងសូដ្យូមដែលមានសារជាតិពុលខ្លាំង ជាហេតុធ្វើឱ្យក្រខ្វក់ដល់ប្រភពទឹក បំផ្លិចបំផ្លាញជីវិតសត្វព្រៃ និង ហ្វូងមច្ឆាជាតិដែលប្រជាពលរដ្ឋមូលដ្ឋានពឹងអាស្រ័យ និង បង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ។[១២៥]

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក៏បានចេញអាជ្ញាប័ណ្ណធ្វើអាជីវកម្មត្បូង ខ្សាច់ និង គ្រឿងសំភារៈសំណង់ផងដែរ ។ តំបន់ទាំងនេះជាទូទៅតូចជាងតំបន់រុករករ៉ែ លើកលែងតែក្រុមហ៊ុនសម្បទានខ្សាច់ តេកា អេស (TKS) ដែលមានប្រវែង៨0 គីឡូម៉ែត្រទ្វេគុណ ស្ថិតក្នុងសួនឧទ្យានជាតិបុទុមសាគរខេត្តកោះកុង ។ របាយការណ៍ជាច្រើនបង្ហាញឱ្យឃើញថា ក្រុមហ៊ុននេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន និង ជីវភាពរស់នៅរបស់ប្រជា-ពលរដ្ឋមូលដ្ឋាន ហើយមានការគិតគូរតិចតួចដល់កិច្ចដំណើរការវាយតំលៃពីផលប៉ះពាល់បរិស្ថាន ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាប្រឈមមុខនឹងការដែលប្រជាពលរដ្ឋនៅតំបន់ជនបទ បាត់បង់ដីធ្លី និងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិកាន់តែច្រើនឡើងៗនាពេលអនាគត ។ កិច្ចដំណើរការកាត់បន្ថយទំហំសម្បទានគោលដៅសេដ្ឋកិច្ចមកនៅត្រឹមផ្ទៃដី ១0.000ហិកតានេះ ត្រូវតែធ្វើឱ្យចប់សព្វគ្រប់ជាការប្រញាប់ ហើយដីដែលកាត់ចេញពីដីសម្បទាននោះត្រូវតែបង្វែរឱ្យទៅជាដីសម្បទានគោលដៅសង្គមកិច្ច ដើម្បីបែងចែកឱ្យប្រជាពលរដ្ឋដែលគ្មានដីធ្លី

---

[១២៤] ក្រុមហ៊ុននានាដែលត្រូវបានចេញអាជ្ញាប័ណ្ណជាថ្មីឱ្យប្រកបអាជីវកម្មនោះមាន : ក្រុមហ៊ុននីអូនា វ៉ាន់វីមិុច (Neoneer/Vannvymex) មានផ្ទៃដី៧៨ គីឡូ ម៉ែត្រក្រឡា នៅភ្នំជី ស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្រុមហ៊ុននីអូនា (Neoneer) មានផ្ទៃដី៨៧.៥ គីឡូម៉ែត្រក្រឡា នៅអណ្តូងបរ ខេត្តបន្ទាយជ័យ ក្រុមហ៊ុនស៊ីម៉ងត៍អង្គរវត្តជាសាខារបស់ក្រុមហ៊ុននីអូនា (Neoneer)មានផ្ទៃដី៣១.៥ គីឡូម៉ែត្រក្រឡា នៅអណ្តូងបរ ខេត្តឧត្តរមានជ័យ ក្រុមហ៊ុនជីញគូ ម៉ិុណឺរ៉ាល (Jinqu Minerals) មានផ្ទៃដី២៨គីឡូម៉ែត្រក្រឡា នៅខេត្តមណ្ឌលគីរី ក្រុមហ៊ុនជីញគូ ម៉ិុណឺរ៉ាល (Jinqu Minerals) មានផ្ទៃដី២៨ គីឡូម៉ែត្រក្រឡា នៅខេត្តក្រចេះ និង ក្រុមហ៊ុនស៊ុនត្រេដឌិញ (Sun Trading) មានផ្ទៃដី១១២ គីឡូម៉ែត្រក្រឡា នៅខេត្តកំពង់ចាម ។

[១២៥] បើចង់ដឹងពត៌មានបន្ថែមចំពោះការជីករ៉ែមាសនេះ សូមមេត្តាអាន *"របាយការណ៍ស្តីពីការជីករ៉ែមាសខ្នាតតូចនៅកម្ពុជា : ការវាយតម្លៃលើសភាពការណ៍"* អង្គការ Oxfam អាមេរិច, ចុះខែកក្កដា ឆ្នាំ២00៤ ។

ហើយរាជរដ្ឋាភិបាល ត្រូវតែតំកល់ប្រយោជន៍ជាតិធំជាងផលប្រយោជន៍ក្រុមហ៊ុនឯកជន ។ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះប្រព័ន្ធតំបន់អភិវឌ្ឍន៍យោធា។

សង្ឃឹមថាប្រទេសកម្ពុជានឹងអនុម័តច្បាប់ និង បទបញ្ញត្តផ្សេងៗមួយចំនួន ដែលមានលក្ខណៈទូលំទូលាយនាពេលដ៏ខ្លីខាងមុខនេះ ដើម្បីរៀបចំគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិរបស់ខ្លួន។ ទោះជាដូច្នេះក្តី ត្រូវតែផ្លាស់ប្តូរទំលាប់អនុវត្តការងាររដ្ឋបាលកន្លងមកឱ្យបានយ៉ាងធំទូលាយ និងឆាប់រហ័ស ប្រសិនបើច្បាប់ចាស់មិនត្រូវបានជំនួសដោយការប្រើប្រាស់ច្បាប់ថ្មី ដើម្បីកែតម្រូវការធ្វើសេចក្តីសម្រេចតាមទំនើងចិត្តរបស់រាជរដ្ឋាភិបាលនោះទេ។

រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវធានាការគោរពច្បាប់ជាតិ និង ច្បាប់អន្តរជាតិ រួមមានបទបញ្ញតិស្តីពីសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង អនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាក៏ជាភាគីហត្ថលេខី។ ការផ្លាស់ប្តូរណាមួយពីការធ្វើកសិកម្មសំរាប់ចិញ្ចឹមជីវិត ទៅជាការធ្វើកសិកម្មសំរាប់រកប្រាក់ចំណូលវិញ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវផងដែរ ចំពោះក្រុមហ៊ុនឯកជនដែលត្រូវបានរាជរដ្ឋាភិបាលផ្តល់សិទ្ធិសំខាន់ៗលើដីរដ្ឋ ដែលជាទ្រព្យសម្បត្តិសាធារណរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។ ក្រុមហ៊ុនឯកជនត្រូវគោរពច្បាប់ និង ទប់ស្កាត់រាល់សកម្មភាពរំលោភ ឬ ការរារាំងណាមួយមិនឱ្យទទួលបានសិទ្ធិមនុស្ស។ រដ្ឋាភិបាល និង ទីភ្នាក់ងារនៃប្រទេសអ្នកផ្តល់ជំនួយប្រព័ន្ធអង្គការសហប្រជាជាតិ និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាមានភារៈកិច្ចទទួលខុសត្រូវដ៏សំខាន់រៀងៗខ្លួន។ ភារកិច្ចរបស់សហប្រតិបត្តិការអន្តរជាតិក្នុងការជំរុញឱ្យមានការរីកចំរើនថែមទៀតខាងវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច និងលើកស្ទួយសិទ្ធិមនុស្សដែលបានដាក់តំកល់ក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តី ពីសិទ្ធិមនុស្ស និង ក្នុងសន្ធិសញ្ញានានាស្តីពីសិទ្ធិមនុស្សអន្តរជាតិ។ បញ្ហាទាំងនេះទាមទារឱ្យទីភ្នាក់ងារ អភិវឌ្ឍន៍ ទ្វេរភាគី និង ពហុភាគី ធានាដល់ការអនុវត្តគំរោងអភិវឌ្ឍន៍ និង កម្មវិធីជំនួយរបស់ខ្លួនប្រកបដោយភាពរលូនស្របតាមគោលការណ៍សិទ្ធិមនុស្ស។ គួរតែទទួលស្គាល់ថា ការគោរពសិទ្ធិមនុស្ស គឺជាកត្តាសំខាន់ជាសារវ័ន្ត និង ជាស្នូលសំរាប់ការគ្រប់គ្រងធនធានធម្មជាតិឱ្យបានល្អ។

របាយការណ៍នេះបានផ្តោតលើវិស័យមួយ នៃការគ្រប់គ្រងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា នោះគឺសម្បទានគោលដៅសេដ្ឋកិច្ច។ ការយល់ដឹងពេញលេញអំពីប្រព័ន្ធសម្បទានទាំងមូល គឺជាសេចក្តីត្រូវការចាំបាច់ជាបន្ទាន់។ បញ្ហានេះទាមទារឱ្យមានយន្តការនៃការទទួលខុសត្រូវ និង ការប្រកាសជាសារធារណៈ ដែលប្រទេសអ្នកផ្តល់ជំនួយបានស្នើឡើងជាច្រើនឆ្នាំមកហើយ។ រាជរដ្ឋាភិបាលបានសន្យាថានឹងអនុវត្តតាម។ តើដីធ្លី និង ព្រៃឈើនៃប្រទេសកម្ពុជាប៉ុន្មានត្រូវបានផ្តល់ជាសម្បទានទៅឱ្យនរណា ហើយដើម្បីគោលដៅអ្វីខ្លះ? គណៈរដ្ឋមន្ត្រីទំនងជាមានព័ត៌មានគ្រប់គ្រាន់ភាគច្រើននៅក្នុងដៃ ហើយគួរតែបញ្ចេញព័ត៌មាននេះឱ្យបានដឹងឮ ដើម្បីជាប្រយោជន៍សាធារណៈដែលមិនអាចប្រកែកបាន។ ផែនទីដីសម្បទានក្នុងប្រទេសកម្ពុជា រួមមានដីតំបន់អភិវឌ្ឍន៍យោធា ក៏

មានសារប្រយោជន៍ជាពិសេសផងដែរ ។ ព័ត៌មាននេះអាចឱ្យប្រទេសអ្នកផ្ដល់ជំនួយ និង ទីភ្នាក់ងារអភិវឌ្ឍន៍នានា បង្កើតកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិភាព និង ចំទិសដៅក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស ការកាត់បន្ថយភាពក្រីក្រ និង យុទ្ធសាស្ត្រចតុកោណ ។

អនុសាសន៍ដែលបានដាក់ចេញពីខាងដើមនៃរបាយការណ៍នេះ មានគោលបំណងដោះស្រាយបញ្ហាទាំងឡាយបានលើកឡើងក្នុងរបាយការណ៍ និង ដើម្បីបង្ហាញពីបំណងក្នុងការទ្រទ្រង់ដល់សន្តិភាព និង សន្តិសុខ ដែលជាសមិទ្ធិផលដ៏ធំធេងបំផុតនៃប្រទេសកម្ពុជា ក្នុងរយៈកាលជាងមួយទសវត្សកន្លងមកនេះ ។

# ឧបសម្ព័ន្ធទី ១

## ក្រុមហ៊ុន ចំការកៅស៊ូទីរីងៈ ករណីសិក្សា

ឃុំទីរីងលាតសន្ធឹងយ៉ាងជ្រៅទៅក្នុងតំបន់ព្រៃ នៃស្រុកសណ្តាន់ ខេត្តកំពង់ធំ ចំងាយ ១០០គ.ម ភាគខាងជើងស្រុកកំពង់ថ្ម តាមបណ្តោយផ្លូវជាតិលេខ៦។ ឃុំទីរីងមាន៨ ភូមិ និងមានប្រជាពលរដ្ឋចំនួនប្រមាណជា ២៦០០នាក់ រស់នៅពឹងផ្អែកទាំងស្រុងលើការធ្វើស្រែចំការ ការដងជ័រ និងការប្រមូលអនុផលព្រៃឈើជាប្រពៃណី ដើម្បីជីវភាពរស់នៅរបស់ពួកគេ។ មានក្រុមហ៊ុនព្រៃសម្បទានចំនួនបី បានធ្វើសកម្មភាពនៅក្នុងតំបន់នេះ តាំងតែពីដើមទសវត្ស ឆ្នាំ១៩៩០: ក្រុមហ៊ុន GAT (Grand Atlantic Timber International “GAT”) ក្រុមហ៊ុនមៀងលីហេង (Mieng Ly Heng) និងក្រុមហ៊ុន កូឡិចស៊ីម (Cambodia Okada Lumber Export Import Enterprise “Colexim”) ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០០១ មានតំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ អគ្គនាយកដ្ឋានចំការកៅស៊ូ និងក្រុមហ៊ុនចំការកៅស៊ូជុប បានចុះពិនិត្យវាយតំលៃតំបន់ដីក្រហមនៅក្នុងឃុំទីរីង ហើយបានកំណត់ថាជាដីសមស្របដែលមានសក្តានុពលសំរាប់ដំណាំកៅស៊ូ។ សម្តេចនាយករដ្ឋមន្ត្រីបានចុះហត្ថលេខាលើអនុក្រឹត្យ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ គឺរយៈពេលពីរសប្តាហ៍មុនការប្រកាសឱ្យប្រើច្បាប់ភូមិបាល ឆ្នាំ២០០១ និងរយៈពេល៣ ខែ មុនការចេញសេចក្តីប្រកាសស្តីពីការផ្អាកជាបណ្តោះអាសន្នរាល់ការកាប់ឈើ និង ដឹកជញ្ជូនឈើ ដែលបានចូលជាធរមាន នៅថ្ងៃ ទី១ ខែមករា ឆ្នាំ២០០២។ អនុក្រឹត្យនេះសំរេចកាត់ផ្ទៃដីក្រហមចំនួន៦២០០ ហិកតាចេញពីតំបន់ព្រៃសម្បទានរបស់ក្រុមហ៊ុនចំនួនបី ហើយប្រគល់ដីក្រហមនោះឱ្យក្រុមហ៊ុនចំការកៅស៊ូជុប [១] ដែលជាក្រុមហ៊ុនរដ្ឋសំរាប់ដាំដើមកៅស៊ូជាលក្ខណៈឧស្សាហកម្ម និងជាលក្ខណៈគ្រួសារ [២] ។ មិនមានការវាយតំលៃពីផលប៉ះពាល់សង្គម ឬផលប៉ះពាល់បរិស្ថានត្រូវបានធ្វើឡើងទេ។ ដោយហេតុថាផ្ទៃដីនេះមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់ព្រៃសម្បទានតទៅទៀតនោះ ទើបសេចក្តីប្រកាសស្តីពីការផ្អាកជាបណ្តោះអាសន្នរាល់ការកាប់ឈើ និងដឹកឈើមិនត្រូវបានអនុវត្តទេ។ សម្បទានិកនៃក្រុមហ៊ុនព្រៃសម្បទានទាំងបីដែលធ្លាប់គ្រប់គ្រងផ្ទៃដី ដែលបានកាត់ចេញពីតំបន់របស់ខ្លួននោះបានត្រូវក្រុមហ៊ុនចំការកៅស៊ូបចុះកិច្ចសន្យាបន្តឱ្យកាប់ឈើនៅលើតំបន់ចំការកៅស៊ូ

---

[១] ជុប គឺជាក្រុមហ៊ុនចំការកៅស៊ូរបស់រដ្ឋមួយ ក្នុងចំនោមក្រុមហ៊ុន៧ ដែលបានគ្រប់គ្រងចំការកៅស៊ូតាំងតែពីឆ្នាំ ១៩៧៩ មក។ វាគឺជាចំការកៅស៊ូដំបូងបំផុតដែលបានបង្កើតឡើង ក្នុងអំឡុងពេល ប្រទេសកម្ពុជាស្ថិតក្រោមអាណាព្យាបាលបារាំង ។

[២] ក្នុងខែសីហា ឆ្នាំ២០០០ រាជរដ្ឋាភិបាលបានប្រកាសឡើងនូវការរបង្កើតអោយមានចំការកៅស៊ូជាលក្ខណៈគ្រួសារ ដែលជាអាទិភាពនៃការអភិវឌ្ឍន៍ទីជនបទ។ ដំណាក់កាលដំបូងនៃគំរោង អភិវឌ្ឍន៍ដំណាំកៅស៊ូខ្នាតតូច បានចាប់ផ្តើមនៅឆ្នាំ ១៩៩៩ ដោយចំណាយទឹកប្រាក់អស់ ៣លានដុល្លាអាមេរិក ហើយផ្តល់ថវិកាដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ។ ក្នុងឆ្នាំ ២០០០ រាជរដ្ឋាភិបាលបានប្រកាសថា រាជរដ្ឋាភិបាលនឹងជួយដល់ប្រជាពលរដ្ឋណាដែលចូលរួមក្នុងគំរោងនេះដោយស្ម័គ្រចិត្ត ដោយមានការផ្តល់ឱ្យនូវសិទ្ធិកម្មសិទ្ធលើដីធ្លី សិទ្ធិលក់ដូរផលិតផលកៅស៊ូដោយសេរី ហើយនិងតាមរយៈការសំរួលការខ្ចីលុយពីធនាគារ ។ ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ត្រូវបានស្នើសុំឱ្យចូលរួមក្នុងការអនុវត្តគំរោងនេះ ហើយដែលគំរោងនេះ ក៏បានទទួលការគាំទ្រពីសហគមន៍អ្នកផ្តល់ជំនួយដែរ ។ គំរោងនេះមានគោលបំណងធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និង ផ្តល់ដល់ពួកគេនូវប្លង់កាន់កាប់ដី ប្រាក់កម្ចី និង ជំនួយបច្ចេកទេស ។

មុនពេលផ្ទៃដីនេះត្រូវឈូសឆាយ ។ ដើមឈើដ៏មានតំលៃ និងដើមច្បោះរបស់ប្រជាពលរដ្ឋយ៉ាងច្រើនសន្ធឹកសន្ធាប់ ត្រូវបានកាប់រំលំដែលទង្វើនេះគឺ ផ្ទុយទាំងស្រុងទៅនឹងការហាមឃាត់ការកាប់ដើមច្បោះ ដែលមានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ[៣] ។

នៅក្នុងខែតុលា ឆ្នាំ២០០៣ នាយកក្រុមហ៊ុនចំការកៅស៊ូទីរីងបានបញ្ជាក់ថា ផ្ទៃដីទំហំ១.៦០០ ហិកតា ត្រូវបានឈូសឆាយរួចហើយ ដែលក្នុងទំហំនេះមាន ២១៥,៥ ហិកតា មិនទាន់បានដាំដុះទេ ទំហំ ៧៨៧ ហិកតាបាន បែងចែកជូនប្រជាពលរដ្ឋ និង ២៩៧ ហិកតា បានដាំដើមកៅស៊ូរួចហើយ ។ គាត់បានប៉ាន់ប្រមាណថាការឈូសឆាយដី និងការដាំដុះនឹងបញ្ចប់នៅឆ្នាំ២០០៧ ។

## ឃុំទីរីង[៤]

ប្រជាពលរដ្ឋរស់នៅក្នុងឃុំទីរីងជាជនជាតិខ្មែរ ដោយមានអ្នកជាប់ពូជពង្សជនជាតិគួយមួយចំនួនតូច ។

| ឈ្មោះភូមិ | ចំនួនប្រជាពលរដ្ឋ | ចំនួនគ្រួសារ |
|---|---|---|
| រនាម | ១៦៣ | ៤០ |
| ក្បាលដំរី | ២០៦ | ៥២ |
| សំរោង | ២៦៧ | ៦៧ |
| ស្រឡៅស្រោង | ៣៤២ | ៧៩ |
| ខោស | ៣៦៦ | ៨០ |
| រន្ទះ | ៣២៧ | ៨៣ |
| លែង | ៣៨៦ | ៨៨ |
| ទំអរ | ៥៥១ | ១២៤ |
| *សរុប* | *២៦០៨* | *៦១៣* |

ចាប់តាំងពីក្រុមហ៊ុន GAT បានបើកប្រតិបត្តិការតំបន់របស់ខ្លួន ក្នុងឆ្នាំ១៩៩៦ ដោយការធ្វើផ្លូវមួយខ្សែ បាននាំឱ្យមានអ្នកចំណូលថ្មីជាច្រើនចូលមកតាំងទីលំនៅ ជាពិសេស នៅភូមិទំអរ ក្នុងឆ្នាំ១៩៩៨ នៅភូមិខោស ក្នុង

---

[៣] មាត្រា ២៩ នៃច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ចែងថា "ការប្រមូលផល អនុផល ត្រូវបានហាមឃាត់លើប្រភេទឈើកំរ ដែលប្រជាជននៅមូលដ្ឋានចោះយកជ័រជាប្រពៃណី ។" មុនការអនុម័តច្បាប់ស្តីពីព្រៃឈើនេះ ក៏មានមាត្រា១៧ នៃវិធានស្តីពីការគ្រប់គ្រងព្រៃឈើ ចុះថ្ងៃ២៥ ខែមិថុនា ឆ្នាំ១៩៩៨ ដែលចែងថា " ការកាប់រំលំដើមច្បោះ ដែលប្រជាជនចោះយកជ័រ ត្រូវហាមឃាត់ " ។

[៤] ការសំភាសន៍ជាលក្ខណៈទូទៅជាមួយមនុស្សចំនួន ៣៥ នាក់ ត្រូវបានធ្វើឡើងជាមួយ ប្រជាពលរដ្ឋនៅមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមេភូមិ តំណាងក្រុមហ៊ុន និងក្រុមដែលមានផលប្រយោជន៍ផ្សេងទៀត ។

ឆ្នាំ១៩៩៩ និង ភូមិស្រឡៅស្រោង ក្នុងឆ្នាំ២០០០ ។ អ្នកចំណូលថ្មីភាគច្រើនមកពីខេត្តកំពង់ចាម ដែលមកដោយខ្លួនឯង ឬក៏បញ្ជូនមកដោយក្រុមហ៊ុនចំការកៅស៊ូ ចំពោះអ្នកធ្វើការឱ្យក្រុមហ៊ុន ។ ពួកគេកាប់រានដីទំហំពី ១ ទៅ ២ហិកតា ដើម្បីធ្វើស្រែ និង ដាំស្វាយចន្ទី ចេក ខ្នុរ និង ល្ហុង ។

បើតាមកំណត់ត្រាឆ្នាំ២០០១ របស់មេឃុំទីរីង ផ្ទៃដីសរុបរបស់ឃុំមានទំហំ៤៦.១៥០ ហិកតា ដែលក្នុងទំហំនេះមាន៤៤.៩៣១ ហិកតា ជាដីព្រៃ ៥០ហិកតា ជាស្រះទឹក ២០០ហិកតា ជាដីវាល ឬដីព្រៃរិចរិល ៦៨៩ ហិកតា ជាដីចំការ និង ១៥១ហិកតា ទៀត ជាវាលស្រែ ។

ជាប្រពៃណី អ្នកស្រុកទាំងនេះរស់នៅដោយពឹងផ្អែកទាំងស្រុងលើការធ្វើស្រែប្រដេញទឹក និងធ្វើកសិកម្មពនេចរ ដើម្បីដាំស្រូវ ពោត ល្ង និងសណ្តែក ។ ដីសំរាប់កសិកម្មប្រភេទនេះ ត្រូវបានប្រើប្រាស់រយៈពេល ពី៥ឆ្នាំទៅ៧ឆ្នាំ មុននឹងមានការកាប់រានលើដីថ្មីដែលត្រូវការ ។ អ្នកស្រុកនេះមានចំណូលបន្ថែមពីការដងជ័រ ។ អ្នកទីមួយដែលចោះដើមជ័រមុនគេ ទទួលបានសិទ្ធិកម្មសិទ្ធិលើដើមច្បោះនោះ ហើយអាចលក់ ឬជួល ដើមច្បោះទាំងនោះដោយសេរី ឬអាចទុកឱ្យដល់កូនចៅរបស់ខ្លួន ។ ជ័រទឹកដែលបានមកពីដើមឈើទាល ត្រូវបានប្រើប្រាស់សំរាប់ធ្វើចន្លុះ និងលាបទូក ។ បើតាមការរៀបរាប់របស់អ្នកស្រុក គ្រួសារខ្លះមានដើមច្បោះរហូតដល់ ១០០ ដើម ឬ ២០០ ដើម ឬក៏ច្រើនជាងនេះ ហើយដែលអាចរកចំណូលបានដល់ទៅ ១០០ដុល្លាអាមេរិកក្នុងមួយ ខែ។ ពីការដងជ័រ ។ ការដងជ័រត្រូវបានគេចាត់ទុកថាជាមុខរបរដែលអាចផ្លាស់ប្តូរទៅតាមកាលៈទេសៈ ព្រោះអ្នកស្រុកអាចនឹងគ្រាន់តែទៅដងជ័រពេលណាដែលគាត់ត្រូវការចំណូល ។ ទន្ទឹមនឹងមុខរបរទាំងនេះ អ្នកស្រុកក៏រកវល្លិ បោចផ្តៅ រកផ្សិត រករុក្ខជាតិសំរាប់ផ្សំថ្នាំបុរាណ បេះផ្លែឈើព្រៃ និង ជីកមើមឈើ ។ ពួកគេបរបាញ់ជ្រូកព្រៃ ឈ្លូស ក្តាន់ញៀង និងរកអណ្តើក ចាប់ត្រកួត សត្វពពូល លលក និងសត្វល្អិតជាច្រើនប្រភេទទៀត ។ ប្រព័ន្ធសេដ្ឋកិច្ច ជាប្រពៃណីនេះ បានផ្តល់ដល់អ្នកស្រុកនូវចំណូល និងជីវភាពរស់នៅជាមូលដ្ឋាន ។

## ជីវិតរស់នៅតាមបែបប្រពៃណីនៅក្នុងព្រៃ

ភូមិខោស ភូមិក្បាលដំរី ភូមិលែង ភូមិរនាម និង ភូមិរន្ទះ គឺជាភូមិ ចាស់ ។[៥] អ្នកភូមិខ្លះបានតំណាលថា បុព្វបុរសរបស់គេបានមកពីប្រទេសឡាវ មករស់នៅទីនេះតាំងពីយូរលង់ណាស់មកហើយ។ កូនចៅជំនាន់ក្រោយៗ បានបន្តរស់នៅតំបន់នេះ ដោយសារជីវភាពរស់នៅមានលក្ខណៈល្អប្រសើរ ។

[៥] ភូមិជាច្រើនត្រូវបានរាយការណ៍ដោយលោក Auguste Pavie ក្នុងឆ្នាំ ១៨៨១ ជាពេលដែលគាត់បានធ្វើដំណើរជុំវិញប្រទេសកម្ពុជា, Pavie Aususte, បេសកកម្ម Pavie, ឥណ្ឌូចិន, ១៨៧៩-១៨៩៥, géographie des voyages, Paris, Ernest Leroux, ភាគ១ ភាគ២ និងភាគ៧ ឆ្នាំ ១៩០១ ដល់ ១៩០២ ។

ក្នុងទសវត្សឆ្នាំ១៩៥០ ភូមិទាំងអស់នេះមានផ្ទះចំនួនតិចតួច ហើយដែលអ្នកតាំងទីលំនៅទាំងអស់ជាសាច់ញាតិនឹងគ្នា ។ ភូមិចាស់ខ្លះ ដែលមានឈ្មោះលើផែនទីបានបាត់បង់ទៅហើយ តែអ្នកភូមិវិញ ជាធម្មតាបានផ្លាស់ប្តូរទីលំនៅត្រឹមតែ២ ឬ៣ គីឡូម៉ែត្រពីភូមិចាស់ ។ ភូមិទីរីងជាភូមិចាស់ ដែលឈ្មោះនេះត្រូវបានដាក់ជាឈ្មោះឃុំផងដែរ ស្ថិតនៅជាប់នឹងព្រៃអារក្សអ្នកតា និងមានស្រះទឹកមួយដែលសត្វព្រៃតែងមកផឹកទឹក ។ បើធ្វើដំណើរដោយរទេះគោ គេត្រូវប្រើពេលវេលា៣ ថ្ងៃ ទើបទៅដល់ភូមិកំពង់ថ្ម ។ នៅតំបន់នេះមានព្រៃក្រាស ។ អ្នកភូមិវ័យចំណាស់ៗ បានរំលឹកថានៅពេលយប់ងងឹតមកដល់ ពួកគាត់មិនហ៊ានធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀតទេ ព្រោះខ្លាចកើតជំងឺគ្រុនចាញ់ សត្វព្រៃយាយី និង ខ្លាចពួកអារក្សអ្នកតាធ្វើ ។

ជីវិតរស់នៅនាពេលនោះគឺមានភាពស្ងប់ស្ងាត់ មានទាំងផលល្អ និង ផលអាក្រក់ ។ មានការងាយស្រួលក្នុងការស្វែងរកម្ហូបអាហារ ។ នៅពេលមានជំងឺ មានគ្រូថ្នាំបុរាណ ផ្តល់ថ្នាំដែលផ្សំពីរុក្ខជាតិ ហើយពួកគេធ្វើពិធីបញ្ជាន់អារក្ស ដើម្បីបណ្តេញព្រលឹងខ្មោចព្រាយបិសាចចេញពីក្នុងខ្លួន ។ ក្មេងៗមានលទ្ធភាពទទួលបានការអប់រំជាមូលដ្ឋាននៅឯទីវត្តអារាម ។

នេះជាសំដីរបស់អ្នកភូមិម្នាក់រស់នៅភូមិរន្ទះ :

*"ព្រៃក្រាស់ខ្លាំងណាស់ ហើយសំបូរទៅដោយសត្វព្រៃជាច្រើន ។ គ្រួសារនីមួយៗមានដើមច្បោះជាច្រើន ។ នៅពេលឃើញមានស្នាមចោះជារង្វះលើដើមឈើនោះមានន័យថា ដើមឈើច្បោះនោះមានម្ចាស់ហើយ ។ គ្មាននរណាម្នាក់ទៀតអាចទៅដងយកជ័រពីដើមច្បោះដែលមានម្ចាស់រួចហើយនោះឡើយ ។ ម្ចាស់អាចជួលដើមច្បោះរបស់ខ្លួនទៅឱ្យអ្នកដទៃបាន ។ ជីវិតរស់នៅទីនេះគឺរបៀបនេះ គឺមិនល្អ ហើយក៏មិនអាក្រក់ពេកដែរ ។ យើងមិនដែលគិតខ្វល់ខ្វាយពីរឿងអ្វីទេ ។ យើងបានជឿជាក់ថា អ្វីៗទាំងអស់នាពេលអនាគតក៏ដូចជាពេលបច្ចុប្បន្នដែរ យើងមិនចាំបាច់ព្រួយបារម្ភអំពីថ្ងៃស្អែកនោះទេ ។ ពេលណាយើងនៅសល់ម្ហូបបន្តិចបន្តួច យើងគ្រាន់តែចេញទៅព្រៃដើម្បីរកអនុផលព្រៃឈើ ដើម្បីដោះដូរ ឬ ក៏លក់ដូរតែប៉ុណ្ណោះ ។ យើងមិនមានជីវភាពធូរធារនោះទេ ប៉ុន្តែជីវិតក៏មិនមានការលំបាកដែរ ។"*

## ចាប់ពីទសវត្ស ឆ្នាំ១៩៧០ រហូតដល់ដើមទសវត្ស ឆ្នាំ១៩៩០: របបសមូហភាព

នៅដើមទសវត្ស ឆ្នាំ១៩៧០ ឃុំទាំងមូលធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហមភ្លាម ។ លុះដល់ឆ្នាំ ១៩៧៤ ភូមិនានាត្រូវបានចាត់ចែងទៅជាសហករណ៍ ។ ដីធ្លី និងការងារត្រូវបានដាក់ជាសមូហភាព ។ ក្នុងឆ្នាំ ១៩៧៥ ខ្មែរក្រហមបាននាំអ្នកខាងក្រៅមករស់នៅក្នុងឃុំ ដែលភាគច្រើនមកពីស្រុកជិតខាង គឺស្រុកកំពង់ស្វាយ ។ ពួកខ្មែរក្រហមបានចោទប្រកាន់ប្រជាជនមូលដ្ឋានមួយចំនួន ថាជាអតីតទាហានលន់ណុល ហើយបានសំលាប់ពួកគេព្រមទាំងក្រុមគ្រួសារ ។ ដីទំហំ ២០០ ទៅ ៣០០ ហិកតា ត្រូវបានឈូសឆាយ ដាំដំណាំកប្បាស និងស្រូវ ។ ការងារ

ជា សហករនៅចំការកប្បាស និងការធ្វើកសិកម្មលើដំឡូងឈើ និង ស្រូវ ត្រូវបានអ្នកស្រុកនិយាយថាមានភាពលំបាកធ្ងន់ធ្ងរ ។ ប្រជាជនមិនធ្លាប់ធ្វើការងាររបៀបជាសហករណ៍ទេ ។ ស្រូវអង្ករមិនសំបូរទាល់តែសោះ ប៉ុន្តែប្រជាជនពឹងផ្អែកលើអនុផលព្រៃឈើ ។

ក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានរុញច្រានខ្មែរក្រហមចេញ តែកងទ័ពវៀតណាមមិនបាននៅជាអចិន្ត្រៃនៅក្នុងតំបន់នេះទេ ។ ជីវិតរស់នៅក្នុងឃុំទីរីង គឺអសន្តិសុខណាស់ ដោយសារតែម្តងមានកងទ័ពវៀតណាម ម្តងមានកងទ័ពខ្មែរក្រហមកាន់កាប់ឃុំនេះ ។ អ្នកស្រុកត្រូវបង្ហាញឱ្យគេដឹងថាខ្លួនមាន "មុខពីរ" គឺនៅខាងខ្មែរក្រហម នៅពេលយប់ និងនៅខាងទ័ពវៀតណាមនៅពេលថ្ងៃ ។ ខ្មែរក្រហមបានដាក់មីន និង ដុតផ្ទះរបស់អ្នកទាំងឡាយណា ដែលពួកគេចោទថាមានជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដូចជាប្រធានភូមិជាដើម ។

អសន្តិសុខបានបន្តមានក្នុងអំឡុងទសវត្សឆ្នាំ១៩៨០ ។ ស្ថិតក្រោមការវាយប្រហារជាបន្តបន្ទាប់ ពីសំណាក់កំលាំងខ្មែរក្រហម និង កំលាំងរបស់រដ្ឋាភិបាល ប្រជាពលរដ្ឋបាននាំគ្នាចាកចេញពីឃុំទីរីង ។ នៅពេលស្ថានភាពបានល្អប្រសើរឡើងវិញជាបណ្តើរៗ ប្រជាជនទាំងនោះបានត្រលប់មកលំនៅដ្ឋានរបស់ខ្លួនក្នុងឃុំទីរីងវិញ ។ នាពេលនោះ គោលនយោបាយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា គឺចាត់ចែងឱ្យប្រជាជនធ្វើការជាក្រុមសាមគ្គី ប៉ុន្តែប្រជាជនមិនអើពើចំពោះប្រព័ន្ធនេះទេ ហើយជ្រើសរើសយករបៀបរស់នៅតាមទម្លាប់ ដែលពួកគាត់ធ្លាប់មានក្នុងអតីតកាល ។

## ក្នុងទសវត្សឆ្នាំ ១៩៩០: ព្រៃសម្បទាន

រាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រុមហ៊ុនកូឡិចស៊ីមនូវព្រៃសម្បទានទំហំ១៤៧.១៨៧ ហិកតា ភាគខាងជើងឃុំទីរីង នៅឆ្នាំ១៩៩២ ។ ក្រុមហ៊ុននេះ បានចាប់ផ្តើមកាប់ឈើមានតំលៃ រួមទាំងដើមឈ្មោះរបស់អ្នកស្រុកយ៉ាងច្រើន ដែលនៅពេលនោះ ច្បាប់បានការអនុញ្ញាតឱ្យកាប់តែក្នុងតំបន់ព្រៃសម្បទានប៉ុណ្ណោះ ។ ប្រជាពលរដ្ឋបាននាំគ្នាតវ៉ា ប៉ុន្តែមិនបានប្រយោជន៍ទាល់តែសោះ ។ ក្រុមហ៊ុនបានយល់ព្រមបង់ប្រាក់តំលៃ៦.០០០ ទៅ ៧.០០០ រៀល (១.៥០ ទៅ១.៧៥ ដុល្លារ) សំរាប់ដើមឈ្មោះមួយដើម ។ អ្នកភូមិនិយាយថា ពួកគេភាគច្រើនមិនបានទទួលលុយ ចំពោះដើមឈ្មោះរបស់ពួកគេ ដែលបានកាប់ដោយក្រុមហ៊ុននោះទេ ។ ប្រជាជនមួយចំនួនបានព្យាយាមរារាំងការកាប់ដើមឈ្មោះ ដូចជាអ្នកដែលរស់នៅភូមិរន្ទះជាដើម ។

ក្នុងឆ្នាំ១៩៩៤ ក្រុមហ៊ុន GAT អន្តរជាតិ និង ក្រុមហ៊ុនមៀងលីហេង ត្រូវបានផ្តល់ឱ្យនូវព្រៃសម្បទានទំហំ១៤៩.៧៨០ ហិកតា ផ្នែកខាងត្បូង និង ១៩៥.៥០០ហិកតា ផ្នែកខាងលិចឃុំទីរីង ។ ផ្ទៃដីទាំងមូលរបស់

ឃុំទីរីង ក៏ដូចជាព្រៃដែលនៅជុំវិញឃុំដែរ បានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ក្រុមហ៊ុនទាំងនេះ ។ ឈើមូលជាច្រើនត្រូវបានដឹកចេញតាមផ្លូវទៅកាន់ស្រុកសណ្តាន់ និង ចេញតាមច្រកស្ទឹងសែនឆ្ពោះទៅកាន់ទន្លេសាប ។

ក្នុងឆ្នាំ១៩៩៦ ក្រុមហ៊ុន GAT អន្តរជាតិ បានធ្វើផ្លូវមួយខ្សែកាត់ព្រៃ ដើម្បីដឹកជញ្ជូនឈើមកកាន់រោងចក្ររបស់ខ្លួន ។ ផ្លូវថ្មីនេះបានកាត់បន្ថយរយៈពេលធ្វើដំណើរទៅកាន់ស្រុកកំពង់ថ្ម ដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦ មកត្រឹមតែ ២ម៉ោង ដោយរថយន្ត ហើយដែលបានសំរបសំរួលដល់ អ្នកស្រុកសំរាប់ការធ្វើដំណើរទៅកាន់ទីផ្សារ និងទៅរកសេវាពេទ្យ ក៏ប៉ុន្តែវាបានបង្កឱ្យមាននូវតំរូវការផ្នែកហិរញ្ញវត្ថុ ព្រមទាំងនាំមកនូវបញ្ហាថ្មីៗជាច្រើន ។

## ចាប់ពីឆ្នាំ២០០១ រហូតមកដល់បច្ចុប្បន្នៈ សកម្មភាពក្រុមហ៊ុនចំការកៅស៊ូជុបរបស់រដ្ឋ និង សម្បទានិកក្រុមហ៊ុនព្រៃសម្បទាន

អនុក្រឹត្យដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ បានអនុញ្ញាតឱ្យកាត់ចេញនូវផ្ទៃដីក្រហម៦.២០០ហិកតា ចេញពីផ្ទៃដីព្រៃសម្បទានទាំងបីដែលមានទំហំ២.១៨១ ហិកតា ចេញពីក្រុមហ៊ុន GAT ទំហំ៣.៥៧៧ ហិកតា ចេញពីក្រុមហ៊ុនកូឡិចស៊ីម និង ៤៤២ហិកតា ចេញពីក្រុមហ៊ុនមៀង លីហេង ។ ក្រុមហ៊ុនចំការកៅស៊ូជុបរបស់រដ្ឋត្រូវបានផ្តល់ឱ្យនូវដីទំហំ៤.៣៥៩ហិកតា សំរាប់ដាំកៅស៊ូជាលក្ខណៈឧស្សាហកម្ម ។ ដីទំហំ១.៨៤១ ហិកតា សំរាប់ទុកបំរុងចែកជូនប្រជាពលរដ្ឋ ដែលក្នុងទំហំនោះមាន៩១២ ហិកតា ជាដីដែលប្រជាពលរដ្ឋកំពុងតែកាន់កាប់ស្រាប់ បូកបន្ថែមនិងដី៩២៩ ហិកតាទៀត ។ មាត្រា៤ នៃអនុក្រឹត្យតំរូវឱ្យក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់ ធ្វើការវាស់វែងជាក់ស្តែង និងរៀបចំធ្វើប្លង់កម្មសិទ្ធកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋណាដែលយល់ព្រមដាំដើមកៅស៊ូលើដីរបស់ខ្លួន និងទទួលបាននូវជំនួយខាងការថែទាំដើមកៅស៊ូរហូតដល់ពេលប្រមូលផល ។

បន្ទាប់ពីក្រុមហ៊ុនព្រៃសម្បទានដែលបានចុះកិច្ចសន្យាបន្តទាំងបីកាប់ព្រៃឈើរួចហើយ ដង្គត់ឈើ ឈើតូចឈើមធ្យម ព្រមទាំងចំការរបស់អ្នកស្រុក មានចំការស្វាយចន្ទី ចេក ល្ហុងជាដើមត្រូវបានឈូសឆាយ ។ ក្នុងខែតុលា ២០០១ ប្រជាពលរដ្ឋបាននាំគ្នាដាក់ពាក្យបណ្តឹងទៅអង្គការក្រៅរដ្ឋាភិបាលក្នុងខេត្តកំពង់ធំ ។ ពួកគាត់បានប្រាប់ថាពួកគាត់មិនចង់ចូលរួមធ្វើដំណាំកៅស៊ូទេ ហើយស្នើសុំត្រលប់មក រករបៀបរស់នៅតាមបែបប្រពៃណីរបស់គាត់វិញ ។ អាជ្ញាធរមិនបានឆ្លើយតបទៅនឹងសំណើរនេះទេ ។

កាលពីខែកុម្ភៈ ឆ្នាំ២០០២ អង្គការ Global Witness បានរកឃើញក្រុមហ៊ុនGATអន្តរជាតិកំពុងកាប់ឈើ ទាំងខាងក្នុង និងខាងក្រៅដែនចំការកៅស៊ូ ។ អង្គការ Global Witness ក៏បានរកឃើញនូវគំនរឈើហុប

ដែលគ្មានស្នាមត្រាញញួរ និង គ្មានចុះបញ្ជីជារបស់ក្រុមហ៊ុនកូឡិចស៊ីម ត្រូវបានដឹកចេញពីតំបន់ចំការកៅស៊ូ ។ វាជាការព្រួយបារម្ភ ដែលក្រុមហ៊ុនទាំងពីរឆ្លៀតយកចំណេញលើស្ថានភាពនេះ ហើយមិនបានបង់ពន្ធជូនរដ្ឋទេ ។ ការិយាល័យកសិកម្មខេត្តកំពង់ធំ បានធ្វើការស៊ើបអង្កេតរួមគ្នាមួយ ហើយបានអះអាងថាជាការពិត នូវអ្វីដែលជាការរកឃើញរបស់ Global Witness ។ ការិយាល័យនេះក៏បានរាយការណ៍ អំពីគោលបំណងរបស់មេឃុំទីរីង ដែលគេចង់បង្កើតសហគមន៍ព្រៃឈើ ។[៦]

**ផលប៉ះពាល់លើជីវភាពរស់នៅ និង ការងារ**

ស្ថានភាពរបស់ប្រជាពលរដ្ឋតំបន់នេះមានការប្រែប្រួលយ៉ាងឆាប់រហ័សបំផុត ជាមួយនឹងការមកដល់នៃចំការកៅស៊ូ ។ ប្រជាពលរដ្ឋភាគច្រើន មានការព្រួយបារម្ភថា ពួកគេមិនមានជំនាញ ដើម្បីចិញ្ចឹមជីវិតដោយការដាំដើមកៅស៊ូនោះទេ ដោយហេតុថាវាមិនមែនជាមុខរបរជាទំលាប់របស់គេ ។ ពួកគេក៏មានការព្រួយបារម្ភផងដែរ ដោយពួកគេមិនមានលទ្ធភាព ដើម្បីចិញ្ចឹមជីវិតក្នុងរយៈពេល៧ ឆ្នាំ នៃការរង់ចាំរហូតដល់ពេលកៅស៊ូផ្តល់ជ័រ ។ នៅពេលដែលប្រជាពលរដ្ឋតវ៉ា បុគ្គលិកនៃក្រុមហ៊ុនចំការកៅស៊ូបានប្រាប់ថា គំរោងដាំដើមកៅស៊ូ នឹងនៅតែដំណើរការទៅមុខ ទោះបីជាមានការតវ៉ាយ៉ាងណាក៏ដោយ ។ គេបានអញ្ជើញមេភូមិឱ្យទៅទស្សនារោងចក្ររបស់ចំការកៅស៊ូជុប នៅខេត្តកំពង់ចាម ប៉ុន្តែទង្វើនេះមិនគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមានការជឿទុកចិត្តពីប្រជាពលរដ្ឋទេ ។

ចំការកៅស៊ូទីរីង បានបង់ប្រាក់តំលៃ ២០០.០០០ រៀល ទៅ ៣០០.០០០ រៀល (៥០ ទៅ ៧៥ ដុល្លារ) ឱ្យគ្រួសារនីមួយៗដែលបាត់បង់ដីចំការឈើហូបផ្លែរបស់គេ នៅក្នុងដែនចំការកៅស៊ូ ។ សំណងនេះធ្វើឡើងតាមករណីនីមួយៗ ជាជាងតាមរយៈគោលការណ៍ប្រាកដប្រជាណាមួយ ។ ក្រុមហ៊ុនក៏បាននិយាយដែរថា ខ្លួននឹងផ្តល់ដីដែលបានឈូសឆាយរួចចំនួន៣ ហិកតា ដល់គ្រួសារទាំងនោះ ។[៧] ការបែងចែកដីធ្លីបានចាប់ផ្តើមធ្វើនៅដើមឆ្នាំ ២០០២ ដោយមានការតវ៉ាពីប្រជាពលរដ្ឋជាច្រើននាក់អំពីការបែងចែកនោះ ព្រោះពួកគេចង់បានដីចំការចាស់របស់គេវិញ ។ រហូតមកដល់ខែមីនា ឆ្នាំ២០០៤ ប្រជាពលរដ្ឋភាគច្រើនបានព្រមទទួលយកដីដែលក្រុមហ៊ុនបានចែក ឱ្យដោយពួកគេព្រួយបារម្ភថា បើមិនយកទេ នៅទីបំផុតពួកគេនឹងមិនបានដីទាល់តែសោះ ។

នាយកក្រុមហ៊ុនចំការកៅស៊ូបានឱ្យដឹងថា ប្រជាពលរដ្ឋមានសេរីភាពពេញលេញក្នុងការដាំដំណាំដែលពួកគាត់ចង់ដាំលើដី៣ ហិកតា ដែលបានបែងចែកឱ្យដល់គ្រួសារនីមួយៗ ។ ចំណែកឯប្រជាពលរដ្ឋវិញបាននិយាយថា

---

[៦] ក្នុងខែឧសភា ឆ្នាំ ២០០២ អង្គការ Global Witness បានរាយការណ៍ ពីការបន្តការកាប់ឈើ នៅក្រៅដែនចំការកៅស៊ូ ក៏ដូចជាប្រើប្រាស់ម៉ាស៊ីនអាឈើខុសច្បាប់ផងដែរ ។ របាយការរបស់អង្គការ Global Witness ស្តីពីបទល្មើសព្រៃឈើ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ ។

[៧] តាមបច្ចេកទេស ដីខ្នាតតូចទាំងអស់ ជាដីដែលមិនស្ថិតក្នុងផ្ទៃដីដែលក្រុមហ៊ុនចំការកៅស៊ូជុបគ្រប់គ្រង ទំហំ ៤.៣៥៩ ហិកតាទេ ។ ក្រុមហ៊ុនមានតួនាទីផ្តល់ជំនួយបច្ចេកទេស តែទៅលើដីខ្នាតតូចទាំងឡាយណាដែលមានចែងនៅក្នុងមាត្រា៣ នៃអនុក្រឹត្យ ដែលហៅថា ភារកិច្ចផ្តល់ជំនួយបច្ចេកទេសខាងការដាំដើមកៅស៊ូ ។

ក្រុមហ៊ុនប្រាប់ពួកគាត់ឱ្យដាំតែដើមកៅស៊ូ បើមិនដូច្នោះទេ ក្រុមហ៊ុននឹងដកហូតយកដីវិញ។ កាលពីខែវិច្ឆិកា ឆ្នាំ ២០០៣ បន្ទាប់ពីមានការសាកសួរ និង អន្តរាគមន៍ពីសំណាក់ការិយាល័យនៃឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និង អង្គការដទៃទៀត នាយកចំការកៅស៊ូទីរ៉ង បានប្រកាសជាសាធារណៈថា ប្រជាពលរដ្ឋអាចដាំដំណាំដែលខ្លួនចង់ដាំលើដីដែលបានចែកឱ្យ ។[៨]

ភូមិដែលមានដីស្រែតិចតួច អ្នកភូមិភាគច្រើនពឹងផ្អែកលើអនុផលព្រៃឈើ ដូចជាភូមិរន្ទះ រនាម និង ខោស គឺជាភូមិដែលទទួលរងនូវផលប៉ះពាល់ខ្លាំងជាងគេ។ ភូមិខោសជាភូមិដំបូងគេ ដែលក្រុមហ៊ុនបានធ្វើពិសោធដាំដើមកៅស៊ូ។ នៅក្នុងឆ្នាំ២០០២ មានប្រជាពលរដ្ឋជាច្រើនគ្រួសារនៅភូមិខោសបានទទួលដីឡូតិ៍ពីក្រុមហ៊ុន និង កូនកៅស៊ូសំរាប់ដាំដុះដោយឥតគិតថ្លៃឡើយ។ គេកំណត់ការដាំកូនកៅស៊ូរយៈពេលជាង៣ឆ្នាំ គឺដាំលើផ្ទៃដី១ ហិកតានៅឆ្នាំទី១ និង ២ហិកតានៅឆ្នាំទី២ និង ៣ ហិកតាទៀតនៅឆ្នាំទី៣។ នៅក្នុងជុំនៃការដាំកៅស៊ូឆ្នាំទី១ ក្រុមហ៊ុនអនុញ្ញាតឱ្យប្រជាពលរដ្ឋដាំប្រភេទដំណាំដូចជាសណ្តែក ពោត តាមរងកៅស៊ូ ប៉ុន្តែមិនអនុញ្ញាតឱ្យដាំស្រូវទេ។ ក្រុមហ៊ុនបានផ្តល់គ្រាប់ពូជសណ្តែក១ បាវ ចំណុះ៦០ គីឡូក្រាម ជូនជាមុនដល់គ្រួសារនីមួយៗ ហើយ គ្រួសារទាំងនេះត្រូវសងសណ្តែកចំណុះដូចគ្នានេះឱ្យក្រុមហ៊ុនវិញនៅឆ្នាំបន្ទាប់។ សណ្តែកជាប្រភេទដំណាំដែលងាយខូច នឹងងាយទទួលការបំផ្លាញពីសត្វល្អិតដែលទាមទាមឱ្យធ្វើការថែទាំជាប្រចាំ។ រយៈពេល១ឆ្នាំក្រោយមក ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមានភាពប្រែប្រួលខុសពីមុន។ គ្រួសារណាដែលមានមធ្យោបាយលុយកាក់ថវិកា និង មានសមាជិកគ្រួសារច្រើន អាចរកចំណូលបានច្រើនពីការធ្វើសណ្តែក។ គ្រួសារក្រីក្រ និងមានសមាជិកតិច អាចរកចំណូលបានតែតិចតួចប៉ុណ្ណោះ។ ដោយយល់ឃើញថាគ្មានលទ្ធភាព ដើម្បីបានប្រាក់គ្រប់គ្រាន់ចិញ្ចឹមជីវិតពីការធ្វើដំណាំលើដីនោះ ទើបគ្រួសារខ្លះបានជួលដីរបស់ខ្លួនទៅអ្នកមកពីក្រៅស្រុកតំលៃពី ១០០.០០០រៀល ទៅ ១៥០.០០០រៀល (២៥ដុល្លារ ទៅ ៣៧.៥០ដុល្លារ) ក្នុង១ ហិកតា សំរាប់រយៈពេល១ ឆ្នាំ។ បញ្ហានេះបាននាំឱ្យមានការព្រួយបារម្ភចំពោះគ្រួសារដែលងាយរងគ្រោះភាគច្រើន គឺគ្រួសារដែលខ្វះសមត្ថភាពចិញ្ចឹមជីវិតតាមរយៈការដាំកៅស៊ូជាលក្ខណៈគ្រួសារ នឹងអាចជួល ឬលក់ដីរបស់ពួកគេទៅឱ្យអ្នកក្រៅស្រុក ហើយជីវភាពរស់នៅរបស់ពួកគេនឹងកាន់តែក្រទៅៗ។

នាយកក្រុមហ៊ុនបានមានប្រសាសន៍ថា គ្រួសារទាំងអស់នៅក្នុងភូមិខោស ត្រូវបានផ្តល់ដីទំហំ៣ ហិកតា ហើយដែលក្រុមហ៊ុន និង មេឃុំបានកត់ឈ្មោះ និង ចំណែកដី នៃគ្រួសារទាំងនេះ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រជាពលរដ្ឋកំពុងតែរង់ចាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីរៀបចំផ្តល់ប្លង់កម្មសិទ្ធិឱ្យពួកគេដូច ដែលមានកំណត់នៅក្នុងអនុក្រឹត្យបង្កើតចំការកៅស៊ូស្រាប់។

---

[៨] សេចក្តីជូនដំណឹងលេខ ៣៨៤ ច.ក.ទ.រ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៣ ដោយលោក ហ៊ឹម អួន នាយកចំការកៅស៊ូទីរ៉ង ។

លោកនាយកក្រុមហ៊ុនបានឱ្យដឹងថា មានកម្មករចំនួន១៥០ នាក់ កំពុងធ្វើការនៅក្នុងចំការកៅស៊ូ ដែលក្នុងនោះមានកម្មករប្រមាណជា១០០ នាក់ មកពីចំការកៅស៊ូជុប ខេត្តកំពង់ចាម និងមានកម្មករពី៥០ ទៅ៦០នាក់ មកពីឃុំទឹរីង។ កម្មករមកពីឃុំទឹរីង បានទទួលប្រាក់ឈ្នួលការងារតិចជាងកម្មករមកពីខេត្តកំពង់ចាម ព្រោះពួកគេខ្វះជំនាញ។ ក្រុមហ៊ុនជួលអ្នកស្រុកភាគច្រើនដែលមានវ័យក្មេង ដោយចុះកិច្ចសន្យាផ្ដល់ប្រាក់ខែ ក្នុងមួយខែពី ១០០.០០០រៀល ទៅ ១២០.០០០រៀល (២៥ ទៅ ៣០ដុល្លារ) ឬក៏ផ្ដល់ប្រាក់ឈ្នួលប្រចាំថ្ងៃ ក្នុងមួយថ្ងៃតិចជាង ១ ដុល្លារ ដើម្បីដាំកូនកៅស៊ូ ឬ សំអាតស្មៅ។ ការងារនេះមានម្ដងម្កាល ហើយអាស្រ័យលើបំណងល្អរបស់ប្រធានក្រុមដែលគេចាត់តាំងឱ្យគ្រប់គ្រងលើកម្មករ។ ក្រុមហ៊ុនចំការកៅស៊ូជុប ជាក្រុមហ៊ុនដែលមានកេរ្តិ៍ឈ្មោះមិនល្អខាងការគោរពសិទ្ធិមនុស្ស និង សិទ្ធិការងារ[៩] ផ្ដល់ប្រាក់ឈ្នួលទាបដល់កម្មករ ហើយម៉ោងធ្វើការទៀតសោតក៏មានរយៈពេលវែង ដែលនៅតែជាការកង្វល់ដដែល។

ក្រុមហ៊ុនចំការកៅស៊ូមិនចង់ពិចារណាលើករណីរបស់អ្នកតាំងទីលំនៅថ្មី ដែលបានកាប់រានដីក្នុងដែនចំការកៅស៊ូ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០២ទេ។ បន្ទាប់ពីក្រុមហ៊ុនឈូសឆាយដីរបស់ប្រជាពលរដ្ឋទាំងនោះ ហើយក្រុមហ៊ុនគិតថាខ្លួនមិនមានការទទួលខុសត្រូវក្នុងការផ្ដល់ដីកន្លែងផ្សេងដល់ពួកគេទេ។

**ផលប៉ះពាល់វប្បធម៌ និងបរិស្ថានសង្គម**

អ្នកស្រុកបាននិយាយថា ពួកគាត់ធ្លាប់រស់នៅយ៉ាងសុខដុមរមនា ដោយមានអ្វីៗ ជាច្រើននៅជុំវិញខ្លួនគាត់ ពួកគាត់ប្រមូលអនុផលព្រៃឈើ តែនៅពេលណាដែលចាំបាច់ ហើយអាចរើសពេលវេលាដើម្បីធ្វើការដោយសេរី។ ពួកគេមិនធ្លាប់ធ្វើការងារដែលមានដាក់កំហិត ដូចជាការងារនៅចំការកៅស៊ូទេ ហើយមានការស្ទាក់ស្ទើរ ដើម្បីធ្វើការទៅតាមការតំរូវរបស់ក្រុមហ៊ុន ។

ការគោរពប្រតិបត្តិសាសនា និង ប្រពៃណីវប្បធម៌ ត្រូវរងនូវផលប៉ះពាល់យ៉ាងខ្លាំង។ តាមជំនឿរបស់អ្នកស្រុកនេះ ព្រៃឈើទាំងអស់សុទ្ធតែមានអារុក្ខអារក្សអ្នកតាតាំងនៅ ដែលពួកគេអាចកំណត់ជោគវាសនារបស់មនុស្សបាន។ នៅក្បែរភូមិនីមួយៗ មានព្រៃអ្នកតា ដែលអ្នកតាហាមការកាប់ឈើ និង ការធ្វើសកម្មភាពមួយចំនួន។ សំណាងអាក្រក់ និងជំងឺដង្កាត់ផ្សេងៗត្រូវបានគេគិតថាកើតឡើងដោយសារតែខុសអ្នកតា។ ពិធីឡើងអ្នកតាត្រូវធ្វើឡើង ដើម្បីសុំសេចក្ដីមេត្តា ឬ ជាការដឹងគុណដល់អ្នកតា។ ប្រជាជនបាននាំគ្នាតវ៉ា ជាពិសេសចំពោះការកាប់ព្រៃឈើទាំងនោះ ដែលពួកគេយល់ថាជាព្រៃដែលមានអ្នកតាជាច្រើនតាំងនៅ។ អ្នកស្រុកនិយាយថា នៅក្នុងភូមិជាច្រើន តាំងពីពេលក្រុមហ៊ុនចាប់ផ្ដើមកាប់ឈើ មានអ្នកស្រុកជាច្រើននាក់បានធ្លាក់ខ្លួនឈឺ។

---

[៩] សូមមើលជាឧទាហរណ៍ *ការងារកុមារ និង ពលកម្មកុមារ នៅចំការកៅស៊ូជុប ក្នុងប្រទេសកម្ពុជា* របស់វិទ្យាស្ថានសិក្សាស្រាវជ្រាវជាន់ខ្ពស់ (ខែកញ្ញា ឆ្នាំ២០០១) ។

ពួកគេសន្មត់ថា នេះ ជាការដាក់ទណ្ឌកម្មរបស់ពួកអារុក្ខអារក្សអ្នកតា ដែលអ្នកតាទាំងនោះនៅលើដើមឈើធំៗ ហើយពួកគាត់បាន បាត់បង់លំនៅដ្ឋានរបស់ខ្លួន ។

ព្រៃអ្នកតានៅស្រឡៅស្រោង ជាព្រៃដែលបានទទួលរងការកាប់បំផ្លាញមុនគេបង្អស់ ។ មុនពេលកាប់ព្រៃនេះ អាជ្ញាធរចំការកៅស៊ូបានរៀបចំពិធីមួយ ដោយមានដាក់ដង្វាយថ្លៃៗមួយចំនួន រួមទាំងជ្រូកផងដែរ ។ អ្នកតាចូលរូប ( មនុស្សដែលអាចទំនាក់ទំនងបានជាមួយអ្នកតា) ត្រូវបានសន្យាផ្តល់ប្រាក់មួយចំនួន និង ផ្តល់ការងារដល់កូនរបស់គាត់ ។ ពេលធ្វើពិធីចូលអ្នកតា រូបបាននិយាយថា អ្នកតា បានយល់ព្រមចាកចេញពីលំនៅដ្ឋានរបស់ គាត់ ដែលនេះជាការអនុញ្ញាតឱ្យកាប់ដើមឈើបាន ។ គេបានទុកតែដើមឈើមួយដើមគត់នៅទីនោះ ដោយមានធ្វើខ្ទមអ្នកតានៅពីក្រោម ។

ក្នុងខែធ្នូ ឆ្នាំ២០០៣ ព្រៃអ្នកតារបស់អ្នកភូមិរន្ទះ ព្រមទាំងទីវាលកប់ខ្មោចពីបុរាណ ដែលគេជឿថាជាសពជីដូន ជីតារបស់អ្នកភូមិរន្ទះ ត្រូវបានក្រុមហ៊ុនធ្វើការឈូសឆាយ ។ ក្នុងអំឡុងពេលពេល៦ សប្តាហ៍ មានក្មេងចំនួន៦ នាក់ បានឈឺស្លាប់ ។ អ្នកភូមិចាត់ទុកការស្លាប់នេះថា កើតឡើងដោយសារតែមានការខឹងសម្បារពីអារុក្ខអារក្សអ្នកតា និងជីដូន ជីតាដែលបានចែកឋានទៅហើយ ។

អ្នកស្រុកនៅទីរីង ក៏ជាអ្នកគោរពប្រតិបត្តិសាសនាព្រះពុទ្ធដែរ ។ ក្រុមហ៊ុនចំការកៅស៊ូបានឧបត្ថម្ភដល់ការកសាងវត្តថ្មីមួយ នៅភូមិស្រឡៅស្រោង ។

សកម្មភាពទាំងឡាយរបស់ក្រុមហ៊ុន បានបង្កើតឱ្យមានទំនាស់នៅក្នុងសហគមន៍ ។ មានអ្នកស្រុកជាច្រើនចង់បន្តជីវភាពរស់នៅតាមទំនៀមទំលាប់របស់ខ្លួន ហើយជំទាស់ទៅនឹងការកែប្រែនានា នៅពេលដែលអ្នកស្រុកផ្សេងទៀតមានការទាក់ទាញដោយការសន្យាផ្តល់អត្ថប្រយោជន៍ខាងសេដ្ឋកិច្ច ។ អ្នកទាំងនោះភាគច្រើន គឺជាអ្នកមានអំណាច និងមានទំនាក់ទំនងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ហើយពឹងផ្អែកលើការទទួលបានលាភសក្ការៈ ។ ពួកគេបានអះអាងថា ការកសាងផ្លូវ សាលារៀន និង វត្តអារាម ព្រមទាំងការផ្តល់ការងារដល់មនុស្សវ័យក្មេង នឹងនាំមកនូវការអភិវឌ្ឍន៍ដល់ឃុំ ។ ភាពខុសគ្នាខាងសេដ្ឋកិច្ចកាន់តែខ្លាំងឡើងៗ ដោយអ្នកខ្លះបានទទួលចំណូលច្រើនគួរសមពីការកាប់ឈើ និងពីសកម្មភាពដទៃៗទៀត ខណៈដែលអ្នកខ្លះទៀតមានជីវភាពកាន់តែក្រទៅៗដោយការបាត់បង់ដើមច្បោះ និង ប្រភពចំណូលផ្សេងៗ ។

ក្រុមហ៊ុនបានរៀបចំបរិវេណមួយនៅជិតភូមិខោស ដោយសង់ផ្ទះថ្មសំរាប់កម្មករ ដែលភាគច្រើនមកពីចំការកៅស៊ូ ខេត្តកំពង់ចាម ក៏ដូចជាសំរាប់អ្នកជំនាញការមកពីប្រទេសម៉ាឡេស៊ី ស្នាក់នៅ ។ ប្រជាពលរដ្ឋមកពីស្រុកកំពង់ថ្មបានបើកភោជនីយដ្ឋានពី៤ ទៅ ៥កន្លែង ។ ស្ត្រីរកស៊ីផ្លូវភេទមួយចំនួនតូចបានចាប់ផ្តើមទៅប្រកបរបរ

រកស៊ីផ្លូវភេទនៅទីនោះ ។ មិនមានព័ត៌មានស្ដីពីជំងឺកាមរោគ រួមទាំងជំងឺអេដស៍ ហើយក៏មិនមានស្រោមអនាម័យ ដាក់លក់នៅហាងណាមួយនៅទីនោះដែរ ។

## អំពើហិង្សា និង អសន្តិសុខ

តាមសេចក្ដីរាយការណ៍ ចាប់តាំងពីក្រុមហ៊ុនបានមកដល់ទីនេះ ប្រជាពលរដ្ឋនៅតំបន់នេះបានប្រឈមមុខ ដាក់គ្នាជាញឹកញាប់ជាមួយសន្តិសុខក្រុមហ៊ុន ហើយមានអំពើហិង្សា និង ការគំរាមគំហែងជាច្រើនករណីទៀតផង ។

នៅខែមេសា ឆ្នាំ១៩៩៧ អ្នកភូមិម្នាក់ឈ្មោះ ចាន់ អឿន បានព្យាយាមបញ្ឈប់អ្នកកាប់ឈើនៃក្រុមហ៊ុន កូឡិចស៊ីម ពីការកាប់ដើមច្បោះរបស់គាត់ ។ គាត់ត្រូវបានសន្តិសុខក្រុមហ៊ុនបាញ់សំលាប់ ហើយសន្តិសុខរូបនេះបាន គេចខ្លួន ដោយមានការជួយជ្រោមជ្រែងពីសន្តិសុខដទៃទៀត ។ សន្តិសុខរូបនេះ មិនត្រូវបានចោទប្រកាន់តាមផ្លូវ ច្បាប់ពីបទមនុស្សឃាតទេ ។ ក្រុមហ៊ុនកូឡិចស៊ីម បានផ្ដល់សំណងជាថវិកាមួយចំនួនដល់គ្រួសារជនរងគ្រោះ ។

បុរសម្នាក់ដែលមានឈ្មោះហៅក្រៅថា "កៅប្រាំ" (នាមប្រើសំរាប់វិទ្យុទាក់ទងគឺ ៩៥) ដែលទទួល មើលការខុសត្រូវលើសន្តិសុខរបស់ក្រុមហ៊ុនមៀងលីហេង គឺជាមនុស្សដែលមានឈ្មោះល្បីខាងឃោរឃៅ ។ កៅប្រាំជាបងប្រុសរបស់ អ្នកស្រី សេង គាង ដែលជាប្រធានក្រុមហ៊ុន សេង គាង និងជាអ្នកម៉ៅការដ៏សំខាន់របស់ ក្រុមហ៊ុនមៀងលីហេង ។ នៅក្នុងភូមិរនាម អ្នកភូមិបានរាយការណ៍ថា ពួកគេ បានទទួលការគំរាមគំហែងដល់ ជីវិតចំពោះកិច្ចខិតខំរបស់ខ្លួន ដើម្បីទប់ស្កាត់ការកាប់ឈើ និង ដឹកជញ្ជូនឈើដោយខុសច្បាប់ ។

កាលពីខែធ្នូ ឆ្នាំ២០០១ អ្នកភូមិរន្ទះ បានព្យាយាមរារាំងការឈូសឆាយព្រៃរបស់ពួកគេ ប៉ុន្តែបានប្រឈម មុខជាមួយសន្តិសុខ ដែលបានបាញ់បង្ហើរក្បាលរបស់ពួកគេ ដែលធ្វើឱ្យពួកគេភ័យខ្លាចមិនហ៊ានបន្តការរារាំង តទៅទៀត ។

មានចោរមួយក្រុម បានធ្វើសកម្មភាពនៅក្នុងតំបន់នោះ ។ កូនប្រសារប្រុសរបស់លោកមេឃុំ ត្រូវបានគេ ចាប់ជំរិតនៅក្នុងឆ្នាំ២០០១ បន្ទាប់ពីបានសំលាប់ចោរម្នាក់ក្នុងក្រុមនោះ ។ គ្រួសាររបស់គាត់បានប្រាប់ឱ្យដឹងថា គាត់បានឱ្យលុយ ២០០០ ដុល្លា ជាថ្នូរនឹងការដោះលែង ។ នៅដើមខែមេសា ឆ្នាំ២០០៣ ជនជាតិម៉ាឡេស៊ី២ នាក់ និងខ្មែរ២ នាក់ ដែលបំរើការនៅចំការកៅស៊ូត្រូវបានចាប់ជំរិត ។ មានពតិមានថាក្រុមហ៊ុនបានឱ្យ ១៥.០០០ដុល្លា ជាថ្នូរនឹងការដោះលែងនេះ ។

បញ្ហាដែលជាកង្វល់ដទៃទៀត គឺការកាប់ឈើអនាធិបតេយ្យនៅក្នុងព្រៃ ។ តាំងតែពីពេលដែលក្រុមហ៊ុន ព្រៃសម្បទានបើកប្រតិបត្តិការកាប់ឈើ ចំណង់ចំណូលចិត្តខាងកាប់ឈើរបស់ប្រជាជននៅតំបន់នេះ មានការកើន

ឡើងយ៉ាងខ្លាំង។ អ្នកស្រុកណាដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអាជ្ញាធរ ឬក៏មានលុយគ្រប់គ្រាន់បង់ឱ្យសន្តិសុខក្រុមហ៊ុននូវ "ថ្លៃឈ្នួលចូលព្រៃ" ដើម្បីអាចចូលទៅក្នុងព្រៃអារឈើ បានប្រាស្រ័យទាក់ទង ទាំងជាមួយអ្នកជំនួញនៅមូលដ្ឋាន និងមកពីតំបន់ក្រៅ ដើម្បីដឹកជញ្ជូនឈើចេញពីឃុំ។ អ្នកទាំងឡាយណា ដែលមិនមានលទ្ធភាពបង់ថ្លៃឈ្នួលចូលព្រៃទេ បានលួចចូលទៅក្នុងព្រៃដើម្បីប្រមូលយកឈើតូចៗ ធ្វើអុសសំរាប់លក់។ ប្រសិនបើសន្តិសុខក្រុមហ៊ុន ឬប៉ូលីសស្រុក ចាប់បាន គេនឹងដកហូតយករទេះគោ ហើយត្រូវបង់លុយមួយចំនួនដើម្បីបានរទេះគោត្រលប់មកវិញ។ ទន្ទឹមគ្នានេះដែរ ដើមឈើតូចៗ និង ឈើមធ្យមដែលបានកាប់រួចហើយ ត្រូវបានទុកចោលឱ្យពុកខូច ឬក៏ត្រូវគេដុតចោល។

នេះសំដីរបស់អ្នកភូមិម្នាក់រស់នៅភូមិរនាម :

*"រៀងរាល់ថ្ងៃ ខ្ញុំបានឃើញឡានធំៗ ដឹកឈើចេញពីឃុំទំរីង។ ខ្ញុំក្រីក្រណាស់ គ្មានលុយបង់ឱ្យមេភូមិ និងមនុស្សរបស់ក្រុមហ៊ុន ដើម្បីចូលព្រៃអារឈើយកមកធ្វើផ្ទះអោយបានសមរម្យទេ។ ខ្ញុំមើលឃើញថាព្រៃឈើចេះតែវិនាសទៅ ហើយជីវិតខ្ញុំក៏វិនាសដូចគ្នាដែរ។*

## ក្រុមហ៊ុន និងអ្នកម៉ៅការបន្ត

ក្រុមហ៊ុន GAT អន្តរជាតិ ត្រូវបានរកឃើញថាកាប់ឈើខុសច្បាប់នៅក្នុងតំបន់សម្បទានរបស់ខ្លួន ក្នុងឆ្នាំ ២០០០ ឆ្នាំ២០០១ និង ឆ្នាំ២០០២ ហើយកិច្ចសន្យាសម្បទានជាមួយរាជរដ្ឋាភិបាល ត្រូវបានលុបចោលវិញ ក្នុងខែមិថុនា ឆ្នាំ២០០២ បន្ទាប់ពីមានការដាក់សម្ពាធយ៉ាងខ្លាំងពីសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ។ នេះគឺជា លើកទី១ហើយ ដែលក្រុមហ៊ុនព្រៃសម្បទានធ្វើអាជីកម្មជាសំខាន់ ត្រូវបានលប់កិច្ចសន្យា។ GAT អន្តរជាតិក៏ មានព្រៃសម្បទាននៅក្នុងខេត្តកោះកុងផងដែរ ហើយត្រូវបានតុលាការខេត្តកោះកុង ផ្តន្ទាទោសពីបទកាប់ឈើខុសច្បាប់ ហើយជាសម្បទានិកតែម្នាក់គត់មិនធ្លាប់មានពីមុនមក ដែលត្រូវបានតុលាការកាត់ទោសពីបទកាប់ឈើខុស ្សាប់នេះ។ ការដាក់ទណ្ឌកម្មរបស់តុលាការគឺ កំណត់ឱ្យក្រុមហ៊ុនបង់ពន្ធលើឈើមូលចំនួន៧៧៧ ដើម ដែលបានកាប់រំលំដោយខុសច្បាប់នៅក្បែរតំបន់សម្បទាន។ ក្នុងខែតុលា ឆ្នាំ២០០៣ Global Witness បានចងក្រងឯកសារស្តីពីសកម្មភាពកាប់ឈើខុសច្បាប់នៅក្នុងអតីតព្រៃសម្បទានក្រុមហ៊ុន GAT ដែលប្រព្រឹត្តឡើងដោយសមាជិកយោធា។ [១០] មានព័ត៌មានថា GAT អន្តរជាតិ មានខ្នងបង្អែកជាមន្ត្រីយោធាជាន់ខ្ពស់។

---

[១០] អង្គការ Global Witness ក៏បានរកឃើញផងដែរ នូវការកាប់ឈើខុសច្បាប់ និងការទន្ទ្រានយកដី ខាងក្រៅព្រំដែនចំការកៅស៊ូ ភាគខាងកើតភូមិខោស និងនៅតំបន់ព្រៃអ្នកតាភូមិទំអរ ។ "ការដឹកជញ្ជូនឈើដោយខុសច្បាប់ ចេញពីព្រៃទំរីងនៅតែបន្ត ។ ឈើមូលដែលកាប់ថ្មីៗត្រូវបានអារជាបន្ទះ និងកាត់ខ្លីៗពី ១ ទៅ ២ម៉ែត្រ ត្រូវបានដឹកជញ្ជូនតាមរថយន្តធំៗ និងតាមឡានដឹកដី ដោយមានតង់គ្របពីលើ ហើយដឹកចេញនៅពេលយប់ ឆ្ពោះទៅកាន់រោងចក្រក្តាបន្ទះ Kingwood ដែលស្ថិតនៅតាមផ្លូវជាតិលេខ ៦ ក្នុងខេត្តកណ្តាល ខាងជើងរាជធានីភ្នំពេញ។...ការដឹកជញ្ជូនមានលក្ខណៈ លាក់លាម ហើយដោយមានការអនុញ្ញាតជារូបភាពដឹក"អុស"។ ការកាប់ដើមច្បោះបានបន្តទាំងខាងក្នុង និង ខាងក្រៅតំបន់ដែលកំណត់ទុក។" សូមមើលលិខិតរបស់អង្គការ Global Witness ចុះថ្ងៃទី២៨ ខែតុលា

ក្រុមហ៊ុនកូឡិចស៊ីម គឺជាក្រុមហ៊ុនចំរុះរវាងរាជរដ្ឋាភិបាលកម្ពុជា និង លោក អូកាដា ជាតំណាងក្រុមហ៊ុនឈើ Marubeni របស់ជប៉ុន ប្រចាំកម្ពុជា ។ ក្រៅពីមានកន្លែងស្តុកឈើដ៏គត់មត់បំផុត និង ការបន្តកាប់ឈើតាំងពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ២០០១ ក្រុមហ៊ុនកូឡិចស៊ីម បានអះអាង ក្នុងឆ្នាំ ២០០១ ថាខ្លួនបានជំពាក់បំណុលប្រហែលជា ២លានដុល្លារ ។ ក្នុងខែឧសភា ឆ្នាំ២០០៣ ក្រុមហ៊ុនកូឡិចស៊ីម បានសុំការអនុញ្ញាតពីរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីដឹកឈើដែលមានតំលៃរហូតដល់ ១លានដុល្លារ ចេញពីឃុំទីរីង បើទោះបីជារយៈពេលកំណត់ក្នុងសេចក្តីប្រកាសស្តីពីការផ្អាកជាបណ្តោះអាសន្នរាល់ការកាប់ និង ដឹកជញ្ជូនឈើ នៅមានសុពលភាពនៅឡើយក្តី ។ សេចក្តីស្នើនេះ នាំឱ្យមានការជំទាស់យ៉ាងខ្លាំងជាបន្តរហូតមក ។ ផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចិរភាពរយៈពេល២៥ ឆ្នាំ របស់ក្រុមហ៊ុនកូឡិចស៊ីម បានដាក់ជូនរាជរដ្ឋាភិបាល ដើម្បីសុំការអនុម័តយល់ព្រម ។

កិច្ចសន្យារបស់ក្រុមហ៊ុនមៀងលីហេង ត្រូវបានលុបចោលក្នុងឆ្នាំ២០០៣ គឺបន្ទាប់ពីមានការពិនិត្យផ្ទៀងផ្ទាត់លើសារពើភ័ណ្ឌរបស់ព្រៃសម្បទាននេះ បានកំណត់ថាមិនមានប្រភពធនធានព្រៃឈើសមល្មមនៅសេសសល់ក្នុងព្រៃសម្បទាន ដែលអាចធ្វើឱ្យសំរេចបានខាងផ្នែកសេដ្ឋកិច្ចទេ ។

សម្បទានិកនៃក្រុមហ៊ុនទាំងបី បានចុះកិច្ចសន្យាបន្តជាមួយក្រុមហ៊ុនដទៃទៀត ដើម្បីកាប់ឈើ ដែលអ្នកម៉ៅការខ្លះ ក្នុងចំណោមនោះមានដូចជាក្រុមហ៊ុន សេង គាង ត្រូវបានគេរាយការណ៍ថា មានជាប់ទាក់ទងសាច់ញាតិ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ។

**អុសយក្ស :        ដំណើរទស្សនកិច្ចរបស់លោកតំណាងពិសេស ក្នុងខែកក្កដា ឆ្នាំ ២០០៣**

តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានទៅទស្សនានៅឃុំទីរីង ក្នុងខែកក្កដា ឆ្នាំ២០០៣ គឺក្នុងអំឡុងទស្សនកិច្ចលើកទី៩ របស់លោកមកកាន់ប្រទេសកម្ពុជា ។ លោកបានជួបជាមួយប្រជាជនរស់នៅក្នុងតំបន់នេះ និងក្រុមប្រឹក្សាឃុំ ហើយបានស្តាប់នូវកង្វល់របស់ពួកគេ ។ នៅពេលជួបប្រជុំជាមួយមន្ត្រីព្រៃឈើប្រចាំមូលដ្ឋាន លោកបានឃើញផ្ទាល់ភ្នែក នូវរថយន្តធុនធ្ងន់ចំនួន៥ គ្រឿង កំពុងដឹកដើមឈើធំៗ ដោយមានទាំង ដើមច្បោះ ផងដែរ ។ ពេលដែលលោកបានសាកសួរអំពីការដឹកនេះ គេបានបង្ហាញលោកនូវលិខិតអនុញ្ញាតដឹកអុស ។ កិច្ចប្រជុំមួយដែលបានរៀបចំទុកជាមុន ជាមួយតំណាងក្រុមហ៊ុនចំការកៅស៊ូត្រូវខកខានទៅវិញ ដោយសារតំណាងក្រុមហ៊ុនអវត្តមាន ។ ពេលត្រឡប់មកភ្នំពេញវិញ លោកតំណាងពិសេសបានសរសេរលិខិតមួយច្បាប់ផ្ញើរជូនសម្តេចនាយករដ្ឋមន្ត្រី ដោយពាំនាំនូវកង្វល់របស់លោក និងស្នើរសុំអន្តរាគមន៍ពីសម្តេចនាយករដ្ឋមន្ត្រី ប៉ុន្តែលោកតំណាងពិសេសមិនបានទទួលនូវការឆ្លើយតបទេ ។

---

ឆ្នាំ២០០៣ ។

## ផែនការសំរាប់ចំការកៅស៊ូនាពេលអនាគត

តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញឱ្យមានចំការកៅស៊ូថ្មី តំបន់ដីក្រហមមួយចំនួនត្រូវបានកត់សំគាល់ ដែលដីទាំងនោះកំពុងតែស្ថិតក្រោមការប្រើប្រាស់ក្នុងការដាំដំណាំរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ឬក៏ស្ថិតនៅក្នុងតំបន់ព្រៃដែលភាគច្រើនតាំងនៅភាគខាងជើង និងភាគឦសាន្តនៃប្រទេសកម្ពុជា ជាទីកន្លែងដែលមានជនជាតិភាគតិចគួយ និងជនជាតិភាគតិចដទៃទៀតកំពុងរស់នៅ ។ ដីក្រហមដែលសមស្របនឹងដំណាំកៅស៊ូត្រូវបានរាយការណ៍ថា មាននៅក្នុងខេត្តរតនគីរី និងមណ្ឌលគីរី ។ ក្រុមហ៊ុនដែលបានដាក់សំណើរទៅរាជរដ្ឋាភិបាលដើម្បីសុំប្រើប្រាស់តំបន់ដីក្រហម មានរួមទាំង ក្រុមហ៊ុន Sunweeve និង ក្រុមហ៊ុន Oriental Grass សុំដីដាំកៅស៊ូនៅក្រុងប៉ៃលិនទំហំ ៥.០០០ហិកតា ក្រុមហ៊ុន សេងគាង សុំដីដាំកៅស៊ូទំហំ ១០.០០០ហិកតា ក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្រុមហ៊ុន Heng Brothers ចំកាត់ សុំដីដាំកៅស៊ូនៅក្នុងឃុំញាង ស្រុកអណ្តូងមាស ខេត្តរតនគីរី ទំហំពី ១០.០០០ហិកតា ទៅ ១៥.០០០ហិកតា និង ក្រុមហ៊ុន Marubeni សុំដីទំហំ១០.០០០ហិកតា ក្នុងស្រុកអូរាំង និងសែនមនោរម្យ ខេត្តមណ្ឌលគីរី ។

## សេចក្តីសន្និដ្ឋាន

ផលប៉ះពាល់ដោយក្រុមហ៊ុនព្រៃសម្បទាន និងសកម្មភាពរបស់ក្រុមហ៊ុនចំការកៅស៊ូ ទៅលើភូមិទាំងអស់និងអ្នកភូមិរស់នៅឃុំទីរឹងមានសភាពធ្ងន់ធ្ងរ ។ អ្នកស្រុកទីរឹងបានផ្លាស់ប្តូរជីវភាពរស់នៅជាប្រពៃណីរបស់ខ្លួនដោយទទួលបានការយកចិត្តទុកដាក់តិចតួចបំផុតដល់សុខមាលភាព ឬវប្បធម៌របស់ខ្លួន ។ អ្វីៗដែលមាននៅជុំវិញខ្លួន ត្រូវបានគេបំផ្លិចបំផ្លាញអស់ ។

ការស្រាវជ្រាវដល់ទីកន្លែង បានរកឃើញថា ព្រៃភាគច្រើននៅតំបន់ទីរឹង ត្រូវបានកាប់បំផ្លាញ ដោយរួមទាំងព្រៃសំខាន់ៗផងដែរ ទង្វើនេះជាការរំលោភច្បាប់ ដែលច្បាប់បានចាត់ថ្នាក់ព្រៃសំខាន់ៗ ចូលក្នុងជំពូកដីសាធារណៈរបស់រដ្ឋ ហើយដែលចំណាត់ថ្នាក់របស់វាត្រូវបានការពារពីការកាប់រំលំ និងពីការប្រគល់ឱ្យក្រុមហ៊ុនព្រៃសម្បទាន ។ ការកាប់ឈើខុសច្បាប់ និងការកាប់ដើមច្បោះនៅតែបន្ត ។ មិនមានការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និង សង្គម ត្រូវបានធ្វើឡើងទេ ។ មានការព្រួយបារម្ភពីគំរោងបង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ ដែលវានឹងចូលរួមចំណែកដល់ការបំផ្លាញបរិស្ថាន ។ មានតំបន់ព្រៃជាច្រើនទៀតនឹងរងនូវការកាប់រំលំ ។ អនាគតរបស់អ្នកភូមិទីរឹងហាក់ដូចជាត្រូវបញ្ចប់ដោយសារតែដើមច្បោះជាច្រើនដើមរបស់ពួកគេ និង ធនធានព្រៃឈើ ដែលពួកគេពឹងផ្អែកទាំងស្រុង នោះ ត្រូវបានបំផ្លាញអស់ ។ ពួកគេពិតជាត្រូវការនូវជំនួយយ៉ាងខ្លាំង ។

## អនុសាសន៍

រាជរដ្ឋាភិបាលគួរតែៈ

- ត្រួតពិនិត្យកិច្ចសន្យាដែលធ្វើឡើងជាមួយក្រុមហ៊ុនកូឡិចស៊ីម ហើយធានាថាក្រុមហ៊ុនចំការកៅស៊ូជុប ត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចរបស់ខ្លួន ស្របតាមអនុក្រឹត្យបង្កើតចំការកៅស៊ូទីរីង និងគោរពតាម ច្បាប់ជាតិ និង ច្បាប់អន្តរជាតិ ។
- តាមឃ្លាំមើល និង បញ្ឈប់សកម្មភាពកាប់ឈើខុសច្បាប់ ខាងក្រៅដែនចំការកៅស៊ូ ។
- បដិសេធសំណើររបស់ក្រុមហ៊ុន កូឡិចស៊ីម ដែលសុំដឹកឈើមូលទៅកាន់រោងចក្រអារឈើខាងក្រៅ ។ ការយល់ព្រមដល់សំណើរនេះ ជាប្រការមួយដែលជំរុញឱ្យមានសកម្មភាពកាប់ឈើជាបន្តទៀត នៅក្នុងតំបន់ដីសម្បទានដែលស្ថិតនៅក្នុងតំបន់ព្រៃ ។[១១]
- ជួយផ្តល់ប្រាក់កម្ចីឱ្យប្រជាពលរដ្ឋរស់នៅឃុំទីរីង ។

នៅថ្នាក់មូលដ្ឋានៈ

- គ្រួសារទាំងឡាយណាដែលដីស្រែចំការ របស់ខ្លួនត្រូវបានឈូសឆាយ គួរតែត្រូវបានបែងចែកឱ្យនូវដីទំហំ ៣ហិកតា ទោះបីជាអ្នកទាំងនោះជាអ្នកតាំងទីលំនៅជាយូរមកហើយ ឬក៏ជាអ្នកតាំងទីលំនៅថ្មីក៏ដោយ ។
- គ្រួសារដែលបានទទួលដី គួរតែមានសេរីភាពក្នុងការដាំដំណាំប្រភេទណាក៏ដោយដែលគេចង់ដាំ ។
- ប្លង់កម្មសិទ្ធិដីធ្លី គួរតែចេញជូនប្រជាពលរដ្ឋដែលបានទទួលដីនោះ ។
- ការចូលរួមក្នុងការដាំកៅស៊ូជាលក្ខណៈគ្រួសារ គួរអនុវត្តតាមការស្ម័គ្រចិត្ត ។
- ក្រុមហ៊ុនចំការកៅស៊ូជុប គួរតែបង្ហាត់បង្រៀនដល់អ្នកដែលចង់ដាំកៅស៊ូ ។

អង្គការក្រៅរដ្ឋាភិបាលគួរតែ ៈ

- ឃ្លាំមើលឱ្យបានជិតដល់ ពីស្ថានភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចងក្រង និងរាយការណ៍ អំពីអំពើរំលោភនានាទៅលើសិទ្ធិរបស់ពួកគាត់ ។
- ជួយដល់ប្រជាពលរដ្ឋមូលដ្ឋាន ក្នុងការស្វែងរកដំណោះស្រាយ ឧទាហរណ៍ ធ្វើឱ្យទទួលបាននូវប្លង់កម្មសិទ្ធិដីធ្លី កម្មវិធីហ្វឹកហ្វឺន កម្មវិធីឥណទាន និង ការទទួលបាននូវការថែទាំខាងសុខភាព និង ការអប់រំ ។

[១១] ជាឧទាហរណ៍ ដីសម្បទានរបស់ក្រុមហ៊ុនហៃនិញ នៅខេត្តកំពង់ស្ពឺ ក្រុមហ៊ុនផលិតម៉េ្សាដំឡូងមីចំកាត់ និង ក្រុមហ៊ុនគ្រីនស៊ី ក្នុងខេត្តស្ទឹងត្រែង ។

# ឧបសម្ព័ន្ធទី២

**កំណត់សាវតាក្រុមហ៊ុនស៊ីជេ កម្ពុជា (CJ Cambodia Company)**

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ក្រុមហ៊ុនស៊ីជេ កម្ពុជា (ភាគហ៊ុន : កូរ៉េខាងត្បូងមានភាគហ៊ុន៩៥ ភាគរយ ហើយខ្មែរមាន៥ ភាគរយ) បានចុះកិច្ចសន្យាមួយជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ លើផ្ទៃដីសម្បទានគោលដៅសេដ្ឋកិច្ចទំហំ៣.០០០ហិកតានៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដើម្បីដាំដំឡូងមីសំរាប់កែឆ្នៃម្សៅមី ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០១ ក្រុមហ៊ុននេះបានចុះកិច្ចសន្យាមួយទៀតលើដីសម្បទានទីពីរដែលមានផ្ទៃដីចំនួន៥.០០០ហិកតា ដែលមានភូមិសាស្ត្រជាប់នឹងដីសម្បទានទីមួយ ដើម្បីដាំដំឡូងមីថែមទៀត ។ ក្រុមហ៊ុនបានឈូសឆាយដីសម្បទានទីមួយភាគច្រើនបានដាំដំឡូងមី ហើយបានជីកប្រឡាយមួយខ្សែព័ទ្ធជុំវិញដីសម្បទាននោះ ។ ក្រុមហ៊ុនកំពុងធ្វើការឈូសឆាយដីសម្បទានទីពីរ ប៉ុន្តែបើតាមសេចក្តីរាយការណ៍បានឱ្យដឹងថាបច្ចុប្បន្ននេះ ក្រុមហ៊ុនបានផ្អាកសកម្មភាពរបស់ខ្លួនលើដីសម្បទានទីពីរហើយ ។

ដីសម្បទានទាំងពីរនេះ លាតសន្ធឹងលើដីមួយភាគធំនៃឃុំត្រែងត្រយឹង ហើយធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋមូលដ្ឋានជាច្រើនភូមិ ។ ស្រុកភ្នំស្រួច គឺជាផ្នែកមួយនៃតំបន់អភិវឌ្ឍន៍ដ៏ធំមួយរបស់យោធា ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៦ សំរាប់ការតាំងទីលំនៅថ្មីរបស់យោធិនរំសាយ ក្នុងនោះក៏មានអតីតទាហានខ្មែរក្រហមផងដែរ ។ ហេតុដូច្នេះ សម្បទាននេះស្ថិតក្រោមការគ្រប់គ្រង "ការការពារ" ដោយផ្ទាល់ពីមន្ត្រីយោធាប្រដាប់អាវុធ និងយោធិនរំសាយ ។ ប្រវត្តិថ្មីៗ នៅតំបន់នេះ គឺមានការប្រយុទ្ធគ្នា ការបែងចែកដី និង ការគ្រប់គ្រងដីដោយយោធា ហើយនៅពេលថ្មីៗនេះ មានការរកចំណេញលើដីធ្លី--ដែលបង្ករឱ្យមានសភាពការណ៍ ច្របូកច្របល់មួយដែលពោរពេញទៅដោយជម្លោះ ការបណ្តេញចេញ ការបំភិតបំភ័យ និងការគំរាមកំហែង ។ ស្រុកភ្នំស្រួចមានផ្ទៃដី ១៥៦.៤៥៥ ហិកតា ដែលក្នុងនោះមានផ្ទៃដី១១៨.៣៩៦ ហិកតា ដែលរាជរដ្ឋាភិបាលចុះ កិច្ចសន្យាសម្បទានគោលដៅសេដ្ឋកិច្ចជាមួយក្រុមហ៊ុន ហើយនៅសល់ដីតែបន្តិចបន្តួចប៉ុណ្ណោះ សំរាប់ប្រជាពលរដ្ឋមូលដ្ឋានធ្វើស្រែចំការ ។

ក្នុងទសវត្សឆ្នាំ១៩៦០ ស្រុកត្រែងត្រយឹងគ្របដណ្តប់ទៅដោយព្រៃឈើ ។ មានប្រជាពលរដ្ឋតែពីរបីគ្រួសារប៉ុណ្ណោះនៅភូមិទាំងប្រាំមួយ ដែលប្រកបរបររកស៊ីចិញ្ចឹមជីវិតដោយការធ្វើស្រែចំការ និង ការប្រមូលអនុផលព្រៃឈើ ។ មានផ្លូវលំមួយខ្សែភ្ជាប់ពីភូមិទាំងនោះទៅផ្លូវជាតិលេខ៤ ។ នៅដើមទសវត្សឆ្នាំ១៩៧០ ខ្មែរក្រហមបានគ្រប់គ្រងតំបន់នេះ ហើយចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គេបានបង្កើតជាសហករ ហើយបានធ្វើការកាប់ឆ្ការដីលើកទំនប់ និងជីកប្រឡាយជាច្រើនខ្សែដើម្បីធ្វើស្រូវប្រាំង ។ ក្នុងកំឡុងទសវត្សឆ្នាំ១៩៨០ និងរហូតដល់

ពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ មានការប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងទ័ពរាជរដ្ឋាភិបាល និង ខ្មែរក្រហមនៅតំបន់នេះ។ ប្រជាពលរដ្ឋបានបោះបង់ភូមិចាស់របស់ខ្លួន ហើយបានមកតាំងទីលំនៅ៧តាមបណ្តោយផ្លូវជាតិលេខ៤។

ក្នុងឆ្នាំ១៩៩៦ កងទ័ពខ្មែរក្រហម ដែលមានបញ្ជាការដ្ឋាននៅតំបន់ប៉ៃលិន បានរត់ចោលជួរ និង បានធ្វើសមាហរណកម្មជាមួយកងយោធពលខេមរភូមិន្ទ។ រាជរដ្ឋាភិបាលបានប្រកាសថាតំបន់នេះជាតំបន់អភិវឌ្ឍន៍យោធា។ មេបញ្ជាការកងវរៈសេនាតូចលេខ៤៤ បានប្រាប់គ្រួសារអតីតខ្មែរក្រហមឱ្យតាំងទីលំនៅ និងកាប់ឆ្ការដីនៅទីនោះ។[១] ដោយមានការអំពាវនាវពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋមកតាំងទីលំនៅ៧លើដីនោះ ក្រោយពីចប់សង្គ្រាម ទើបមានប្រជាពលរដ្ឋជាច្រើនគ្រួសារដែលគ្មានទីលំនៅ៧ក្នុងប្រទេសបានមកជាបន្តបន្ទាប់ពីខេត្តតាកែវ បាត់ដំបង និង ខេត្តដទៃទៀត ដើម្បីសុំដីធ្លីនៅទីនេះ។

ក្នុងឆ្នាំ១៩៩៨ ភូមិចំនួន១៦ ត្រូវបានបង្កើតឡើង ក្រោមការគ្រប់គ្រងរបស់អតីតនាយទាហានខ្មែរក្រហមមួយរូបដែលធ្វើជាប្រធានឃុំ។ គេបានបង្កើតឃុំ " ក្រៅផ្លូវការ " មួយ ដែលក្នុងនោះគ្រួសារនីមួយ៧ បានផ្តល់ដីសំរាប់ធ្វើលំនៅដ្ឋាន និង ដីសំរាប់ធ្វើស្រែចំការ។ គេបានកេណ្ឌអ្នកភូមិជាច្រើននាក់ ដើម្បីស្ថាបនាផ្លូវ និងស្ពាន ហើយគ្រួសារប្រជាពលរដ្ឋទាំងនោះបានសង់ផ្ទះ កាប់ឆ្ការដី និង ធ្វើស្រែចំការទៀតផង។ គ្រួសារនីមួយ៧បានបង់ប្រាក់ចំនួន១០.០០០ រៀល (២.៥ ដុល្លារ) សំរាប់ចំណាយលើ "ថ្លៃឈ្នួលកិច្ចការរដ្ឋបាល" ដើម្បីបានប័ណ្ណកម្មសិទ្ធិដីធ្លីដែលអាជ្ញាធរមូលដ្ឋាន "ក្រៅផ្លូវការ" បានចេញឱ្យ។ ក្នុងពេលនោះ នៅមានព្រៃក្រាសខ្លះដែរ ប៉ុន្តែចាប់តាំងពីពេលនោះមក ដើមឈើមានតំលៃត្រូវពួកយោធាកាប់អស់ នៅសល់តែដើមឈើដែលគ្មានតំលៃប៉ុណ្ណោះ។ រាជរដ្ឋាភិបាលមិនទទួលស្គាល់ឃុំ " ក្រៅផ្លូវការ " នេះទេ ហើយបច្ចុប្បន្នភូមិទាំងនោះ គឺជាផ្នែកមួយនៃភូមិទាំងប្រាំបីដែលក្រៅផ្លូវការ។

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ ក្រុមហ៊ុនស៊ីជេកម្ពុជានេះបានចុះកិច្ចសន្យាលើកទីមួយរបស់ខ្លួន។ ក្នុងឆាំ២០០០ អភិបាលស្រុក មេឃុំ តំណាងក្រុមហ៊ុន និងសមាជិកកងយោធពលខេមរភូមិន្ទ បានអញ្ជើញប្រជាពលរដ្ឋមូលដ្ឋានឱ្យចូលរួមការប្រជុំ។ ពួកគេបានប្រាប់ប្រជាពលរដ្ឋថា ឥឡូវដីនេះជាដីរបស់ក្រុមហ៊ុន ហើយអ្នកដែលរស់នៅលើដីសម្បទានត្រូវតែចាកចេញពីដីនោះ។ ក្រោយនេះបន្តិចមក ក្រុមហ៊ុនបានចាប់ផ្តើមកាប់ឈើ ឈូសឆាយដី និងឈូសបំផ្លាញវាលស្រែ។ អាជ្ញាធរឃុំ " ក្រៅផ្លូវការ " ទាំងនេះ បានប៉ុនប៉ងព្យាយាមប្រមូលយក " ប័ណ្ណកម្មសិទ្ធិដីធ្លី " មកវិញ ហើយសន្យាថានឹងប្រគល់ប្រាក់ចំនួន១០.០០០ រៀលឱ្យវិញ។ ទាហានប្រដាប់អាវុធបានបំភិតបំភ័យប្រជាពលរដ្ឋឱ្យប្រគល់ " ប័ណ្ណកម្មសិទ្ធិដីធ្លី " និងឱ្យចាកចេញពីដីរបស់ខ្លួន។

---

[១] ក្រោយមកកងវរសេនាតូចលេខ ៤៤ បានប្តូរទៅជាកងពលតូចលេខ ៤៤ វិញ ហើយឥឡូវនេះគេស្គាល់ថាជា កងពលទ័ពថ្មើរជើងដោយមានលោកឧត្តមសេនីយ៍ត្រី ស្រ៊ុន សារឿន ជាមេបញ្ជាការ ។

ក្នុងឆ្នាំ២០០១ ប្រជាពលរដ្ឋមូលដ្ឋានបានដាក់ពាក្យបណ្តឹងទៅអភិបាលស្រុក អភិបាលខេត្ត និង តុលាការ ប៉ុន្តែបានទទួលលទ្ធផលតិចតួចប៉ុណ្ណោះ ។ អភិបាលខេត្តបានសុំឱ្យធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថាន និងសង្គម ប៉ុន្តែមិនបានទទួលជោគជ័យទេ ។ អង្គការលូថេរ៉ាន់បំរើពិភពលោក (Lutheran World Federation) និង អង្គការក្រៅរដ្ឋាភិបាលអង្គការ អាដហុក (ADHOC) បានទទួលពាក្យបណ្តឹងចំនួន១៨៧ ពាក្យបណ្តឹង ពីប្រជាពលរដ្ឋក្នុងប្រាំបីភូមិ ដើម្បីដាក់ជូនតុលាការ ។ អង្គការជំនួយផ្នែកច្បាប់ នៃកម្ពុជា (Legal Aid of Cambodia) បានទទួលសំណុំរឿងដីធ្លីនេះ ។ ប្រជាពលរដ្ឋមូលដ្ឋានបានស្នើសុំឱ្យទទួលស្គាល់សិទ្ធិលើដីធ្លី និង កំណត់ព្រំប្រទល់ដីលំនៅដ្ឋាន ព្រមទាំងដីស្រែចំការរបស់ខ្លួន ។

អង្គការលូថេរ៉ាន់បំរើពិភពលោកបាននិងកំពុងធ្វើការជាមួយប្រជាពល រដ្ឋមូលដ្ឋាននៅឃុំត្រែងត្រយឹង តាំងពីឆ្នាំ១៩៩៧ នៅពេលដែលរាជរដ្ឋាភិបាលបានប្រកាសថា ប្រជាពលរដ្ឋអាច តាំងទីលំនៅ៧តំបន់នេះបាន ។ តាំងពីក្រុមហ៊ុនបានចាប់ផ្តើមសកម្មភាពការងាររបស់ខ្លួនមក អង្គការលូថេរ៉ាន់បំរើ ពិភពលោកបានជួបប្រទះការលំបាកជាច្រើន ។ សេចក្តីអន្ទះសាររបស់អ្នកភូមិចង់ ចូលរួមក្នុងការធ្វើគ្រោងអភិវឌ្ឍន៍សំរាប់រយៈពេលវែងក៏បានថយចុះ ដោយសារតែភាពមិនប្រាកដប្រជារបស់ខ្លួន ។ ផ្នែកមួយនៃកម្មវិធីតស៊ូមតិរបស់អង្គការលូថេរ៉ាន់បំរើពិភពលោកបាន និងកំពុង ជួយអ្នកភូមិឱ្យទទួលបានដីធ្លីរបស់ខ្លួនមកវិញ ។ កាលពីខែមិថុនា ឆ្នាំ២០០៣ អង្គការនេះបានសង់ផ្ទះសហគមន៍ឡើងវិញ នៅភូមិអូរកូនត្រុំ បន្ទាប់ពីត្រូវបានដុតបំផ្លាញ ។ គ្មានជនណាម្នាក់ត្រូវ បានគេចាប់ខ្លួនក្នុងករណីនេះទេ ហើយក៏មិនបានធ្វើការស៊ើបអង្កេតណាមួយដែរ ។

លោកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានទស្សនានៅឃុំត្រែងត្រយឹង កាលពីខែវិច្ឆិកា ឆ្នាំ២០០៣ ហើយលោកបានជួបជាមួយប្រជាពលរដ្ឋមូលដ្ឋាននៅទីនោះ ។ តាងនាមឱ្យប្រជាពលរដ្ឋចំនួន ២២២ នាក់ ដែលបានចុះហត្ថលេខាលើញត្តិមួយ ដែលញត្តិនេះលោកបានប្រគល់ជូនសម្តេចនាយករដ្ឋមន្ត្រី នៅក្នុងឱកាសនៃកិច្ចប្រជុំមួយកាលពីដើមខែធ្នូ ឆ្នាំ២០០៣ ។ សម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា លោកនឹងជួយធ្វើអន្តរាគមន៍ក្នុងរឿងនេះ ។

តាមសេចក្តីរាយការណ៍ជាបន្តបន្ទាប់ពីអង្គការក្រៅរដ្ឋាភិបាលនានា បង្ហាញឱ្យឃើញថា ការយាយី និង ការគំរាមកំហែងពីយោធាបានថយចុះ ប៉ុន្តែសភាពការណ៍ទូទៅនៅតែមានដូចមុនដដែល ។ អង្គការលូថេរ៉ាន់បំរើពិភពលោក បានរៀបចំកិច្ចប្រជុំមួយ កាលពីខែមិថុនា ឆ្នាំ២០០៤ ជាមួយក្រុមប្រឹក្សាឃុំ និងលោក វរសេនីយ៍ទោ ស្វាយ សុធី ដែលជាតំណាងក្រុមហ៊ុន ស៊ីជេ កម្ពុជា នៅមូលដ្ឋាន ដើម្បីធ្វើការដោះស្រាយ ពីស្ថានភាពប្រជាពលរដ្ឋ ២២គ្រួសារ ក្នុងចំណោមប្រជាពលរដ្ឋ៥៦ គ្រួសារ ដែលទទូចចង់រស់នៅក្នុងភូមិក្រោលទន្សោងរបស់ខ្លួន ហើយដែលភូមិនេះស្ថិតនៅក្នុងដីសម្បទានទីពីរ ក្នុងខណៈពេលដែលប្រជាពលរដ្ឋជាច្រើនគ្រួសារ ទៀតត្រូវគេបង្ខំឱ្យចាក

ចេញ ។ នៅក្នុងសម័យអង្គប្រជុំនោះ លោកវរៈសេនីយ៍ទោ ស្វាយ សុធី បានលើកឡើងថា ក្រុមហ៊ុននឹងប្រគល់ដីស្រែចំការចំនួន២.៥ ហិកតា ជូនគ្រួសារនីមួយៗ តែនៅពេលដែលតំណាងក្រុមហ៊ុនបានជូន ដំណឹងពីរឿងនេះប្រជាពលរដ្ឋជាច្រើនគ្រួសារបានបដិសេធទៅវិញ ។ ពីព្រោះគ្រួសារប្រជាពលរដ្ឋទាំងនោះចង់បានដីបី ហិកតា ហើយចាប់តាំងពីពេលនោះមក គឺមិនមានការពិភាក្សាអំពីករណីនេះទៀតឡើយ ។

ដូច្នេះជំលោះដីធ្លីនេះត្រូវបានដាក់ជូនគណៈកម្មការសុរិយោដីស្រុក ប៉ុន្តែរហូតមកដល់ពេលនេះប្រជាពល-រដ្ឋមិនទាន់បានទទួលចម្លើយអ្វីនៅឡើយទេ ។

# បញ្ជី ដីសម្បទានសំរាប់គោលដៅសេដ្ឋកិច្ច

(ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងការិយាល័យខេត្ត ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត)

**<u>ឧបសម្ព័ន្ធ ៣</u>**

| លេខរៀង | ទីតាំងតាមខេត្ត~ស្រុក | សម្បទានិក | ភាគហ៊ុន (បញ្ជីCDC) | ផ្ទៃដីជាហិកតា | គោលដៅ | កាលបរិច្ឆេទនៃការចាប់ផ្តើមកិច្ចសន្យា | កាលបរិច្ឆេទផុតកំណត់ | | ព័ត៌មានបន្ថែម |
|---|---|---|---|---|---|---|---|---|---|
| **ខេត្តកំពង់ស្ពឺ** | | | | | | | | | |
| ១ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុន Cambo Victor Investing & Development Co. | តៃវ៉ាន់: ៩៥% កម្ពុជា:៥% | ២៦.៥៥០ | ស្រូវ ពោត ដំឡូងមី សណ្តែកដី និង សណ្តែកសៀង | ១៣ សីហា ២០០១ | ១៣ សីហា ២០៧១ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ២ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុនហៃនិញ Cambodia Haining Group Co. | ចិន: ១០០% | ២១.២៥០ | ដំឡូងមី ដូងប្រេង និង ចិញ្ចឹមសត្វ | ២៣ កក្កដា ១៩៩៨ | ២៣ កក្កដា ២០៦៨ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៣ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន China | កម្ពុជា:៥១% | ១៤.៧០០ | ពោត បន្លែ និង | ២៩ កញ្ញា | គ្មាន | លិខិតរបស់ ក្រសួង | មានទីតាំង |

---

* កិច្ចសន្យា រកបានដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | National Corporation for Overseas Economic Cooperation Laostar | ចិន: ៤៩ % | បន្ថយមក ត្រឹម ៨.000 | ស្រូវ | ២000 | | កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ក្នុងតំបន់ អភិវឌ្ឍន៍ យោធភូមិ ភាគ ៣ តាមលិខិត ដែលចេញ ដោយលោក ឧត្តម សេនីយ៍ គន់ គីម |
| ៤ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុន Henan (Cambodia) Economic & Trade Development Zone | ចិន: ១00% | ៤.១00 | ដំឡូងមី, ដូងប្រេង, ការចិញ្ចឹមសត្វ | ២៩ កក្កដា ១៩៩៩ | ២៩ កក្កដា ២0៦៨ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៥ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុនអភិវឌ្ឍន៍ ដំណាំឧស្សាហកម្ម អ៊ុក ឃុន（ADUOK） | គ្មាន | ១២.៥0៦ | ស្វាយចន្ទី | ២៥ ឧសភា ២00១ កិច្ចសន្យាដំបូង : មេសា ១៩៩២ | ២៥ ឧសភា ២0៧១ | ក្រុមហ៊ុន | |
| ៦ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុន CJ Cambodia Co.LTD | កូរ៉េ: ៩៥% កម្ពុជា:៥% | ៣.000 | ដំឡូងមី | ១៥ វិច្ឆិកា ១៩៩៩ | គ្មាន | លិខិតរបស់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | នេសាទ | |
| ៧ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុន CJ Cambodia Co.LTD | កូរ៉េ: ៩៥% កម្ពុជា:៥% | ៥.០០០ | ដំឡូងមី | ២០ មេសា ២០០១ | ២០ មេសា ២០៧១ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៨ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុន Kimsville Corp Co. | សហរដ្ឋអាមេរិក ១០០% | ៣.២០០ | ដំឡូងមី | ២៤ តុលា ២០០០ | ២៤ តុលា ២០៧០ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៩ | ស្រុកភ្នំស្រួច | *ក្រុមហ៊ុន Golden Land Development Co. Ltd. | គ្មាន | ២.១០០ កើនដល់ ៤.៩០០ | អាកាស្យា និង ដើម ប្រេងខ្យល់ | ០៥ មីនា ២០០៤ | ០៥ មីនា ២០៧៤ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | កិច្ចសន្យាជាមួយតំបន់អភិវឌ្ឍន៍យោធភូមិភាគ៣, តាមផែនទី |
| ១០ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន ហ៊ួរ ហុង | កម្ពុជា: ១០០% | ២.០៤០ | ដំណាំហូបផ្លែ និង ការចិញ្ចឹមសត្វ | មិនទាន់បានចុះកិច្ចសន្យា | | លិខិតរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ដីតំបន់អភិវឌ្ឍន៍យោធភូមិភាគ៣ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១១ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Un Borin Trade & Agriculture Development Co. | កម្ពុជា: ១០០% | ១៦.៦០០ | ដំឡូងឈើ និង អំពៅ | មិនទាន់បានចុះកិច្ចសន្យា | | លិខិត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ១២ | ថ្លង | ក្រុមហ៊ុន M. Consolidated Plantation Co. | ម៉ាឡេស៊ី : ១០០% | ១២.៧០០ | គ្មាន | មិនទាន់បានចុះកិច្ចសន្យា | | លិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ១៣ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Direct International Co.Ltd | គ្មាន | ៣.១០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ | |
| ១៤ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន ប៊ុន សំណាង | គ្មាន | ១០.០០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ | ដីតំបន់អភិវឌ្ឍន៍យោធភូមិភាគ៣ |
| ១៥ | ស្រុកភ្នំស្រួច | ក្រុមហ៊ុនអូស្វាន់ ហាស្សាន់ | គ្មាន | ៣០.០០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ១៦ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Pacific Plantation Co.Ltd | គ្មាន | ២.៧៨០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | គ្មាន |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ខេត្តកំពង់ស្ពឺ | |
| ១៧ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Srae Khlong Estate Co. | គ្មាន | ៣.៤០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ១៨ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន United Plantation Corporation | គ្មាន | ២.៧៦០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ១៩ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Agroproduce International | គ្មាន | ២.៤៦០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | ដីតំបន់អភិវឌ្ឍន៍យោធ ភូមិភាគ ៣ |
| ២០ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន ស៊ី ធី | គ្មាន | ១.៣៥០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ២១ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Tony International Land Development Co.Ltd | គ្មាន | ១.៩០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | ដីតំបន់អភិវឌ្ឍន៍យោធភូមិភាគ ៣ |
| ២២ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Yuanda Wolf (Cambodia) Silk Co.Ltd | គ្មាន | ១.៤០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ [illegible] | ផែនទីជាន់គ្នាជាមួយឧទ្យានជាតិ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ខេត្តកំពង់ស្ពឺ | គិរីរម្យ |
| ២៣ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Sino Agriculture Resources | គ្មាន | ២.២០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ២៤ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន Capital Hill Plantation Co. | គ្មាន | ៣.៣៥០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ២៥ | ស្រុកភ្នំស្រួច | ក្រុមហ៊ុន តុង ណាំ អា | គ្មាន | ៣០៤ | ដាំអំពៅ,សង់មន្ទីរពេទ្យ សណ្ឋាគារ, និងមជ្ឈមណ្ឌលពាណិជ្ជកម្ម | គ្មាន | គ្មាន | ទស្សនះកិច្ចអង្កេត | ផែនទី |
| ២៦ | ថ្ពង | ក្រុមហ៊ុន ផេង ហ្វា | ( មិនដឹងច្បាស់ពីឈ្មោះក្រុមហ៊ុន) | ៣.០០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ២៧ | ថ្ពង | ក្រុមហ៊ុនខ្មែរអភិវឌ្ឍន៏ដំណាំកៅស៊ូ | គ្មាន | ១៣.០០០ | អំពៅ | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |
| ២៨ | ឱរ៉ាល់ | ក្រុមហ៊ុនខ្មែរអភិវឌ្ឍន៏ដំណាំកៅស៊ូ | គ្មាន | ៤០.០០០ | គ្មាន | គ្មាន | គ្មាន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកំពង់ស្ពឺ | គ្មាន |

| **ខេត្ត កំពង់ចាម** | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២៩ | ជើងព្រៃ | *ក្រុមហ៊ុន Agro Star Invest. | កម្ពុជា: ១០០% | ២.៤០០ | កសិដ្ឋានចិញ្ចឹមសត្វ និង ស្វាយចន្ទី | មករា ១៩៩៥ | មករា ២០៦៥ | ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ៣០ | | ក្រុមហ៊ុនចំការកៅស៊ូសូគីម៉ិច | កម្ពុជា: ១០០% | ៩.៩០០ | ដំណាំកៅស៊ូ | ២៧ ឧសភា ១៩៩៨ | គ្មាន | លិខិត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ៣១ | | ក្រុមហ៊ុន T.T.Y Agricultural Plan Development Co. | កម្ពុជា: ១០០% | ១.០៧០ | ដំណាំកៅស៊ូ | ០២ ឧសភា ២០០០ | គ្មាន | លិខិត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ៣២ | | សហគមន៍គ្រួសារហេង សារ៉ាត់ | គ្មាន | ៥០០ | ដំណាំកៅស៊ូ | ២៣ មករា ១៩៩២ | គ្មាន | លិខិត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ៣៣ | | ក្រុមហ៊ុនបុប្ផាអង្គររីម៉ិចត្រង់កុង | គ្មាន | ៥.០០០ | គ្មាន | មិនទាន់ចុះកិច្ចសន្យា | | លិខិត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៤ | | ក្រុមហ៊ុន មៀង លីហេង វិនិយោគ | គ្មាន | ៣.០០០ | គ្មាន | មិនទាន់ចុះកិច្ចសន្យា | | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| **ខេត្ត កំពត** | | | | | | | | | |
| ៣៥ | | ក្រុមហ៊ុន ខេមលេន អាហារណ៍នីហរណ៍ | គ្មាន | ១៦.៤០០ | ដូងប្រេង | ២៦ តុលា ២០០០ | គ្មាន | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ | |
| ៣៦ | | ក្រុមហ៊ុន Cambodian Tapioca PTY Enterprise | ម៉ាឡេស៊ីៈ៥១% កម្ពុជាៈ ៤៩ % | ៥.១០០ | ដំឡូងមី | មិនទាន់ចុះកិច្ចសន្យា | | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៣៧ | | ក្រុមហ៊ុន ShingYue Commercial PTY Ltd | ម៉ាឡេស៊ីៈ ១០០% | ១០.០០០ | ដំណាំកៅស៊ូ | មិនទាន់ចុះកិច្ចសន្យា | | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៣៨ | | ក្រុមហ៊ុន China Evergret Cambodia Agriculture Development | ចិនៈ៩៣,៩០% កម្ពុជាៈ៦,១០% | ៤.០០០ | ដង្កូវនាង, ពោត, បន្លែ និង ស្រូវ | មិនទាន់ចុះកិច្ចសន្យា | | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៩ | | ក្រុមហ៊ុន ស៊ីន ថៃ កំពត | កម្ពុជា: ៦០% តៃវ៉ាន់:៤០% | ៥.៧០០ | ស្វាយចន្ទី, ធុរ៉េន, ពោត និង សណ្តែក | មិនទាន់ចុះ កិច្ចសន្យា | | លិខិត របស់ ក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ | |
| **ខេត្ត កោះកុង** | | | | | | | | | |
| ៤០ | | ក្រុមហ៊ុន Talam Plantation Holding Co. | គ្មាន | ៣៦.៧០០ | ដូងប្រេង និង ដំណាំកៅស៊ូ | ០៥ តុលា ១៩៩៨ | គ្មាន | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៤១ | | *ក្រុមហ៊ុន The Green Rich Co.Ltd | តៃវ៉ាន់:១០០% | ៦០.២០០ ត្រូវបាន បន្ថយ មកត្រឹម ១៨.៣០០ | ដូងប្រេង និង អាកាស្យា | ២៥ វិច្ឆិកា ១៩៩៨ | ២៥ វិច្ឆិកា ២០៦៨ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ | |
| ៤២ | | ក្រុមហ៊ុន China Cambodia State Farm International | ចិន: ១០០% | ៧.៥០០ | ដំណាំកសិកម្ម និងចិញ្ចឹមសត្វ | ០៦ តុលា ១៩៩៨ | គ្មាន | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៤៣ | | ក្រុមហ៊ុនដូងប្រេង ចុង ស៊ីន កម្ពុជា | តៃវ៉ាន់: ៨៧% កម្ពុជា:១៣% | ១៦.០០០ | ដំណាំសណ្តែក សៀង និង វាយនភ័ណ្ឌ | មិនទាន់ចុះ កិច្ចសន្យា | | លិខិត របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤៤ | កំពង់សីលា | ក្រុមហ៊ុន(Cambodia) Malaysia Palm Oil Investment and Development Co.Ltd | គ្មាន | ៨.២៣៥ | ដូងប្រេង | គ្មាន | គ្មាន | លិខិតស្នើសុំ ដាក់ជូន នាយករដ្ឋមន្ត្រី | ផែនទី |
| **ខេត្ត រតនៈគិរី** | | | | | | | | | |
| ៤៥ | | ក្រុមហ៊ុនមិត្តភាព ម៉ែន សារុន និង រ៉ាម៉ា ខ្មែរ | គ្មាន | ២០.000 | ដូងប្រេង | ២១ ធ្នូ ១៩៩៩ | គ្មាន | លិខិតរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៤៦ | | ក្រុមហ៊ុន តាយ សេង នីហរណ៏អាហារណ៏ | គ្មាន | ២.000 | គ្មាន | មិនទាន់ចុះ កិច្ចសន្យា | | លិខិតរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៤៧ | អណ្តូងមាស | ក្រុមហ៊ុន Heng Brother Co.Ltd | គ្មាន | ១០.000 | ដំណាំកៅស៊ូ | គ្មាន | គ្មាន | អង្គការ ក្រៅរដ្ឋាភិបាល | |
| **ខេត្ត មណ្ឌលគិរី** | | | | | | | | | |
| ៤៨ | | ក្រុមហ៊ុន Ford Thai | | ២00 | គ្មាន | មិនទាន់ចុះ កិច្ចសន្យា | | លិខិតរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៤៩ | ស្រុកអូរាំង | ក្រុមហ៊ុន Marubeni | គ្មាន | ១១.២៣១ | ដំណាំកៅស៊ូ | គ្មាន | គ្មាន | សព្វថ្ងៃក្រុមហ៊ុន កំពុងធ្វើសកម្មភាព | ផែនទី |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៥០ | ស្រុកអូរាំង | ក្រុមហ៊ុន WUZHISHAN L.S. GROUP | គ្មាន | ស្នើសុំ ១៩៩.៩៩៩ តែទីស្តីការគណៈរដ្ឋមន្ត្រី សំរេចអោយតែ ១០.០០០ សិន | ដើមស្រល់ | គ្មាន | គ្មាន | លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី | |
| **ខេត្ត ស្ទឹងត្រែង** | | | | | | | | | |
| ៥១ | ថឡាបរិវត្ត | *ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចាំកាត់ | កម្ពុជា:៥០% ចិន :៥០% | ៧.៤០០ | ដើម ម៉ៃសាក់ | ១៣ កញ្ញា ១៩៩៩ | ១៣ កញ្ញា ២០៦៩ | ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ៥២ | ស្រុក សៀមប៉ាង និងស្រុកស្ទឹងត្រែង | *ក្រុមហ៊ុន Green Sea Industry Co. (ក្រុមហ៊ុន ម៉ុង ឫទ្ធី) | គ្មាន | ១០០.៨៥២ | ដើម ម៉ៃសាក់ | ២៣ វិច្ឆិកា ២០០១ | ២៣ វិច្ឆិកា ២០៧១ | ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **ខេត្ត តាកែវ** | | | | | | | | | |
| ៥៣ | | ក្រុមហ៊ុន លីម គ្រី អភិវឌ្ឍន៍កសិកម្ម | កម្ពុជា:១00% | ១.0៥0 | ដំណាំស្រូវ | មិនទាន់ចុះកិច្ចសន្យា | | លិខិតរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| **ក្រុងព្រះសីហនុ** | | | | | | | | | |
| ៥៤ | ខ័ណ្ឌព្រៃនប់ | ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគដំណាំដូងប្រេងកម្ពុជា | កម្ពុជា:១00% | ១១.000 | ដំណាំដូងប្រេង | 0៩ មករា ១៩៩៥ | | លិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៥៥ | ខ័ណ្ឌព្រៃនប់ | ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគដំណាំដំឡូងមីកម្ពុជា | កម្ពុជា:៦0% ថៃ:៤0% | ១.៨00 | ដំឡូងមី | ១៨ មីនា ២000 | | លិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| **ខេត្ត កំពង់ឆ្នាំង** | | | | | | | | | |
| ៥៦ | ស្រុកទឹកផុស, ស្រុកសាមគ្គីមានជ័យ និង ស្រុកបរិបូរណ៍ | ក្រុមហ៊ុន ភាពីម៉ិច | គ្មាន | ១៧៦0៦៥ | ដើមប្រេងខ្យល់ | 0៨ មករា ២000 | ២0៧0 | ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **ខេត្ត ពោធិ៍សាត់** | | | | | | | | | |
| ៥៧ | ស្រុកក្រវាញ, ស្រុកក្រគរ និងស្រុក សំពៅមាស | ក្រុមហ៊ុន ភាពីម៉ិច | គ្មាន | ១៣៨៩៦ ៣ | ដើម ប្រេងខ្យល់ | ០៨ មករា ២០០០ | ២០៧០ | ចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៥៨ | ស្រុកក្រគរ | ក្រុមហ៊ុនរតនៈវិសាល អភិវឌ្ឍន៍ | កម្ពុជា:៧១% ចិន:២៩% | ៣,០០០ | ស្វាយចន្ទី | ១៥ តុលា ១៩៩៩ | គ្មាន | លិខិតរបស់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| ៥៩ | | ក្រុមហ៊ុន សួរ គា | កម្ពុជា:១០០% | ៣០០ | ស្វាយចន្ទី | មិនទាន់ចុះ កិច្ចសន្យា | | លិខិតរបស់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |
| **ខេត្ត កំពង់ធំ** | | | | | | | | | |
| ៦០ | | ក្រុមហ៊ុន Cambodia Eversky | កម្ពុជា:១០០% | ១០,០០០ | ដំណាំកប្បាស | ០៣ មករា ១៩៩៨ | គ្មាន | លិខិតរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៦១ | ស្រុកសន្ទុក និង ស្រុកប្រាសាទសំបូរ | ក្រុមហ៊ុន Cam Chi International Agriculture Development | កម្ពុជា:៥០% ចិន:៥០% | ២៦,៥០០ | ដំឡូងមី ពោត ដំណាំហូបផ្លែ និង ចិញ្ចឹមសត្វ | ០៣ មីនា ២០០០ | ០៣ មីនា ២០៧០ | ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| **ខេត្ត បាត់ដំបង** | | | | | | | | | |
| ៦២ | កំរៀង | *ក្រុមហ៊ុនលាងហ៊ួហុង អាហារណ៍ នីហរណ៍ និង អភិវឌ្ឍន៍ដំណាំ កសិ-ឧស្សាហកម្ម និង កែច្នៃ | កម្ពុជា: ១០០% | ៨,០០០ | អំពៅ និង ដំឡូងមី | ០៧ កក្កដា ២០០០ | ០៧ កក្កដា ២០៧០ | ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ៦៣ | ប៉ៃលិន | ក្រុមហ៊ុន Pacific Delta Trading and Shipping Co.Ltd | គ្មាន | ២៧,០០០ | អំពៅ | គ្មាន | គ្មាន | ក្រុមហ៊ុន | ផែនទី |
| ៦៤ | | ក្រុមហ៊ុន Naco Rice | គ្មាន | ២,០០០ | គ្មាន | មិនទាន់បានចុះកិច្ចសន្យា | គ្មាន | លិខិតរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |

ខែ វិច្ឆិកា ឆ្នាំ ២០០៤

# ឧបសម្ព័ន្ធទី ៤

## ក្រុមហ៊ុនភាពីម៉ិច ចំកាត់ និងដីសម្បទាន ក្នុងខេត្តពោធិសាត់ និង កំពង់ឆ្នាំង[១]


**សេចក្តីសង្ខេប**

រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចសន្យាចំនួនពីរ ជាមួយក្រុមហ៊ុនភាពីម៉ិច ចំកាត់ កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០០០ ផ្តល់សម្បទានដីរដ្ឋចំនួន ៣១៥.០២៨ ហិកតា នៅក្នុងខេត្តពោធិសាត់ និង ខេត្ត កំពង់ឆ្នាំង នៅតំបន់ពាយ័ព្យនៃប្រទេសកម្ពុជា សំរាប់រយៈពេល ៧០ ឆ្នាំ ដើម្បីដំណើរការដាំឈើកសិឧស្សាហកម្ម ដាំដំណាំកសិកម្មផ្សេងៗ និងសាងសង់រោងចក្រផលិតក្រដាស និងរោងចក្រកែច្នៃកសិផល ។ កាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០០ ក្រុមហ៊ុនភាពីម៉ិច និងក្រុមហ៊ុន China Corporation of State Farms Group បានចុះកិច្ច ព្រមព្រៀងដាក់ទុនវិនិយោគចំនួន ៧០ លាន ដុល្លារ ជាប្រាក់កម្ចីដែលបានផ្តល់ដោយធនាគារនីហរណ៏អាហរណ៏ នៃប្រទេសចិន (The Import-Export Bank of China) ដល់រាជរដ្ឋាភិបាលកម្ពុជា ។ ប្រជាពលរដ្ឋជាង ១០០.០០០ នាក់រស់នៅលើតំបន់ដីសម្បទានដែលស្ថិតនៅចន្លោះតំបន់ការពារពីរកន្លែងគឺ បឹងទន្លេសាប និង ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ។ មិនមានការពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវជាមួយប្រជាពលរដ្ឋមូលដ្ឋាន ដែលទទួលផលប៉ះពាល់ និង មិនបានធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថានតាមដែលបានតម្រូវ ព្រមទាំងមិនបានធ្វើការសិក្សាពីផលប៉ះពាល់ ខាងសង្គមកិច្ចឡើយ ។


---

១ ឧបសម្ព័ន្ធនៃរបាយការណ៏របស់លោកតំណាងពិសេស របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ស្តីពីដីសម្បទានគោលដៅសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ដែលបានចេញផ្សាយក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៤

នៅពេលក្រុមហ៊ុនចាប់ផ្តើមធ្វើការឈូសឆាយដី នៅក្នុងខែមីនា ឆ្នាំ២០០០ ប្រជាពលរដ្ឋមូលដ្ឋាន ដែលទទួលផលប៉ះពាល់ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន បានធ្វើការតវ៉ា ។ នៅពេលនោះក្រុមហ៊ុនក៏បានបញ្ឈប់សកម្មភាពរបស់ខ្លួន ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការស្នើសុំរបស់សហគមន៍មូលដ្ឋាន ដើម្បីបង្កើតសហគមន៍ព្រៃឈើត្រូវបានបដិសេធ ហើយនៅដើមខែវិច្ឆិកា ឆ្នាំ២០០៤ ក្រុមហ៊ុនបានចាប់ផ្តើមសកម្មភាពរបស់ខ្លួនតទៅទៀត ។ ប្រជាពលរដ្ឋមូលដ្ឋានបានធ្វើការតវ៉ាប្រឆាំងនឹងសកម្មភាពរបស់ក្រុមហ៊ុន ក្នុងពេលប៉ុន្មានខែក្រោយមក ហើយតំណាងសហគមន៍ត្រូវទទួលរងនូវការបំភិតបំភ័យជាបន្តបន្ទាប់ពីសំណាក់អាជ្ញាធរ ។ លក្ខខណ្ឌការងារនៅលើដីសម្បទានទៀតសោតក៏មានភាពតឹងតែងខ្លាំង ។ កាលថ្ងៃទី២៤ ខែកុម្ភៈ លោកនាយករដ្ឋមន្ត្រីបានធ្វើការឆ្លើយតបចំពោះពាក្យបណ្តឹង ដែលប្រជាពលរដ្ឋមូលដ្ឋាន បានផ្ញើថ្វាយព្រះមហាក្សត្រព្រះបាទនរោត្តមសីហមុនី ស្នើឱ្យព្រះអង្គជួយធ្វើអន្តរាគមន៍ ។ លោកនាយករដ្ឋមន្ត្រី បានចាត់ទុកទង្វើនេះថាជាភាពរឹកររដែលបង្ករឡើងដោយមនុស្សមួយក្រុមតូចដែលតែងតាំងខ្លួនដោយខ្លួនឯង ដើម្បីបំរើផលប្រយោជន៍ឱ្យគណបក្សនយោបាយ ។ លោកបានគូស បញ្ជាក់ថា ការវិនិយោគ គឺជាការរួមចំណែកដល់ជីវភាពរស់នៅរបស់ប្រជាជន ការកាត់បន្ថយភាពក្រីក្ររបស់ ប្រជាពលរដ្ឋនៅតំបន់ជនបទ និងដើម្បីបង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៃប្រទេសកម្ពុជា ។ ប្រជាពលរដ្ឋមូលដ្ឋាននៅតែបន្តស្នើសុំបង្កើតសហគមន៍ព្រៃឈើ ។ នៅពាក់កណ្តាលខែមីនា ក្រុមហ៊ុនបានបញ្ឈប់សកម្មភាពយ៉ាងបន្ទាន់ នៅលើដីសម្បទានទាំងពីរកន្លែងនោះ បុគ្គលិក និងអ្នកបំរើការទាំងអស់បានចាកចេញពីទីនោះ ដោយទុកតែមន្ត្រីនគរបាលឱ្យយាមការដ្ឋាននោះតែប៉ុណ្ណោះ ។

នៅក្នុងរបាយការណ៍របស់លោកតំណាងពិសេស ស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ច លោកបានផ្តល់ជូនអនុសាសន៍ជាច្រើន ដើម្បីអនុវត្តចំពោះសម្បទានដែលបានផ្តល់ឱ្យក្រុមហ៊ុនភាពីម៉ិច ។

## ១. កិច្ចសន្យា ៖

រាជរដ្ឋាភិបាលកម្ពុជា បានចុះកិច្ចសន្យាដីសម្បទានគោលដៅសេដ្ឋកិច្ចចំនួនពីរ ជាមួយក្រុមហ៊ុនភាពី ម៉ិច ចំកាត់ កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០០០ ផ្តល់សម្បទានដីរដ្ឋចំនួន ៣១៥.០២៨ ហិកតា នៅក្នុង ខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំង សំរាប់រយៈពេល៧០ ឆ្នាំ ដើម្បីដំណើរការដាំឈើកសិឧស្សាហកម្ម ដាំដំណាំកសិកម្មផ្សេងៗ និងសាងសង់រោងចក្រផលិតក្រដាស និងរោងចក្រកែច្នៃកសិផល ។ កិច្ចសន្យានេះ ត្រូវបាន

ចុះហត្ថលេខាដោយប្រធានក្រុមហ៊ុនភាពីម៉ិច គឺលោក ឡាវ ម៉េងឃីន ដែលជាប្តីរបស់អ្នកស្រី ឈឹង សុភាព ហើយដែល ឈ្មោះក្រុមហ៊ុនត្រូវបានដាក់តាមឈ្មោះនេះ[២] ។

កាលពីថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០០ ក្រុមហ៊ុនភាពីម៉ិច និងក្រុមហ៊ុន China Corporation of State Farms Group បានចុះហត្ថលេខាលើកិច្ចសន្យាសហប្រតិបត្តិការមួយ ដើម្បីដាក់ទុនចំនួន៧០ លានដុល្លារ ដែលជាប្រាក់កម្ចី ដែលបាន ផ្តល់ដោយធនាគារនីហរណ៍ អាហរណ៍នៃប្រទេសចិន (The Import-Export Bank of China) ដល់រាជរដ្ឋាភិបាល កម្ពុជា ។

ប្រាក់កក់ដែលបានតម្រូវ នៅក្នុងកិច្ចសន្យាដីសម្បទានគោលដៅសេដ្ឋកិច្ចភាគច្រើន គឺមួយដុល្លារ ក្នុងមួយ ហិកតា ។ កិច្ចសន្យាខ្លះថែងពីការបង់ប្រាក់កក់សរុប ដូចជាករណីនៃក្រុមហ៊ុនភាពីម៉ិច ដែលបានបង់ប្រាក់កក់ សរុបចំនួន ២០.០០០ ដុល្លារ សំរាប់ផ្ទៃដីសរុប ១៣៨.៩៦៣ ហិកតា (ស្មើនឹង ០,១៤ ដុល្លារ ក្នុងមួយហិកតា) នៅក្នុងខេត្តពោធិសាត់ និងប្រាក់កក់សរុបចំនួន ២០.០០០ ដុល្លារ សំរាប់ផ្ទៃដីសរុប ១៧៦.០៦៥ ហិកតា នៅក្នុង ខេត្តកំពង់ឆ្នាំង ។ កិច្ចសន្យាមិនបានតម្រូវឱ្យបង់ប្រាក់ឈ្នួលប្រចាំឆ្នាំ ជូនរដ្ឋាភិបាលឡើយ រហូតទាល់តែច្បាប់ស្តីពី ប្រាក់ឈ្នួលចូលជាធរមានសិន ។

## ២. សហគមន៍មូលដ្ឋាន និង បរិស្ថាន

មិនមានការពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវជាមួយប្រជាពលរដ្ឋមូលដ្ឋាន ដែលទទួលផលប៉ះពាល់ដោយ សម្បទានដីទេ ។ មិនបានធ្វើការវាយតំលៃពីផលប៉ះពាល់បរិស្ថានតាមដែលបានតម្រូវ ព្រមទាំងមិនបានធ្វើការ សិក្សាពីផលប៉ះពាល់ខាងសង្គមកិច្ចឡើយ ។ តាមការប៉ាន់ស្មានមានប្រជាពលរដ្ឋប្រមាណជា ១០០.០០០ នាក់ រស់នៅលើដីសម្បទាននោះ ។ ពួកគេពឹងអាស្រ័យទាំងស្រុងលើរបរកសិកម្ម ការកាប់ឈើ និង ការប្រមូលអនុផល ព្រៃឈើ ។ សម្បទានទាំងនេះមានព្រំប្រទល់ជាប់គ្នា ហើយស្ថិតនៅចន្លោះតំបន់ការពារពីរកន្លែង គឺ បឹងទន្លេសាប និង ទីជម្រកសត្វព្រៃភ្នំឱរ៉ាល់ ។ ការដែលដីសម្បទានស្ថិតនៅជិតបឹងទន្លេសាបពេកនាំឱ្យខូចបរិស្ថានយ៉ាងធ្ងន់ធ្ងរ ដូចជាការបាក់ច្រោះដី ភាពក្រខ្វក់ដល់ផ្លូវទឹកដែលហូរចាក់ទៅក្នុងបឹង និងបំផ្លាញជំរកត្រីពង ដែលផ្លាស់ទីទៅតាម

---

[២] លោក ឡាវ ម៉េង ឃីន ក៏ជាប្រធានក្រុមហ៊ុន អ៊ូជីសាន អិល អេស គ្រុប ចំកាត់ ដែលកាលពីខែសីហា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានជំហ៊ានដំបូងចំនួន ១០.០០០ ហិកតា សំរាប់ធ្វើចំការស្រល់ ក្នុងទំហំដីសម្បទានសរុបចំនួន ១៩៩.៩៩៩ ហិកតា នៅក្នុងខេត្តមណ្ឌលគិរី ។ ក្រុមហ៊ុនភាពីម៉ិច និងក្រុមអ៊ូជីសាន មានទីស្នាក់ការតែមួយជាមួយគ្នា នៅរាជធានីភ្នំពេញ ។

រដូវ ។ អ្នកនេសាទនៅបឹងទន្លេសាបក៏ពឹងអាស្រ័យលើឈើ និងអនុផលព្រៃឈើនៅក្នុងតំបន់ដីសម្បទាននេះដែរ ដូចជាឈើសំរាប់សង់លំនៅដ្ឋាន និងជ័រសំរាប់លាបទូក និងវល្លិសំរាប់ធ្វើឧបករណ៍ចាប់ត្រី ។

តំបន់ដែលទទួលរងផលប៉ះពាល់ច្រើនជាងគេ ដោយសម្បទាន គឺឃុំអន្សារចំបក់ ក្នុងស្រុកក្រគរ ខេត្តពោធិសាត់ ។ ឃុំនេះមានប្រាំមួយភូមិ ដែលមានប្រជាជាពលរដ្ឋប្រមាណជា ៦.៨០០ គ្រួសារ ។ ផ្ទៃដីដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនមានទំហំជាងបីភាគបួន នៃផ្ទៃដីសរុបដែលប្រជាពលរដ្ឋក្នុងឃុំនោះបានប្រើប្រាស់ជាប្រពៃណី ។ ផ្ទៃដីដែលនៅសល់ចំនួន ៣.០០០ ហិកតាទៀត សំរាប់ឃុំប្រើប្រាស់ គឺជាដីដែលមិនសមស្របសំរាប់ធ្វើកសិកម្ម និងជាវាលស្មៅសំរាប់សត្វពាហណៈឡើយ ព្រោះវាជាតំបន់ដែលទទួលរងនូវទឹកជំនន់តាមរដូវ ។ នៅរដូវវស្សា និងពេលមានទឹកជំនន់ជារៀងរាល់ឆ្នាំពីបឹងទន្លេសាប តាមធម្មតាប្រជាពលរដ្ឋធ្វើការផ្លាស់ទីសត្វពាហណៈ ហើយជារឿយៗគឺគ្រួសាររបស់ពួកគេផងដែរ ទៅកាន់ទីខ្ពង់រាប ហើយបច្ចុប្បន្ននេះ ទីតាំងនោះបានក្លាយជាផ្នែកមួយនៃដីសម្បទានទៅហើយ ។ ការសិក្សាស្រាវជ្រាវលើកដំបូងបង្ហាញថា ប្រាក់ចំណូលជាងពាក់កណ្តាលរបស់ប្រជាពលរដ្ឋក្នុងឃុំអន្សារចំបក់ បានមកពីការប្រមូលអនុផលព្រៃឈើ ហើយថា ៩០ ភាគរយនៃប្រជាពលរដ្ឋក្នុងឃុំនេះ ពឹងផ្អែកលើអនុផលព្រៃឈើនេះ ។ នៅពេលដែលក្រុមហ៊ុនបានទទួលការអនុញ្ញាតឱ្យធ្វើការកាប់ឆ្ការលើផ្ទៃដីដំបូងដែលមានទំហំ ៦.៨០០ ហិកតា នៅក្នុងឃុំអន្សារចំបក់ កាលពីខែមីនា ឆ្នាំ ២០០០ ហើយបានចាប់ផ្តើមសកម្មភាពរបស់ខ្លួន មានប្រជាពលរដ្ឋជាច្រើនបានធ្វើការតវ៉ាយ៉ាងខ្លាំងក្លា ហើយនៅពេលនោះគេបានអនុញ្ញាតឱ្យប្រជាពលរដ្ឋស្នាក់នៅដីនោះ ។[៣]

នៅពេលដែលមន្ត្រីនៃការិយាល័យឧត្តមស្នងការ អ.ស.ប ទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR/ Cambodia) បានទៅទស្សនកិច្ចនៅតំបន់សម្បទាននោះ កាលពីខែ ឧសភា និង ខែ កក្កដា ឆ្នាំ ២០០៣ គេមិនឃើញមានសកម្មភាពរបស់ក្រុមហ៊ុននៅខេត្តទាំងនេះឡើយ ហើយប្រជាពលរដ្ឋមូលដ្ឋានក៏មិនបានដឹងពីផែនការណាមួយដែរ ។ នៅក្នុងភូមិមួយចំនួន ប្រជាពលរដ្ឋមិនបានដឹងអំពីកិច្ចសន្យារបស់ក្រុមហ៊ុនភាពីម៉ិច ហើយអាជ្ញាធរមូលដ្ឋាន និង អាជ្ញាធរខេត្តបាននិយាយថា ពួកគេមិនបានដឹងឮអំពីក្រុមហ៊ុនភាពីម៉ិច តាំងពីឆ្នាំ ២០០០ មក ។[៤] មន្ត្រីនៃការិយាល័យប្រចាំនៅកម្ពុជា (OHCHR/ Cambodia) ក៏បានដឹងដែរថា អាជ្ញាធរខេត្តពោធិសាត់ បានបដិសេធសំណើររបស់ប្រជាពលរដ្ឋមូលដ្ឋាន ដែលបានស្នើសុំបង្កើតសហគមន៍ព្រៃឈើ ដោយអះអាងថា មានតែក្រុមហ៊ុនភាពីម៉ិចតែមួយគត់ ដែលមានសិទ្ធិលើដីនោះ ។ នៅក្នុងខេត្តកំពង់ឆ្នាំង មន្ត្រីនៃការិយាល័យ

---

[៣] សេចក្តីអធិប្បាយពិស្តារមានតាមលំដាប់នៃព្រឹត្តិការណ៍ជាហូរហែរនៅក្នុងរបាយការណ៍នេះ ។

[៤] មន្ត្រីការិយាល័យឧត្តមស្នងការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR/Cambodia) បានទៅទស្សនកិច្ចនៅដីសម្បទានមួយកន្លែង ដែលមានទំហំ ៣.០០០ ហិកតា ដែលគ្រប់គ្រងដោយក្រុមហ៊ុនឈ្មោះរតនៈវិសាល ស្ថិតនៅក្នុងដីសម្បទានរបស់ក្រុមហ៊ុនភាពីម៉ិច ក្នុងខេត្តពោធិសាត់ ដែលក្រសួងកសិកម្មបានផ្តល់ឱ្យក្នុងឆ្នាំ១៩៩៩ ដែលក្នុងនោះមានផ្ទៃដីចំនួន ៨០០ ហិកតា ត្រូវបានធ្វើការកាប់ឆ្ការព្រៃរួចហើយៗបានដាំដើមស្វាយចន្ទី ។

ប្រចាំនៅកម្ពុជា (OHCHR/ Cambodia) បានប្រទះឃើញចំការមួយដែលមានទំហំ ២០.000 ហិកតា ស្ថិតនៅក្នុងព្រំប្រទល់ដីសម្បទាន ក្នុងស្រុកសាមគ្គីមានជ័យ ដែលនៅក្នុងពេលនោះ ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានរុក្ខាប្រម៉ាញ់ នៅទីក្រុងភ្នំពេញ ។ ២.000 ហិកតា នៃផ្ទៃដីនោះត្រូវបានធ្វើការកាប់ឆ្ការព្រៃ ហើយបានដាំដើមប្រេងខ្យល់ ។ អ្នកស្រុកបាននិយាយថា ដីមួយចំនួនរបស់ពួកគេ ត្រូវបានធ្វើការឈូសឆាយ ដោយមិនបានចេញប្រាក់សំណងអ្វីឡើយ ។

### ៣. ការចាប់ផ្តើមធ្វើសកម្មភាពជាថ្មី

រយៈពេលប៉ុន្មានឆ្នាំក្រោយមក គឺនៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២00៤ អគ្គនាយករង ក្រសួងកសិកម្មដោយមានការយល់ព្រមពីរដ្ឋមន្ត្រី បានអនុម័តយល់ព្រមលើសំណើររបស់ក្រុមហ៊ុនភាពីម៉ិច ក្នុងការកាប់ឆ្ការដីសម្បទានដែលមានទំហំ ១0.000 ហិកតា នៅក្នុងខេត្តពោធិសាត់ និង ១0.000 ហិកតាទៀត នៅក្នុងខេត្តកំពង់ឆ្នាំង ។ គេបានអនុញ្ញាតឱ្យក្រុមហ៊ុននាំចូលគ្រឿងចក្រ និង អ្នកបច្ចេកទេសចំនួន ៤0 នាក់ ។ ក្រសួងបានស្នើសុំឱ្យក្រុមហ៊ុនធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីកំណត់យកតំបន់ដែលត្រូវធ្វើការឈូសឆាយ ហើយអភិបាលខេត្តពោធិសាត់បានបង្កើតក្រុមការងារមួយដោយមានមន្ត្រីដែលពាក់ព័ន្ធ នៅមូលដ្ឋានធ្វើការជាមួយមន្ត្រីមកពីក្រសួងកសិកម្ម ដើម្បីធ្វើការវាយតំលៃ និង កំណត់ផ្ទៃដី ។

ក្រុមហ៊ុនភាពីម៉ិចបានចាប់ផ្តើមកាប់ឆ្ការដីភ្លាម១ ជាមួយក្រុមហ៊ុនអ៊ូជីសាន អិល អេស គ្រុប ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងជំនាញ ។ កសិករនៅក្នុងខេត្តទាំងពីរនេះ បានចាប់ផ្តើមធ្វើការតវ៉ា កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ។ រយៈពេលប៉ុន្មានម៉ោងដំបូង នៃថ្ងៃ ទី ១៣ ខែ វិច្ឆិកា មានការគប់គ្រាប់បែកមួយគ្រាប់ទៅលើអ្នកស្រុក ដែលកំពុងដេកនៅក្នុងបរិវេណនៃវិហារឥស្លាមមួយក្នុងភូមិ បណ្តាលឱ្យអ្នកតវ៉ាចំនួនប្រាំបីនាក់ត្រូវរងរបួស ។ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា គឺនៅថ្ងៃចុងក្រោយនៃបេសកកម្មលើកទីដប់មួយរបស់លោកតំណាងពិសេស លោកបានចេញផ្សាយនូវរបាយការណ៍ និងអនុសាសន៍ស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ច ផ្អែកលើទស្សនវិស័យខាងសិទ្ធិមនុស្ស ។ នៅក្នុងសន្និសិទ្ទកាសែត ដែលអមដោយការចេញរបាយការណ៍ផងដែរនោះ លោកតំណាងពិសេសបានសំដែងនូវសេចក្តីសោកស្តាយអំពីការវាយប្រហារដោយគ្រាប់បែកដៃ ដោយលោកបានធ្វើការអំពាវនាវសុំឱ្យធ្វើការស៊ើបអង្កេតលើករណីនេះឱ្យហ្មត់ចត់ ហើយបានអំពាវនាវសុំឱ្យអាជ្ញាធរស្តាប់ប្រជាពលរដ្ឋ និង ឆ្លើយតបចំពោះកង្វល់របស់ពួកគេ ។

ក្រុមហ៊ុនបានបន្តកាប់រំលំដើមឈើ និង ធ្វើការឈូសឆាយដី ដោយបានបង្កើតជំរុំចំនួនបួន នៅក្នុងទីតាំងផ្សេងៗគ្នា នៅលើដីសម្បទានក្នុងខេត្តពោធិសាត់ ហើយនឹងជំរុំមួយទៀត នៅក្នុងខេត្តកំពង់ឆ្នាំង ។ ប្រជាពលរដ្ឋមូលដ្ឋានបានបន្តធ្វើការតវ៉ា ប៉ុន្តែមិនបានទទួលលទ្ធផលអ្វីឡើយ ។ ផ្ទុយទៅវិញ ពួកគេត្រូវទទួលរងនូវការបំភិតបំភ័យ និង ការគំរាមកំហែង ។

ដោយមានការព្រួយបារម្ភអំពីសភាពការណ៍ និងទំនាស់រវាងប្រជាពលរដ្ឋ និង ក្រុមហ៊ុន និង អាជ្ញាធរមូលដ្ឋាន និង អជ្ញាធរខេត្ត មន្ត្រីនៃការិយាល័យប្រចាំនៅកម្ពុជា (OHCHR/ Cambodia) បានទៅទស្សនកិច្ចនៅដីសម្បទានចំនួនពីរកន្លែង កាលពីថ្ងៃ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥ ដើម្បីជួបជាមួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ និង ដើម្បីស្វែងយល់ថែមទៀត អំពីសភាពការណ៍ និងកង្វល់របស់ពួកគេ ។

## ៤. កង្វល់របស់ប្រជាពលរដ្ឋ នៅខេត្តពោធិសាត់

អ្នកស្រុកប្រមាណជាង ១០០ នាក់ បានធ្វើការប្រមូលផ្តុំគ្នា នៅក្នុងភូមិខ្សាច់ល្អិត ក្នុងខេត្តពោធិសាត់ ។ អ្នកស្រុកទាំងនោះបានសំដែងនូវការខឹងសម្បាយ៉ាងខ្លាំង ដែលក្រុមហ៊ុនបានធ្វើការរុករានទន្ទ្រាននៅលើទឹកដីរបស់ពួកគេ ។ ដោយការប្រឈមមុខទៅនឹងកំលាំងចំរុះ របស់ក្រុមហ៊ុន អាជ្ញាធរមូលដ្ឋាន និង អាជ្ញាធរថ្នាក់ជាតិ ប្រជាពលរដ្ឋបាននិយាយថា ពួកគេគ្មានអ្វីជាទីពឹងទៀតទេ ត្រូវបានបំភ្លេចចោលនិងត្រូវបានបោះបង់ចោល ។ ពួកគេនិយាយថា បើអស់ព្រៃហើយ គេគ្មានរបររកស៊ីចិញ្ចឹមជីវិតទៀតឡើយ ។ ប្រជាពលរដ្ឋគ្មានមធ្យោបាយដើម្បីធ្វើការតវ៉ា ក្រៅតែពីការបង្ហូរទឹកភ្នែក ។ ពួកគេបានស្នើសុំឱ្យទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិជួយដល់ពួកគេ និង ជួយការពារព្រៃកុំឱ្យបាត់បង់ ។ ពួកគេក៏បានស្នើសុំឱ្យជួយរៀបចំឱ្យពួកគេអាចជួបជាមួយលោកនាយករដ្ឋមន្ត្រី ដើម្បីថ្លែងរៀបរាប់ដោយផ្ទាល់អំពីកង្វល់របស់ខ្លួន ។

អ្នកស្រុកម្នាក់បាននិយាយថា :

*"រដ្ឋាភិបាលបានលើកឡើងអំពីការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែតាមពិតគឺរដ្ឋាភិបាលកំពុងព្យាយាមលុបបំបាត់អ្នកក្រីក្រទៅវិញទេ ។ ពួកគេបានបំផ្លាញយើង ដោយការដណ្តើមយកដីព្រៃរបស់យើង ប្រជាពលរដ្ឋចំនួន ៧០ ភាគរយនឹងត្រូវបាត់ផុតទៅ ដូច្នេះមានតែប្រជាពលរដ្ឋចំនួន ៣០ ភាគរយប៉ុណ្ណោះ ដែលនឹងរស់នៅតទៅទៀត ។ កាលពីក្នុងរបបប៉ុល ពត យើងដាច់ពោះស្លាប់ភ្លាមៗ ប៉ុន្តែយើងអាចរក្សាព្រៃរបស់យើងបាន ។ នៅក្នុងរបបប្រជាធិបតេយ្យ គឺគេទុកឱ្យយើងរស់នៅយ៉ាងលំបាកវេទនាក្នុងរយៈពេលដ៏យូរមុននឹងស្លាប់ ។ អំពើហឹង្សានឹងកើតមានពីព្រោះយើងមិនចង់ស្លាប់ទេ"* ។

ស្ត្រីចំណាស់ម្នាក់បាននិយាយថា :

*"លោកនាយករដ្ឋមន្ត្រីបានលក់ដីឱ្យក្រុមហ៊ុន យើងមិនបានលក់ដីនោះទេ ។ ក្នុងចំណោមពួកយើង គ្មានអ្នកណាម្នាក់បានផ្តិតមេដៃលើឯកសារទាំងនោះឡើយ ។ សូមលោកមេត្តាជួយរៀបចំឱ្យយើងបានជួបពិភាក្សាជាមួយលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ផង ។"*

ការដែលអ្នកស្រុកអាចចូលទៅរកអនុផលព្រៃឈើពីក្នុងព្រៃជុំជិតនោះបាន ជួយឱ្យពួកគេអាចទ្រទ្រង់ជីវភាពរស់នៅបានជាច្រើនជំនាន់មកហើយ និង បានធានាដល់ការរស់រានមានជីវិតរបស់អ្នកស្រុក ជាពិសេសនៅក្នុងពេលមានគ្រោះរាំងស្ងួត និងការប្រមូលផលស្រូវបានតិចតួចស្តួចស្តើង ដែលបញ្ហានេះកើតមានជារឿយៗនៅក្នុងរយៈកាលប៉ុន្មានឆ្នាំ ថ្មីៗនេះ ។

អ្នកស្រុកវ័យក្មេងម្នាក់បាននិយាយថា :

*"យើងមានការព្រួយបារម្ភអំពីការបាត់បង់ដី និងព្រៃ ព្រោះអ្វីៗត្រូវបានលួសឆាយអស់ ហើយយើងពឹងផ្អែកទាំងស្រុងលើព្រៃឈើ ។ "*

ស្ត្រីចំណាស់ម្នាក់បាននិយាយបន្ថែមទៀតថា :

*"គ្រួសាររបស់ខ្ញុំទាំងអស់គឺពឹងផ្អែកលើព្រៃឈើ និង អនុផលព្រៃឈើ ដែលយើងប្រមូលមកពីទីនោះ ហើយការធ្វើបែបនេះមានជាច្រើនជំនាន់មកហើយ ។ "*

អ្នកស្រុកម្នាក់ទៀតបាននិយាយថា :

*"ឥឡូវនេះដល់រដូវប្រមូលផលផ្លែឈើនៅក្នុងព្រៃហើយ តែយើងមិនអាចចូលបាន ព្រោះក្រុមហ៊ុនបានបិទមិនឱ្យចូលតំបន់នោះ ។ មិនតែប៉ុណ្ណោះក្រុមហ៊ុនបានបិទផ្លូវទឹក និងអូរ ដែលធ្វើឱ្យប្រឡាយ ដែលយើងធ្លាប់តែប្រើប្រាស់ទឹកត្រូវរីងស្ងួត ។ នៅរដូវវស្សា នៅពេលដែលទីវាលទំនាបទទួលរងនូវទឹកជំនន់ យើងតែងតែនាំយកសត្វពាហណៈរបស់យើងទៅកាន់ទីដែលខ្ពស់នៅក្នុងព្រៃ ។ ឥឡូវនេះ តើសត្វពាហណៈរបស់យើងអាចរស់បានយ៉ាងដូចម្តេចទៅ?*

ប្រជាពលរដ្ឋបាននិយាយថា ពួកគេធ្វើការនៅលើវាលស្រែរយៈពេលពីបួនទៅប្រាំមួយខែ ហើយនៅសល់ពីនេះពួកគេប្រមូលអនុផលព្រៃឈើពេញមួយឆ្នាំ។ ប្រជាពលរដ្ឋមានការព្រួយបារម្ភអំពីវាលស្មៅសំរាប់សត្វពាហណៈ ហើយជាពិសេសទៅទៀតនោះគឺទីទួលខ្ពស់ ត្រូវគេឈូសឆាយអស់ហើយ។ ពួកគេបាននិយាយថា គេមិនមានជំនាញ ដើម្បីស្វែងរកការងារធ្វើនៅទីក្រុងភ្នំពេញទេ ហើយនៅពេលដែលពួកគេលើកយកបញ្ហានេះប្រាប់អាជ្ញាធរមូលដ្ឋាន អាជ្ញាធរមូលដ្ឋានបានប្រាប់ពួកគេថា លោកយករដ្ឋមន្ត្រីបានលក់ដីនេះ ទៅឱ្យក្រុមហ៊ុនអស់ហើយៗ អាជ្ញាធរមូលដ្ឋានមិនអាចធ្វើអ្វីបានទេ។ ពួកគេបានធ្វើការតវ៉ាជាច្រើនលើកមកហើយ ប៉ុន្តែមិនមានអាជ្ញារថ្នាក់លើណាចេញមុខដោះស្រាយបញ្ហារបស់ពួកគេឡើយ។

ការបាត់បង់របរចិញ្ចឹមជីវិតនេះ បង្ហាញថាមិនមានការរក្សាចំពោះការផ្តល់ការងារ ជានិរន្តភាព ឬ ការផ្តល់ទម្រង់ផ្សេង នៃការបង្កើតប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋភាគច្រើន។ កន្លងមក សកម្មភាព របស់ក្រុមហ៊ុនបាននាំឱ្យមានការបង្កើតការងារដែលមានប្រាក់ចំណូលទាប មានរយៈពេលខ្លី នៅការដ្ឋានបណ្តុះកូនដើមប្រេងខ្យល់ និងនៅកន្លែងកាប់ឆ្ការព្រៃ។ កម្មករភាគច្រើនត្រូវបានក្រុមហ៊ុនជួលមកពីខាងក្រៅ ពីព្រោះប្រជាពលរដ្ឋមូលដ្ឋានមិនចង់រួមចំណែកក្នុងការកាប់បំផ្លាញព្រៃឈើ ដែលពួកគេពឹងអាស្រ័យទេ។ ទោះបីជានៅក្នុងភូមិខ្សាច់ល្អិតមានប្រជាពលរដ្ឋចំនួន៣២០ គ្រួសាររស់នៅក៏ដោយក៏មានអ្នកស្រុកចំនួនតែប្រាំនាក់ប៉ុណ្ណោះ ដែលធ្វើការឱ្យក្រុមហ៊ុននេះ នៅកំឡុងពេលទស្សនកិច្ចរបស់យើង។

អ្នកស្រុកម្នាក់បាននិយាយថា រយៈពេលពីរថ្ងៃមុនការធ្វើទស្សនកិច្ចរបស់យើង កាលពីថ្ងៃទី ១៤ ខែកុម្ភៈ តំណាងក្រុម ហ៊ុនភាពីម៉ិច រួមមានអ្នកស្រីសុភាព ប្រធានរដ្ឋបាលព្រៃឈើ និងមន្ត្រីរដ្ឋាភិបាលជាច្រើនរូបទៀតបានចុះមកការដ្ឋានរបស់ក្រុមហ៊ុននៅតំបន់កាច់កង ដើម្បីចែកចាយអង្ករ និងសារ៉ុងដល់កម្មករ។ គេក៏បានអញ្ជើញប្រជាពលរដ្ឋឱ្យចូលរួមផងដែរ ប៉ុន្តែមានប្រជាពលរដ្ឋតែបួននាក់ប៉ុណ្ណោះមកពីភូមិខ្សាច់ល្អិត និង ១០នាក់មកពីភូមិផ្សេងទៀត នៅក្នុងឃុំនោះបានចូលរួម។

ស្ត្រីម្នាក់ដែលបានលក់ទំនិញឱ្យកម្មករនៅលើដីសម្បទាន បានបរិយាយអំពីស្ថានភាពការងារដូច្នេះថា : *"រៀងរាល់ព្រឹក កម្មករចូលធ្វើការចាប់ពីម៉ោង ៦:៣០ នាទី រហូតដល់ម៉ោង ១០:៣០ នាទី ហើយនៅពេលរសៀល ចាប់ពីម៉ោង ១៣:៣០ នាទី រហូតដល់ម៉ោង ១៧:០០។ កម្មករទាំងនោះ ក៏ធ្វើការនៅថ្ងៃចុងសប្តាហ៍ដែរ គឺក្នុងមួយខែពួកគេឈប់សំរាកតែបីថ្ងៃប៉ុណ្ណោះ។ ពួកគេទទួលបានប្រាក់ឈ្នួល ៥.០០០ រៀល ក្នុងមួយថ្ងៃ។*

ជំរុំដែលតាំងនៅលើដីសម្បទាន រួមមានផ្ទះខ្ទមដំរយឹករយាកដែលធ្វើពីដើមឫស្សី និង តង់កៅស៊ូ ដោយគ្មាន គ្រឿងសំភារៈដើម្បីរក្សាអានាម័យទេ។ នៅក្នុងពេលធ្វើទស្សនកិច្ចនោះ កម្មករភាគច្រើនមិនមាន វត្តមាននៅ ទីនោះទេ ដោយនៅពេលនោះកម្មករទើបតែបានទទួលប្រាក់ឈ្នួល ហើយបានធ្វើដំណើរត្រឡប់ទៅ លំនៅដ្ឋានរៀងខ្លួន។ ក្រុមហ៊ុនមិនបានផ្តល់មុង និងសេវាថែទាំសុខភាព នៅការដ្ឋានរបស់ខ្លួនទេ។ ចំពោះកម្មករ ដែលមានជម្ងឺមិនអាចធ្វើការបានត្រូវបានក្រុមហ៊ុនបញ្ឈប់ប្រាក់ឈ្នួល។ ស្ត្រីម្នាក់ដែលធ្វើការនៅទីនោះ បាននិយាយថា នៅពេលដែលគាត់កំពុងធ្វើការកាប់ឈើនៅក្នុងព្រៃ ស្រាប់តែមានបន្លារដ៏ធំមួយបាន ចាក់ទម្លុះស្បែកជើងផ្ទាត់របស់គាត់ ហើយធ្វើឱ្យរបួសបាតជើងរបស់គាត់យ៉ាងធ្ងន់ធ្ងរ។ គាត់មិនអាចធ្វើការឱ្យក្រុមហ៊ុនអស់រយៈពេលដ៏យូរ ហើយក្រុមហ៊ុនបានផ្តាច់ប្រាក់ឈ្នួលរបស់គាត់ភ្លាម១បន្ទាប់ពីរងរបួស។ ឥឡូវនេះ គាត់គ្មាននៅ សេសសល់ លុយកាក់អ្វី ដើម្បីធ្វើដំណើរទៅផ្ទះសម្បែងគាត់បានឡើយ។ គ្រួសារមួយដែលបើកហាងតូចមួយនៅ ក្នុងជំរុំនោះ បានបង្ហាញប្រាប់អ្នកធ្វើទស្សនកិច្ច អំពីថ្នាំពេទ្យគ្រប់ប្រភេទដែលគេបានដាក់នៅក្នុងថង់ប្លាស្ទិកមួយ ដែលភាគ ច្រើនគឺជាថ្នាំបំបាត់ការឈឺចាប់ ថ្នាំការពារជម្ងឺគ្រុនចាញ់ និងថ្នាំរាគរូស។ ក្នុងករណីដែលមានជម្ងឺ កម្មករត្រូវតែ ទិញឱសថនេះ ហើយដែលមានតែឱសថនេះប៉ុណ្ណោះសំរាប់ពួកគេ។

នៅពាក់កណ្តាលខែមីនា ក្រុមហ៊ុនបានបញ្ឈប់សកម្មភាពភ្លាម១ បានដកបុគ្គលិករបស់ខ្លួន និងដកយក សម្ភារៈទាំងអស់ចេញ ហើយទុកតែកងរាជអាវុធហត្ថចំនួនប្រាំមួយនាក់នៅទីនោះ ដើម្បីយាមកាមកន្លែង បណ្តុះកូនឈើ។ គេមិនបានដឹងអំពីគោលបំណង និងសកម្មភាពសំរាប់ថ្ងៃអានាគតរបស់ក្រុមហ៊ុននេះនៅឡើយ ទេ។

## ៥. កង្វល់របស់ប្រជាពលរដ្ឋ នៅខេត្តកំពង់ឆ្នាំង

ការប្រជុំលើកទីពីរ ធ្វើឡើងជាមួយតំណាងសហគមន៍ និង សកម្មជនព្រៃឈើនានា ដែលត្រូវបានរៀបចំ ធ្វើនៅជិតទីតាំងក្រុមហ៊ុនស្ថិតនៅក្នុងភូមិវាលស្បូវ ឃុំតាំងក្រសាំង ស្រុកទឹកផុស ក្នុងខេត្តកំពង់ឆ្នាំង។ គេបាន និយាយថា មានការគាបសង្កត់ពីសំណាក់អាជ្ញាធរមូលដ្ឋាន ទៅលើប្រជាពលរដ្ឋមូលដ្ឋាន ឱ្យទទួលយកដីសម្បទាន និងផលប៉ះពាល់របស់ ក្រុមហ៊ុនទៅលើប្រជាពលរដ្ឋមូលដ្ឋាន។ ពួកគេនិយាយថា ប្រជាពលរដ្ឋមិនបានទទួលការ ណែនាំប្រាប់អំពីដីសម្បទាន ហើយក៏មិនឃើញលិខិតស្នាមអ្វីដែរ មិនតែប៉ុណ្ណោះ ពួកគេបានទទួលការគំរាមកំហែង ជាបន្តបន្ទាប់រហូតមក ហើយគេបានប្រាប់ថា បើអ្នកណាម្នាក់ប្រឆាំងនឹងការវិនិយោគនៅក្នុងតំបន់នេះ នឹងត្រូវ ចាប់ខ្លួន។

នៅពេលមិនយូរប៉ុន្មាន បន្ទាប់ពីការធ្វើទស្សនកិច្ចរបស់ព្រះមហាក្សត្រព្រះនរោត្តមសីហមុនី ទៅខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៤ លោកអភិបាលខេត្តបានជួបជាមួយប្រជាពលរដ្ឋ នៅភូមិវាលស្បូវ ស្នើសុំឱ្យប្រជាពលរដ្ឋបញ្ឈប់ការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន ។ បើតាមតំណាងសហគមន៍ ដែលមានវត្តមាននាពេលនោះ បញ្ជាក់ថា លោកអភិបាលខេត្តបាននិយាយថា ៖

*"នាយករដ្ឋមន្ត្រីបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ដូច្នេះហើយបងប្អូនមិនអាចធ្វើអ្វីបានទេ ម្យ៉ាងព្រៃនេះជាព្រៃរិចរិល និងមិនមានប្រយោជន៍ ដូច្នេះទុកឱ្យក្រុមហ៊ុនកាប់ដើមឈើទាំងនេះចោលទៅ ដើម្បីអភិវឌ្ឍន៍តំបន់នេះ"* ។

កាលពីមុន លោកអភិបាលខេត្តបានពិភាក្សាអំពីការបង្កើតសហគមន៍ព្រៃឈើជាមួយអ្នកស្រុក ។

ស្ត្រីម្នាក់ដែលមាអាយុ៣៨ ឆ្នាំ មានកូន ១២ នាក់ ដែលបានដាំស្រូវនៅក្នុងតំបន់ដីសម្បទាន បានរាយការណ៍ថា ៖

*"នៅពេលដែលខ្ញុំធ្វើការតវ៉ាពីដីសម្បទាន នគរបាលមូលដ្ឋានបានកោះអញ្ជើញប្តីខ្ញុំ ទៅធ្វើការសាកសួរ ហើយមន្ត្រីទាំងនោះបានធ្វើការគំរាមកំហែងគាត់ ។ ដីស្រែរបស់ខ្ញុំនឹងត្រូវលោមព័ទ្ធទៅដោយដើមប្រេងខ្យល់ ។ ដើមប្រេងខ្យល់ស្រូបយកទឹកអស់ពីលើផ្ទៃដី ហើយវានឹងធ្វើឱ្យខូចដល់ដីស្រែរបស់ខ្ញុំទៀតផង"* ។

ពួកគេបាននិយាយថា ផ្ទៃដីចំនួន ១.៨០០ ហិកតា ត្រូវបានគេធ្វើការឈូសឆាយនៅតំបន់វាលស្បូវ វាលស្រែទាំងនោះត្រូវបានគេធ្វើការឈូសឆាយ ហើយផ្លូវរទេះគោ ទៅកាន់វាលស្រែនោះត្រូវបានគេដាំដើមប្រេងខ្យល់ ។

កម្មករម្នាក់បាននិយាយរៀបរាប់អំពីលក្ខខណ្ឌការងារនៅទីតាំងក្រុមហ៊ុននេះ នៅក្នុងភូមិថ្លុងពពក ថា

*"ដើម្បីបានប្រាក់ឈ្នួលអតិបរមា ៦០០០ រៀល ក្នុងមួយថ្ងៃ កម្មករត្រូវកាប់ដីឱ្យបាន ៦០ រណ្តៅ ហើយរណ្តៅនីមួយៗ មានទំហំ(ជម្រៅ ៤០ សង្ទីម៉ែត្រ និងទទឹង ៤០ សង្ទីម៉ែត្រ) ។ វាជាការងារមួយដែលលំបាកខ្លាំងណាស់ ដោយសារតែធាតុអាកាសក្តៅ និង ដីរឹងហើយកម្មករភាគច្រើនអាចកាប់ដីបានតែ ៣០ រណ្តៅប៉ុណ្ណោះ ដូច្នេះពួកគេធ្វើការពេញមួយថ្ងៃ រកបានប្រាក់តែ ៣០០០ រៀល តែប៉ុណ្ណោះ"* ។

កម្មករម្នាក់ទៀតនិយាយថា គាត់មកធ្វើការនៅចំការនេះ ពីព្រោះគាត់ធ្វើស្រូវមិនបានផល ហើយគ្មានលុយកាក់។ បើតាមកម្មករម្នាក់បានឱ្យដឹងថា មានកម្មករប្រមាណជា ៨០០ នាក់ ធ្វើការនៅការដ្ឋាននេះ។ លក្ខខណ្ឌការងារមានលក្ខណៈស្រដៀងគ្នានៅខេត្តពោធិសាត់ ហើយដូចជានៅខេត្តពោធិសាត់ បើកម្មករណាឈឺត្រូវតែចេញលុយព្យាបាលខ្លួនដោយខ្លួនឯង ហើយត្រូវគេកាត់ប្រាក់ឈ្នួលទៀតផង។ ព្រោះតែលក្ខខណ្ឌការងារលំបាកខ្លាំងពេក ទើបមានកម្មករប្រមាណជា ៣០០ នាក់ បានឈប់ធ្វើការឱ្យក្រុមហ៊ុន ហើយបានចាកចេញនៅថ្ងៃធ្វើទស្សនកិច្ចនេះ។

នៅការដ្ឋានឈូសឆាយដី និងបណ្តុះកូនដើមប្រេងខ្យល់ មន្ត្រីរបស់យើងបានជួបជាមួយប្រធានគ្រប់គ្រងគំរោង ដែលគាត់និយាយថា គាត់មកពីខេត្តហៃណាន នៃសាធារណរដ្ឋប្រជាមានិតចិន។ គាត់មិនអាចរៀបរាប់បានល្អិតល្អន់អំពីទំហំ និង ប្រតិបត្តិការពង្រីកដីសម្បទាននេះឡើយ ហើយគាត់បានគូសបញ្ជាក់ថា គាត់ទទួលខុសត្រូវតែលើការងារដាំដុះតែប៉ុណ្ណោះ។ គាត់បាននិយាយថា ការងារនេះត្រូវការកម្មករច្រើន នៅក្នុងដំណាក់កាលនៃការចាប់ផ្តើមដំបូង ប៉ុន្តែក្រោយពីបានធ្វើការដាំដុះរួច គេត្រូវការកម្មករចំនួនតិចតួចតែប៉ុណ្ណោះ។

ការដ្ឋាន និង ទីតាំងនេះត្រូវបានកងសន្តិសុខយាមកាម។ នៅក្នុងពេលធ្វើទស្សនកិច្ច យើងឃើញមានកម្មករជាច្រើនក្រុមកំពុងដាំកូនដើមប្រេងខ្យល់ នៅលើផ្ទៃដីដែលបានរៀបចំរាស់រំលីងសំរាប់ដាំកូនឈើទាំងនោះ អ្នកខ្លះទៀតកំពុងស្រោចទឹកកូនឈើនៅថ្នាលផ្សេងពីនេះ ឬ កំពុងកាប់រណ្តៅ ។

## ឃុំក្រាំងស្គា

តំណាងសហគមន៍ខ្លះបានធ្វើដំណើរពីភូមិរបស់ខ្លួន ដែលស្ថិតនៅជិតឃុំក្រាំងស្គា ដើម្បីទៅចូលរួមប្រជុំ។ គ្រាន់តែប្រជាពលរដ្ឋ នៅឃុំក្រាំងស្គាតែមួយប៉ុណ្ណោះ មានចំនួនប្រមាណជា ៤០០០ គ្រួសារ ដែលមានប្រជាពលរដ្ឋសរុបប្រមាណជា ១២.០០០ នាក់ អ្នកទាំងនោះប្រកបរបរចិញ្ចឹមជីវិតជាចម្បង គឺការប្រមូលអនុផលព្រៃឈើ។ ពួកគេនិយាយថា កន្លងមកមិនមានការអភិវឌ្ឍន៍ណាមួយនៅឃុំក្រាំងស្គានេះទេ ហើយជាការប្រសើរ ត្រូវតែរក្សាព្រៃឈើទាំងនេះ ពីការអភិវឌ្ឍន៍របៀបក្រុមហ៊ុននេះ។ នៅពេលដែលក្រុមហ៊ុន ភាពីម៉ិចបានព្យាយាមបង្កើតជំរុំនៅក្នុងឃុំក្រាំងស្គា ក្នុងខែមករា ឆ្នាំ ២០០៥ ដោយបាននាំចូលនូវកម្មករចំនួន៣០០ នាក់នោះ ពួកគេបាននិយាយថាអ្នកស្រុករាប់ រយនាក់បានធ្វើការតវ៉ា ហើយក្រុមហ៊ុនត្រូវបានបង្ខំចិត្តចាកចេញ ពីទីនោះ។

ទោះបីជាមានការគំរាមកំហែងយ៉ាងណាក៏ដោយ តំណាងសហគមន៍បាននិយាយថា ការតវ៉ានៅតែធ្វើជាបន្ត : *"ប្រជាពលរដ្ឋយល់ដឹងពីសិទ្ធិរបស់ខ្លួន ដែលច្បាប់បានកំណត់ ។ ប្រជាលរដ្ឋច្រើនជាង ១០.០០០ នាក់ នៅឃុំក្រាំងស្គា ពឹងពាក់លើព្រៃឈើ ហើយក្រុមហ៊ុនអាចផ្តល់ការងារបានតែសំរាប់មនុស្សមួយរយនាក់តែប៉ុណ្ណោះ"* ។

រយៈពេលពីរថ្ងៃបន្ទាប់ពីការធ្វើទស្សនកិច្ច គឺនៅថ្ងៃទី ១៨ ខែ កុម្ភៈ អភិបាលស្រុកទឹកផុស បានកោះអញ្ជើញអនុប្រធានឃុំក្រាំងស្គា និងសមាជិកក្រុមប្រឹក្សាឃុំម្នាក់ ហើយបានប្រាប់ឱ្យពួកគេឈប់ធ្វើការតវ៉ា បើពុំនោះទេ ពួកគេនឹងត្រូវបាត់បង់តួនាទី ។ កាលពីថ្ងៃទី ២៨ ខែកុម្ភៈ លោកអភិបាលស្រុកបានកោះអញ្ជើញតំណាង សហគមន៍ចំនួនប្រាំបីរូប ពីឃុំក្រាំងស្គា មកប្រជុំជាមួយអភិបាលស្រុករងទីមួយ និងទីពីរ និងប្រធានមន្ទីរស្រុកមួយរូប ។ គេបានប្រាប់ឱ្យឈប់ធ្វើការផ្សព្វផ្សាយព័ត៌មាន ហើយថាការធ្វើបែបនេះគឺខុសច្បាប់ ហើយថាពួកគេគ្មានសិទ្ធិនិងការទទួលខុសត្រូវ ដើម្បីពន្យល់ពីច្បាប់ព្រៃឈើ ច្បាប់ភូមិបាល និងច្បាប់ដទៃទៀត ដល់អ្នកស្រុកឡើយ ហើយថានេះគឺជាបុព្វសិទ្ធិតែមួយគត់របស់អាជ្ញាធរមានសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធ ។ គេបានប្រាប់ឱ្យបញ្ឈប់រាល់សកម្មភាពទាំងអស់ ដែលអាចនាំឱ្យរាំងស្ទះដល់ការអភិវឌ្ឍន៍របស់ក្រុមហ៊ុននៅក្នុងស្រុក ។

ការប្រឈមមុខគ្នា រវាងប្រជាពលរដ្ឋមូលដ្ឋាន នៅក្នុងឃុំក្រាំងស្គា និងក្រុមហ៊ុន និងមន្ត្រីរដ្ឋបាលព្រៃឈើបានកើតមានឡើង កាលពីថ្ងៃទី១១ ទី១៥ និង ថ្ងៃទី១៧ ខែ មីនា នៅពេលដែលមន្ត្រីទាំងនោះបានចុះទៅធ្វើការវាស់វែងព្រំប្រទល់ដីសម្បទាន ។ ដោយសារតែការប្រឈមមុខនឹងអ្នកស្រុក ទើបពួកគេបានបោះបង់ចោលការខិតខំប្រឹងប្រែងនេះ ។ ប្រជាពលរដ្ឋមូលដ្ឋានបានដាក់នូវសំណើជាច្រើន ដោយរួមមានទាំងការសុំបង្កើតសហគមន៍ព្រៃឈើ ដែលមន្ត្រីរដ្ឋបាលព្រៃឈើបានយល់ព្រមបញ្ជូនទៅថ្នាក់ខេត្ត ។

កាលពីថ្ងៃទី២៣ ខែមីនា ក្រុមហ៊ុនបានបញ្ឈប់សកម្មភាពទាំងស្រុង នៅក្នុងខេត្តកំពង់ឆ្នាំង ។ មន្ត្រីក្រុមហ៊ុនបានរុះរើចោលសំណង់នានាពីការដ្ឋានរបស់ខ្លួន ហើយបានចាកចេញពីតំបន់ក្រុមហ៊ុន ដោយនាំយកទៅជាមួយនូវសម្ភារៈទាំងអស់របស់ខ្លួន ។ មានសេចក្តីរាយការណ៍ថា ក្រុមហ៊ុនបានទុកនគរបាលពីរនាក់នៅការដ្ឋានដើម្បីថែទាំកូនឈើ ។ ដូចគ្នានឹងស្ថានភាពនៅខេត្តពោធិសាត់ដែរ តើមានអ្វីនឹងកើតឡើងនៅពេលអានាគតនោះមិនទាន់ ដឹងនៅឡើយទេ ។

## ៦. លិខិតពីលោកនាយករដ្ឋមន្ត្រី

កាលពី ថ្ងៃទី ៤ ខែ កុម្ភៈ សហគមន៍នៅស្រុកក្រគរ បរិបូរណ៍ និងទឹកផុស បានផ្ញើលិខិតថ្វាយព្រះមហាក្សត្រសីហមុនី ទូលថ្វាយអំពីស្ថានភាពរបស់ពួកគេ និងស្វែងរកការជួយអន្តរាគមន៍ពីព្រះអង្គ។ ព្រះមហាក្សត្របានបញ្ជូនលិខិតនោះទៅលោកនាយករដ្ឋមន្ត្រី ហើយបានបញ្ជូនទៅឱ្យសហគមន៍ទាំងនោះ នូវការឆ្លើយតបរបស់លោកនាយករដ្ឋមន្ត្រី ដែលសហគមន៍បានទទួលលិខិតនោះកាលពីថ្ងៃទី ៥ ខែ មីនា កន្លងមកនេះ។

នៅក្នុងលិខិតរបស់លោក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ លោកនាយករដ្ឋមន្ត្រីបាននិយាយថា មានតែជនមួយក្រុមតូចដែលតាំងខ្លួនថាជាតំណាងប្រជាពលរដ្ឋ ជាអ្នកទទួលខុសត្រូវចំពោះការតវ៉ានេះ។ ពួកគេបានធ្វើការផ្សព្វផ្សាយព័ត៌មានបំភ្លើស ហើយថាប្រជាពលរដ្ឋបានផ្តិតមេដៃលើពាក្យបណ្តឹង ដើម្បីសុំជំនួយពីកាកបាតក្រហម ឬ ពីព្រះមហាក្សត្រប៉ុណ្ណោះ ចំណែកការវាយប្រហារដោយគ្រាប់បែកវិញ គឺមានបំណង " បំពងសំលេងឃោសនា " របស់ពួកគេ ការតវ៉ានោះបំរើផលប្រយោជន៍របស់គណៈបក្សប្រឆាំង ដើម្បីទំលាក់កំហុសលើរដ្ឋាភិបាល និងបង្កឱ្យមានភាពវឹកវរ ក្នុងសង្គមតែប៉ុណ្ណោះ"។

លោកបាននិយាយថា អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានគាំទ្រដល់ការវិនិយោគទុនរបស់ក្រុមហ៊ុនដោយសារដីមួយភាគធំគឺជាដីខ្សាច់ គ្មានជីជាតិ ហើយគ្មានទឹកគ្រប់គ្រាន់សំរាប់ធ្វើដំណាំកសិកម្ម មានតែដើមឈើមួយចំនួនដូចជា ដើមប្រេងខ្យល់ និងដើមអាកាស្យាប៉ុណ្ណោះដែលអាចដុះលូតលាស់បានឆាប់រហ័ស។ អនុផលសំខាន់ ដែលបានមកពីព្រៃនោះគឺអុសដុត និងផ្លែឈើផ្សេងៗ ដែលគេអាចប្រមូលបានតែម្តងគត់ ក្នុងមួយឆ្នាំៗ ហើយអាចរកចំណូលបានយ៉ាងច្រើនបំផុត ២០.០០០ ទៅ ៣០.០០០ រៀល ប៉ុណ្ណោះ រីឯក្រុមហ៊ុនវិញ អាចផ្តល់ការងារឱ្យប្រជាពលរដ្ឋបាន ២.៥០០ នាក់ ក្នុងខេត្តនីមួយៗ ហើយកម្មករម្នាក់ៗអាចទទួលបានប្រាក់ឈ្នួលប្រចាំខែ ១៥០.០០០ រៀល និងអង្ករចំនួន ២៥ គីឡូក្រាម។ លោកបាននិយាយបន្តទៀតថា ការកាប់រាន និងការឈូសឆាយដី គឺធ្វើតែចំពោះដីណាដែលទំនេរ គ្របដណ្តប់ដោយកម្ពោចព្រៃ និងឈើតូចៗដែលគ្មានតំលៃ ហើយក្រុមហ៊ុនមិនបានចូលរុករានទន្ទ្រានដីប្រជាពលរដ្ឋឡើយ។

លិខិតនេះបានបន្តទៀតថា ការវិនិយោគនៅក្នុងក្រុមហ៊ុនភាពីម៉ិច បាននាំមកនូវបច្ចេកវិជ្ជាទំនើបខាងវិទ្យាសាស្ត្រ ចូលមកក្នុងទឹកដីនៃប្រទេសកម្ពុជា ជាពិសេសគឺបច្ចេកវិជ្ជាក្នុងការបណ្តុះកូនឈើ ដែលពីដើមមកយើងធ្លាប់បានឃើញតែនៅកន្លែងពិសោធន៍ នៃបណ្តាប្រទេសអភិវឌ្ឍន៍ "។ សម្បទានមានគោលដៅអភិវឌ្ឍន៍តំបន់ព្រៃរិចរិលតាមរយៈការដាំដើមឈើដែលដុះលូតលាស់ ដើម្បីផលិតវត្ថុធាតុដើម សំរាប់ឧស្សាហកម្មផលិតក្រដាស។

នេះគឺជាព្រឹត្តិការណ៍ដ៏ថ្មីស្រឡាងមួយ សំរាប់ព្រះរាជាណាចក្រកម្ពុជា ”។ ការធ្វើវិនិយោគប្រកបដោយ ជោគជ័យ គឺជាការរួមចំណែកដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៅប្រទេសកម្ពុជា។ មន្ត្រីរដ្ឋាភិបាល និងអ្នកជំនាញការជាច្រើន នឹងធ្វើទស្សនកិច្ច ដើម្បីផ្សព្វផ្សាយនូវការយល់ដឹងអំពីការពិត និង សារៈសំខាន់នៃការវិនិយោគ។ ពួកគេទាំងនោះ ក៏នឹងបន្តស្រាវជ្រាវរកអ្នកផ្តើមគំនិត និងអ្នកដែលទទួលខុសត្រូវចំពោះការវាយប្រហារដោយគ្រាប់បែកដៃ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ដើម្បីនាំខ្លួនជននោះទៅតុលាការវិនិច្ឆ័យទោសតាមផ្លូវច្បាប់។ ពួកគេនឹងធ្វើការសិក្សា ដើម្បីកំណត់ទំហំដីរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីធ្វើការដកដីនោះ ចេញពីដីសម្បទាន ហើយពួកគេយល់ព្រម រក្សាទុកព្រៃមួយចំនួនដែលមានគុណភាពខ្ពស់ សំរាប់ប្រជាពលរដ្ឋមូលដ្ឋាន ដោយចាត់ទុកសំណើររបស់ប្រជាពល រដ្ឋថាជាការសមហេតុផល។ ពួកគេក៏បានស្នើសុំឱ្យក្រុមហ៊ុនគោរពតាមការសន្យារបស់ខ្លួន ថានឹងអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវ សាលារៀន មន្ទីរពេទ្យ ត្រពាំង អណ្តូងទឹក ។ល។ ស្របតាមយុទ្ធសាស្ត្រឈ្នះឈ្នះ ដើម្បី កសាងជំនឿទុកចិត្ត ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការណ៍ល្អ ដើម្បីភាពចំរើនរុងរឿង និងផល ប្រយោជន៍ទាំងអស់គ្នា។

គេមិនបានធ្វើការធានាចំពោះប្រជាពលរដ្ឋមូលដ្ឋាន នាំឱ្យមានការព្រួយបារម្ភថា លោកនាយករដ្ឋមន្ត្រី មិនបានដឹងសព្វគ្រប់អំពីបញ្ហានេះទេ។ ពួកគេនិយាយថាព្រៃឈើទាំងនេះ ជាព្រៃដែលជ្រុះស្លឹកនៅរដូវប្រាំង ហើយ លាស់សន្លឹកឡើងវិញនៅរដូវវស្សា ហើយថាសកម្មភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងអ្នករស់នៅជិតព្រៃនេះ បានផុសចេញពីបេះដូងរបស់ពួកគេ មិនបំរើឱ្យគណៈបក្សនយោបាយ និងដើម្បីតែភាពត្រឹមត្រូវនៅក្នុងសហគមន៍ របស់គេប៉ុណ្ណោះ ចំពោះការផ្ទុះគ្រាប់បែក គឺមិនបានបង្ករឡើងដោយប្រជាពលរដ្ឋនោះទេ ព្រោះពួកគេមិនមាន អាវុធ និងជាតិផ្ទុះ ហើយព្រៃឈើបានផ្តល់ឱ្យពួកគេនូវឈើដ៏មានតំលៃ ដែលគ្រួសារនីមួយៗអាចរកប្រាក់ចំណូល បានពី ១០.០០០ ទៅ ៥០.០០០ រៀល ក្នុងមួយថ្ងៃ ពីការប្រមូលអនុផលព្រៃឈើ ទៅតាមរដូវនិងចំនួនសមាជិក គ្រួសារ ហើយប្រជាពលរដ្ឋអាចចិញ្ចឹមគោរាប់ពាន់ក្បាលនៅក្នុងព្រៃនោះទៀតផង។ ពួកគេនិយាយថាក្នុងព្រៃនោះ មានសត្វព្រៃច្រើនប្រភេទ រួមទាំងសត្វព្រៃកម្រ ដែលបង្ករគ្រោះថ្នាក់មួយចំនួន ហើយកន្លងមកមិនមានអាជ្ញាធរ មានសមត្ថកិច្ច ឬស្ថាប័នជំនាញណាមួយបានកំណត់ព្រំប្រទល់ព្រៃសំរាប់ប្រជាពលរដ្ឋ ឬ ដីសមស្របសំរាប់ សហគមន៍ និង ដីសំរាប់សត្វពាហណៈឡើយ។

## ៧. លំដាប់ពេលវេលានៃព្រឹត្តិការណ៍ ចាប់ពីខែមករា ឆ្នាំ១៩៩៧ ដល់ ខែ មីនា ឆ្នាំ ២០០៥

### ឆ្នាំ ១៩៩៧ ដល់ ២០០១

- ក្រុមហ៊ុនភាពីម៉ិចបានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩៧ ទៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ស្នើសុំដីសម្បទានទំហំ ៣១៥.០០០ ហិកតា នៅក្នុងខេត្តកំពង់ឆ្នាំង និង ខេត្តពោធិសាត់ និងដីសម្បទានមួយកន្លែងទៀតទំហំ ១៦.១០០ ហិកតា នៅក្នុងខេត្តកោះកុង ដើម្បីដាំដើមឈើ និងបង្កើតរោងចក្រផលិតក្រដាស ។
- តាមរយៈលិខិត ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ក្រសួងកសិកម្ម បានជូនដំណឹងទៅនាយករដ្ឋមន្ត្រីទីមួយ និងនាយករដ្ឋមន្ត្រីទីពីរ ថាក្រសួងបានយល់ព្រមជាគោលការណ៍ ផ្តល់ជូនផ្ទៃដីទំហំ ៣៣០.០០០ ហិកតា តាមសំណើររបស់ក្រុមហ៊ុនភាពីម៉ិច ហើយថាដីដែលត្រូវផ្តល់ជាជំហ៊ានដំបូងមានទំហំ ៤០.០០០ ហិកតា នៅក្នុងខេត្ត កំពង់ឆ្នាំង និងខេត្តពោធិសាត់ ដើម្បីអោយក្រុមហ៊ុនចាប់ផ្តើមសាកល្បងការងារសិន ។
- មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង បានផ្ញើលិខិតមួយច្បាប់ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៧ ទៅក្រសួងកសិកម្ម ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតំលៃរបស់ខ្លួន អំពីដីសម្បទានដែលបានស្នើសុំ នៅក្នុងខេត្តកំពង់ឆ្នាំង ។ ការវាយតំលៃបានបង្ហាញថា ដីទំហំ ១៤០.០០០ ហិកតា អាចផ្តល់ឱ្យបាន ប៉ុន្តែតំបន់នោះរួមមានព្រៃចំរុះដែលកំពុងលូតលាស់ឡើងវិញ ហើយអាចទាញយកផលបានដោយអនុវត្តតាមបែបបទបច្ចេកទេសក្នុងការកាប់ឈើ ។  ដីដែលមានទំហំ ១៤០.០០០ ហិកតា មិនបានរាប់បញ្ចូលនូវដីព្រៃពាក់ព័ន្ធការតាំងស្ថានីយបណ្តុះកូនឈើនៅក្នុងស្រុកសាមគ្គីមានជ័យ ដែលគ្របដណ្តប់លើផ្ទៃដី ២១.០៦៥ ហិកតា

---

[៥] ឧបសម្ព័ន្ធនេះ ត្រូវបានរៀបចំឡើង កាលពីខែមីនា ឆ្នាំ ២០០៥ បន្ទាប់ពីការចេញផ្សាយ កាលពីខែវិច្ឆិកា ឆ្នាំ២០០៤ នូវរបាយការណ៍ស្តីពីសម្បទាន ដីគោលដៅសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ។ ទោះបីជាក្រុមហ៊ុនភាពីម៉ិច ត្រូវបានគេលើកមកនិយាយក៏ដោយ នៅពេលកំពុងសិក្សាស្រាវជ្រាវដើម្បីធ្វើរបាយការណ៍នេះ ក្រុមហ៊ុននេះមិនមានសកម្មភាពទេ ។ ក្រុមហ៊ុននេះបានចាប់ផ្តើមធ្វើសកម្មភាពរបស់ខ្លួន មួយសប្តាហ៍ មុនការចេញផ្សាយរបាយការណ៍នេះ ។

[៦] លោក ឡាវ ម៉េង ឃីន ក៏ជាប្រធានក្រុមហ៊ុន អ៊ូជីសាន អិល អេស គ្រុប ចំកាត់ ដែលកាលពីខែសីហា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានជំហ៊ានដំបូងចំនួន ១០.០០០ ហិកតា សំរាប់ធ្វើចំការស្រល់ ក្នុងទំហំដីសម្បទានសរុបចំនួន ១៩៩.៩៩៩ ហិកតា នៅក្នុងខេត្តមណ្ឌលគីរី ។ ក្រុមហ៊ុនភាពីម៉ិច និងក្រុមអ៊ូជីសាន មានទីស្នាក់ការតែមួយជាមួយគ្នា នៅរាជធានីភ្នំពេញ ។

[៧] សេចក្តីអធិប្បាយពិស្តារមានតាមលំដាប់នៃព្រឹត្តិការណ៍ជាហូរហែរនៅក្នុងរបាយការណ៍នេះ ។

[៨] មន្ត្រីការិយាល័យឧត្តមស្នងការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR/Cambodia) បានទៅទស្សនកិច្ចនៅដីសម្បទានមួយកន្លែង ដែលមានទំហំ ៣.០០០ ហិកតា ដែលគ្រប់ក្រងដោយក្រុមហ៊ុនឈ្មោះរតនៈវិសាល ស្ថិតនៅក្នុងដីសម្បទានរបស់ក្រុមហ៊ុនភាពីម៉ិច ក្នុងខេត្តពោធិសាត់ ដែលក្រសួងកសិកម្មបានផ្តល់ឱ្យក្នុងឆ្នាំ១៩៩៩ ដែលក្នុងនោះមានផ្ទៃដីចំនួន ៨០០ ហិកតា ត្រូវបានធ្វើការកាប់ឆ្ការព្រៃរួចហើយៗបានដាំដើមស្វាយចន្ទី ។

ដីព្រៃដែលតាំងជាគប់ឧស និង កូនឈើ នៅក្នុងស្រុកទឹកផុស ដែលមានផ្ទៃដី ៧.០០០ ហិកតា និងដីព្រៃ វិចរិលមួយចំនួន ដែលអ្នកស្រុកបានប្រើប្រាស់ដើម្បីធ្វើស្រែមានផ្ទៃដី ៦.៣៨៤ ហិកតា។

- លោកអភិបាលខេត្តកំពង់ឆ្នាំង បានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៧ ទៅលោកនាយករដ្ឋមន្ត្រីទីពីរ ដោយបានឯកភាពតាមគោលការណ៍របស់រដ្ឋាភិបាល និងក្រសួងកសិកម្ម ក្នុងការផ្តល់ដីសម្បទានទៅអោយក្រុមហ៊ុនភាពីម៉ិច ដោយបញ្ជាក់ថាដីទំហំ ១៤៤.៨០០ ហិកតា អាចផ្តល់សំរាប់វិនិយោគដាំឈើ និងបង្កើតរោងចក្រផលិតក្រដាស។ ដីស្ថានីយបណ្តុះកូនឈើ នៅក្នុងស្រុកសាមគ្គីមានជ័យ និងព្រៃគប់ឧស និងកូនឈើ នៅក្នុងស្រុកទឹកផុស គួរបង្វែរឱ្យក្រុមហ៊ុនភាពីម៉ិច។ ផ្ទៃដីសរុបដែលត្រូវផ្តល់ឱ្យគួរតែមានផ្ទៃដីសរុបចំនួន ១៧៦.០៦៥ ហិកតា។
- មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ខេត្តពោធិសាត់ បានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី១៣ ខែ សីហា ឆ្នាំ១៩៩៧ ទៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតំលៃរបស់ខ្លួន អំពីដីសម្បទានដែលបានស្នើសុំ។ របាយការណ៍បានបញ្ជាក់ថា ដីទំហំ ១៣៨.៤៦៣ ហិកតា អាចផ្តល់ឱ្យបាន។ ដីនេះមិនរួមបញ្ចូលដីចំការព្រៃម៉ៃសាក់ នៅក្នុងស្រុកសំពៅមាស ដែលមានផ្ទៃដី ២០ ហិកតា ចំការព្រៃអាកាស្យា នៅក្នុងស្រុកសំពៅមាស ដែលមានផ្ទៃដី ៤០ ហិកតា ដីព្រៃដាំនៅក្នុងស្រុកក្រគរ ដែលមានទំហំ ១៧៧ ហិកតា ដីក្រុមហ៊ុនអភិវឌ្ឍន៍រតនៈវិសាល នៅក្នុងស្រុកក្រគរទំហំ ៣.០០០ ហិកតា និងដីព្រៃបំរុងទុកដែលមានទំហំ ១០០ ហិកតា។
- គណៈរដ្ឋមន្ត្រីបានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ទៅក្រសួងកសិកម្ម ដោយបញ្ជាក់ថារដ្ឋាភិបាលបានសំរេចផ្តល់ដីទំហំ ១៧៦.០៦៥ ហិកតា ក្នុងខេត្តកំពង់ឆ្នាំង និង ដីទំហំ ១៣៨.៩៦៣ ហិកតា ក្នុងខេត្តពោធិសាត់ ទៅឱ្យក្រុមហ៊ុនភាពីម៉ិច ដើម្បីដាំដើមឈើ និងបង្កើតរោងចក្រផលិតក្រដាស។
- កាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០០០ កិច្ចសន្យាពីរត្រូវបានចុះហត្ថលេខា រវាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រុមហ៊ុនភាពីម៉ិច ដែលតំណាងដោយលោក ឡាវ ម៉េងឃីន ។ ដីសម្បទានមានទំហំ ១៧៦.០៦៥ ហិកតា ស្ថិតនៅក្នុងស្រុកចំនួនបី (ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ និងស្រុកបរិបូរណ៍) ក្នុងខេត្តកំពងឆ្នាំង និងដីទំហំ ១៣៨.៩៦៣ ហិកតា នៅក្នុងស្រុកចំនួនបី (ស្រុកក្រវ៉ាន់ ស្រុកក្រគរ និងស្រុកសំពៅមាស) ក្នុងខេត្តពោធិសាត់។

## ៨. បន្ទាប់ពីការចុះកិច្ចសន្យា

- ថ្ងៃទី៧ ខែមីនា ឆ្នាំ២000 លោក ចាន់ តុង អ៊ីវ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសរសេរលិខិតមួយច្បាប់ទៅលោកអភិបាលខេត្តពោធិសាត់ ស្នើសុំឱ្យលោកសហការជាមួយ ក្រុមហ៊ុន ភាពីម៉ិច ដែលបើតាមក្រសួងកសិកម្ម ក្រុមហ៊ុននេះនឹងអនុវត្តលើផ្ទៃដីចំនួន ៥.000 ហិកតា នៅក្នុង ឆ្នាំទីមួយ នៃប្រតិបត្តិការក្នុងខេត្តពោធិសាត់។ នៅថ្ងៃជាមួយគ្នានោះដែរ ក្រសួងបានចេញលិខិតមួយច្បាប់ អនុញ្ញាតឱ្យបុគ្គលិកចំនួនបួននាក់ ចុះទៅខេត្តពោធិសាត់ នៅថ្ងៃទី៩ ខែ មីនា ឆ្នាំ២000 ដើម្បីសិក្សាអំពី កម្មសិទ្ធិដី និងព្រំប្រទល់ដីសម្បទាន។ លោកអភិបាលខេត្តពោធិសាត់បានសរសេរលិខិតទៅប្រធានមន្ទីរ កសិកម្មខេត្តពោធិសាត់ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលស្រុកក្រគរ ស្នើសុំ សហការជាមួយតំណាងក្រសួងកសិកម្ម និងក្រុមហ៊ុនភាពីម៉ិច។
- ប្រធានមន្ទីរកសិកម្មខេត្តពោធិសាត់ បានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២000 តាមរយៈលោក អភិបាលខេត្តពោធិសាត់ ទៅក្រសួងកសិកម្ម ដើម្បីជូនដំណឹងអំពីលទ្ធផលដែលបានរកឃើញ ទាក់ទងនឹងកម្ម សិទ្ធិដីរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងព្រំប្រទល់ដីសម្បទានរបស់ក្រុមហ៊ុនភាពីម៉ិចក្នុងខេត្តពោធិសាត់។ លិខិត នេះបានកំណត់ផ្ទៃដីទំហំ ៦.៨00 ហិកតា ស្ថិតនៅក្នុងឃុំពីរ គឺ ឃុំអន្សារចំបក់ និងឃុំក្បាលត្រាច ក្នុងស្រុក ក្រគរ។
- ក្រសួងកសិកម្ម បានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២000 ទៅនាយកក្រុមហ៊ុនភាពីម៉ិច ដោយ បញ្ជាក់ថា " ប្រជាពលរដ្ឋមូលដ្ឋានមិនមានកម្មសិទ្ធិដីធ្លី "លើដីសម្បទាន ដែលបានជ្រើសរើសផ្តល់ដល់ក្រុមហ៊ុន ទេ ដូច្នេះហើយក្រសួងកសិកម្មអនុញ្ញាតឱ្យក្រុមហ៊ុន ចាប់ផ្តើមធ្វើការនៅក្នុងតំបន់នោះ តាមលក្ខខណ្ឌដែល មានចែងនៅក្នុងកិច្ចព្រមព្រៀងវិនិយោគ។ ក្រសួងកសិកម្មក៏បានយល់ព្រមតាមសំណើររបស់ក្រុមហ៊ុន ដើម្បី ចាប់ផ្តើមកិច្ច ប្រតិបត្តិការរបស់ខ្លួននៅក្នុងឆ្នាំទីមួយ លើផ្ទៃដី ៦.៨00 ហិកតា។
- ក្រុមហ៊ុនភាពីម៉ិច បានធ្វើសំណើរមួយ ចុះថ្ងៃទី២0 ខែមេសា ឆ្នាំ២000 ទៅលោកអភិបាលខេត្តពោធិសាត់ តាមរយៈអភិបាលស្រុកក្រគរ ដើម្បីបើកស្ថានីយមួយនៅក្នុងឃុំអន្សារចំបក់ ជាកន្លែងដែលត្រូវដាក់គ្រឿង ចក្រសំរាប់ប្រើប្រាស់ និងសាងសង់ឃ្លាំង និងទីជំរកផ្សេងទៀត។
- នៅពេលដែលក្រុមហ៊ុនចាប់ផ្តើមឈូសឆាយ ប្រជាពលរដ្ឋមូលដ្ឋានធ្វើពាក្យបណ្តឹងទៅអង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរខេត្ត និងអាជ្ញាធរជាតិ។ ពួកគេក៏បានបិទផ្លូវ និងធ្វើបាតុកម្មប្រឆាំងនឹងក្រុមហ៊ុន។ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២000 ប្រជាពលរដ្ឋមកពីឃុំអន្សារចំបក់ បានដាក់ពាក្យបណ្តឹងទៅអង្គការក្រៅរដ្ឋាភិបាលខាង សិទ្ធិមនុស្ស អង្គការលីកាដូ ដោយធ្វើការតវ៉ាអំពីការការឈូសឆាយដីទំហំ ៦.៨00 ហិកតា។ ក្នុងខែកក្កដា ឆ្នាំ

២០០០ បុគ្គលិកអង្គការលីកាដូ បានទៅទស្សនកិច្ចនៅតំបន់ ដែលមានផលប៉ះពាល់ ហើយបានធ្វើសម្ភាសន៍ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ ។

- ក្រុមហ៊ុន China Corporation of State Farms Group ជាដៃគូររបស់ក្រុមហ៊ុនភាពីម៉ិច ក្នុងការធ្វើចំការដើមប្រេងខ្យល់ និងការសាងសង់រោងចក្រផលិតក្រដាស ។ កិច្ចសហប្រតិបត្តិការវិនិយោគនេះ ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០០ ដោយមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ រវាងក្រុមហ៊ុនភាពីម៉ិច និងប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនChina Corporation of State Farms Group នៅក្នុងការជួបជុំគ្នាមួយ ដែល ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ។
- ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០១ ប្រជាពលរដ្ឋក្នុងឃុំអន្សារចំបក់ បានផ្ញើពាក្យបណ្តឹងមួយ ទៅអង្គការ NGO Forum និងវិទ្យុអាស៊ីសេរី ។
- ថ្ងៃទី៧ ខែមីនា ឆ្នាំ២០០១ មានការប្រជុំមួយ ធ្វើឡើងនៅមន្ទីរឃុំអន្សារចំបក់ ដោយមានការចូលរួមពីមន្ត្រីមកពី មន្ទីរបរិស្ថានខេត្ត នាយកដ្ឋានរុក្ខាប្រម៉ាញ់ សាលាខេត្ត អភិបាលរងស្រុកក្រគរ ប្រធានឃុំអន្សារចំបក់ ប្រធានភូមិនៃភូមិដែលទទួលរងផលប៉ះពាល់ចំនួនប្រាំមួយភូមិ សមាជិកប្រាំមួយរូប នៃគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងប្រជាពលរដ្ឋមួយចំនួនទៀត ។ ប្រជាពលរដ្ឋបានធ្វើការតវ៉ាប្រឆាំងនឹងគំរោងរបស់ ក្រុមហ៊ុនភាពីម៉ិចនៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយបានលើកឡើងនូវគំនិតបង្កើតឱ្យមានសហគមន៍ព្រៃឈើ ។ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (Legal Aid of Cambodia) អង្គការអាដហុក និងអង្គការ Global Witness បានដឹកនាំការស៊ើបអង្កេតរួមគ្នាមួយ នៅក្នុងឃុំអន្សរចំបក់ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ ។
- ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០១ មានដំណើរទស្សនកិច្ចសិក្សាទៅកាន់ឃុំនេះ ដែលដឹកនាំដោយសម្ព័ន្ធភាពសំរបសំរួលការគាំទ្រសង្គមស៊ីវិលខេត្តពោធិសាត់ (Pursat Civil Society Advocacy Coordination Alliance) ដោយមានការចូលរួមពីតំណាងអង្គការផ្នែកបរិស្ថាន អង្គការជំនួយផ្នែកច្បាប់ អង្គការសិទ្ធិមនុស្ស និងអង្គការក្រៅរដ្ឋាភិបាលផ្នែកអភិវឌ្ឍន៍ មកពីទីក្រុងភ្នំពេញ ។ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ មានការប្រជុំមួយ ធ្វើឡើងរវាងអង្គការក្រៅរដ្ឋាភិបាលទាំងនេះ មន្ត្រីនានានៃរដ្ឋាភិបាល និងតំណាងប្រជាពលរដ្ឋជាច្រើនរូបទៀត ។
- នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០១ និងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ ប្រជាពលរដ្ឋមកពីឃុំអន្សារចំបក់ បានដាក់ពាក្យបណ្តឹងទៅលោកនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ព្រះអង្គម្ចាស់នរោត្តមរណឫទ្ធ ប្រឆាំងនឹងគំរោងរបស់ក្រុមហ៊ុនភាពីម៉ិច ។ បណ្តឹងដដែលនេះដែរ បានផ្ញើទៅក្រសួងកសិកម្ម ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍អាស៊ី ។ បណ្តឹងស្រដៀងគ្នានេះ បានប្តឹង

អំពីដីសម្បទាន នៅក្នុងខេត្តកំពង់ឆ្នាំង ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០១ ដោយប្រជាពលរដ្ឋនៅឃុំក្រាំងស្គា ស្រុកទឹកផុស និងថ្ងៃទី២៩ ខែកក្កដា មកពីស្រុកបរិបូណ៌។

- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) បានផ្ញើលិខិតមួយច្បាប់ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០១ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធទៅស្ថានទូតបារាំង ស្ថានទូតជប៉ុន ស្ថានទូតអូស្ត្រាលី ស្ថានទូតអាមេរិក និងស្ថានទូតអង់គ្លេស ទៅអង្គការស្បៀងអាហារនិងកសិកម្ម (FAO) និងទៅអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងទីភ្នាក់ ងារ អ.ស.ប នានា ដើម្បីសុំឱ្យធ្វើអន្តរាគមន៍។ ឯកសារពាក់ព័ន្ធក៏ត្រូវបានផ្ញើទៅខាងសារព័ត៌មាន និងក្រសួង បរិស្ថាន ក្រសួងកសិកម្ម និងនាយកដ្ឋានរុក្ខាប្រមាញ់ផងដែរ។
- ពាក្យបណ្តឹងអំពីសកម្មភាពរបស់ក្រុមហ៊ុន នៅក្នុងខេត្តពោធិសាត់ ត្រូវបានក្រសួងយុត្តិធម៌ បញ្ជូនទៅប្រធានតុលាការខេត្តពោធិសាត់ នៅមុនការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងខែកុម្ភៈ ឆ្នាំ២០០២។ ចៅក្រមបានបញ្ជូនពាក្យបណ្តឹងនោះទៅអតីតគណៈកម្មាធិការដោះស្រាយជំលោះដីធ្លីខេត្ត ដែលបច្ចុប្បន្ននេះបានដូរឈ្មោះមកជា គណៈកម្មការសុរិយោដី។

## ចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៥

- ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៤ លោកអគ្គនាយករង នៃក្រសួងកសិកម្ម ដោយមានការយល់ព្រមពីរដ្ឋមន្ត្រី បានឯកភាពលើពាក្យសុំរបស់ក្រុមហ៊ុនភាពីម៉ិច ដើម្បីឈូសឆាយផ្ទៃដីចំនួន ១០.០០០ ហិកតា ក្នុងខេត្តពោធិសាត់ និង ១០.០០០ ហិកតា ក្នុងខេត្តកំពង់ឆ្នាំង ដោយបានអនុញ្ញាតឱ្យក្រុមហ៊ុននាំចូលនូវគ្រឿងចក្រ និងអ្នកបច្ចេកទេសចំនួន៤០ នាក់មកធ្វើការនៅក្នុងតំបន់ដីសម្បទាន។ ក្រសួងបានតម្រូវឱ្យក្រុមហ៊ុនធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីកំណត់តំបន់ដែលត្រូវធ្វើការឈូសឆាយ។ លោក អ៊ុង សាមី អភិបាលខេត្តពោធិសាត់ បានបង្កើតក្រុមការងារមួយ ជាមួយមន្ត្រីថ្នាក់មូលដ្ឋាន រួមមានមន្ត្រីមកពីផ្នែករដ្ឋបាលព្រៃឈើ នគរបាល កងរាជអាវុធហត្ថ មន្ត្រីផ្នែកបរិស្ថាន គណៈកម្មាធិការសុរិយោដី និងមេឃុំ ដើម្បីធ្វើការជាមួយមន្ត្រីនានា មកពីក្រសួងកសិកម្ម ដើម្បីធ្វើការវាយតំលៃ និងកំណត់ផ្ទៃដី។
- មិនយូរប៉ុន្មាន ក្រុមហ៊ុនបាននាំចូលគ្រឿងចក្រ និងកម្មករប្រមាណជា១០០ នាក់មកកាន់តំបន់សម្បទាន ដែលគេហៅថា កាច់កង ក្នុងឃុំអន្សារចំបក់ ដែលស្ថិតនៅចំងាយប្រហែលជាប្រាំមួយគីឡូម៉ែត្រ ពីផ្លូវជាតិ។
- នៅក្នុងសប្តាហ៍ទីពីរ នៃខែវិច្ឆិកា ឆ្នាំ២០០៤ ក្រុមហ៊ុនបានចាប់ផ្តើមធ្វើការឈូសឆាយដី នៅក្នុងឃុំថ្លុងពពក ដែលស្ថិតនៅជាប់ព្រំប្រទល់ភូមិវាលស្បូវ ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង នៅក្នុងតំបន់ព្រៃ ដែលប្រជាពលរដ្ឋមូលដ្ឋានទាមទារប្រើប្រាស់សំរាប់សហគមន៍ព្រៃឈើ។ ក្រុមហ៊ុននេះបាននាំចូលនូវម៉ាស៊ីន

ឈូសដីចំនួនពីរគ្រឿង និងកម្មករជាង១០០ នាក់ ដែលកម្មករភាគច្រើនមកពីខេត្តពោធិសាត់ និងខេត្តកំពង់ស្ពឺ ដើម្បីធ្វើការកាប់រំលំដើមឈើ និងកាប់ឆ្ការព្រៃដោយដៃ ។ ប្រជាពលរដ្ឋមូលដ្ឋានបានធ្វើការ រារាំងក្រុមហ៊ុន ដែលព្យាយាមបើកប្រតិបត្តិការពង្រីកដីទៅក្នុងស្រុកបរិបូណ៌ ដែលស្ថិតនៅជិតទីនោះ ។

- ប្រជាពលរដ្ឋនៅក្នុងខេត្តទាំងពីរនេះ បានធ្វើការតវ៉ាចំពោះសកម្មភាពរបស់ក្រុមហ៊ុន កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៤ ។ នៅក្នុងពេលប៉ុន្មានម៉ោងដំបូង នៃថ្ងៃទី១៣ ខែវិច្ឆិកា មានព្រឹត្តិការណ៍គប់គ្រាប់បែក មួយគ្រាប់ទៅលើអ្នកស្រុកដែលធ្វើការតវ៉ានិងដែលកំពុងដេក នៅក្នុងបរិវេណវិហារឥស្លាមមួយក្នុងភូមិ បណ្តាលឱ្យអ្នកតវ៉ាប្រាំបីនាក់ត្រូវរង របួស ។ លោកតំណាងពិសេសបានសំដែងនូវការសោកស្តាយ ចំពោះការវាយប្រហារនេះ ហើយបានអំពាវនាវ សុំឱ្យធ្វើការស៊ើបអង្កេតលើករណីនេះអោយបានហ្មត់ចត់ ។
- ថ្ងៃទី១៣ ខែវិច្ឆិកា អភិបាលស្រុកក្រគរ និងតំណាងមួយរូប នៃអភិបាលខេត្តពោធិសាត់បានធ្វើដំណើរមកដល់ ដោយមានលិខិតមួយច្បាប់ពីលោកអភិបាលខេត្ត ។ លិខិតនោះបានស្នើឱ្យប្រជាពលរដ្ឋទាំងអស់វិលត្រឡប់ទៅ កាន់លំនៅដ្ឋាន ដើម្បីមើលថែទាំស្រូវស្រែរបស់ខ្លួន ហើយសុំឱ្យទុកតែតំណាងម្នាក់ៗពីភូមិនីមួយៗ ស្នាក់នៅទីនោះ ដើម្បីពិភាក្សាជាមួយអាជ្ញាធរអំពីសំណើរពីររបស់ខ្លួនគឺ ការមិនប្រគល់ដីឱ្យក្រុមហ៊ុនភាពីម៉ិច និងការសុំឱ្យក្រុមហ៊ុនដកគ្រឿងចក្រទាំងអស់ចេញពីតំបន់នេះ ។ លិខិត បានបញ្ជាក់ថែមទៀតថា អាជ្ញាធរ ត្រូវការពេលប្រាំពីរថ្ងៃ ដើម្បីធ្វើការឆ្លើយតបទៅនឹងសំណើរបស់ប្រជាពលរដ្ឋ ពីព្រោះក្រុមហ៊ុនបានទទួលការ អនុញ្ញាតពីរដ្ឋាភិបាល ដើម្បីប្រតិបត្តិការនៅក្នុងតំបន់នេះ ។ នៅក្នុងអំឡុងពេលប្រាំពីរថ្ងៃនេះ ក្រុមហ៊ុនត្រូវ ផ្អាកសកម្មភាព ហើយប្រជាពលរដ្ឋអាចមានសិទ្ធិបញ្ឈប់សកម្មភាពរបស់ ក្រុមហ៊ុនបាន ប្រសិនបើឃើញថា ក្រុមហ៊ុននៅតែបន្តធ្វើការកាប់ឈូសឆាយតទៅទៀត ។
- តំណាងអភិបាលខេត្តបានប្រកាសផ្តល់រង្វាន់ជាទឹកប្រាក់ចំនួន ១.០០០ ដុល្លារ ដល់ជនណាដែលអាចផ្តល់ព័ត៌ មានអំពីអ្នកគប់គ្រាប់ដៃ និងដល់ជនណាដែលមានបំណងផ្តល់ព័ត៌មានដល់អាជ្ញាធរអំពីបញ្ហានេះ និងផ្តល់រង្វាន់ ជាទឹកប្រាក់ចំនួន ២.០០០ ដុល្លារ ដល់ជនណាដែលបានគប់គ្រាប់បែក ហើយចេញមកសារភាព ។ អាស្រ័យ ដោយមិនឃើញមានដំណោះស្រាយ ទើបប្រជាពលរដ្ឋបានបន្តធ្វើការតវ៉ាតទៅទៀត ។
- ថ្ងៃទី១៤ ខែវិច្ឆិកា មានប្រជាពលរដ្ឋជាច្រើននាក់មកពីតំបន់ដែលទទួលរងផលប៉ះពាល់ ព្រមទាំង ប្រជាពលរដ្ឋមកពីខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។ ប្រជាពលរដ្ឋ ត្រូវគេរាយការណ៍ថា មានចំនួនកើន ឡើងដល់ជាង ១.០០០ នាក់ ។ កងរាជអាវុធហត្ថ និងនគរបាលប្រដាប់អាវុធ ត្រូវបានគេដាក់ពង្រាយនៅតាម កែងផ្លូវ និងនៅតាមផ្លូវដីឆ្លោះទៅកាន់ភូមិនានា ដើម្បីរារាំងប្រជាពលរដ្ឋកុំឱ្យមកចូលរួមតវ៉ា ។ ប្រជាពលរដ្ឋ ដែលបានធ្វើដំណើរមកដល់ផ្លូវជាតិលេខប្រាំរួចហើយត្រូវបានគេបញ្ឈប់ និងបំបែកហ្វូង ។ ប្រជាពលរដ្ឋ

មួយចំនួនដែលមានបំណងធ្វើដំណើរទៅសាលាខេត្តពោធិសាត់ ត្រូវបានគេឃាត់មិនឱ្យធ្វើដំណើរទៅមុនទៀត ។ ចរាចរនៅលើផ្លូវជាតិលេខ៥ត្រូវបានបិទ ។

- អាជ្ញាធរបានប្រកាសថាគណៈប្រតិភូថ្នាក់ជាតិមួយក្រុម ដែលមានសមាសភាពមន្ត្រីក្រសួងកសិកម្ម និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងតំណាងក្រុមហ៊ុននឹងមកជួបប្រជាពលរដ្ឋ នៅចំណុចព្រំប្រទល់រវាងខេត្តទាំងពីរនៅថ្ងៃបន្ទាប់ ។ ប្រជាពលរដ្ឋបានស្នើសុំឱ្យអាជ្ញាធរធ្វើជាលាយលក្ខអក្សរ ហើយឯកសារនោះត្រូវផ្តិតមេដៃដោយតំណាងអាជ្ញាធរខេត្ត និងតំណាងប្រជាពលរដ្ឋចំនួនប្រាំរូប ។[៥] នៅថ្ងៃទី១៥ វិច្ឆិកា ឆ្នាំ ២០០៤ មានតែអភិបាលរង មកពីខេត្តចំនួនពីរតែប៉ុណ្ណោះ បានមកជួបប្រជាពលរដ្ឋ ។ មិនមានដំណោះស្រាយណាមួយឡើយ ។
- ក្នុងឃុំក្បាលត្រាច ស្រុកក្រគរ នគរបាលបានអញ្ជើញប្រធានភូមិមួយចំនួន ទៅសាលាឃុំដើម្បីធ្វើការសាកសួរ ។ ការប្រជុំនោះត្រូវបានគេរាយការណ៍ថា នគរបាលបានចោទប្រកាន់ប្រធានភូមិថាជាអ្នកញុះញង់ប្រជាពលរដ្ឋឱ្យធ្វើការតវ៉ា ។ ប្រជាពលរដ្ឋបានសំរេចចិត្តវិលត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញ ។
- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ ប្រជាពលរដ្ឋធ្វើបាតុកម្មម្តងទៀត ។ នៅវេលាម៉ោងប្រមាណជា១ រសៀល ប្រជាពលរដ្ឋបានចាប់ផ្តើមធ្វើការប្រមូលផ្តុំគ្នា នៅលើចិញ្ចើមផ្លូវជាតិលេខ៥ ដែលចំងាយប្រមាណជាមួយគីឡូម៉ែត្រពីច្រកផ្លូវចូលទៅការដ្ឋានរបស់ក្រុមហ៊ុនភាពីម៉ិច នៅជិតកន្លែងដែលមានការវាយប្រហារដោយគ្រាប់បែកដៃ ។ តំណាងសហគមន៍បានស្រែកតវ៉ា ដោយមានការចាក់សារចុះសារឡើងនូវសន្ទរកថា របស់លោកនាយករដ្ឋមន្ត្រីដែលបានថ្លែង កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ នៅក្នុងវេទិកាជីផ្លីថ្នាក់ជាតិ នៅទីក្រុងភ្នំពេញ ។ នៅម៉ោងប្រហែលជា ២:៣០ រសៀល មានប្រជាពលរដ្ឋបានចាប់ផ្តើមធ្វើដំណើរជាក្បួនឆ្ពោះទៅកាន់ការដ្ឋាននោះ ។ នគរបាលស្លៀកពាក់ឯកសណ្ឋាន និងប្រដាប់ដោយអាវុធប្រហែលជា២០ នាក់ ឈរនៅផ្លូវច្រកចូល ។ ដោយមានការភ័យខ្លាចមានការប៉ះទង្គិចគ្នា រវាងពួកបាតុករ និងអ្នកស្រុកដែលធ្វើការឱ្យក្រុមហ៊ុននាំឱ្យអ្នកតវ៉ាបោះបង់ចោលគំនិតនៃការតវ៉ានៅការដ្ឋានរបស់ក្រុមហ៊ុនវិញ ។ កងរាជអាវុធហត្ថ និងនគរបាលប្រដាប់អាវុធប្រហែលជា ២០ នាក់ ក៏បានដាក់របាំងរាំងផ្លូវជាតិ ត្រង់ចំណុចព្រំប្រទល់ខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំង ដើម្បីរារាំងប្រជាពលរដ្ឋ ពីខេត្តកំពង់ឆ្នាំង ដែលធ្វើដំណើរមកចូលរួមធ្វើបាតុកម្ម ។
- ផែនការរៀបចំពិធីបុណ្យមួយ នៅក្នុងសប្តាហ៍ទីពីរ នៃខែមករា ឆ្នាំ២០០៥ ក្នុងខេត្តពោធិសាត់ ដើម្បីបំបួសដើមឈើ ដោយមានការចូលរួមពីព្រះសង្ឃនិមន្តមកពីវត្តជាច្រើន ត្រូវបានធ្វើការរារាំងដោយ អាជ្ញាធរមូលដ្ឋាន ។ ព្រះសង្ឃគ្រប់វត្តនៅក្នុងស្រុក បានទទួលលិខិត ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០០៥ ពីព្រះគ្រូ

---

[៥] លោក អ៊ីហួត លោក ឡឹក ធួង លោក គុជ វេង អ្នកស្រី យិន ពេជ្រ និង លោក ជា ភ័ណ្ឌ

អនុគុណស្រុកក្រគរ និងមន្ទីរធម្មការនិងសាសនា ដោយបានធ្វើការហាមប្រាមព្រះសង្ឃទាំងអស់ មិនឱ្យចូលរួមក្នុងពិធីបុណ្យនេះ និងនៅក្នុងសកម្មភាពទាំងឡាយដែលទាក់ទងនឹងព្រៃឈើ ដោយបានចាត់ទុកថាជារឿង នយោបាយ ។

- បន្ទាប់មកសហគមន៍បានសំរេចចិត្តរៀបចំពិធីបុណ្យប្រពៃណីប្រចាំឆ្នាំ ដែលហៅថា "ពិធីបុណ្យឡើងអ្នកតា " នៅជើងភ្នំមួយ ក្នុងព្រៃស័ក្តសិទ្ធិ ស្ថិតនៅក្នុងស្រុកក្រគរ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥ ។ តាមប្រពៃណី មនុស្សចាស់ទុំ នៅក្នុងសហគមន៍ជាអ្នកសំរេចពីកាលបរិច្ឆេទ នៃពិធីបុណ្យនេះ ហើយបន្ទាប់មកត្រូវប្រកាសប្រាប់អ្នកភូមិ ។ នៅឆ្នាំនេះ តំណាងសហគមន៍ត្រូវសរសេរលិខិតទៅអភិបាលស្រុក ដើម្បីសុំការអនុញ្ញាត និងត្រូវជូនដំណឹងទៅប្រធានភូមិ និងមេឃុំផងដែរ ។ ពួកគេបាននិយាយថា នគរបាល មេឃុំ និងមន្ត្រីស្រុកមានវត្តមាននៅក្នុងពិធីបុណ្យនោះ ដើម្បីការពារសន្តិសុខដល់ប្រជាពលរដ្ឋ ។ ពិធីបុណ្យនេះចាប់ផ្តើមធ្វើពីម៉ោងប្រហែលជា ៩:៣០ ព្រឹក ដល់ម៉ោង ២:៣០ រសៀល ។ អ្នកស្រុកប្រមាណជា ១០០ នាក់ និងព្រះសង្ឃ ១១ អង្គ មកពីវត្តចំនួនបី បានចូលរួមក្នុងពិធីបុណ្យនេះ ។ នៅក្នុងពេលធ្វើពិធីបុណ្យនេះ អ្នកស្រុកបានយកស្បង់ និងទង់ធ្វើពីស្បង់ដាក់រុំលើដើមឈើនៅតំបន់ព្រៃអ្នកតា ។ ពិធីបុណ្យនេះបានប្រព្រឹត្តទៅដោយមិនមានឧប្បត្តិហេតុធ្ងន់ធ្ងរឡើយ ។ មន្ត្រីនៃការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅ កម្ពុជា (OHCHR/Cambodia) និងអង្គការក្រៅរដ្ឋាភិបាលមានវត្តមាននៅទីនោះ ដើម្បីតាមឃ្លាំមើលសភាពការណ៍ ។ លុះដល់ថ្ងៃបន្ទាប់មក នគរបាលបានស្រង់ឈ្មោះព្រះសង្ឃទាំងឡាយដែលនិមន្តពីវត្តមួយចំនួនមកចូលរួមក្នុងពិធីនេះ ។
- នៅក្នុងខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥ ប្រជាពលរដ្ឋប្រមាណជា៣០០ នាក់បានប្រមូលផ្តុំគ្នាក្នុងឃុំក្រាំងស្គា ដើម្បីធ្វើការតវ៉ា បន្ទាប់ពីក្រុមហ៊ុនបាននាំយកកម្មករប្រមាណជា ៣០០ នាក់ចូល ក្នុងតំបន់នេះ ដើម្បីបង្កើតជំរុំទីពីរ បន្ថែមលើជំរុំដែលស្ថិតនៅឃុំថ្លុងពពក ។ ក្រុមហ៊ុនបានដកកម្មករចេញវិញ ។ លុះពីរបីថ្ងៃក្រោយមក អ្នកស្រុកប្រមាណជា ៣០ នាក់បានធ្វើដំណើរទៅសាលាស្រុកទឹកផុស ដើម្បីជួបជាមួយអាជ្ញាធរស្រុក ដើម្បីស្នើសុំឱ្យក្រុមហ៊ុនបញ្ឈប់ប្រតិបត្តិការនៅក្នុងសហគមន៍របស់ខ្លួន ។
- ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ អ្នកស្រុកប្រមាណជា ៥០ នាក់មកពីឃុំអន្សារចំបក់ បានព្យាយាមបញ្ឈប់សកម្មភាពរបស់ក្រុមហ៊ុន ប៉ុន្តែត្រូវគេបំបែកហ្វូង នៅក្នុងខណៈដែលពួកគេកំពុងធ្វើដំណើរទៅកាន់ការដ្ឋាន ដោយកងរាជអាវុធហត្ថ និងនគរបាលដែលបានបិទផ្លូវទៅកាន់ការដ្ឋានក្រុមហ៊ុន ។
- ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ ប្រធានសហគមន៍បានទទួលលិខិតមួយច្បាប់ពីព្រះមហាក្សត្រនរោត្តម សីហមុនី ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៥ ។ លិខិតនោះ បានផ្ញើទៅប្រជាពលរដ្ឋស្រុកទឹកផុស ស្រុកបរិបូណ៌

និងស្រុកក្រគរ ដែលបានបញ្ជាក់ថាព្រះអង្គបានទទួលពាក្យបណ្តឹងរបស់ពួកគេ ចុះថ្ងៃទី៤ ខែកុម្ភៈ ហើយ មានព្រះបន្ទូលប្រាប់ប្រជាពលរដ្ឋថា ព្រះអង្គបានបញ្ជូនពាក្យបណ្តឹងនោះទៅលោកនាយករដ្ឋមន្ត្រីនៅថ្ងៃនោះ។

- ថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៥ សហគមន៍បានទទួលចំលើយជាលាយលក្ខអក្សរពីលោកនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៤ ខែកុម្ភៈ ដែលព្រះមហាក្សត្របានបញ្ជូនទៅឱ្យសហគមន៍។ អាជ្ញាធរមូលដ្ឋាន ត្រូវបានគេរាយការណ៍ថា ក៏បានទទួលលិខិតចំលងមួយច្បាប់ដែរ។ ប្រជាពលរដ្ឋយល់ថា លោកនាយករដ្ឋមន្ត្រីមិនបានទទួលព័ត៌មានគ្រប់គ្រាន់ទេ ហើយមិនបានយល់ពីស្ថានភាពរបស់ពួកគេទៀតផង។
- ការប្រឈមមុខគ្នារវាងប្រជាពលរដ្ឋមូលដ្ឋាន ក្នុងឃុំក្រាំងស្គា និងក្រុមហ៊ុន និងមន្ត្រីរដ្ឋបាលព្រៃឈើ បានកើតមាន កាលពីថ្ងៃទី១១ ទី១៥ និងទី១៧ ខែមីនា ឆ្នាំ២០០៥ នៅពេលដែលមន្ត្រីទាំងនោះ បានទៅកំណត់ព្រំប្រទល់ដីសម្បទាន។ មន្ត្រីទាំងនោះ ត្រូវចាកចេញពីទីនោះ បន្ទាប់ពីប្រជាពលរដ្ឋមូលដ្ឋានប្រមាណជា ១០០ នាក់ បានធ្វើការតវ៉ាអំពីសកម្មភាពរបស់ពួកគេ និងបានធ្វើការជេរប្រមាថដល់មន្ត្រីទាំងនោះ។ ប្រជាពលរដ្ឋមូលដ្ឋានបានធ្វើការទាមទារជាច្រើន ក្នុងនោះរួមមានការស្នើសុំបង្កើតសហគមន៍ព្រៃឈើផងដែរ ហើយដែលមន្ត្រីរដ្ឋបាលព្រៃឈើ បានយល់ព្រមបញ្ជូនសំណើនោះទៅថ្នាក់ខេត្ត។
- នៅពាក់កណ្តាលខែមីនា ក្រុមហ៊ុនបានបញ្ឈប់សកម្មភាពនៅក្នុងការដ្ឋានរបស់ខ្លួនក្នុងខេត្តពោធិសាត់ ដោយបានដកបុគ្គលិក និងគ្រឿងចក្ររបស់ខ្លួនចេញពីទីនោះ ហើយទុកតែកងរាជអាវុធហត្ថចំនួនប្រាំមួយនាក់ដើម្បីយាមកាមកន្លែងបណ្តុះកូនឈើ។
- ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៥ ក្រុមហ៊ុនបានបញ្ឈប់សកម្មភាពនៅក្នុងស្រុកទឹកផុស។ អ្នកបច្ចេកទេសជនជាតិចិនបានរុះរើចោលនូវសំណង់នានារបស់ខ្លួន ហើយបានចាកចេញពីការដ្ឋានរបស់ក្រុមហ៊ុននៅរសៀលថ្ងៃនោះ ដោយនាំយកទៅជាមួយនូវគ្រឿងសំភារៈទាំងអស់របស់ខ្លួន រួមមានរថយន្តធុនតូច រថយន្តដឹកទំនិញ ម៉ូទ័របូមទឹក និងម៉ាស៊ីនភ្លើងមួយគ្រឿង។ តាមប្រភពព័ត៌មានពីមន្ត្រីនគរបាលបានឱ្យដឹងថា ពួកគេបានរើទីតាំងពីទីនេះទៅកាន់ ដីសម្បទានរបស់ក្រុមហ៊ុនអ៊ូជីសាននៅក្នុងខេត្តមណ្ឌលគីរី ប៉ុន្តែព័ត៌មាននេះមិនទាន់បានបញ្ជាក់ថាច្បាស់លាស់នៅឡើយទេ។ នគរបាលពីរនាក់ ត្រូវគេរាយការណ៍ថា បានស្នាក់នៅក្នុងការដ្ឋានដើម្បីមើលការខុសត្រូវកន្លែងបណ្តុះកូនឈើ។

## ៩. ស្ថានភាពរបស់សកម្មជនព្រៃឈើ និងតំណាងសហគមន៍

### នៅក្នុងខេត្តពោធិសាត់

- ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ មេឃុំម្នាក់ ក្នុងស្រុកក្រគរ បានអញ្ជើញលោក អ៊ុំ ហួត មកផ្ទះរបស់គាត់ ដើម្បីប្រជុំ។ ប្រធាននគរបាល លោកប៊ុន វណ្ណា មន្ត្រីនគរបាលព្រហ្មទណ្ឌស្រុកពីររូប និងនគរបាលឃុំមួយរូប ក៏មានវត្តមាននៅទីនោះដែរ។ នគរបាលបានសួរចំលើយលោក អ៊ុំ ហួត អំពីកិរិតវប្បធម៌ ទំនាក់ទំនងខាងនយោបាយ និងសកម្មភាពរបស់គាត់ជាមួយអង្គការក្រៅរដ្ឋាភិបាល។ នគរបាលបានសួរគាត់ថា តើគាត់បានទទួលប្រាក់បៀវត្សពីអង្គការណា ហើយតើអង្គការណាដែលបានជួយឧបត្ថម្ភដល់ការតវ៉ានៅពេលថ្មីៗនេះ តើគាត់ជាសមាជិកនៃគណៈបក្សនយោបាយណា តើគាត់មានកូនប៉ុន្មាននាក់ ហើយកូនទាំងនោះរស់នៅឯណា។ ហេតុអ្វីបានជាគាត់មានទូរស័ព្ទដៃ ហើយតើគាត់ប្រកបរបររកស៊ីអ្វី ? តើគាត់មានដឹងថា អង្គការណាដែលបានជួលជនពាល ២០ នាក់ ហើយផ្តល់ប្រាក់បៀវត្សចំនួនពីរខែ ឱ្យជនទាំងនោះ ដើម្បីដុតបំផ្លាញការដ្ឋានរបស់ក្រុមហ៊ុន ហើយថាតើគាត់មានព័ត៌មានអំពីការវាយប្រហារដោយគ្រាប់បែកដៃឬទេ?
- ថ្ងៃដដែលនោះ មន្ត្រីស្រុកពីររូប បានទៅផ្ទះតំណាងសហគមន៍ម្នាក់ទៀត គឺលោក ឡឹក ធួង ដើម្បីប្រគល់ឱ្យគាត់វិញ នូវលិខិតដែលគាត់ និងលោក អ៊ុំ ហួត បានផ្ញើជូនអភិបាលស្រុក ដើម្បីសុំការអនុញ្ញាត ធ្វើបាតុកម្មនៅថ្ងៃទី៣០ ខែវិច្ឆិកា ។ មន្ត្រីទាំងនោះបានសុំឱ្យគាត់ផ្តិតមេដៃទទួលសំបុត្រ ដើម្បីបញ្ជាក់ថាគាត់បានទទួលសំបុត្រ និងការឆ្លើយតបពីអភិបាលស្រុកដែលបញ្ជាក់ថាលោកគ្មានសមត្ថកិច្ចផ្តល់ការអនុញ្ញាតនេះទេ ដោយសារ នេះគឺជាបុព្វសិទ្ធិរបស់ក្រសួងមហាផ្ទៃ។ លោកឡឹក ធួង បានផ្តិតមេដៃលើលិខិតនោះ។
- ថ្ងៃទី ៨ ខែធ្នូ កងរាជអាវុធហត្ថប្រាំនាក់ប្រដាប់ដោយអាវុធ ស្លៀកពាក់ស៊ីវិល បានមកផ្ទះរបស់លោក គុជ វេង ដែលជាតំណាងសហគមន៍ព្រៃឈើ ក្នុងឃុំក្បាលត្រាច ស្រុកក្រគរ។ ពួកគេបានថតរូបគាត់ និងសួរចំលើយគាត់អំពីការងាររបស់គាត់ ក្នុងការរៀបចំសហគមន៍ព្រៃឈើនៅក្នុងឃុំ។ កងរាជអាវុធហត្ថបានសាកសួរគាត់លំអិតអំពីអង្គការក្រៅរដ្ឋាភិបាល ជាពិសេសអង្គការលីកាដូ ដែលបានជួយគាំទ្រគាត់ និងសហគមន៍ព្រៃឈើ។ ពួកគេក៏បានសាកសួរគាត់អំពីគោលបំណងក្នុងការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន នៅក្នុងប៉ុន្មានខែខាងមុខ។ កងរាជអាវុធហត្ថបានចាកចេញពីផ្ទះគាត់ ប្រហែលជា៣០ នាទីក្រោយមក។
- ថ្ងៃទី ២៧ ខែ ធ្នូ លោក វ៉ែន ហ៊ុល ជាកសិករ និងជាអ្នកតវ៉ាម្នាក់ ត្រូវបានចាប់ខ្លួនពីផ្ទះរបស់គាត់ នៅភូមិសន្ទុង ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដោយកងរាជអាវុធហត្ថបួននាក់ ស្លៀកពាក់ស៊ីវិល បន្ទាប់ពីមានបណ្តឹងពីតំណាងក្រុមហ៊ុនម្នាក់។ កងរាជអាវុធហត្ថបានអញ្ជើញគាត់ទៅកំណាត់ដីរបស់គាត់ នៅ

ក្នុងតំបន់ដីសម្បទាន ហើយបានចាប់គាត់ នៅពេលដែលពួកគេបានឆ្លងផុតព្រំប្រទល់ខេត្ត ដោយបានបង្ហាញដីកាចាប់ខ្លួន ដែលចេញដោយតុលាការខេត្តពោធិសាត់ ។ គាត់ត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងមនុស្សឃាតលើមន្ត្រីជនជាតិចិនម្នាក់ ដែលធ្វើការឱ្យក្រុមហ៊ុន នៅក្នុងតំបន់កាច់កង់ ឃុំអន្សារចំបក់ កាលពីព្រឹកថ្ងៃទី ១២ ខែវិច្ឆិកា នៅពេលដែលលោក វ៉ែន ហ៊ុល ត្រូវគេរាយកាណ៍ថា បានជេរប្រមាថដល់ក្រុមហ៊ុនថា" ធ្វើអោយប្រទេសកម្ពុជាទៅជាប្រទេសខ្មោច" ហើយបានអះអាងប្រាប់អ្នកបច្ចេកទេសថា នឹងធ្វើឱ្យពួកគេចាកចេញពីទីនោះអោយបាន ។ លោក វ៉ែន ហ៊ុន ត្រូវបានគេនាំខ្លួនទៅសួរចម្លើយ នៅទីបញ្ជាការកងរាជអាវុធហត្ថស្រុក ហើយត្រូវបានគេឃុំខ្លួននៅទីនោះអស់មួយយប់ មុនពេលបញ្ជូនខ្លួនទៅតុលាការខេត្តពោធិសាត់ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០០៤ ហើយត្រូវបានចៅក្រមស៊ើបអង្កេតសំរេចឃុំខ្លួនគាត់រង់ចាំការស៊ើបអង្កេត ។ នៅទីបញ្ជាការកងរាជអាវុធហត្ថស្រុក កងរាជអាវុធហត្ថបានសាកសួរសំនួរបើកផ្លូវជាច្រើន អំពីការគប់គ្រាប់បែកដៃ ។ លោក វ៉ែន ហ៊ុល កំពុងតែជាប់ពន្ធនាគារ ក្នុងខេត្តពោធិសាត់ ពីបទប៉ុងប៉ងមនុស្សឃាត ។ ការសុំឱ្យនៅក្រៅឃុំរបស់គាត់ត្រូវបានតុលាការបដិសេធ ។ គាត់មានមេធាវីការពារ មកពីគំរោងអ្នកការពារក្តីកម្ពុជា ។

## នៅខេត្តកំពង់ឆ្នាំង

- ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៤ លោក ប្រាជ រិន អភិបាលរងខេត្តកំពង់ឆ្នាំង ក្នុងពេលថ្លែងទៅកាន់ប្រជាពលរដ្ឋ លោកបានអំពាវនាវឱ្យតំណាងអង្គការក្រៅរដ្ឋាភិបាលម្នាក់បង្ហាញខ្លួន ហើយលោកបាន និយាយថា មានអង្គការក្រៅរដ្ឋាភិបាលមួយ នៅពីខាងក្រោយការតវ៉ានេះ ពីព្រោះប្រជាពលរដ្ឋភាគច្រើនដែលធ្វើការតវ៉ានេះមកពីសហគមន៍ព្រៃឈើ ។ នៅថ្ងៃដដែលនេះដែរ អភិបាលស្រុកបរិបូណ៌បានកោះអញ្ជើញបុគ្គលិកម្នាក់នៃអង្គការ ក្រៅរដ្ឋាភិបាលមួយដែលធ្វើការនៅក្នុងស្រុកនោះ ដើម្បីធ្វើការសាកសួរអំពីភាពស្របច្បាប់របស់អង្គការនេះ និង សកម្មភាពរបស់ខ្លួន ហើយបានស្នើសុំឱ្យផ្តល់ឯកសារផ្លូវច្បាប់មួយចំនួន ដើម្បីបញ្ជូនទៅអភិបាលខេត្តកំពង់ ឆ្នាំង ។
- ក្រុមអ្នកតវ៉ាជាច្រើនមកពីឃុំក្រាំងស្គា ស្រុកទឹកផុស ត្រូវទទួលរងនូវការគំរាមកំហែង និងការបំភិតបំភ័យ នៅពេលវិលត្រឡប់ទៅភូមិរបស់ខ្លួនវិញ បន្ទាប់ពីបានចូលរួមធ្វើបាតុកម្មនៅពាក់កណ្តាលខែវិច្ឆិកា ។ មេឃុំក្រាំងស្គា ដែលមិនគាំទ្រការតវ៉ា បានធ្វើការគំរាមដកសមាជិកក្រុមប្រឹក្សាឃុំម្នាក់ចេញពីមុខតំណែងរបស់គាត់ ។ ហើយក៏បានគំរាមថានឹងរាយរាយការណ៍ពីគាត់ ទៅអាជ្ញាធរខេត្ត ដើម្បីចាប់គាត់ដាក់គុក ។ មេឃុំរូបនេះបាន និយាយថា សមាជិកក្រុមប្រឹក្សាឃុំ និងអ្នកដទៃទៀតដែលពាក់ព័ន្ធ នឹងត្រូវគេដកហូតយកដីរបស់ខ្លួន ប្រសិន ជាគេនៅតែបន្តធ្វើការតវ៉ាតទៅទៀត ។

- អភិបាលស្រុកទឹកផុស បានជួបជាមួយប្រជាពលរដ្ឋ នៅថ្ងៃទី២៤ និងថ្ងៃទី៣០ ខែវិច្ឆិកា។ គាត់បានប្រាប់ពួកគេថា អ្នកដែលបានធ្វើការតវ៉ានឹងត្រូវទទួលទណ្ឌកម្មពីអាជ្ញាធរ ហើយថាការតវ៉ានេះគឺជាសកម្មភាពខុសច្បាប់ ព្រោះថារដ្ឋាភិបាលមិនអនុញ្ញាតឱ្យពួកគេរៀបចំធ្វើ ហើយថាបើសិនជាពួកគេចង់ចូលរួមក្នុងសកម្មភាពទាំងនេះ ត្រូវតែសុំការអនុញ្ញាតពីអាជ្ញាធរជាមុនសិន។ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា គាត់បានប្រាប់លោក ឡុង ធី ជំទប់ឃុំក្រាំងស្កាថា ក្រុមហ៊ុននឹងមិនធ្វើការឈូសឆាយដីរបស់ប្រជាពលរដ្ឋទេ ហើយថាប្រតិបត្តិការរបស់ក្រុមហ៊ុនគឺជាប្រតិបត្តិការស្របច្បាប់ ហើយប្រជាពលរដ្ឋមិនចាំបាច់ធ្វើការតវ៉ាតទៅទៀតទេ។
- ថ្ងៃទី ៨ ខែធ្នូ ប្រជាពលរដ្ឋដែលដើរប្រមូលស្នាមមេដៃ ពីអ្នកភូមិដែលទទួលផលប៉ះពាល់ដើម្បីគាំទ្រ ញត្តិមួយនៅក្នុងឃុំពេជ្រចង្វា ស្រុកបរិបូណ៌ ត្រូវបានគេកោះអញ្ជើញឱ្យមកសាលាឃុំពេជ្រចង្វា។ ញត្តិដែល មានស្នាមមេដៃត្រូវបានគេដកហូត បន្ទាប់ពីការប្រជុំដែលមាននគរបាលឃុំ និងនគរបាលស្រុកចូលរួមផង។ ប្រជាពលរដ្ឋ មានបំណងផ្ញើញត្តិនោះ ជាមួយនិងញត្តិមួយទៀតរបស់ប្រជាពលរដ្ឋខេត្តពោធិសាត់ ថ្វាយព្រះមហាក្សត្រព្រះ នរោត្តមសីហមុនី នៅទិវាសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៤។
- ថ្ងៃទី១៦ ខែ ធ្នូ លោក ជា ភ័ណ្ឌ ជាតំណាងសហគមន៍ភូមិអញ្ចាញ ឃុំក្រាំស្កា ត្រូវបានអភិបាលស្រុកអញ្ជើញមកសាលាស្រុកទឹកផុស ហើយបានប្រាប់គាត់ឱ្យឈប់ធ្វើការតវ៉ាតទៅទៀត ពីព្រោះក្រុមហ៊ុនកំពុងធ្វើវិយោគនៅក្នុងខេត្ត។ ចាប់តាំងពីដើមខែធ្នូ លោក ជា ភ័ណ្ឌ និងក្រុមរបស់គាត់ បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "*The Green Invasion*" អំពីផលប៉ះពាល់នៃចំការឈើ។ នៅពេលបញ្ចាំងម្តងៗ នគរបាលខេត្តស្លៀកពាក់ស៊ីវិលបានចូលរួម ហើយស្រង់ឈ្មោះអ្នកដែលមកមើល ហើយបានតាមឃ្លាំមើលគាត់និងក្រុមរបស់គាត់ជានិច្ច។ អាជ្ញាធរមូលដ្ឋានបានគំរាមចាប់ខ្លួនពួកគេ ប្រសិនបើគេនៅតែបន្តធ្វើការតវ៉ាតទៅទៀត។ លោក សោម សុទ្ធ ប្រធានភូមិរ៉ា ក្នុងឃុំក្រាំងស្កា លោក គង់ សំអ៊ិម មេឃុំ លោក ឈុង ឃឿន អភិបាលស្រុក លោក ស៊ុង កុសល មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងលោក នូ សារឿន មន្ត្រីនៃនាយកដ្ឋានកសិកម្ម បានគំរាមចាត់វិធានការចំពោះជនទាំងឡាយណាដែលមើលភាពយន្តឯកសារ នេះ។ មិនតែប៉ុណ្ណោះ ពួកគេបានគំរាមចាប់អ្នកណាដែលនិយាយទិតៀនពីដើមប្រេងខ្យល់។ មេឃុំបាន និយាយថា តំណាងសហគមន៍ ត្រូវបានគេចាត់ទុកថាជាអ្នកញុះញង់ឱ្យមានការតវ៉ា ហើយថា គេនឹងចាប់អ្នកទាំងនោះដាក់គុក។ ក្រោយពីព្រះរាជទស្សនកិច្ចរបស់ព្រះមហាក្សត្រព្រះនរោត្តមសីហមុនី ទៅកាន់ខេត្តកំពង់ឆ្នាំង កាលពីខែធ្នូកន្លងមកនេះ ការគំរាមកំហែង និងការបំភិតបំភ័យ ត្រូវបានគេរាយការណ៍ថា មានការថយចុះមួយរយៈ។
- ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៥ អភិបាលស្រុកទឹកផុស បានអញ្ជើញតំណាងសហគមន៍បីរូប ពីឃុំក្រាំងស្កាមកកាន់សាលាស្រុករបស់គាត់។ ដោយប្រជាពលរដ្ឋមានការភ័យខ្លាចថា លោកអភិបាលស្រុកធ្វើការគាប

សង្កត់តំណាងរបស់ខ្លួន ហើយបង្ខំឱ្យពួកគេផ្ដិតមេដៃលើឯកសារ ដែលនាំឱ្យខូចដល់ផលប្រយោជន៍របស់សហ-គមន៍ ទើបប្រជាពលរដ្ឋមួយក្រុមមានគ្នា៣០ នាក់ បានអមដំណើរតំណាងរបស់ខ្លួនទាំងបីរូបនោះ ។ ប្រជាពលរដ្ឋបានស្នើសុំឱ្យអភិបាលស្រុកបើកការប្រជុំ និងរៀបចំឱ្យមានការប្រជុំច្រើនទៀតនៅថ្ងៃអានាគត ទាក់ទងនឹងដីសម្បទានក្នុងឃុំរបស់ខ្លួន ។

- ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥ អភិបាលស្រុក បានអញ្ជើញប្រធានភូមិរ៉ា និងតំណាងសហគមន៍ ក្នុងឃុំក្រាំងស្គា មកកាន់សាសាលាស្រុក ។ មិនមាននរណាម្នាក់មកតាមការអញ្ជើញនោះទេ ។
- បន្ទាប់ពីការធ្វើទស្សនកិច្ចរបស់មន្ត្រីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR) ថ្ងៃទី១៦ ខែកុម្ភៈ មក អភិបាលស្រុកទឹកផុស បានអញ្ជើញអនុប្រធានឃុំក្រាំស្គា និងលោកម៉ែន សឿន ជាសមាជិកក្រុមប្រឹក្សាឃុំ មកកាន់សាលាស្រុក នៅរសៀលថ្ងៃទី១៨ ខែកុម្ភៈ ។ គាត់បានប្រាប់ពួកគេឱ្យឈប់ធ្វើការតវ៉ាតទៅទៀត បើពុំនោះទេនឹងត្រូវដកហូតចេញពីមុខតំណែង ។
- ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ប្រធានសហគមន៍ប្រាំបីរូប ក្នុងឃុំក្រាំងស្គា ត្រូវបានអញ្ជើញ មកកាន់សាលាស្រុកទឹកផុស ដើម្បីចូលរួមប្រជុំ ដែលមានរយៈពេលបួនម៉ោង ។ លោក អ៊ូ សាខន អភិបាលរងទីមួយស្រុក លោកអ៊ុង ប៊ុនខឿន អភិបាលរងទីពីរស្រុក និងប្រធានមន្ទីរស្រុកមួយរូប មានវត្តមានក្នុងពេលនោះ ។ ពួកគេបានធ្វើការព្រមានដល់តំណាងសហគមន៍ ឱ្យឈប់ផ្សព្វផ្សាយព័ត៌មាន ដែលពួកគេបាននិយាយថា ជាព័ត៌មានខុសច្បាប់ ។ ពួកគេបានប្រាប់អ្នកទាំងនោះថា គេមិនមានសិទ្ធិ និងការទទួលខុសត្រូវ ក្នុងការដើរពីភូមិមួយទៅភូមិមួយ ដើម្បីពន្យល់ប្រាប់ប្រជាពលរដ្ឋអំពីច្បាប់ព្រៃឈើ ច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធដទៃទៀតនោះទេ ការធ្វើបែបនេះគឺផ្ទុយទៅនឹងគោលការណ៍របស់រដ្ឋ ហើយថាមានតែអាជ្ញាធរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចប៉ុណ្ណោះដែលមានសិទ្ធិ និងភារកិច្ចទាំងនេះ ។ ពួកគេបានប្រាប់អ្នកទាំងនោះឱ្យបញ្ឈប់សកម្មភាពទាំងឡាយណាដែលជាឧបសគ្គដល់ការអភិវឌ្ឍន៍ របស់ក្រុមហ៊ុននៅក្នុងស្រុក ។

**រៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា** (OHCHR/ Cambodia) **ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥ ។**